សំរាប់លក់

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

# រូបវិទ្យា ១០



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# រូបវិទ្យា

## ថ្នាក់ទី ១០

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** លោក ទូច ចាន់ទុំ អ្នកស្រី អៀម ច័ន្ទឌី
លោក សូ គន្ធី អ្នកស្រី ឈុំ ណារី
លោក ផាង ស្រ៊ុយ លោក ជា សែ

**អ្នកវាយអត្ថបទ** អ្នកស្រី ហាក់ ផាន្នី

**វិចិត្រករ** លោក សិដ្ឋ ចាន់រដ្ឋា

**អ្នករៀបរៀង** លោក ស៊ឹម ចាន់ធី

**អ្នករចនាទំព័រ** លោក ហាក់ វណ្ណថា

សូមថ្លែងអំណរគុណចំពោះ
ការជួយឧបត្ថម្ភរបស់អង្គការ JICA

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ២៧៥៧ អយក.ប្រក. ចុះថ្ងៃទ១៤ ខែមិថុនា ឆ្នាំ២០០៧ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©
**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី១៣ ឆ្នាំ២០២០ ចំនួន ៣៥ ០០០ ច្បាប់

ISBN 9-789-995-000-752

# អារម្ភកថា

សារសំខាន់នៃសៀវភៅរូបវិទ្យាថ្នាក់ទី10 គឺឱ្យសិស្សស្គាល់ច្បាស់អំពីបាតុភូតដែលកើតឡើងនៅជុំវិញខ្លួនយើងតាមរយៈវិធីវិទ្យាសាស្ត្រ ។

សៀវភៅរូបវិទ្យាថ្នាក់ទី10 មានទម្រង់ដូចខាងក្រោម :

- មេរៀននីមួយៗមានបញ្ជាក់អំពីវត្ថុបំណងច្បាស់លាស់
- ខ្លឹមសារមេរៀនផ្តើមចេញពីឧទាហរណ៍នៃបាតុភូតដែលមាននៅក្នុងជីវភាពរស់នៅ
- មេរៀនមានសកម្មភាពពិសោធន៍ដើម្បីឱ្យសិស្សយកទៅអនុវត្តន៍ផ្ទាល់
- ចុងមេរៀននីមួយៗមានសង្ខេបគន្លឹះមេរៀនដើម្បីឱ្យសិស្សចងចាំអ្វីដែលសិស្សបានរៀន
- មេរៀននីមួយៗមានសំណួរនិងលំហាត់ហើយសៀវភៅនេះក៏មានសំណួរនិងលំហាត់សម្រាប់ជំពូកនីមួយៗផងដែរ ។

ជាទីបញ្ចប់គណៈកម្មការនិពន្ធ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ JICA ជាពិសេសអ្នកឯកទេសជប៉ុន ដែលបានជួយផ្តល់យោបល់សម្រាប់អ្នកនិពន្ធ ព្រមទាំងលោកគ្រូ អ្នកគ្រូដែលបានសម្រួលនិងផ្តល់យោបល់ក្នុងការសាកល្បង រួមទាំងគណៈកម្មការវង្វាយតម្លៃដែលបានជួយត្រួតពិនិត្យនិងផ្តល់យោបល់លើសៀវភៅនេះ ។

ដើម្បីឱ្យសៀវភៅសិស្សនេះកាន់តែល្អប្រសើរ យើងខ្ញុំនឹងទទួលរាល់ការរិះគន់ និងកែលម្អបន្ថែមពីសំណាក់លោកគ្រូ អ្នកគ្រូដោយក្តីរីករាយ ។

**គណៈកម្មការនិពន្ធ**

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# បញ្ជីអត្ថបទ

ទំព័រ

**វិធីវិទ្យាសាស្ត្រ រង្វាស់ និងសុវត្ថិភាពពិសោធន៍** ........ 1

**សេចក្តីផ្តើមរូបវិទ្យា** ........ 15

ជំពូក1 : មេកានិច ........ 17

**1.** ចលនាត្រង់ ........ 18

**2.** ច្បាប់ចលនារបស់ញូតុន ........ 34

**3.** កម្មន្ត ថាមពល និងអានុភាព ........ 48

**4.** សម្ពាធនៃសន្ទនីយស្តាទិច ........ 60

ជំពូក2 : ទែម៉ូឌីណាមិច ........ 75

**1.** សីតុណ្ហភាព ........ 76

**2.** ទ្រឹស្តីស៊ីនេទិចនៃរូបធាតុ ........ 82

**3.** កម្តៅ ........ 86

ជំពូក3 : អគ្គិសនីនិងម៉ាញេទិច ........ 101

**1.** អេឡិចត្រូស្តាទិច ........ 102

**2.** ចរន្តជាប់និងម៉ាញេទិច ........ 112

**3.** ចរន្តឆ្លាស់ ........ 128

ជំពូក4 : អុបទិច ........ 137

**1.** ធម្មជាតិនិងដំណាលនៃពន្លឺ ........ 138

**2.** ឡង់ទី ........ 150

ជំពូក5 : ថាមពល និងជីវិត ........ 169

**1.** ការបំប្លែងថាមពលដែលមានប្រភពខុសៗគ្នាឱ្យទៅជាថាមពលអគ្គិសនី ........ 170

**2.** ការបំប្លែងថាមពលអគ្គិសនីឱ្យទៅជាថាមពលផ្សេងៗ ........ 176

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# វិធីវិទ្យាសាស្ត្រ រង្វាស់ និងសុវត្ថិភាពពិសោធន៍

## 1. នាទីវិទ្យាសាស្ត្រ

អ្វីៗទាំងអស់នៅជុំវិញខ្លួន និងនៅក្នុងរាងកាយយើង ពិតជាមានអាថ៌កំបាំងច្រើនរាប់មិនអស់ ។ មុខងាររបស់អ្នកវិទ្យាសាស្ត្រគឺបកស្រាយនូវអាថ៌កំបាំងទាំងនោះ ។ ការងារនេះមិនខុសពីអ្នកជំនាញស៊ើបអង្កេតប៉ុន្មានដែរ ។ អ្នកវិទ្យាសាស្ត្រតែងតែរិះរកគ្រប់វិធីដើម្បីរកឱ្យឃើញនូវការពិតដែលមានក្នុងធម្មជាតិ ។

អ្នកវិទ្យាសាស្ត្រចង់ស្វែងរកការពិតនៃហេតុការណ៍ដែលបានកើតឡើង ។អ្វីទៅជាហេតុការណ៍ ? ភាវៈរស់រាប់លានប្រភេទខុសៗគ្នាដែលមានជីវិតនៅលើផែនដី គឺជាឧទាហរណ៍មួយហេតុការណ៍ ។ ពិតមែនតែហេតុការណ៍កើតមានឡើងមានទំហំធំធេង ប៉ុន្តែវិទ្យាសាស្ត្រមានន័យទូលំទូលាយជាងនេះទៅទៀត ។

អ្នកវិទ្យាសាស្ត្រជនជាតិបារាំងដ៏ល្បីល្បាញម្នាក់នៅសតវត្សទី 19 មានគំនិតថា “វិទ្យាសាស្ត្រកើតឡើងដោយហេតុការណ៍ជាច្រើន វាប្រៀបបីដូចជាផ្ទះមួយសង់ឡើងពីដុំឥដ្ឋដែរ ” ។ ប៉ុន្តែការប្រមូលផ្តុំនូវហេតុការណ៍មិនច្រើនជាងវិទ្យាសាស្ត្រ ហើយដុំឥដ្ឋមួយក៏មិនអាចស្មើនឹងផ្ទះមួយដែរ ។

ដូចនេះអ្នកវិទ្យាសាស្ត្ររកឃើញនូវហេតុការណ៍កាន់តែស្មុគស្មាញនិងស៊ីជម្រៅ ។ អ្នកវិទ្យាសាស្ត្រសាកល្បងប្រើប្រាស់ហេតុការណ៍ទាំងនោះដើម្បីដោះស្រាយនូវអាថ៌កំបាំងធម្មជាតិដ៏ធំធេងនេះ ។ យើងពេញចិត្តនឹងភាពឆ្លល់ដ៏ឆ្លាតវាងវៃរបស់យើងតាមរយៈការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ ។

ការប្រើប្រាស់សម្ភារៈអេឡិចត្រូនិក ឱសថព្យាបាលជំងឺ ការទស្សន៍ទាយមុននៃអាកាសធាតុ ។ ទាំងនេះបង្ហាញថា យើងមិនអាចរស់នៅដោយគ្មានការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្របានឡើយ ។

## 2. វិធីវិទ្យាសាស្ត្រ

វិទ្យាសាស្ត្របានផ្តល់សារៈសំខាន់យ៉ាងច្រើនដល់យើងទាំងអស់គ្នាដើម្បីឱ្យបានយល់ច្បាស់អំពីបាតុភូត ហេតុការណ៍ឬព្រឹត្តិការណ៍ណាមួយដែលកើតឡើងនៅជុំវិញខ្លួនយើង ។ ម្យ៉ាងវិញទៀតវិទ្យាសាស្ត្រជួយយើងក្នុងការទម្លាយអាថ៌កំបាំងនៃគ្រោះមហន្តរាយធម្មជាតិ តាមរយៈរបកគំហើញរូបធាតុឬបច្ចេកវិទ្យាថ្មីៗដែលធ្វើឱ្យពិភពលោកមានការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។ ដើម្បីទទួលជោគជ័យក្នុងការងារវិទ្យាសាស្ត្រ អ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវអនុវត្តតាមលំដាប់លំដោយនៃវិធីមួយដែលគេឱ្យឈ្មោះថា “ **វិធីវិទ្យាសាស្ត្រ** ” ។ ទ្រឹស្តីដែលអ្នកវិទ្យាសាស្ត្របានរកឃើញ យើងយកមកអនុវត្តដល់សព្វថ្ងៃនេះ ជាលទ្ធផលនៃការអនុវត្តតាមបែបវិធីវិទ្យាសាស្ត្រនេះឯង ។

**លំដាប់លំដោយនៃវិធីវិទ្យាសាស្ត្រមាន 5 ជំហានគឺ**

① ការកំណត់បញ្ហា

② ការបង្កើតសម្មតិកម្ម

③ ការធ្វើតេស្តសម្មតិកម្មឬការធ្វើពិសោធន៍

④ លទ្ធផល

⑤ ការវិភាគនិងការសន្និដ្ឋាន ។

youtube.com/moeys

## 2.1 ការកំណត់បញ្ហា

ការកំណត់បញ្ហាផ្ដើមចេញពីចំណាប់អារម្មណ៍ទៅលើបាតុភូតឬព្រឹត្តិការណ៍ណាមួយដែលកើតមានឡើងនៅជុំវិញខ្លួនយើងតាមរយៈការសង្កេតរបស់យើង ។ ខាងក្រោមនេះជាឧទាហរណ៍ងាយៗដែលបង្ហាញពីបាតុភូតមួយចំនួនទាក់ទងទៅនឹងមុខវិជ្ជាវិទ្យាសាស្ត្រ ។



1. តើគ្រាប់រុក្ខជាតិត្រូវការពន្លឺដើម្បីដុះពន្លកឬទេ?




2. តើកត្តាអ្វីខ្លះដែលជំរុញឱ្យដែកឡើងច្រេះ?



3. តើកត្តាអ្វីដែលជះឥទ្ធិពលទៅលើល្បឿននៃការធ្លាក់ចុះ?

ដូចនេះ ការកំណត់បញ្ហាជាការបង្កើត " **សំណួរ** " ដែលកើតចេញពីចម្ងល់របស់យើងតាមរយៈការសង្កេតបាតុភូតឬហេតុការណ៍ណាមួយ ។

## 2.2 ការបង្កើតសម្មតិកម្ម

សម្មតិកម្មមានន័យថា លទ្ធផលសង្ឃឹមទុកជាមុនដែលអាចនឹងកើតមានឡើង ។ ដូច្នេះការបង្កើតសម្មតិកម្ម ជាការព្យាករណ៍ឬការទាយទុកជាមុន ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហាដែលយើងបានចោទសួរពីខាងដើម ។ សម្មតិកម្ម ដែលបង្កើតហើយនេះ ត្រូវមានលក្ខណៈច្បាស់លាស់និងត្រឹមត្រូវ ហើយគេអាចយកទៅធ្វើតេស្តសម្មតិកម្មបាន ។ ឧទាហរណ៍ : ប្រសិនបើ យើងជ្រើសរើសគ្រាប់រុក្ខជាតិ តើវាជាគ្រាប់រុក្ខជាតិប្រភេទអ្វី ? គ្រាប់ស្វាយ គ្រាប់ល្ហុង គ្រាប់ខ្នុរ. . . ។ល។ ប្រសិនបើយើងជ្រើសរើសដែក តើត្រូវយកដែកប្រភេទអ្វី ? ដែកគោល ដែកថែប ដែកលួស . . ។ ម្យ៉ាងទៀត សម្មតិកម្មដែលយើងបង្កើតមានច្រើនបែបសណ្ឋានណាស់ អាស្រ័យនឹងផលដែលយើងរំពឹងទុក ។ ខាងក្រោមនេះជាសម្មតិកម្មដែលយើងលើកឡើង :

ឧទាហរណ៍ទី 1 " គ្រាប់សណ្តែកត្រូវការពន្លឺដើម្បីដុះពន្លក " ។

ឧទាហរណ៍ទី 2 " ទឹកអំបិលអាចជាកត្តាដែលជំរុញឱ្យដែកឡើងច្រែះ " ។

ឧទាហរណ៍ទី 3 " ម៉ាសអាចជាកត្តាដែលជះឥទ្ធិពលទៅលើល្បឿននៃការធ្លាក់ចុះ " ។

## 2.3 ការធ្វើតេស្តសម្មតិកម្ម (ពិសោធន៍)

តេស្តសម្មតិកម្មគឺជាការពិសោធជាក់ស្តែង ដើម្បីផ្ទៀងផ្ទាត់ថា អ្វីដែលយើងបានព្យាករណ៍ទុកជាមុននោះពិតជាត្រឹមត្រូវឬមិនត្រឹមត្រូវតាមសម្មតិកម្ម ។ ម្យ៉ាងទៀតការពិសោធត្រូវមានបទដ្ឋានការងារច្បាស់លាស់រួមមាន សម្ភារៈពិសោធ ដំណើរការពិសោធនិងការពិសោធត្រួតពិនិត្យឬពិសោធន៍ប្រៀបធៀប ។




នៅក្នុងការពិសោធវាមានកត្តានិងផលប៉ះពាល់ជាច្រើនដែលធ្វើឱ្យដំណើរការពិសោធរបស់យើងមានភាពប្រែប្រួល ។ ដូច្នេះមុននឹងពិសោធ យើងត្រូវពិនិត្យលក្ខខណ្ឌឱ្យបានច្បាស់លាស់ជាមុនសិន ។

## 2.4 លទ្ធផល

លទ្ធផលជាទិន្នន័យ ដែលទទួលបានពីការពិសោធតាមរយៈការសង្កេតនិងការវាស់វែងយ៉ាងត្រឹមត្រូវ ។ ទិន្នន័យនេះចែកចេញជាពីរផ្នែកគឺ :

***ទិន្នន័យផ្នែកបរិមាណ :*** ជាទិន្នន័យដែលយើងអាចវាស់វែងបានច្បាស់លាស់ ដូចជា ប្រវែង ម៉ាស មាឌ ពេលវេលា សីតុណ្ហភាព តង់ស្យុង . . . ។

***ទិន្នន័យផ្នែកគុណភាព :*** ជាទិន្នន័យដែលយើងពិបាកនឹងវាស់វែងឱ្យបានច្បាស់លាស់មានដូចជា ក្លិន ពណ៌ រសជាតិ រូបភាព សូរ. . . ។

ចំពោះ***ឧទាហរណ៍ទី 2 :*** ក្រោយពីទុកវាអស់រយៈពេលមួយសប្តាហ៍មក គេទទួលបានលទ្ធផលដូចតទៅ : ដែកគោលដែលគេដាក់ក្នុងសូលុយស្យុងអំបិលមានពណ៌ត្នោតជាង ។ នេះមានន័យថា វាឡើងច្រែះជាងដែកគោលក្នុងទឹកធម្មតា ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## 2.5 ការវិភាគនិងសន្និដ្ឋាន

ការវិភាគទិន្នន័យមានន័យថា “**ទិន្នន័យដែលទទួលបាននោះគាំទ្រឬមិនគាំទ្រសម្មតិកម្ម** ” ដែលយើងបានបង្កើត ។ ប៉ុន្តែលទ្ធផលនៅក្នុងឧទាហរណ៍ទី 2 នោះ គឺបាន**គាំទ្រសម្មតិកម្ម** ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា : “**ទឹកអំបិលអាចជំរុញឱ្យមានការឡើងច្រែះ** ” ត្រូវបានគាំទ្រដោយពិសោធន៍ ។ ករណីនេះ ហាក់ដូចជាថា ***កត្តាមួយក្នុងចំណោមកត្តាដែលជំរុញឱ្យមានការឡើងច្រែះគឺទឹកអំបិល*** ។ យើងប្រើពាក្យ **ហាក់ដូចជា**នេះ ព្រោះយើងធ្វើការពិសោធបានតែម្តង ។ យើងមិនអាចសន្និដ្ឋានការពិសោធនោះត្រឹមត្រូវបាន 100% នោះទេ ។ ប្រសិនបើយើងធ្វើការពិសោធច្រើនដងសាចុះសាឡើង ហើយលទ្ធផលនៃការពិសោធនោះ បានគាំទ្រសម្មតិកម្មគ្រប់ករណី ។ ពេលនោះសម្មតិកម្មរបស់យើងនឹងក្លាយជា **ទ្រឹស្តី** ។ ដូច្នេះទ្រឹស្តីមានន័យថា “ ***ជាការពន្យល់អំពីបាតុភូត ឬព្រឹត្តិការណ៍ផ្សេងៗជាច្រើនដែលត្រូវបានគាំទ្រដោយពិសោធន៍***” ។

**ដ្យាក្រាមខាងក្រោមនេះ** បង្ហាញអំពីជំហានទាំងប្រាំនៃវិធីវិទ្យាសាស្ត្រ ដែលអ្នកវិទ្យាសាស្ត្រ និងអ្នកស្រាវជ្រាវបានអនុវត្តក្នុងការធ្វើពិសោធជាច្រើនដង ដោយមានការគាំទ្រពីសម្មតិកម្ម ដើម្បីបង្កើតទ្រឹស្តីមួយដែលមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ ។




1. ការពន្យល់អំពីអ្វីមួយដែលកំណត់ថានឹងកើតមានឡើងនៅជុំវិញខ្លួនយើង ។
2. ការពន្យល់ទៅលើបាតុភូតឬព្រឹត្តិការណ៍ផ្សេងៗដែលត្រូវបានគាំទ្រដោយពិសោធន៍ ។

facebook.com/moeys krou.moeys.gov.kh youtube.com/moeys

# 3. រង្វាស់និងខ្នាត

## 3.1 ទំហំរូបនិងខ្នាត SI ( Système International )

រង្វាស់គឺបង្ហាញនូវក្បួននិងច្បាប់ធម្មជាតិជាមួយនឹងទំហំជាលេខ ។ ឧបករណ៍រង្វាស់នីមួយៗត្រូវបានក្រិតតាមខ្នាតគំរូ (Standard) ។ បើសិនជាយើងចង់ផ្តល់លទ្ធផលនៃរង្វាស់ទៅឱ្យអ្នកណាម្នាក់ដែលចង់ចម្លងរង្វាស់យើង នោះខ្នាតគំរូត្រូវបានកំណត់ ។ បើសិនជាជនជាតិខ្មែរយើងប្រាប់ទៅជនបរទេសនូវរង្វាស់ 5 ព្យាម ជនបរទេសនោះក៏ពុំដឹងថា ព្យាមជាអ្វីទេ ។ ប៉ុន្តែបើយើងប្រើប្រព័ន្ធខ្នាតអន្តរជាតិ ហើយប្រាប់គេថា ជញ្ជាំងមានកម្ពស់ 2m គេអាចដឹងថា វាមានប្រវែងពីរដងនៃខ្នាតគំរូ ។

គ្រប់ទំហំរូបទាំងអស់សុទ្ធតែមានតម្លៃជាលេខនិងខ្នាត ។

***ឧទាហរណ៍ :*** 2.3m ( 2.3 តម្លៃជាលេខ និង m ជាខ្នាត) ។

ក្នុងឆ្នាំ 1960 គណៈកម្មការអន្តរជាតិបានបង្កើតខ្នាតគំរូសម្រាប់ទំហំរូបផ្សេងៗ ។ ប្រព័ន្ធដែលបង្កើតនោះគេឱ្យឈ្មោះហៅថា ប្រព័ន្ធខ្នាតអន្តរជាតិ ( Système International ) ឬសរសេរកាត់ SI ។ ក្នុងប្រព័ន្ធខ្នាតនេះ គេប្រើខ្នាតគ្រឹះប្រាំពីរដូចក្នុងតារាង :

| ទំហំរូប | ឈ្មោះ | និមិត្តសញ្ញា |
|---|---|---|
| ប្រវែង | ម៉ែត | m |
| ម៉ាស | គីឡូក្រាម | kg |
| ពេល | វិនាទី | s |
| ចរន្តអគ្គិសនី | អំពែ | A |
| សីតុណ្ហភាព | កែលវិន | K |
| អាំងតង់ស៊ីតេពន្លឺ | កង់ដឺឡា | cd |
| បរិមាណរូបធាតុ | ម៉ូល | mol |

ទំហំផ្សេងៗទៀត ត្រូវបានទាញចេញពីទំហំគ្រឹះខាងលើ***ឧទាហរណ៍*** ដូចជាល្បឿន សំទុះ .... ។

## 3.2 ខ្នាតគ្រឹះគំរូ

### ក. ប្រវែង

ក្នុងប្រព័ន្ធ SI ខ្នាតប្រវែងគឺម៉ែត (m) ។ ក្នុងឆ្នាំ 1960 និង 1970 ម៉ែត គឺជាប្រវែងស្មើនឹង

1 650 763.73 ដងនៃជំហានរលកក្នុងសុញ្ញកាសរបស់ពន្លឺលឿងទុំដែលបញ្ចេញដោយអ៊ីសូតូប 86 របស់អាតូមគ្រីបតុង (Kr) ។ តែទោះជាយ៉ាងណាក៏ដោយនៅខែតុលាឆ្នាំ 1983 ម៉ែតត្រូវបានកំណត់ឡើងវិញថា ម៉ែតគឺជាប្រវែងដាលនៃពន្លឺក្នុងសុញ្ញកាសក្នុងរយៈពេល 1/299 792 458 វិនាទី ។

ខ. ម៉ាស

ក្នុងប្រព័ន្ធ SI ខ្នាតម៉ាសគិតជាគីឡូក្រាម (kg) ។ គីឡូក្រាមគឺជាម៉ាសគំរូធ្វើអំពីប្លាទីនបញ្ចុះអ៊ីរីដ្យូម (Platinum-iridium) ដែលគេតម្កល់ទុកក្នុងការិយាល័យអន្តរជាតិខាងទម្ងន់និងរង្វាស់នៅទីក្រុងសែវ (Sèvres) ប្រទេសបារាំង ។

គ. ពេល

ក្នុងប្រព័ន្ធ SI ពេលត្រូវបានគិតជាវិនាទី (s) ។ មុនឆ្នាំ 1960 វិនាទីជារយៈពេលដែលស្មើនឹង 1/31 556 925.9747 នៃឆ្នាំត្រូពិច ។ ឆ្នាំត្រូពិចនេះមានរយៈពេលតូចជាងរយៈពេលដែលផែនដីវិលជុំវិញព្រះអាទិត្យបន្តិច ។ ក្នុងឆ្នាំ 1967 វិនាទីត្រូវបានកំណត់ជាថ្មីថាជារយៈពេលដែលត្រូវនឹង 9 192 631 770 ដងនៃខួបរលកពន្លឺរបស់អាតូមសេស្យូម 133 ។

## 3.3 បុព្វបទនៃខ្នាត SI

ដើម្បីសម្រួលក្នុងការគណនា ពហុគុណនិងអនុពហុគុណនៃខ្នាត ត្រូវបានអនុញ្ញាតឱ្យប្រើដោយគ្រាន់តែបន្ថែមនូវបុព្វបទទៅលើខ្នាតគ្រឹះ ។

តារាងបុព្វបទមួយចំនួន

| | កត្តាដែលត្រូវគុណ | បុព្វបទ | និមិត្តសញ្ញា |
|---|---|---|---|
| ពហុគុណ | $10^{12}$ | តេរា | T |
| | $10^{9}$ | ហ្សីកា | G |
| | $10^{6}$ | មេកា | M |
| | $10^{3}$ | គីឡូ | k |
| | $10^{2}$ | ហិចតូ | h |
| | $10^{1}$ | ដេកា | da |

| ខ្នាតគ្រឹះ | | | |
|---|---|---|---|
| អនុពហុគុណ | $10^{-1}$ | ដេស៊ី | d |
| | $10^{-2}$ | សង់ទី | c |
| | $10^{-3}$ | មីលី | m |
| | $10^{-6}$ | មីក្រូ | μ |
| | $10^{-9}$ | ណាណូ | n |
| | $10^{-12}$ | ពីកូ | p |

## 3.4 ការវិភាគខ្នាត

ទំហំគ្រឹះដែលប្រើសម្រាប់ពណ៌នានៅក្នុងរូបវិទ្យាហៅថា វិមាត្រ (dimension) ។ ឧទាហរណ៍ៈ ប្រវែង ម៉ាស ពេល ទាំងអស់នេះជាវិមាត្រ (dimension) ។

ក្នុងការអនុវត្តដើម្បីងាយស្រួលគេត្រូវប្រើខ្នាតជាក់លាក់ដូចជា m , s និង kg ដូចបញ្ជាក់ក្នុងតារាងខាងក្រោម ។ ការប្រើខ្នាតបែបនេះ អាចឱ្យគេធ្វើប្រមាណវិធីដូចជា ទំហំពីជគណិត ដែលអាចសម្រួលគ្នាបាន ។ ការប្រើប្រាស់ខ្នាតដើម្បីផ្ទៀងផ្ទាត់សមីការហៅថា វិភាគខ្នាត ។

រូបមន្តរូបវិទ្យាក៏ដូចជាសមីការគណិតវិទ្យាដែរ ដែលអង្គទាំងសងខាងនៃសមីការត្រូវតែស្មើគ្នាទាំងតម្លៃនិងទាំងខ្នាត ។

| ទំហំ | ខ្នាត |
|---|---|
| ម៉ាស | kg |
| ពេល | s |
| ប្រវែង | m |
| ផ្ទៃ | $m^2$ |
| មាឌ | $m^3$ |
| ល្បឿន | m/s |
| សំទុះ | $m/s^2$ |

***ឧទាហរណ៍ទី1 :*** គេមានទំហំប្រវែង $a = 3.0\text{m}$ និង $b = 4.0\text{m}$ ។ បញ្ចូលតម្លៃនេះទៅក្នុងសមីការ $a \times b = c$ គេបាន $3.0\text{m} \times 4.0\text{m} = 12\text{m}^2$ ។ អង្គទាំងសងខាងមានតម្លៃស្មើគ្នា $(3 \times 4 = 12)$ ហើយអង្គទាំងសងខាងមានខ្នាតដូចគ្នា $(\text{m} \times \text{m} = \text{m}^2)$ ។

***ឧទាហរណ៍ទី2 :*** គេមានសមីការពីរ $v = v_0 + at$ និង $x = \frac{v}{2a}$ ដែលក្នុងនោះ $x$ ជាចម្ងាយគិតជា m , $v$ និង $v_0$ ជាល្បឿនគិតជា m/s , $a$ ជាសំទុះគិតជា $m/s^2$ និង $t$ ជាពេលគិតជា s ។ តើសមីការទាំងពីរនេះផ្ទៀងផ្ទាត់ខ្នាតត្រឹមត្រូវឬទេ ?

***សមីការទី 1 :*** $v = v_0 + at$ បញ្ចូលខ្នាតនៃទំហំនីមួយៗ យើងបាន : $\frac{\text{m}}{\text{s}} = \frac{\text{m}}{\text{s}} + \frac{\text{m}}{\text{s}^2} \times \text{s}$

ដោយសម្រួល s គេបាន : $\frac{m}{s} = \frac{m}{s} + \frac{m}{s}$ ។ ដូច្នេះសមីការទី 1 ផ្ទៀងផ្ទាត់ខ្នាតត្រឹមត្រូវ ។

***សមីការទី 2 :*** $x = \frac{v}{2a}$

ខ្នាតរបស់ $x$ ដែលនៅខាងឆ្វេងដៃគិតជា m

ខ្នាតរបស់ $\frac{v}{2a}$ ដែលនៅខាងស្តាំដៃគិតជា $\frac{m/s}{m/s^2} = \frac{m}{s} \times \frac{s^2}{m} = s$

ដូច្នេះសមីការនេះមិនផ្ទៀងផ្ទាត់ខ្នាតទេ ព្រោះ m មិនដូចខ្នាត s ទេ (ប្រវែង $\neq$ ពេល) ។

## 3.5 លេខមានន័យ

ជាញឹកញាប់អ្នកផ្តល់ទិន្នន័យជាលេខ កាលណាអ្នកដោះស្រាយលំហាត់មួយ ។ ជាទូទៅទិន្នន័យនោះអាចជាចំនួនជាក់លាក់ឬចំនួនដែលបានមកពីការវាស់វែង ។ ចំនួនជាក់លាក់ជាចំនួនដែលគ្មានល្អៀង តែចំនួនដែលបានមកពីការវាស់វែង ជាទូទៅមានកម្រិតល្អៀងមួយ ។ បញ្ហាគឺថា តើត្រូវប្រាប់ល្អៀងនៃលទ្ធផលដែលកើតឡើងនោះយ៉ាងដូចម្តេច?

***ឧទាហរណ៍ :*** $t = \frac{x}{v} = \frac{5.3\text{m}}{1.67\text{m/s}} = 3.173652\text{s}$ តើចម្លើយគួរយកប៉ុន្មានខ្ទង់ក្រោយចុច ?

ជាគោលការណ៍តួលេខមានន័យក្នុងរង្វាស់នីមួយៗ គឺជាតួលេខដែលគេទទួលស្គាល់ថាជាតួលេខជាក់លាក់និងថែមមួយតួលេខខាងក្រោយទៀតជាលេខមិនជាក់លាក់ ។ លេខទាំងនេះបានមកពីការអានផ្ទាល់នៃឧបករណ៍រង្វាស់និងថែមមួយលេខទៀតដែលបានមកពីការប៉ាន់ស្មាននៃប្រភាគរបស់ប្រឡោះក្រិតដ៏តូច ។

ទំហំ 2.5cm មានលេខជាក់លាក់គឺលេខ 2 និងលេខមិនជាក់លាក់គឺលេខ 0.5 ។ ចំណែកទំហំ 2.54cm មានលេខជាក់លាក់ 2 និង 5 ។ ចំណែក 0.04 ជាលេខមិនជាក់លាក់ ។ គេថា 2.54cm មានភាពជាក់លាក់ជាង 2.5cm ។ 2.5cm មានតួលេខមានន័យពីរចំណែក 2.54cm មានតួលេខមានន័យបី ។ វាអាចមានការភ័ន្តច្រឡំចំពោះចំនួនខ្លះដែលមានលេខសូន្យមួយឬច្រើន ។ ក្នុងករណីនេះ គេត្រូវប្រើក្បួនដូចខាងក្រោម :

- សូន្យទាំងឡាយណាដែលនៅខាងដើមនៃចំនួន មិនមែនជាតួលេខមានន័យទេ គេប្រើវាសម្រាប់ញែកផ្នែកទសភាគប៉ុណ្ណោះ ។

***ឧទាហរណ៍ :*** 0.0254m មានតួលេខមានន័យបីគឺ (2, 5 , 4)

- សូន្យដែលនៅចន្លោះចំនួនជាតួលេខមានន័យ ។

***ឧទាហរណ៍ :*** 104.6m មានតួលេខមានន័យបួនគឺ (1, 0 , 4, 6)

- សូន្យនៅខាងក្រោយជាប់ចុចជាតួលេខមានន័យដែរ ។

***ឧទាហរណ៍ :*** 2075.0 មានតួលេខមានន័យប្រាំគឺ (2, 0 , 7 , 5 , 0) ។

- ក្នុងចំនួនទាំងមូលដែលគ្មានផ្នែកទសភាគហើយបញ្ចប់ដោយលេខសូន្យមួយឬច្រើន សូន្យទាំងនោះអាចជាតួលេខមានន័យឬមិនអាចជាតួលេខមានន័យ ។

***ឧទាហរណ៍ :*** 500kg អាចមានមួយលេខជាក់លាក់គឺ 5 អាចមានពីរលេខជាក់លាក់គឺ 50 អាចមានបីលេខជាក់លាក់គឺ 500 ។ ក្នុងករណីដោយឡែកមួយនេះគេអាចសរសេរ 500kg ជា :

$5 \times 10^2$kg សម្រាប់ 1 លេខជាក់លាក់

$5.0 \times 10^2$kg សម្រាប់ 2 លេខជាក់លាក់

$5.00 \times 10^2$kg សម្រាប់ 3 លេខជាក់លាក់ ។

**សម្គាល់ :** នៅខាងក្រោមយើងតាងតួលេខមានន័យដោយអក្សរកាត់ ***(ល.ន)*** ។

**លេខមានន័យក្នុងប្រមាណវិធី** : ក្នុងប្រមាណវិធីគុណ និងចែកគេត្រូវរក្សាចំនួនតួលេខមានន័យយ៉ាងហោចឱ្យស្មើនឹងទំហំដែលមានតួលេខមានន័យតិចជាងគេ ។

***ឧទាហរណ៍ :*** $\frac{5.3\text{m (2 លន)}}{1.67\text{m/s (3 លន)}} = 3.2\text{s (2 លន)}$

$\underset{\text{(2 លន)}}{2.4\text{m}} \times \underset{\text{(3 លន)}}{3.65\text{m}} = 8.76\text{m}^2 = \underset{\text{(2 លន)}}{8.8\text{m}^2}$

$\frac{725.0\text{m} \quad \text{(4 លន)}}{0.125\text{s} \quad \text{(3 លន)}} = 5800\text{m/s} = \underset{\text{(3 លន)}}{5.80 \times 10^3\text{m/s}}$

> ***ចំណាំ :*** *ផលគុណឬផលចែក ដែលបានមកពីការគុណឬចែកនឹងចំនួនថេរត្រូវគិតតាមចំនួនដែលយកមកគុណឬចែកនោះ ។*

***ឧទាហរណ៍*** :

$\underset{\text{(4 លន)}}{0.2786} \times 8 = \underset{\text{(4 លន)}}{2.229}$

$\frac{5.16 \quad \text{(3 លន)}}{2} = 2.58 \text{ (3 លន)}$

- ក្នុងប្រមាណវិធីដកនិងបូក គេរក្សាទុកផ្នែកទសភាគនៃចម្លើយនូវចំនួនតួលេខឱ្យស្មើនឹងចំនួនតួលេខនៃទំហំដែលមានចំនួនតួលេខតិចជាងគេក្នុងផ្នែកទសភាគ ។

***ឧទាហរណ៍*** : $23.1 + 0.546 + 1.45 = 25.09$

23.1 ជាចំនួនដែលតួលេខផ្នែកទសភាគមានតិចជាងគេ ។ គេសរសេរលទ្ធផលប្រហែល 25.1

$157 - 5.5 = 151.5$

157 គ្មានតួលេខក្នុងផ្នែកទសភាគទេ គេយកចម្លើយប្រហែល 152 ។

# 4. សុវត្ថិភាពក្នុងទីពិសោធន៍

ការធ្វើពិសោធន៍ប្រកបដោយសុវត្ថិភាពមានសារៈសំខាន់ណាស់ ។ ធាតុគីមីខ្លះធ្វើឱ្យយើងមានគ្រោះថ្នាក់ប្រសិនបើយើងប្រើប្រាស់ខុស និងខ្វះបម្រុងប្រយ័ត្ន ។ ដូច្នេះដើម្បីចៀសវាងគ្រោះថ្នាក់ យើងត្រូវមានវិធានសម្រាប់អនុវត្តក្នុងពេលពិសោធដោយមានបម្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ដល់សុវត្ថិភាពទីពិសោធន៍ ។


*ពិសោធន៍ខ្វះការប្រុងប្រយ័ត្ន*

ធាតុគីមី ដូចជាទឹកក៏អាចបណ្តាលឱ្យមានគ្រោះថ្នាក់បានដែរ ។ ដើម្បីរក្សាសុវត្ថិភាពក្នុងពេលពិសោធ យើងត្រូវមានការយល់ដឹងក្នុងការប្រើប្រាស់ធាតុគីមីឱ្យបានត្រឹមត្រូវ គឺត្រូវមានបម្រុងប្រយ័ត្នជាមុន ដូចជាការពិនិត្យស្លាកសញ្ញាធាតុគីមីមុននឹងយកមកប្រើដោយអនុវត្តតាមការណែនាំជាដើម... ។

***ចំណុចបម្រុងប្រយ័ត្នទាំងឡាយដែលតែងតែអនុវត្តក្នុងទីពិសោធន៍ :***

- ត្រូវពាក់អាវអៀមការពារសុវត្ថិភាពជានិច្ច ។ នៅទីពិសោធន៍មានធាតុគីមីខ្លះអាចធ្វើឱ្យខូចខាតសម្លៀកបំពាក់យើង ពេលវាខ្ទាតមកប៉ះ ដូចនេះយើងត្រូវពាក់អៀមការពារជាប់ជានិច្ចរាល់ពេលចូលធ្វើពិសោធន៍ម្តងៗ ។
- ត្រូវពាក់វ៉ែនតាការពារភ្នែកជានិច្ចនៅពេលដំណើរការពិសោធ ព្រោះប្រសិនបើសារធាតុគីមីខ្លះខ្ទាតប៉ះភ្នែកវាអាចបណ្តាលឱ្យភ្នែកយើងឈឺឬខ្វាក់ ។ ហាមពាក់វ៉ែនតា កញ្ចក់កែវនៅពេលធ្វើពិសោធន៍ ។
- មិនត្រូវធ្វើការម្នាក់ឯងនៅក្នុងទីពិសោធន៍ទេ គឺត្រូវឋិតក្រោមការដឹកនាំរបស់គ្រូជានិច្ច ។
- មិនត្រូវពាក់គ្រឿងអលង្ការដូចជា : ខ្សែក ខ្សែដៃ ក្រវិល . .. ព្រោះវាអាចខូចខាតដោយប៉ះសារធាតុគីមី ។
- ត្រូវចងសក់ទៅក្រោយឱ្យអស់ឬកាត់សក់ខ្លី ។
- ត្រូវស្លៀកសម្លៀកបំពាក់ធ្វើពីអំបោះជាការប្រសើរ ។ កុំស្លៀកសម្លៀកបំពាក់ធ្វើពីនីឡុងនិងប៉ូលីអេស្ទែរ ព្រោះវាអាចឆេះនិងរលាយរហ័សជាងអំបោះ ។
- ត្រូវពាក់ស្បែកជើងកវែងឬប៊ូដើម្បីការពារជើងពេលកំពប់សារធាតុគីមី ។ មិនត្រូវពាក់ស្បែកជើង ផ្ទាត់ សង្រែកឬស្បែកជើងកំណាត់ទេ ។

- មិនត្រូវយកកាបូប សាក់កាដូ ឬវត្ថុផ្សេងៗ ដូចជាគ្រឿងតុបតែងខ្លួនចូលទីពិសោធន៍ទេ ត្រូវទុកវត្ថុទាំងនេះនៅលើតុរៀន ហើយយកតែសៀវភៅឬសៀវភៅកត់ត្រាមួយប៉ុណ្ណោះ ។
- ពិនិត្យដោយយកចិត្តទុកដាក់នូវស្លាកសញ្ញារបស់ធាតុគីមី ។
- ធ្វើការដោយប្រុងប្រយ័ត្ននៅក្នុងទីពិសោធន៍ ។ ពេលខ្លះយើងត្រូវយកធាតុគីមីពីកន្លែងទុកមកតុពិសោធន៍ដោយប្រុងប្រយ័ត្នកុំឱ្យទង្គិចឬប៉ះនឹងសិស្សដទៃ ។
- ហាមយកអាហារ ភេសជ្ជៈ ស្ករកៅស៊ូ និងជក់បារីនៅក្នុងបន្ទប់ពិសោធន៍ ។
- មិនត្រូវភ្លក់ធាតុគីមីឬប៉ះវាដោយផ្ទាល់ដៃទេ ។
- កុំកាន់ចានក្តៅ ចំពុះប៊ុនសិននិងប្រភពកម្តៅផ្សេងទៀតដែលទើបប្រើប្រាស់រួច ។
- កុំប្រើឧបករណ៍អគ្គិសនីដែលមានខ្សែដាច់រលាត់ឬរមួល ។ ជូតដៃឱ្យស្ងួតមុននឹងប្រើឧបករណ៍អគ្គិសនីដើម្បីចៀសវាងគ្រោះថ្នាក់ដោយសារភ្លើងឆក់ ។
- បើសម្លៀកបំពាក់ឆេះដោយភ្លើងយើងត្រូវទៅកន្លែងរ៉ូប៊ីណេទឹកសុវត្ថិភាព ឈរពីក្រោមវាហើយបើកទឹកដាក់កន្លែងដែលឆេះ ។
- បើសារធាតុគីមីខ្ទាតប៉ះដៃឬប៉ះភ្នែកត្រូវទៅកន្លែងរ៉ូប៊ីណេទឹកលាងដៃឬបើកភ្នែកនិងត្រលៀសគ្រាប់ភ្នែកក្នុងកែវឬផ្តិលទឹកឱ្យបាន 15 នាទី ។
- បើយើងធ្វើឱ្យកំពប់សារធាតុគីមីលើឥដ្ឋឬលើកៅអីក្នុងបន្ទប់ពិសោធន៍ត្រូវជម្រាបគ្រូភ្លាម កុំព្យាយាមលាងសំអាតដោយខ្លួនឯង ។ គ្រូនឹងណែនាំពីរបៀបលាងសំអាតប្រកបដោយសុវត្ថិភាព ។
- កាន់សារធាតុគីមីដោយប្រុងប្រយ័ត្នជាពិសេស អាស៊ីត បាសអាល់កាលី សារធាតុពុល និងសារធាតុឆេះ ។
- ប្រើទូសម្រួបសម្រាប់ពិសោធន៍ណាដែលទាក់ទងនឹងសារធាតុពុលឬសារធាតុដែលមានសកម្មភាពគីមីខ្លាំង ។
- ចូរកាន់ឧបករណ៍ធ្វើពីកែវដោយបម្រុងប្រយ័ត្ន ។
- ត្រូវស្គាល់កន្លែងទុកដាក់ឧបករណ៍ពន្លត់អគ្គិភ័យនិងរបៀបប្រើប្រាស់វា ។
- ត្រូវរាយការណ៍ឬផ្តល់ព័ត៌មានដល់គ្រូរាល់គ្រោះថ្នាក់ទាំងឡាយដែលកើតមានក្នុងពេលធ្វើពិសោធន៍ដើម្បីរកវិធីដោះស្រាយ ។
- ប្រើប្រាស់ធាតុគីមីតាមបរិមាណដែលសមស្របឬត្រូវការចៀសវាងយកមកលើសកម្រិត ។
- កុំយកធាតុគីមីចេញក្រៅបន្ទប់ពិសោធន៍ ។
- កុំប្រឡែងគ្នាឬធ្វើថ្លុកកំប្លែងក្នុងបន្ទប់ពិសោធន៍ ។

facebook.com/moeys.gov.kh youtube.com/moeys krou.moeys.gov.kh

- ត្រូវសំអាតសំភារៈ ឧបករណ៍ និងកន្លែងពិសោធន៍ក្រោយពេលធ្វើរួច ។
- ត្រូវលាងដៃជាមួយសាប៊ូនិងទឹកមុនពេលចេញពីបន្ទប់ពិសោធន៍ ។
- ត្រូវគោរពតាមការណែនាំឱ្យបានហ្មត់ចត់ ។
- ច្បាប់ឬបទបញ្ជាទាំងអស់នេះត្រូវអនុវត្តគ្រប់ពេលអ្នកនៅក្នុងទីពិសោធន៍ ។
- ត្រូវស្គាល់ច្បាស់ពីនិមិត្តសញ្ញានិងអត្ថន័យរបស់ស្លាកសញ្ញាសុវត្ថិភាពនៃសារធាតុគីមី ។

**ចូរពិនិត្យឱ្យបានច្បាស់ពីនិមិត្តសញ្ញាសុវត្ថិភាពដូចខាងក្រោម :**



**អៀមឬអាវការពារ** : សញ្ញានេះបញ្ជាក់ថា ត្រូវពាក់អៀមការពារសម្លៀកបំពាក់ក្នុងទីពិសោធន៍ ។



**វ៉ែនតាសុវត្ថិភាព** : សញ្ញានេះបញ្ជាក់ថា ត្រូវពាក់វ៉ែនតានៅក្នុងទីពិសោធន៍គ្រប់ពេល ។



**លាងសំអាត** : ត្រូវលាងដៃមុនពេលចាកចេញពីបន្ទប់ពិសោធន៍ ការពារដៃកុំឱ្យប៉ះមុខនិងមាត់ ។



**សារធាតុឬធាតុគីមីពុល** :
កុំហិតឬប៉ះដោយផ្ទាល់នូវសារធាតុពុលខ្លាំង ។



**សំរាមបោះចោល** : ត្រូវចោលកាកសំណល់ក្នុងធុង ។
មានធាតុគីមីខ្លះធ្វើឱ្យខូចខាតដល់បរិស្ថាន ។



**សុវត្ថិភាពឧបករណ៍កែវ** : មិនត្រូវដាក់កែវដែលមានផ្ទុកធាតុគីមីឬរបស់ផ្សេងៗនៅកែមកៅអីឬតុពិសោធន៍ ។



**សារធាតុផ្ទុះ** : សារធាតុនេះជាសារធាតុដែលមានប្រតិកម្មខ្លាំងក្លានិងផ្ទុះ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys



**សុវត្ថិភាពដៃ :** បើធាតុគីមីជាប់នឹងស្បែកឬសម្លៀកបំពាក់ឬភ្នែកត្រូវលាងភ្លាម ។



**សារធាតុងាយឆេះ :** សារធាតុនេះងាយឆាបឆេះដោយអណ្តាតភ្លើង ។ វាអាចបង្កគ្រោះថ្នាក់អគ្គីភ័យ ។



**សារធាតុដែលស៊ីឬកាត់ :** សារធាតុនេះអាចធ្វើអោយខូចខាតនិងបំផ្លាញជាលិកា រួមមានភ្នែកនិងស្បែក ។

## ? សំណួរនិងលំហាត់

### វិធីវិទ្យាសាស្ត្រ

1. តើវិទ្យាសាស្ត្រមាននាទីដូចម្តេច ?
2. ដូចម្តេចដែលហៅថាវិទ្យាសាស្ត្រ ?
3. តើលំដាប់លំដោយការងារអ្វីខ្លះដែលអ្នកវិទ្យាសាស្ត្របានអនុវត្តក្នុងការស្រាវជ្រាវរបស់ខ្លួន ?
4. ចូរពន្យល់ពីជំហាននីមួយៗ របស់វិធីវិទ្យាសាស្ត្រ ។
5. អ្វីទៅជាទិន្នន័យផ្នែកបរិមាណនិងជាទិន្នន័យផ្នែកគុណភាព ? ចូរឱ្យជាឧទាហរណ៍ ។
6. តើទ្រឹស្តីមានអត្ថន័យយ៉ាងដូចម្តេច ?

### រង្វាស់និងខ្នាត

1. គ្រប់ទំហំរូបទាំងអស់សំដែងឡើងដោយអ្វី ?
2. តើអ្វីទៅប្រព័ន្ធខ្នាតអន្តរជាតិ SI ?
3. ក្នុងប្រព័ន្ធខ្នាតអន្តរជាតិ SI តើខ្នាតគ្រឹះមានប៉ុន្មាន ? អ្វីខ្លះ ?
4. តើអ្វីទៅខ្នាតគ្រឹះគំរូ ? មានប៉ុន្មាន ? អ្វីខ្លះ ?
5. តើបុព្វបទពហុគុណនៃខ្នាតគ្រឹះមានអ្វីខ្លះ ?
6. តើបុព្វបទអនុពហុគុណនៃខ្នាតគ្រឹះមានអ្វីខ្លះ ?

7. ចូរធ្វើការវិភាគខ្នាតក្នុងរូបមន្តខាងក្រោម :

ក. $x = x_o + v_o t + \frac{1}{2}at^2$ ខ. $E = mc \times \Delta t$

គ. $h = \frac{1}{2}gt^2$ ឃ. $v^2 = \frac{2g}{h}$

តើរូបមន្តណាខ្លះផ្ទៀងផ្ទាត់ខ្នាតត្រឹមត្រូវ ហើយណាខ្លះមិនត្រឹមត្រូវ ?

8. តើភាពជាក់លាក់នៃរង្វាស់ត្រូវចង្អុលបង្ហាញដោយអ្វី ?

9. ក្នុងរង្វាស់ខាងក្រោម តើលេខមានន័យមានប៉ុន្មាន ?

ក. $0.025\text{m}^2$ ខ. 10.5kg

គ. 201.0L ឃ. $15 \times 10^2\text{m}^3$

ង. $25.5 \times 10^3\text{kg}$ ច. 0.12cm

10. គេមានរង្វាស់ពីរ 4.3cm និង 4.35cm ។ តើរង្វាស់ណាមានភាពជាក់លាក់ជាងគេ ?

## សុវត្ថិភាពក្នុងទីពិសោធន៍

1. តើយើងត្រូវពាក់វ៉ែនតាសុវត្ថិភាពនៅពេលណា ?
2. តើយើងត្រូវធ្វើដូចម្តេច នៅពេលដែលបែកឧបករណ៍ពិសោធន៍ធ្វើពីកែវ ?
3. ក្រោយពីសំអាតកន្លែងធ្វើពិសោធន៍រួច តើអ្នកត្រូវធ្វើដូចម្តេចមុននឹងចេញពីបន្ទប់ពិសោធន៍ ?
4. តើយើងត្រូវប្រើទូសម្រូបនៅពេលណា ?
5. តើផ្លាកសញ្ញានេះ



មានន័យដូចម្តេច ?

6. ចូរអានប្រយោគខាងក្រោមនេះដោយយកចិត្តទុកដាក់ហើយសរសេរពាក្យ ខុសឬត្រូវនៅខាងក្រោយប្រយោគនីមួយៗ :

ក. ត្រូវពាក់វ៉ែនតាសុវត្ថិភាពពេលដែលអ្នកដុតធាតុគីមី ________ ។

ខ. ញ៉ាំអាហារ ភេសជ្ជៈ ស្ករកៅស៊ូនិងជក់បារីក្នុងបន្ទប់ពិសោធន៍ ________ ។

គ. ធាតុគីមីដែលមិនត្រូវប្រើ ត្រូវយកទៅទុកនៅកន្លែងដើមវិញ ________ ។

ឃ. ប្រឡែងគ្នាឬធ្វើប្លុកកំប្លែងនៅក្នុងបន្ទប់ពិសោធន៍ ________ ។

youtube.com/moeys
khmoeys.gov.kh
facebook.com/moeys.gov.kh

# សេចក្ដីផ្តើម

## 1. បុរេកថា




យើងអាចនិយាយទៅកាន់មិត្តភក្តិឬសាច់ញាតិរបស់យើងដែលរស់នៅបរទេសនៅក្នុងពិភពលោក ដោយប្រើប្រាស់ទូរស័ព្ទឬក៏ទាក់ទងគ្នាតាមរយៈអ៊ីនធើណែត ហើយយើងក៏មានភាពសប្បាយរីករាយជាមួយនឹងទូរទស្សន៍ ម៉ាស៊ីនចាក់ស៊ីឌី វីស៊ីឌី ឬឌីវីឌីផងដែរ ។

យើងអាចធ្វើដំណើរទៅគ្រប់ទីកន្លែងទាំងអស់ដោយរថយន្ត ឬរថភ្លើង នៅពេលអនាគតយើងនឹងអាចធ្វើដំណើរទៅកាន់លំហអាកាសយ៉ាងងាយស្រួលដោយប្រើប្រាស់យានអវកាសឬកាំជ្រួច ។ យើងអាចនិយាយបានថាការរស់នៅប្រកបដោយភាពទាន់សម័យនេះគឺដោយសារតែផ្លែផ្ការបស់រូបវិទ្យា ប្រសិនបើគ្មានរូបវិទ្យានោះការរស់នៅរបស់យើងនឹងជួបប្រទះនូវការលំបាក ។ ដូច្នេះការសិក្សារូបវិទ្យាពិតជាមានសារប្រយោជន៍ខ្លាំងណាស់ សម្រាប់សង្គមមនុស្ស ។ ប្រសិនបើគ្មាននរណាម្នាក់សិក្សាពីរូបវិទ្យាទៀតទេនោះ យើងអាចទស្សន៍ទាយបានថាការរស់នៅប្រកបដោយផាសុខភាពរបស់យើងនឹងមិនអាចនឹងបន្តទៅមុខបានទៀតទេ ។

គោលបំណងនៃការសិក្សារូបវិទ្យា គឺដើម្បីស្វែងយល់ឱ្យស៊ីជម្រៅពីពិភពដែលយើងរស់នៅ មានន័យថាអ្វីៗទាំងអស់នៅក្នុងធម្មជាតិគឺសុទ្ធតែគោរពតាមច្បាប់ផ្សេងៗរបស់រូបវិទ្យា ពោលគឺរូបវិទ្យាជាអ្នកបង្កើតនូវវិធាននិងច្បាប់ទាំងឡាយក្នុងធម្មជាតិដោយចេញពីភាគល្អិតដំបូងរហូតដល់ពិភពលោកទាំងមូលដូចរូបខាងលើ ។ រូបវិទ្យាសិក្សាដោយផ្អែកលើការសង្កេត ពិសោធន៍ និងរង្វាស់ទំហំផ្សេងៗដូចជាមុខវិជ្ជាវិទ្យាសាស្ត្រដទៃទៀតដែរ ។ វត្ថុបំណងចម្បងរបស់រូបវិទ្យា គឺកំណត់ព្រំដែននៃច្បាប់គ្រឹះដែលក្ដោបទៅលើបាតុភូតធម្មជាតិ ហើយប្រើប្រាស់ច្បាប់ទាំងនោះ ដើម្បីអភិវឌ្ឍន៍ទ្រឹស្ដី ឬទស្សន៍ទាយនូវលទ្ធផលពិសោធន៍ក្រោយៗទៀត ។ម្យ៉ាងវិញទៀតច្បាប់គ្រឹះទាំងឡាយដែលប្រើសម្រាប់ការអភិវឌ្ឍទ្រឹស្តីទាំងនោះត្រូវបានបកស្រាយដោយភាសាគណិតវិទ្យា ។

## 2. ប្រវត្តិរូបវិទ្យា

វិទ្យាសាស្ត្របានបង្កើតឡើងក្នុងប្រទេសក្រិកនៅសតវត្សទី 3 និងទី 4 មុនគ្រិះសករាជហើយបានផ្ដល់នូវផ្លូវដ៏ត្រចះត្រចង់ ។ នៅសម័យនោះមធ្យោបាយក្នុងការពិសោធដោយប្រើវិធីវិទ្យាសាស្ត្រពុំទាន់ត្រូវបានគេបង្កើតឡើងទេ ។ ក្នុងកំឡុងពេល 200ឆ្នាំ បន្ទាប់មកទើបអ្នករូបវិទ្យាជនជាតិអ៊ីតាលីម្នាក់ឈ្មោះ **កាលីលេ**( Galileo Galilei )(1564 -1642) បានធ្វើការបង្ហាញពីវិធីពិសោធន៍ដែលមានលក្ខណៈវិទ្យាសាស្ត្រប្លែកៗជាច្រើន ដូច្នេះហើយទើបគេហៅគាត់ថា **បិតាពិសោធន៍** ។ រូបវិទ្យាត្រូវបានអភិវឌ្ឍន៍ដោយប្រើប្រាស់វិធីពីរយ៉ាងគឺទ្រឹស្ដីនិងពិសោធន៍ ។

កាលណាមានភាពមិនស្របគ្នារវាងទ្រឹស្ដី និងពិសោធន៍កើតមានឡើង ពេលនោះទ្រឹស្ដីថ្មីៗក៏ត្រូវបានបង្កើតឡើងដែរ ដើម្បីពន្យល់និងបំបាត់ភាពមិនស្របគ្នា ឬភាពមន្ទិលនេះចេញ ។ ឧទាហរណ៍ច្បាប់ចលនារបស់លោកញូតុន (Isaac Newton) (1642 - 1727) នៅក្នុងសតវត្សទី17 បានបកស្រាយពីចលនារបស់អង្គធាតុដែលមានល្បឿនធម្មតា (តូច) ប៉ុន្តែច្បាប់នេះមិនអាចអនុវត្តបានទេ ចំពោះចលនារបស់អង្គធាតុណាមួយដែលមានល្បឿនលឿនធៀបនឹងល្បឿនពន្លឺ ប៉ុន្តែក្នុងករណីអង្គធាតុមានល្បឿនលឿន **(ធៀបបាននឹងល្បឿនពន្លឺ)** នេះត្រូវបានបកស្រាយដោយលោកអាំងស្តាំង (Albert Einstein ) (1879 - 1955) ។ នៅដើមឆ្នាំ1900 គេហៅទ្រឹស្ដីនេះថា **ទ្រឹស្ដីធៀប** ហើយទ្រឹស្ដីនេះបានផ្ដល់លទ្ធផលដូចគ្នានឹងច្បាប់ចលនារបស់ញូតុនដែរ ។ ដូច្នេះទ្រឹស្ដីរបស់លោកអាំងស្តាំងមានភាពទូលំទូលាយនិងទូទៅជាងគេក្នុងទ្រឹស្ដីនៃចលនា ។

**ក្នុងការសិក្សារូបវិទ្យាចែកជាពីរផ្នែកគឺ រូបវិទ្យាបុរាណឬក្លាសិច និងរូបវិទ្យាទំនើប ។**

រូបវិទ្យាក្លាសិចជាផ្នែកផ្សេងៗនៃរូបវិទ្យាដែលបានអភិវឌ្ឍន៍មុនឆ្នាំ1900 ដោយគិតទាំងទ្រឹស្ដី បញ្ញត្តិ ច្បាប់ និងពិសោធន៍មានមេកានិចក្លាសិច ទែម៉ូឌីណាមិច និងអេឡិចត្រូម៉ាញេទិច ។ លោកញូតុនជាអ្នកអភិវឌ្ឍរូបវិទ្យាជាប្រព័ន្ធទ្រឹស្ដី និងជាប្រភពដើមនៃការប្រើប្រាស់គណិតវិទ្យាសម្រាប់អនុវត្ត ។ ការអភិវឌ្ឍជាចម្បងក្នុងមេកានិចបានបន្តក្នុងសតវត្សទី 18 ប៉ុន្តែផ្នែកទែម៉ូឌីណាមិច អគ្គិសនី និងម៉ាញេទិចមិនទាន់ត្រូវបានអភិវឌ្ឍន៍នៅឡើយទេរហូតដល់ចុងសតវត្សទី 19 ។

នៅចុងសតវត្ស 19 រូបវិទ្យាទំនើបក៏ចាប់ផ្ដើមកើតឡើងដើម្បីអភិវឌ្ឍន៍នូវអ្វីៗដែលរូបវិទ្យាក្លាសិចមិនអាចបកស្រាយបាន ។

ការអភិវឌ្ឍសំខាន់ៗក្នុងរូបវិទ្យាទំនើបគឺ ទ្រឹស្ដីធៀប និងមេកានិចកង់ទិច ប៉ុន្តែយើងនឹងសិក្សាទ្រឹស្ដីនៃផ្នែកទាំងពីរនេះនៅកម្រិតសាកលវិទ្យាល័យ ។

# ជំពូក 1 មេកានិច



នៅក្នុងធម្មជាតិ មនុស្ស សត្វ រុក្ខជាតិសុទ្ធតែមានចលនា ។ ចលនាទាំងនោះប្រែប្រួលតាមពេលវេលាឥតឈប់ឈរ ។ កម្លាំងជាបុព្វហេតុធ្វើឱ្យមានបម្រែបម្រួលចលនា ។ ចំណេះដឹងដែលមាននៅក្នុងជំពូកនេះនឹងអាចដោះស្រាយចម្ងល់របស់អ្នកបានខ្លះៗដូចជា ហេតុអ្វីបានជាផ្លែឈើទុំជ្រុះឬវត្ថុធ្លាក់តម្រង់មករកដី? ហេតុអ្វីគេត្រូវសំលៀងកាំបិតឱ្យមុតមុននឹងយកទៅប្រើ ? ហេតុអ្វីបានជាម្ជុល មានម៉ាសតូចមួយលិចចូលក្នុងទឹក ចំណែកឯ ទូក កប៉ាល់មានម៉ាសធំបែរជាអណ្តែតលើទឹកទៅវិញ ?.... ។

**មេរៀនទី 1 : ចលនាត្រង់**

**មេរៀនទី 2 : ច្បាប់ចលនារបស់ញូតុន**

**មេរៀនទី 3 : កម្មន្ត ថាមពល និងអានុភាព**

**មេរៀនទី 4 : សម្ពាធនិងសន្ទនីយស្តាទិច**

facebook.com/moeys.gov.kh

មេរៀនទី

# 1 ចលនាត្រង់

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីភាពខុសគ្នារវាងទំហំវ៉ិចទ័រនិងទំហំស្កាលែ ។
- បង្ហាញពីទំនាក់ទំនងរវាងបំលាស់ទី វ៉ិចទ័រល្បឿន និងសំទុះ ។
- បកស្រាយអំពីសំទុះថេរនៃអង្គធាតុធ្វើចលនាតាមមួយវិមាត្រតាមក្រាប ។

គ្រប់អង្គធាតុក្នុងធម្មជាតិមានចលនាឥតឈប់ឈរ ។ ក្នុងមេរៀននេះយើងសិក្សាអំពីចលនា **មេកានិច** ។ ចលនាមេកានិចគឺជាបំលាស់ប្តូរទីតាំងអង្គធាតុមួយធៀបទៅនឹងអង្គធាតុមួយទៀត ។ គេថាចលនានៃអង្គធាតុមួយជាចលនាត្រង់ឬចលនាកោងគឺអាស្រ័យនឹងរាងគន្លងនៃចលនា ។ គន្លងនៃចលនាគឺជាសំណុំចំណុចទាំងឡាយបន្តបន្ទាប់នៃចល័តដែលបានចរ ។

## 1. វ៉ិចទ័រ

***ឧទាហរណ៍ :*** ធីតាបានធ្វើដំណើរពីភូមិ $A$ ទៅភូមិ $B$ ។ បន្ទាប់មកនាងធ្វើដំណើរទៅភូមិ $C$ (រូបទី 1.1) ។ តើនាងផ្លាស់ទីបានចម្ងាយប៉ុន្មាន ? ដោយដឹងថាចម្ងាយពី $A$ ទៅ $B$ គឺ 6.0km និងពី $B$ ទៅ $C$ គឺ 4.0km ។ បំលាស់ទីពី $A$ ទៅ $C$ ស្មើនឹង 6.0km + 4.0km = 10km តើត្រឹមត្រូវឬទេ ? មិនត្រឹមត្រូវទេ បំលាស់ទី $AC$ តិចជាង 10km ព្រោះតម្លៃនៃបំលាស់ទី $AC$ គឺជាប្រវែង $AC$ និងវាមានទិសដៅពី $A$ ទៅ $C$ ។ ទំហំទាំងឡាយណាដែលមានតម្លៃនិងទិសដៅហៅថា**ទំហំវ៉ិចទ័រ** ។




***រូបទី*** *1.1*

គេតាងវ៉ិចទ័រដោយសញ្ញាព្រួញដែលមាន $O$ ជាគល់ព្រួញតាងឱ្យគល់វ៉ិចទ័រ $C$ ជាចុងព្រួញតាងឱ្យទិសដៅវ៉ិចទ័រនិងប្រវែង $OC$ តាងឱ្យទំហំឬតម្លៃវ៉ិចទ័រ ។ គេសរសេរវ៉ិចទ័រ $\overrightarrow{OC}$ ។




***រូបទី*** *1.2*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 1.1 ទំហំវ៉ិចទ័រនិងស្កាលែ

ទំហំរូបវិទ្យាមាន ម៉ាស កម្លាំង ល្បឿន សំទុះ សម្ពាធ កម្មន្ត ថាមពល អានុភាព ពេល ចម្ងាយ បំលាស់ទី . . . ។

គេចែកទំហំទាំងនោះជាពីរ គឺទំហំវ៉ិចទ័រនិងទំហំស្កាលែ ។ ទំហំរូបវិទ្យាដែលជាទំហំវ៉ិចទ័រមាន បំលាស់ទី វ៉ិចទ័រល្បឿន សំទុះ កម្លាំង ។ល ។ ទំហំរូបវិទ្យាដែលមិនទាក់ទងនឹងទិសដៅ ហៅថាទំហំ ស្កាលែ ដូចជាសីតុណ្ហភាព សម្ពាធ ថាមពល កម្មន្ត ម៉ាស ពេល ។ល ។

***ឧទាហរណ៍ :*** អង្គធាតុមួយផ្លាស់ទីត្រង់តាមទិស $x'x$ ពី $O$ ទៅ $A$ ។ វ៉ិចទ័រ $\overrightarrow{OA}$ ហៅថា **បំលាស់ទី** ។




***រូបទី*** *1.3*

## 1.2 វ៉ិចទ័រពីរស្មើគ្នា

វ៉ិចទ័រពីរ $\vec{A}$ និង $\vec{B}$ ស្មើគ្នា កាលណាវ៉ិចទ័រទាំងពីរនោះមានប្រវែងស្មើគ្នានិងទិសដៅដូចគ្នា។

ដូច្នេះ $\vec{A} = \vec{B}$ បើ $A = B$ ហើយ $\vec{A}$ និង $\vec{B}$ មានទិសដៅដូចគ្នា ។




***រូបទី*** *1.4*

## 1.3 ផលបូកពីរវ៉ិចទ័រ

### ក. ផលបូកពីរវ៉ិចទ័រមានទិសដៅដូចគ្នា

គេមានវ៉ិចទ័រពីរ $\vec{A}$ និង $\vec{B}$ មានទិសដៅដូចគ្នា ។ គេបានវ៉ិចទ័រ $\vec{C} = \vec{A} + \vec{B}$ ។ ដើម្បីសង់វ៉ិចទ័រផ្គួប $\vec{C}$ គេរំកិលវ៉ិចទ័រ$\vec{B}$ ដោយរក្សាទិសរបស់វាទៅដាក់លើទិសនៃវ៉ិចទ័រ $\vec{A}$ ដោយដាក់គល់នៃវ៉ិចទ័រ $\vec{B}$ ត្រង់ចុងព្រួញនៃវ៉ិចទ័រ $\vec{A}$ (រូបទី *1.5*) ។ យើងបានវ៉ិចទ័រផ្គួប $\vec{C}$ ដែលមានប្រវែង $C = A + B$ ។




***រូបទី*** *1.5*

***ឧទាហរណ៍ :*** $A = 3\text{cm}$ , $B = 2\text{cm}$ ។យើងបានវ៉ិចទ័រ $\vec{C}$ ដែលវ៉ិចទ័រនោះមានប្រវែង $C = 3\text{cm} + 2\text{cm} = 5\text{cm}$ ។

## ខ. ផលបូកពីរវ៉ិចទ័រមានទិសដៅផ្ទុយគ្នា

គេមានវ៉ិចទ័រពីរ $\vec{A}$ និង $\vec{B}$ មានទិសដៅផ្ទុយគ្នា ។ គេបានវ៉ិចទ័រ $\vec{C} = \vec{A} + (-\vec{B}) = \vec{A} - \vec{B}$ វ៉ិចទ័រផ្គួប $\vec{C}$ មានប្រវែង $C = A - B$ ។

ដើម្បីសង់វ៉ិចទ័រផ្គួប $\vec{C}$ យើងរំកិលវ៉ិចទ័រ $\vec{B}$ ដោយរក្សាទិសរបស់វាទៅដាក់លើទិសនៃវ៉ិចទ័រ $\vec{A}$ ដោយដាក់គល់នៃវ៉ិចទ័រ $\vec{B}$ ត្រង់ចុងព្រួញនៃវ៉ិចទ័រ $\vec{A}$ ។



***រូបទី** 1.6*

***ឧទាហរណ៍ :*** $A = 3\text{cm}$ , $B = 2\text{cm}$ ។ យើងបានវ៉ិចទ័រ $\vec{C}$ ដែលវ៉ិចទ័រនោះមានប្រវែង $C = 3 - 2 = 1\text{cm}$ ។

## គ. ផលបូកពីរវ៉ិចទ័រមានទិសបង្កើតបានមុំ θ

ដើម្បីសង់វ៉ិចទ័រផ្គួបនៃវ៉ិចទ័រ $\vec{C}$ ដែល$\vec{C} = \vec{A} + \vec{B}$ គេត្រូវអនុវត្តតាមវិធានអង្កត់ទ្រូងប្រលេឡូក្រាម ។ គេដាក់គល់នៃវ៉ិចទ័រ $\vec{A}$ និង $\vec{B}$ រួមគ្នា ហើយក៏ជាគល់នៃវ៉ិចទ័រផ្គួប $\vec{C}$ ដែរ ។ $\vec{C}$ ជាអង្កត់ទ្រូងរបស់ប្រលេឡូក្រាមដែលមានជ្រុង $|\vec{A}|$ និង$|\vec{B}|$ (រូបទី *1.7*) ។ ម្យ៉ាងទៀតដើម្បីសង់វ៉ិចទ័រផ្គួប $\vec{C}$ ដែល $\vec{C} = \vec{A} + \vec{B}$ គេត្រូវរំកិលវ៉ិចទ័រ $\vec{B}$ ដោយរក្សាទិសដៅឱ្យនៅដដែល ដោយធ្វើយ៉ាងណាឱ្យគល់នៃវ៉ិចទ័រ$\vec{B}$ ភ្ជាប់ទៅនឹងចុងព្រួញនៃវ៉ិចទ័រ $\vec{A}$ បន្ទាប់មកគេភ្ជាប់គល់នៃវ៉ិចទ័រ $\vec{A}$ ទៅនឹងចុងព្រួញនៃវ៉ិចទ័រ$\vec{B}$ (រូបទី *1.8*) ។



***រូបទី** 1.7*

ករណី $\vec{A} \perp \vec{B}$ គេបានវ៉ិចទ័រ $\vec{C}$ ដែលមានប្រវែង $C = \sqrt{A^2 + B^2}$ (រូបទី *1.9*) ។



***រូបទី** 1.8*

តាមឧទាហរណ៍ខាងលើ(រូបទី *1.1*) ក្នុងចំណុច 1 បង្ហាញថា បំលាស់ទី $AC$ ដែលធីតាធ្វើបានគឺ

$$AC = \sqrt{(AB)^2 + (BC)^2}$$

ដោយ $AB = 6.0\text{km}$ និង $BC = 4.0\text{km}$

ដូច្នេះ

$$AC = \sqrt{(6.0\text{km})^2 + (4.0\text{km})^2} = 7.2\text{km} < 10\text{km}$$ ។



***រូបទី** 1.9*

youtube.com/moeys
facebook.com/moeys.gov.kh

## 1.4 កូអរដោនេនៃវ៉ិចទ័រ

គេមានវ៉ិចទ័រ $\vec{A}$ ស្ថិតក្នុងប្លង់ $xy$ និងបង្កើតបានមុំ $\theta$ ជាមួយអ័ក្ស $Ox$ ។ គេធ្វើចំណោលកែងវ៉ិចទ័រ $\vec{A}$ លើអ័ក្ស $\overrightarrow{Ox}$ និងលើអ័ក្ស $\overrightarrow{Oy}$ គេបាន $\overrightarrow{A_x}$ និង $\overrightarrow{A_y}$ ។



រូបទី 1.10

តាម(រូបទី 1.10) នៅលើអ័ក្សកូអរដោនេ គេឃើញមានវ៉ិចទ័របី ។ ក្នុងត្រីកោណកែង $OBC$ គេបាន $\vec{A} = \vec{A}_x + \vec{A}_y$ ដោយ $\overrightarrow{Ox} \perp \overrightarrow{Oy}$

$\Rightarrow \quad A = \sqrt{A_x^2 + A_y^2}$ ( ទ្រឹស្តីបទពីតាគ័រ) ។

ដើម្បីងាយក្នុងដំណោះស្រាយលំហាត់ ចូរអ្នកចងចាំនូវរូបមន្តខ្លះខាងក្រោមហើយអ្នកនឹងទទួលបាននូវចំណេះដឹងយ៉ាងស៊ីជម្រៅ នៅពេលអ្នកសិក្សាបញ្ញត្តិនេះក្នុងមុខវិជ្ជាឯកទេសគណិតវិទ្យា :

$\sin\theta = \dfrac{AC}{BC} \qquad \cos\theta = \dfrac{AB}{BC}$

| $\theta$ | $0°$ | $30°$ | $45°$ | $60°$ | $90°$ | $180°$ |
|---|---|---|---|---|---|---|
| $\sin\theta$ | 0 | 0.5 | 0.707 | 0.866 | 1 | 0 |
| $\cos\theta$ | 1 | 0.866 | 0.707 | 0.5 | 0 | –1 |



រូបទី 1.11

# 2. បំលាស់ទី ល្បឿន វ៉ិចទ័រល្បឿន

## 2.1 ចម្ងាយចរនិងបំលាស់ទី

ចម្ងាយចរជាប្រវែងសរុបនៃចលនារបស់អង្គធាតុដោយមិនគិតពីទិសដៅនៃចលនា ។ ចំណែក **បំលាស់ទីជាចម្ងាយដែលគេវាស់តាមខ្សែត្រង់និងតាមទិសដៅជាក់លាក់ ។**



រូបទី 1.12

ចំណុច $M$ មួយផ្លាស់ទីលើបន្ទាត់ $x'x$ ។ យើងដៅទិសដៅវិជ្ជមានតាមទិសដៅ**បំលាស់ទី** ។ យើងជ្រើសរើសចំណុច $O$ ជាគល់អាប់ស៊ីសនិងខណៈដើមពេល ។

ដើម្បីកំណត់ទីតាំងចល័ត $M$ មួយតាំងនៅ គេត្រូវរកទីតាំងនោះធៀបទៅនឹងចំណុចតម្រុយ ដែលហៅថា **គល់អាប់ស៊ីស** (ចំណុច $O$ ) ។

**បំលាស់ប្តូរទីតាំងចល័តពីទីតាំងមួយទៅទីតាំងមួយទៀតហៅថាបំលាស់ទី** $\Delta x$ ។

youtube.com/moeys khmou.moeys.gov.kh facebook.com/moeys.gov.kh

យើងបានបំលាស់ទី $\Delta x = x_2 - x_1$ ដែល $x_1$ ជាអាប់ស៊ីសនៃទីតាំងដើម និង $x_2$ ជាអាប់ស៊ីសនៃទីតាំងស្រេច ។ **បំលាស់ទី** ជាទំហំវ៉ិចទ័រ គិតពីតម្លៃ (ប្រវែងប៉ុន្មាន ?)និងទិសដៅ (ទៅទិសដៅខាងណា ?) ។

**លក្ខណៈទាំងពីរនៃបំលាស់ទី** :

- **បំលាស់ទី** គឺជាចម្ងាយរវាងទីតាំងដើមនិងទីតាំងស្រេច ។
- **បំលាស់ទី** មានទិសដៅពីទីតាំងដើមទៅទីតាំងស្រេច ។

ក្នុងប្រព័ន្ធ SI ខ្នាតនៃបំលាស់ទីគឺម៉ែត (m) គីឡូម៉ែត (km) សង់ទីម៉ែត(cm)......... ។ល ។

***ឧទាហរណ៍ទី1 :*** វត្ថុមួយផ្លាស់ទីលើអ័ក្ស $x'x$ ពីចំណុច $A(x_1 = -1.0\text{cm})$ ទៅចំណុច $Bx_2 = 4.0\text{cm}$ ។ បំលាស់ទីនៃវត្ថុគឺ $\Delta x = x_2 - x_1 = 4.0\text{cm} - (-1.0\text{cm}) = 5.0\text{cm}$ និងមានទិសដៅតាមទិសដៅ $x$ វិជ្ជមាន ។

***ឧទាហរណ៍ទី2 :*** រថយន្តមួយត្រូវបានបើកបរទៅទិសខាងកើតបានចម្ងាយ 10.0km ។ បន្ទាប់មករថយន្តនោះបរត្រឡប់ក្រោយបានចម្ងាយ 4.0km ។ គណនាចម្ងាយចរនិងបំលាស់ទី ។




***រូបទី** 1.13*

### ✍ ដំណោះស្រាយ

- ចម្ងាយចរ : $d = 10.0 + 4.0 = 14.0\text{km}$
- បំលាស់ទី : $\Delta x = 10.0 - 4.0 = 6.0\text{km}$ ។

## 2.2 ល្បឿន វ៉ិចទ័រល្បឿន

### ក. ល្បឿន

ល្បឿននៃអង្គធាតុមួយសំគាល់ភាពលឿនឬយឺតនៃចលនារបស់អង្គធាតុនោះហើយកំណត់ដោយផលធៀបរវាងចម្ងាយចរនិងរយៈពេល ។

រូបមន្ត : ល្បឿន $= \dfrac{\text{ចម្ងាយចរ}}{\text{រយៈពេល}}$ ឬ $\boxed{v = \dfrac{d}{t}}$

$d$ ជាចម្ងាយចរគិតជាម៉ែត (m) , $t$ ជារយៈពេលគិតជាវិនាទី (s) និង $v$ ល្បឿនគិតជាម៉ែតក្នុងមួយវិនាទី (m/s) ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

ភាគច្រើននៃអង្គធាតុមិនមានចលនាដោយល្បឿនថេរទេ ដូចជារថភ្លើងមួយចេញដំណើរពីស្ថានីយ ចលនារបស់វាកាន់តែលឿនទៅៗរហូតដល់ល្បឿនថេរ បន្ទាប់មកវាកាន់តែយឺតទៅៗរហូតដល់ឈប់នៅស្ថានីយ ។ ហេតុនេះហើយ គេត្រូវកំណត់ល្បឿនមធ្យមនៃចលនារបស់រថភ្លើងនោះ ។

រូបមន្ត : ល្បឿនមធ្យម $= \dfrac{\text{ចម្ងាយចរសរុប}}{\text{រយៈពេលសរុប}}$ ឬ $\boxed{\bar{v} = \dfrac{d}{t}}$

$d$ ជាចម្ងាយចរសរុបគិតជាម៉ែត (m) , $t$ ជារយៈពេលសរុបគិតជាវិនាទី (s) និង $\bar{v}$ ល្បឿនមធ្យមគិតជាម៉ែតក្នុងមួយវិនាទី (m/s) ។

***ឧទាហរណ៍ :*** កីឡាករម្នាក់រត់បានចម្ងាយ 120m ក្នុងរយៈពេល 10.0s ។ តើល្បឿនមធ្យមរបស់កីឡាករនោះប៉ុន្មាន ?

**ដំណោះស្រាយ**

- ល្បឿនមធ្យមរបស់កីឡាករ

តាមរូបមន្ត $\bar{v} = \dfrac{d}{t}$ ដោយ $d = 120\text{m}$ និង $t = 10.0\text{s}$

យើងបាន $\bar{v} = \dfrac{120\text{m}}{10.0\text{s}}$

ដូច្នេះ $\boxed{\bar{v} = 12.0\text{m/s}}$ ។

## ១. វ៉ិចទ័រល្បឿន

**វ៉ិចទ័រល្បឿនគឺជាបម្រែបម្រួលបំលាស់ទីក្នុងមួយខ្នាតពេល** ។ កាលណាអ្នកនិយាយពីវ៉ិចទ័រល្បឿននៃវត្ថុមួយអ្នកត្រូវគិតដល់ល្បឿននិងទិសដៅដែលបានឆ្លងកាត់ ។

$$\text{វ៉ិចទ័រល្បឿន} = \frac{\text{បំលាស់ទី(ចម្ងាយត្រង់)}}{\text{រយៈពេលចរ}}$$




*រូបទី 1.14 ក្រាបតាងបំលាស់ទីអនុគមន៍នឹងពេល t*

ឧបមានៅខណៈ $t_1$ ចល័តនៅត្រង់ចំណុចមួយដែលមានទីតាំង $x_1$ និងនៅខណៈ $t_2$ ចល័តនៅត្រង់ចំណុចមួយដែលមានទីតាំង $x_2$ ។

វ៉ិចទ័រល្បឿនមធ្យមគឺជាផលធៀបរវាងបំលាស់ទី $\Delta x$ ដែលចរបានក្នុងចន្លោះរយៈពេល $\Delta t$ និងរយៈពេល $\Delta t$ នោះ ។ គេសរសេរ : $v_{av} = \dfrac{\Delta x}{\Delta t} = \dfrac{x_2 - x_1}{t_2 - t_1}$

ដូច្នេះ $\text{វ៉ិចទ័រល្បឿនមធ្យម} = \dfrac{\text{បំលាស់ទីសរុប}}{\text{រយៈពេលចរ}}$ ។

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

លើក្រាបដែលតាងអនុគមន៍ $x(t)$ វ៉ិចទ័រល្បឿនមធ្យម $v_{av}$ ជាមេគុណប្រាប់ទិសនៃបន្ទាត់ដែលភ្ជាប់ចំណុចពីរនៅលើខ្សែកោង $x(t)$ : ចំណុចមួយត្រូវនឹងចំណុច $x_2$ នៅខណៈ $t_2$ ចំណុចមួយទៀតត្រូវនឹងចំណុច $x_1$ នៅខណៈ $t_1$ ។ ដូចបំលាស់ទីដែរ វ៉ិចទ័រល្បឿនមធ្យម $v_{av}$ មានទាំងទំហំនិងទាំងទិសដៅ ។ ទំហំរបស់វាគឺជាមេគុណប្រាប់ទិសនៃបន្ទាត់ ។ $v_{av}$ មានតម្លៃវិជ្ជមាន កាលណាបន្ទាត់ទ្រេតនោះឡើងពីឆ្វេងទៅស្តាំនិងផ្ទុយមកវិញ $v_{av}$ មានតម្លៃអវិជ្ជមានកាលណាបន្ទាត់ទ្រេតនោះចុះពីស្តាំទៅឆ្វេង ។ វ៉ិចទ័រល្បឿនមធ្យមត្រូវតែមានសញ្ញាដូចបំលាស់ទី $\Delta x$ ព្រោះ $\Delta t$ មានតម្លៃវិជ្ជមានជានិច្ច ។

***ឧទាហរណ៍ :*** ក្នុងឧទាហរណ៍ទី 2 (រូបទី *1.13*) ក្នុងចំនុច (2.1) ឧបមាថា រយៈពេលដែលរថយន្តបរគឺ $t = 0.4\text{h}$ ។ គណនាល្បឿនមធ្យមនិងវ៉ិចទ័រល្បឿនមធ្យម ។

✍ **ដំណោះស្រាយ**

- ល្បឿនមធ្យម

តាមរូបមន្ត $\bar{v} = \dfrac{d}{t}$ ដោយ $d = 14\text{km}$ និង $t = 0.4\text{h}$

យើងបាន $\bar{v} = \dfrac{14\text{km}}{0.4\text{h}}$

ដូច្នេះ $\bar{v} = 35\text{km/h}$

- វ៉ិចទ័រល្បឿនមធ្យម $v_{av} = \dfrac{\Delta x}{\Delta t} = \dfrac{6\text{km}}{0.4\text{h}} = 15\text{km/h}$ ។

## 3. វ៉ិចទ័រល្បឿនខណៈ

តាមក្រាបដែលតាងបំលាស់ទីជាអនុគមន៍នៃពេលរបស់ចលនានៃវត្ថុមួយដែលចាប់ផ្តើមពីចំណុចគម្រុយ $O$ វ៉ិចទ័រល្បឿនមធ្យមនៃវត្ថុក្រោយពីបានផ្លាស់ទីក្នុងរយៈ $t = 6.0\text{s}$ គឺវ៉ិចទ័រល្បឿនមធ្យម $v_{av} = \dfrac{\text{បំលាស់ទីសរុប}}{\text{រយៈពេលចរ}}$

យើងបាន $v_{av} = \dfrac{6.0}{6.0}$

ដូច្នេះ $v_{av} = 1\text{m/s}$ ។



***រូបទី*** *1.15*

វ៉ិចទ័រល្បឿនខណៈរបស់វត្ថុនៅខណៈ $t = 6.0\text{s}$ គឺជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រង់ចំណុច $t = 6.0\text{s}$ ។ ក្នុងករណីនេះ វ៉ិចទ័រល្បឿនខណៈរបស់វត្ថុនៅខណៈ $t = 6\text{s}$ គឺ $v = \dfrac{\Delta x}{\Delta t}$

ដោយ $\Delta x = 8.0\text{m} - 4.5\text{m} = 3.5\text{m}$ និង $\Delta t = 7.0\text{s} - 5.0\text{s} = 2.0\text{s}$

យើងបាន $v = \dfrac{3.5\text{m}}{2\text{s}}$

ដូច្នេះ $v = 1.7\text{m/s}$ មានទិសដៅចេញពីចំណុច $O$ (រូបទី *1.15*) ។

**សំគាល់ :** ភាពខុសគ្នារវាងរយៈពេល $\Delta t$ ក្នុងវ៉ិចទ័រល្បឿនមធ្យមនិងវ៉ិចទ័រល្បឿនខណៈ គឺនៅត្រង់ $\Delta t$ នៅក្នុងវ៉ិចទ័រល្បឿនមធ្យមធំជាង $\Delta t$ នៅក្នុងវ៉ិចទ័រល្បឿនខណៈ ។ ចំពោះវ៉ិចទ័រល្បឿនខណៈ $\Delta t$ ខិតទៅរកសូន្យ ហេតុនេះវាជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនៅត្រង់ចំណុចមួយលើខ្សែកោងនៅខណៈនោះ ។

ល្បឿនជាទំហំនៃវ៉ិចទ័រល្បឿន ។ ល្បឿនជាវ៉ិចទ័រល្បឿនកាលណាល្បឿននោះបានបញ្ជាក់ទិសដៅនិងសញ្ញាពីជគណិតរបស់វា ។ វ៉ិចទ័រល្បឿនមួយគឺ $+5\text{m/s}$ និងមួយទៀតគឺ $-5\text{m/s}$ វ៉ិចទ័រល្បឿនទាំងពីរមានល្បឿន $5\text{m/s}$ ប៉ុន្តែទិសដៅផ្ទុយគ្នា ។ ឧបករណ៍វាស់ល្បឿន(កុងទ័រល្បឿន)របស់រថយន្ត ទោចក្រយានយន្ត (ម៉ូតូ)ប្រើសម្រាប់វាស់ល្បឿន មិនមែនវាស់វ៉ិចទ័រល្បឿនទេ ព្រោះវាមិនបានកំណត់ទិសដៅរបស់ល្បឿនឡើយ ។

## 4. សំទុះ

កាលណាវ៉ិចទ័រល្បឿននៃអង្គធាតុមួយប្រែប្រួល គេថាអង្គធាតុនោះមានសំទុះ ។

### 4.1 សំទុះមធ្យម

ឧបមា នៅខណៈ $t_1$ ចល័តមានវ៉ិចទ័រល្បឿន $\vec{v}_1$ និងនៅខណៈ $t_2$ ចល័តមានវ៉ិចទ័រល្បឿន $\vec{v}_2$ ចំពោះចលនាលើអ័ក្សមួយសំទុះមធ្យមនៅចន្លោះពេល $\Delta t$ គឺ $\bar{a} = \dfrac{v_2 - v_1}{t_2 - t_1} = \dfrac{\Delta v}{\Delta t}$ ។

***ឧទាហរណ៍ទី1 :*** រថយន្តមួយចេញដំណើរពីចំណុច $O$ តម្រង់ទៅទិសខាងលិច(រូបទី *1.16*) ។ គណនាសំទុះមធ្យម ។



***រូបទី** 1.16*

✍ **ដំណោះស្រាយ**

- សំទុះមធ្យម $\bar{a} = \dfrac{\Delta v}{\Delta t}$

ដោយ $\Delta v = 20\text{m/s} - 0\text{m/s} = 20\text{m/s}$ និង $\Delta t = 10\text{s} - 0\text{s} = 10\text{s}$

ដូច្នេះ $\bar{a} = \dfrac{20\text{m/s}}{10\text{s}} = 2\text{m/s}^2$ ឆ្ពោះទៅទិសខាងលិច ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

**ឧទាហរណ៍ទី2 :** រថយន្តមួយបើកបរលើផ្លូវត្រង់ដោយល្បឿន $v = 30\text{m/s}$ ។ ក្រោយ 10s រថយន្តនោះឈប់(រូបទី *1.17* ) ។ គណនាសំទុះមធ្យម ។




**រូបទី** *1.17*

✍ **ដំណោះស្រាយ**

- សំទុះមធ្យម $\bar{a} = \dfrac{\Delta v}{\Delta t}$ តែ $\Delta v = 0\text{m/s} - 30\text{m/s} = -30\text{m/s}$ និង

  $\Delta t = 10\text{s} - 0\text{s} = 10\text{s}$ ដូច្នេះ $\bar{a} = \dfrac{-30\text{m/s}}{10\text{s}} = -3\text{m/}s^2$ ។

សញ្ញាអវិជ្ជមានបញ្ជាក់ថា សំទុះមធ្យមមានតម្លៃអវិជ្ជមាន មានន័យថាក្នុងរយៈពេល10s នេះ វ៉ិចទ័រល្បឿនថយចុះ ។ គេថាចលនារបស់រថយន្តជាចលនាយឺត ។

## 4.2 សំទុះខណៈ

ឧបមានៅខណៈពីរជិតគ្នា $t$ និង $t + \Delta t$ $\vec{v}$ ជាវ៉ិចទ័រល្បឿននៅខណៈ$t$ និង$\vec{v} + \Delta\vec{v}$ ជាវ៉ិចទ័រល្បឿននៅខណៈ $t + \Delta t$ ។

សំទុះមធ្យមសរសេរ : $\bar{a} = \dfrac{\Delta v}{\Delta t}$ បើ $\Delta t$ ខិតទៅរកសូន្យ $\Delta v$ ក៏ខិតទៅរកសូន្យដែរ ។ សំទុះមធ្យម $\dfrac{\Delta v}{\Delta t}$ ខិតទៅរកតម្លៃកម្រិតមួយដែលសំគាល់បម្រែបម្រួលល្បឿននៃចល័តនៅខណៈ $t$ ។ តម្លៃកម្រិតនេះហៅថា**សំទុះខណៈ** ។




**រូបទី** *1.18*

តាមក្រាបនៃ(រូបទី *1.18* ) យើងអាចកំណត់សំទុះខណៈ នៅខណៈ $t = 6\text{s}$ ។

សំទុះខណៈគឺ $a = \dfrac{\Delta v}{\Delta t}$

ដោយ $\Delta v = 7.3\text{m/s} - 5.0\text{m/s} = 2.3\text{m/s}$ និង $\Delta t = 6.5\text{s} - 5.5\text{s} = 1.0\text{s}$

យើងបាន $a = \dfrac{2.3\text{m/s}}{1\text{s}}$

ដូច្នេះ $a = 2.3\text{m/}s^2$ ទិសដៅចេញពីចំនុច $O$ ។

ដូច្នេះ **សំទុះខណៈគឺជាបម្រែបម្រួលវ៉ិចទ័រល្បឿននៅខណៈនោះ** ។ តាមក្រាបនេះ សំទុះនៅខណៈណាមួយគឺជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះខ្សែកោង $v(t)$ នៅខណៈនោះ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

**វ៉ិចទ័រសំទុះ $\vec{a}$ មាន** :

- គល់ត្រង់ទីនៃចំណុចចល័តនោះ
- ទិសដៅ តាមទិសដៅអវិជ្ជមាននៃគន្លងបើ $a<0$ តាមទិសដៅវិជ្ជមាននៃគន្លងបើ $a>0$ ។
- តម្លៃស្មើនឹងតម្លៃកម្រិតនៃ $\frac{\Delta v}{\Delta t}$ ។

ល្បឿនគិតជាម៉ែតក្នុងមួយវិនាទី (m/s) និងរយៈពេលគិតជាវិនាទី (s) ។ ដូច្នេះសំទុះគិតជាម៉ែតក្នុងមួយវិនាទីការេ $(m/s^2)$ ។

## 5. ចលនាអង្គធាតុតាមមួយវិមាត្រ

ចលនានៃចំណុចរូបធាតុមួយដែលមានសំទុះប្រែប្រួលជាអនុគមន៍នៃពេល វាជាចលនាដែលមានភាពសាំញ៉ាំនិងពិបាកវិភាគ ។ នៅក្នុងមេរៀននេះយើងសិក្សាពីចលនាណាដែលមានសំទុះថេរ ។ ចលនាលើអ័ក្សមួយដែលមានសំទុះថេរ ជា**ចលនាត្រង់ប្រែប្រួលស្មើ**។

ឧបមាថាវត្ថុមួយមានចលនានៅដើមពេល $t = 0$ ចល័តធ្វើចលនាដោយល្បឿនដើម $v_0$ ។ បន្ទាប់មកនៅខណៈ $t$ វត្ថុនោះផ្លាស់ទីដោយល្បឿន $v$ ។គេអាចសរសេរសំទុះមធ្យមជាផលធៀបរវាងបម្រែបម្រួលវ៉ិចទ័រល្បឿននិងរយៈពេលនៅចន្លោះបម្រែបម្រួលនៃវ៉ិចទ័រល្បឿននោះ ។ ប៉ុន្តែដោយសំទុះមិនប្រែប្រួល សំទុះមធ្យមនិងសំទុះខណៈមានតម្លៃដូចគ្នា ។

ដូច្នេះ គេបាន : $a = \bar{a} = \frac{\Delta v}{\Delta t} = \frac{v - v_0}{t - 0}$

$$\boxed{v = v_0 + at}$$ ។



***រូបទី*** *1.19*

តាមទំនាក់ទំនងខាងលើនេះ បង្ហាញឱ្យឃើញថា វ៉ិចទ័រល្បឿនខណៈសមាមាត្រនឹងរយៈពេល ។ ក្រាបនេះជាបន្ទាត់ដែលមានមេគុណប្រាប់ទិសជាសំទុះ $a$ ដែល $a = \frac{\Delta v}{\Delta t}$ មានតម្លៃថេរ ។ តម្លៃវិជ្ជមាននៃមេគុណប្រាប់ទិសនេះបញ្ជាក់ពីតម្លៃវិជ្ជមាននៃសំទុះ ។ ប្រសិនបើសំទុះមានតម្លៃអវិជ្ជមាន មានន័យថាមេគុណប្រាប់ទិសនៃបន្ទាត់ទ្រេតនោះចុះពីឆ្វេងទៅស្តាំ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

កាលណាសំទុះមានតម្លៃថេរ ក្រាប(សំទុះ-ពេល)ជាបន្ទាត់ដែលមានមេគុណប្រាប់ទិសមានតម្លៃស្មើនឹងសូន្យ ។ ដូច្នេះ $a = \frac{v - v_0}{t}$ = ថេរ ។

រ៉ិចទ័រល្បឿនដែលមានសំទុះថេរ ប្រែប្រួលជាអនុគមន៍លីនេអ៊ែនៃពេលនិងមានសមីការ $v = v_0 + at$ ។



រូបទី 1.20

គេអាចសរសេរ រ៉ិចទ័រល្បឿនមធ្យមនៅចន្លោះពេលមួយតាមមធ្យមនព្វន្តដែលមានរ៉ិចទ័រល្បឿនដើម $v_0$ និងរ៉ិចទ័រល្បឿនចុងក្រោយ $v$ គឺ : $v_{av} = \frac{v + v_0}{2}$ (1)



រូបទី 1.21

ឧបមានៅខណៈ $t = 0$ វត្ថុមួយស្ថិតនៅត្រង់ទីតាំង $x_0$ ។ បន្ទាប់មកនៅខណៈ $t$ វត្ថុនោះស្ថិតនៅត្រង់ទីតាំង $x$ ។ រ៉ិចទ័រល្បឿនមធ្យមនៅចន្លោះពេលពី 0 ទៅ $t$ គឺ

$$v_{av} = \frac{\Delta x}{\Delta t} = \frac{x - x_0}{t - 0} = \frac{x - x_0}{t} \quad (2)$$

និង $v = v_0 + at$ (3)

(1)(2) និង(3)គេបាន $\frac{v_0 + at}{2} + \frac{v_0}{2} = \frac{x - x_0}{t}$

ដូច្នេះ $\boxed{x = x_0 + v_0 t + \frac{1}{2}at^2}$ ឬ $\boxed{x - x_0 = v_0 t + \frac{1}{2}at^2}$ ។

ក្រាប(បំលាស់ទី -ពេល)នៃចលនាត្រង់មួយដែលមានសំទុះវិជ្ជមាននិងថេរមានសមីការ $x = x_0 + v_0 t + \frac{1}{2}at^2$ ខ្សែកោងនេះមានរាងជាប៉ារ៉ាបូល ។



រូបទី 1.22 ក្រាបតាង(បំលាស់ទី-ពេល)ចលនាត្រង់

មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនៃខ្សែកោងនៅខណៈ $t = 0$ ស្មើនឹងរ៉ិចទ័រល្បឿនដើម $v_0$ និងមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះនៃខ្សែកោងនៅខណៈ $t$ ស្មើនឹងរ៉ិចទ័រល្បឿននៅខណៈនោះ $v$ ។

តាមទំនាក់ទំនង $v = v_0 + at \Rightarrow t = \frac{v - v_0}{a}$

$$x - x_0 = v_0\frac{v - v_0}{a} + \frac{1}{2}a\left(\frac{v - v_0}{a}\right)^2 = 2a(x - x_0) = (v - v_0)v - (v_0 + 2v_0)$$

គេបាន $2a(x - x_0) = v^2 - v_0^2$ ។

នៅខណៈ $t = 0$ , $x_0 = 0$ សមីការខាងលើទៅជា $\boxed{2ax = v^2 - v_0^2}$ ។

facebook.com/moeys.gov.kh
youtube.com/moeys

***ឧទាហរណ៍ :*** រថយន្តមួយបើកបរដោយល្បឿនប្រែប្រួលជាអនុគមន៍នៃពេល តាងដោយក្រាបខាងស្តាំ ។ ចូរពណ៌នានិងគូសក្រាបតាង(សំទុះ-ពេល) នៃចលនារបស់រថយន្តនោះ ។



***រូបទី*** *1.23*

**ដំណោះស្រាយ**

ពណ៌នានិងគូសក្រាបតាង(សំទុះ-ពេល) នៃចលនារបស់រថយន្តនោះ



***រូបទី*** *1.24* ***ពណ៌នាចលនារបស់រថយន្ត***



***រូបទី*** *1.25* ***ក្រាបតាង(សំទុះ-ពេល)***

| ទីតាំង | រយៈពេល | ចលនា |
|---|---|---|
| ① | 0s ដល់ 10s | វ៉ិចទ័រល្បឿនកើនស្មើពី 0m/s ដល់ 15m/s<br>សំទុះថេរ $a = \frac{15-0}{10} = 1.5\text{m/s}^2$ ។ រថយន្តធ្វើចលនាស្ទុះស្មើ ។ |
| ② | 10s ដល់ 15s | វ៉ិចទ័រល្បឿនថេរ 15m/s សំទុះ = 0m/s ។ រថយន្តធ្វើចលនាត្រង់ស្មើ ។ |
| ③ | 15s ដល់ 20s | វ៉ិចទ័រល្បឿនថយចុះស្មើពី 15m/s មក 0m/s<br>សំទុះថេរ $a = \frac{0-15}{5} = -3\text{m/s}^2$ ។ រថយន្តមានចលនាយឺតស្មើ ។ |
| ④ | 20s ដល់ 25s | វ៉ិចទ័រល្បឿនមានតម្លៃសូន្យ ។ រថយន្តនៅស្ងៀម ។ |
| ⑤ | 25s ដល់ 30s | វ៉ិចទ័រល្បឿនកើនស្មើពី 0m/s ដល់ 10m/s<br>សំទុះមានតម្លៃថេរ $a = \frac{10-0}{5} = 2\text{m/s}^2$ ។រថយន្តធ្វើចលនាស្ទុះស្មើ ។ |

krou.moeys.gov.kh youtube.com/moeys facebook.com/moeys.gov.kh

# ពិសោធន៍ទន្លាក់សេរី

ក្នុងជីវភាពរស់នៅយើងសង្កេតឃើញវត្ថុទាំងអស់ធ្លាក់ចុះសំដៅមករកផែនដី ។ នៅក្នុងមេរៀននេះយើងធ្វើពិសោធន៍អំពីទន្លាក់សេរី ។ ទន្លាក់សេរីនៃវត្ថុមួយជាចលនាក្រោមអំពើតែមួយគត់នៃទម្ងន់ ។ វាជាចលនាស្ទុះស្មើដែលមានទិសដៅពីលើចុះក្រោមនិងមានសំទុះ $\vec{g}$ ថេរ ។

សមីការនៃចលនាទន្លាក់សេរីគឺ

- កម្ពស់ធ្លាក់ $s = v_0 t + \frac{1}{2}gt^2$
- ល្បឿន $v = v_0 + gt$
- សំទុះ $a = g = 9.80\text{m}/\text{s}^2$

**1. វត្ថុបំណង :** ដើម្បីគណនាសំទុះនៃទន្លាក់សេរី ។

**2. សំភារះ:** ឧបករណ៍វង្វាស់ពេលមួយ (Recording - timer) ត្រង់ស្វូមួយ ប្រភពចរន្តឆ្លាស់មួយដែលមានប្រេកង់ $f = 50\text{Hz}$ អង្គធាតុមួយដុំ ជើងទម្រមួយ ក្រដាសមួយសន្លឹក (A4) ស្កុត កន្ត្រៃនិងក្រដាសកាបូន $5\text{cm} \times 5\text{cm}$ មួយសន្លឹក ។

**3. ដំឡើងសំភារះនិងពិសោធន៍**

- កាត់ក្រដាសទទឹង 1cm ឱ្យបាន 5 ជម្រៀក រួចបិទស្កុតបន្តគ្នាឱ្យបានប្រវែងប្រហែល 1.4m ។
- ប្រើស្កុតបិទក្រដាសកាបូនលើឧបករណ៍វង្វាស់ពេល ។
- ស៊កក្រដាសដែលបានកាត់រួចនោះក្នុងឧបករណ៍វង្វាស់ពេល ។
- ភ្ជាប់ចុងក្រដាសផ្នែកខាងក្រោមទៅនឹងអង្គធាតុ ។
- យកឧបករណ៍វង្វាស់ពេលដែលបានរៀបចំហើយទៅភ្ជាប់នឹងផ្នែកខាងលើនៃជើងទម្រ ។
- មួលតម្រូវប៊ូតុងនៃត្រង់ស្វូត្រង់ 3V ។
- ភ្ជាប់ត្រង់ស្វូទៅនឹងប្រភព បន្ទាប់មកភ្ជាប់ឧបករណ៍វង្វាស់ពេលទៅនឹងត្រង់ស្វូ ។
- លើកផ្នែកខាងលើនៃក្រដាសឱ្យត្រង់ឡើងលើ ។
- លែងក្រដាសទន្ទឹមនឹងការបិទសៀគ្វី ។




*រូបទី 1.26 ពិសោធន៍ទន្លាក់សេរី*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 4. សង្កេត-លទ្ធផល

- សង្កេតនូវស្នាមចំណុចៗលើក្រដាសស រួចវង់លើចំណុចដែលត្រូវវាស់ចម្ងាយរៀង 5 ចំណុចម្ដងដូច(រូប *1.27*) ។
- រយៈពេលដៅពីចំណុចមួយទៅចំណុចមួយទៀតគឺ $\frac{1}{50}$s
- រយៈពេលសម្រាប់ 5 ចំណុចគឺ $\frac{1 \times 5}{50}\text{s} = \frac{1}{10}\text{s}$
- តាងចម្ងាយពីចំណុចនៃវង់ទី1 ទៅចំណុចនៃវង់ទី2 និងចំណុចនៃវង់បន្តបន្ទាប់គឺ $\Delta s_1$ , $\Delta s_2$ , $\Delta s_3$ ......... រៀងគ្នា ។
- វាស់ $\Delta s_1$ , $\Delta s_2$ , $\Delta s_3$ ......... ដោយប្រើម៉ែត ។
- ស្រង់តម្លៃដែលវាស់បាននិងគណនាដាក់ចូលក្នុងតារាងខាងក្រោម



***រូបទី 1.27***

| ចំណុច | $t$(s) | $s$(cm) | $\Delta t$(s) | $\Delta s$(cm) | $v$(cm/s) | $\Delta v$(cm/s) | $a$(cm/s$^2$) |
|---|---|---|---|---|---|---|---|
| ទី 0 | $t_0$ = | $S_0$ = | | | | | |
| ទី 5 | $t_1$ = | $S_1$ = | $\Delta t_1 = t_1 - t_0$ | $\Delta s_1 = s_1 - s_0$ | $v_1 = \frac{\Delta s_1}{\Delta t_1}$ | $\Delta v_1 = v_2 - v_1$ | $a_1 = \frac{\Delta v_1}{\Delta t_1}$ |
| ទី 10 | $t_2$ = | $S_2$ = | $\Delta t_2 = t_2 - t_1$ | $\Delta s_2 = s_2 - s_1$ | $v_2 = \frac{\Delta s_2}{\Delta t_2}$ | $\Delta v_2 = v_3 - v_2$ | $a_2 = \frac{\Delta v_2}{\Delta t_2}$ |
| ទី 15 | $t_3$ = | $S_3$ = | $\Delta t_3 = t_3 - t_2$ | $\Delta s_3 = s_3 - s_2$ | $v_3 = \frac{\Delta s_3}{\Delta t_3}$ | $\Delta v_3 = v_4 - v_3$ | $a_3 = \frac{\Delta v_3}{\Delta t_3}$ |
| ទី 20 | $t_4$ = | $S_4$ = | $\Delta t_4 = t_4 - t_3$ | $\Delta s_4 = s_4 - s_3$ | $v_4 = \frac{\Delta s_4}{\Delta t_4}$ | $\Delta v_4 = v_5 - v_4$ | $a_4 = \frac{\Delta v_4}{\Delta t_4}$ |
| ទី 25 | $t_5$ = | $S_4$ = | $\Delta t_5 = t_5 - t_4$ | $\Delta s_5 = s_5 - s_4$ | $v_5 = \frac{\Delta s_5}{\Delta t_5}$ | | |

- បន្ទាប់ពីបានទិន្នន័យហើយគូសក្រាបទាំងបីដូចខាងក្រោម



***រូបទី 1.28***

***ក្រាបតាង(បំលាស់ទី-ពេល)***



***រូបទី 1.29***

***ក្រាបតាង(វ៉ិចទ័រល្បឿន-ពេល)***



***រូបទី 1.30***

***ក្រាបតាង(សំទុះ-ពេល)***

- សំទុះនៃចលនាទន្លាក់សេរី $a = \frac{a_1 + a_2 + a_3}{3}$
- កម្រិតល្អៀង $= \left|\frac{g - a}{g}\right| \times 100 = \left|\frac{9.80 - a}{9.80}\right| \times 100 = ........ \%$

## 5. សន្និដ្ឋាន

តើសំទុះទន្លាក់នៃពិសោធន៍មានតម្លៃប៉ុន្មាន? តើវាមានកម្រិតល្អៀងមានប៉ុន្មានភាគរយ?

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

## មេរៀនសង្ខេប

- ទំហំវ៉ិចទ័រគឺជាទំហំដែលត្រូវគិតទាំងតម្លៃនិងទិសដៅ ។ គេតាងវ៉ិចទ័រដោយសញ្ញាព្រួញ ។
- ទំហំស្កាលែជាទំហំដែលគេគិតតែតម្លៃរបស់វាប៉ុណ្ណោះ ។
- វ៉ិចទ័រផ្គួបនៃវ៉ិចទ័រពីរគឺជាអង្កត់ទ្រូងនៃប្រលេឡូក្រាមដែលមានវ៉ិចទ័រទាំងពីរជាជ្រុង ។
- វ៉ិចទ័រ $\vec{A}$ មួយអាចបំបែកជាវ៉ិចទ័រកែងពីរ $\vec{A_x}$ និង $\vec{A_y}$ ដែល $A = \sqrt{A_x^2 + A_y^2}$ ។
- បំលាស់ទីគឺជាចម្ងាយពីទីតាំងដើមទៅទីតាំងស្រេច គេបាន $\Delta x = x - x_0$ ។ បំលាស់ទីជាទំហំវ៉ិចទ័រ ។
- វ៉ិចទ័រល្បឿនមធ្យមគឺជាផលធៀបរវាងបំលាស់ទីនិងរយៈពេលនៃបំលាស់ទីនោះ $v_{av} = \dfrac{\Delta x}{\Delta t}$ ។
- វ៉ិចទ័រល្បឿនខណៈ គឺជាតម្លៃកម្រិតនៃវ៉ិចទ័រល្បឿនមធ្យមឬមេគុណប្រាប់ទិសនៃបន្ទាត់នៅត្រង់ចំណុចពីរជិតគ្នាបំផុតនៃខ្សែកោងនៃក្រាប(ចម្ងាយ-ពេល) ។
- សំទុះមធ្យម $\bar{a} = \dfrac{\Delta v}{\Delta t}$ ។ សំទុះខណៈនៅខណៈណាមួយជាមេគុណប្រាប់ទិសនៃខ្សែកោង $v(t)$ នៅត្រង់ចំណុចនោះ ។
- ក្នុងចលនាតាមមួយវិមាត្រដែលមានសំទុះថេរ សមីការពេលសរសេរ : $x = x_0 + v_0 t + \frac{1}{2}at^2$ និង $v = v_0 + at$ ។
- ទន្លាក់សេរីជាចលនាតាមអ័ក្សតែមួយ(ជាចលនាស្ទុះស្មើដែលមានទិសដៅពីលើចុះក្រោម) ។

## សំណួរនិងលំហាត់

1. ចូររកឧទាហរណ៍ទំហំវ៉ិចទ័រនិងទំហំស្កាលែនីមួយៗឱ្យបានប្រាំ ។
2. ចូររកលក្ខណៈខុសគ្នារវាងទំហំវ៉ិចទ័រនិងទំហំស្កាលែ ។
3. តើបំលាស់ទីនិងចម្ងាយចរខុសគ្នាយ៉ាងដូចម្តេច ?
4. ចូរសរសេររូបមន្តល្បឿនមធ្យម ។
5. ចូរសរសេរសមីការដែលបញ្ជាក់ពីទំនាក់ទំនង $a, x, v_0$ និង $t$ ក្នុងចលនាតាមមួយវិមាត្រ ។
6. ដូចម្តេចដែលហៅថាទន្លាក់សេរី ?
7. ចូរសង់វ៉ិចទ័រផ្គួបនិងវាស់តម្លៃរបស់វា ដែល $a = 3\text{cm}$ $b = 4\text{cm}$ និង $(\vec{a} \perp \vec{b}) = 90°$ ។

8. មនុស្សម្នាក់រត់បានចម្ងាយ 120m ក្នុងរយៈពេល 12s ។ តើល្បឿនមធ្យមរបស់គាត់មានតម្លៃស្មើនឹងប៉ុន្មាន ?

9. រថយន្តមួយចេញដំណើរពីល្បឿនសូន្យតាមផ្លូវត្រង់មួយ ។ ក្រោយរយៈពេលពីរនាទីមករ៉ិចទ័រល្បឿនរថយន្តនោះគឺ 20m/s ។ រកសំទុះមធ្យមរបស់រថយន្តនោះ ។

10. ចលនាត្រង់មួយមានសមីការពេល $x = 10 + 20t - 5t^2$ ដោយ $x$ គិតជាម៉ែត (m) និង $t$ គិតជាវិនាទី (s) ។

ក. កំណត់ប្រភេទនៃចលនានិងគណនាសំទុះ ។

ខ. គណនាល្បឿនខណៈនៅខណៈ $t = 0$ និង $t = 2\text{s}$ ។

គ. តើចល័តឋិតនៅទីតាំងណា នៅខណៈដែលល្បឿនមានតម្លៃស្មើនឹងសូន្យ?

11. គេចោលបាល់មួយត្រង់ឡើងលើដោយល្បឿនដើម$20\text{m}/s$ ។ ពីរវិនាទីក្រោយមកគេចោលបាល់មួយទៀតត្រង់ឡើងលើដែរក្នុងលក្ខខណ្ឌដូចបាល់ទីមួយ ។ តើបាល់ទាំងពីរនោះនឹងជួបគ្នានៅខណៈណានិងនៅទីតាំងណា គេសន្មតថាចលនារបស់បាល់ជាចលនាទន្លាក់សេរីនិងយក $g \approx 9.80\text{m}/\text{s}^2$ ។

12. ឃ្លីមួយធ្លាក់ដោយសេរី ។ ល្បឿនរបស់វាជាអនុគមន៍នៃពេលបញ្ជាក់ដោយក្រាភិចខាងស្ដាំនេះ ។

ក. រកទំនាក់ទំនងរវាង $v$ និង $t$ ។ ចូរទាញរកទំនាក់ទំនងដែលមានចម្ងាយចរ $x$ និងពេល $t$ ។

ខ. បង្ហាញថានៅខណៈ $t_0$ ចម្ងាយចរ $x$ សមាមាត្រនឹងផ្ទៃក្រឡានៃត្រីកោណ $OAB$ ។



រូបទី1.31

គ. តាមក្រាបនិងតាមការគណនា ។ ចូរកំណត់ចម្ងាយចររវាងខណៈ $t = 2\text{s}$ និង $t = 5\text{s}$ ។

មេរៀនទី

# 2 ច្បាប់ចលនារបស់ញូតុន

**ចប់មេរៀននេះ សិស្សអាច**

❒ បង្ហាញពីច្បាប់ទី 1 ញូតុនឬច្បាប់និចលភាព ។

❒ បង្ហាញពីច្បាប់ទី 2 ញូតុន $F = ma$ ឬ $\vec{F} = m\vec{a}$ ។

❒ បង្ហាញពីច្បាប់ទី 3 ញូតុន(អំពើនិងប្រតិកម្ម) $F_1 = -F_2$ ឬ $\vec{F}_{12} = -\vec{F}_{21}$ ។

youtube.com/moeys

## 1. កម្លាំង

ពេលយើងសិក្សាអំពីកម្លាំង យើងនឹកដល់អ្នកវិទ្យាសាស្ត្រដ៏ល្បីម្នាក់ឈ្មោះ **អ៊ីសាក់ញូតុន** ។ គាត់កើតនៅប្រទេសអង់គ្លេសនៅឆ្នាំ **1642** ។ គាត់ជាអ្នកវិទ្យាសាស្ត្រ និងគណិតវិទូដែរ ។ គាត់បានបង្កើតគណិតវិទ្យាវិភាគ បានអភិវឌ្ឍន៍ច្បាប់នៃចលនា បានបង្កើតរូបមន្តនៃច្បាប់ទំនាញសកលនិងបានរកឃើញលក្ខណៈជាច្រើននៃពន្លឺ ។

krou.moeys.gov.kh

### 1.1 សញ្ញាណកម្លាំង




facebook.com/moeys

*រូបទី 1.32*

តាម(រូបទី *1.32* (ក) )តើអ្នកគិតថារទេះនឹងផ្លាស់ទីដែរឬទេ ? វាជាការពិតណាស់ បើក្មេងនោះមានកាយសម្បទារឹងមាំ រទេះនោះនឹងផ្លាស់ទី ផ្ទុយទៅវិញបើក្មេងនោះពុំមាំមួនទេ រទេះនោះគ្រាន់តែបម្រុងនឹងផ្លាស់ទីប៉ុណ្ណោះ ។ ឯ(រូបទី *1.32* (ខ) )បង្ហាញឱ្យឃើញថាកុមារនោះអាចបញ្ឈប់រទេះមិនឱ្យមានចលនា ។ (រូបទី *1.32* (គ) )បាល់មួយកំពុងរមៀលលើទីលាន អ្នកទាត់បាល់នឹងអាចប្រែប្រួលល្បឿននិងអាចប្តូរទិសដៅនៃចលនា ។ (រូបទី *1.32* (ឃ) )អ្នកសង្កត់រ៉ឺស័រ រ៉ឺស័រខូចទ្រង់ទ្រាយ ។

តាមឧទាហរណ៍ទាំងបួននេះបង្ហាញថា **កម្លាំងជាបុព្វហេតុ** :

- ធ្វើឱ្យអង្គធាតុមានចលនាឬបម្រុងមានចលនា
- បញ្ឈប់ឬផ្លាស់ប្តូរទិសដៅចលនានៃអង្គធាតុ
- ធ្វើឱ្យអង្គធាតុខូចទ្រង់ទ្រាយ ។

កម្លាំងជាទំហំវ៉ិចទ័រ ។ គេតាងកម្លាំងដោយ $\vec{F}$ ដែលមាននិមិត្តសញ្ញា $\xrightarrow{\vec{F}}$ ខ្នាតនៃកម្លាំងគឺញូតុន (N) ។ គេចែកកម្លាំងជាពីរយ៉ាង គឺកម្លាំងប៉ះនិងកម្លាំងពីចម្ងាយ ។

**ឧទាហរណ៍កម្លាំងផ្សេងៗ**

| **កម្លាំងប៉ះ** | **កម្លាំងពីចម្ងាយ** |
|---|---|
|   <br> ***កម្លាំងទាញរ៉ឺស័រ*** |   <br> ***កម្លាំងអង្គធាតុ*** M ***ទាញអង្គធាតុ*** *m* |
|   <br> ***កម្លាំងរុញរទេះ*** |   <br> ***កម្លាំងចម្រានចេញរវាងបន្ទុក*** $+Q$ ***ច្រានបន្ទុក*** $+q$ |
|   <br> ***កម្លាំងទាត់បាល់*** |   <br> ***កម្លាំងឆក់ទាញរវាងមេដែកនិងដែកគោល*** |

***រូបទី*** *1.33*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 1.2 ផលបូកកម្លាំង




***រូបទី 1.34***

## 2. ច្បាប់ទី 1 ញូតុន

### 2.1 ច្បាប់ទី 1 : ច្បាប់និចលភាព




មុននឹងពោលច្បាប់ទី 1 ញូតុន យើងពិនិត្យពិសោធន៍ងាយមួយ ។ សន្មតថាមានឃ្លីមួយស្ថិតនៅនឹងថ្កល់លើតុ ។ ជាការពិតណាស់ឃ្លីនឹងស្ថិតនៅស្ងៀមលើតុដដែល ។ ឥឡូវអ្នកគិតថា រុញឃ្លីតាមទិសដេកដោយកម្លាំងរុញធំជាងកម្លាំងកកិតរវាងឃ្លីនិងតុ(កម្លាំងរុញ កម្លាំងកកិតនិងកម្លាំងផ្សេងៗដែលមានអំពើលើឃ្លីជាកម្លាំងក្រៅ) ។អ្នកអាចរក្សាចលនាឃ្លីឱ្យមានវិចទ័រល្បឿនថេរដោយអនុវត្តន៍កម្លាំងដែលមានអាំងតង់ស៊ីតេ(ទំហំ)ស្មើនឹងកម្លាំងកកិតតែមានទិសដៅផ្ទុយគ្នា ។ បើសិនអ្នកបង្កើនកម្លាំងរុញកាន់តែខ្លាំងមានន័យថាកម្លាំងនោះមានទំហំធំជាងកម្លាំងកកិត នោះអ្នកនឹងឃើញឃ្លីមានចលនាស្ទុះ ។ បើអ្នកបញ្ឈប់ការរុញឃ្លីនោះ វានឹងឈប់បន្ទាប់ពីមានចលនាបានចម្ងាយយ៉ាងខ្លីពីព្រោះកម្លាំងកកិតបន្ថយចលនារបស់ឃ្លី ។ ឧបមាឥឡូវនេះអ្នករុញឃ្លីដដែលនោះឱ្យឆ្លងកាត់ផ្ទៃរលោងនៃតុ ពេលនោះអ្នកនឹងឃើញឃ្លីនឹងឈប់ម្តងទៀត ក្រោយពីអ្នកបញ្ឈប់ការរុញវា ប៉ុន្តែវាមិនឈប់ភ្លាមដូចករណីមុនទៀតឡើយ ។

ឥឡូវនេះ បើអ្នកបង្កើនផ្ទៃរលោងនៃតុឱ្យកាន់តែរលោងទៅៗ រហូតកម្លាំងកកិតមានតម្លៃតូចទៅៗដែលអាចចោលបាន នោះឃ្លីនឹងបន្តផ្លាស់ទីដោយល្បឿនថេរ បន្ទាប់ពីអ្នកលែងរុញវា ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

*ច្បាប់ទី 1 : បើអង្គធាតុមួយមិនរងអំពើនៃកម្លាំងផ្សេងៗទេ ឬវារងតែកម្លាំងផ្គួបស្មើនឹងសូន្យ បើវានៅនឹងថ្កល់វានៅនឹងដដែល តែបើវាមានចលនា ចលនានោះជាចលនាត្រង់ស្មើ ។*

បើគ្មានកម្លាំងណាមួយធ្វើឱ្យប្រែប្រួលចលនារបស់អង្គធាតុទេ នោះវ៉ិចទ័រល្បឿនរបស់វាមិនប្រែប្រួលឡើយ ។ តាមច្បាប់ទី 1 យើងសន្និដ្ឋានថា អង្គធាតុណាមួយគឺស្ថិតនៅស្ងៀមឬផ្លាស់ទីដោយវ៉ិចទ័រល្បឿនថេរ(ចលនាត្រង់ស្មើ) លក្ខណៈនៃអង្គធាតុដែលប្រឆាំងនឹងបម្រែបម្រួលវ៉ិចទ័រល្បឿនរបស់វាត្រូវបានគេហៅថា **និចលភាពនៃអង្គធាតុ** ។

## 2.2 ម៉ាស



**រូបទី** 1.36

យើងរុញតុនិងកៅអីដោយប្រើកម្លាំងដូចគ្នា យើងសង្កេតឃើញកៅអីងាយផ្លាស់ទីជាងតុ ព្រោះតុមាននិចលភាពធំជាងកៅអី ។ គេថាតុមានម៉ាសធំជាងកៅអី(រូបទី 1.36 ) ។



**រូបទី** 1.37

ដូច្នេះ**ម៉ាសជាទំហំដែលកំណត់និចលភាពនៃវត្ថុ** ។ ក្នុងប្រព័ន្ធ SI ម៉ាសគិតជាគីឡូក្រាម(kg) ។ ឧបករណ៍សម្រាប់ថ្លឹងម៉ាស គឺជញ្ជីងប្រើកូនបួតឬជញ្ជីងអេឡិចត្រូនិច(រូបទី 1.37 ) ។ ចំពោះកម្លាំងតែមួយដដែលមានអំពើលើវត្ថុពីរ វត្ថុដែលមានម៉ាសធំជាង វត្ថុនោះមានចលនាដោយសំទុះតូចជាង ។ ដូចនេះ ម៉ាសរបស់អង្គធាតុច្រាសសមាមាត្រនឹងសំទុះរបស់វា(រូបទី 1.38 ) ។

បើអង្គធាតុទី 1 នោះមានម៉ាស $m_1$ និងសំទុះ $a_1$ ហើយអង្គធាតុទី 2 មានម៉ាស $m_2$ និងសំទុះ $a_2$ គេបាន $\frac{m_1}{m_2} = \frac{a_2}{a_1}$ ។

***ឧទាហរណ៍ :*** បើគេផ្តល់កម្លាំងទៅលើអង្គធាតុមួយដែលមានម៉ាស 10kg អង្គធាតុនោះមានសំទុះ $2m/s^2$ តែបើគេផ្តល់កម្លាំងដដែលទៅលើអង្គធាតុមួយទៀតដែលមានម៉ាស 5g អង្គធាតុនោះមានសំទុះ $4m/s^2$ ។ ម៉ាសជាទំហំស្កាលែ ដូច្នេះដើម្បីធ្វើផលបូកម៉ាសរបស់អង្គធាតុត្រូវគោរពច្បាប់នព្វន្ត ។

***ឧទាហរណ៍ :*** ស្ករសមួយកញ្ចប់មានម៉ាស 3kg និងស្ករសមួយកញ្ចប់ទៀតមានម៉ាស 2kg ស្ករសទាំងពីរកញ្ចប់មានម៉ាសសរុប 3kg + 2kg = 5kg ។

ម៉ាសនៃអង្គធាតុមួយមិនមែនជាទម្ងន់នៃអង្គធាតុនោះទេ ។ ម៉ាសនិងទម្ងន់ជាទំហំពីរខុសគ្នា ម៉ាសនៃអង្គធាតុមួយមានតម្លៃថេរ ទោះបីគេយកអង្គធាតុនោះទៅទីណាក៏ដោយ ។ ឯទម្ងន់នៃអង្គធាតុនោះប្រែប្រួលទៅតាមទីកន្លែងដែលវាស្ថិតនៅ ។ អ្នកនឹងសិក្សាអំពីទម្ងន់ក្នុងមេរៀននេះដែរ ។

***ឧទាហរណ៍ :*** ដុំដែកមួយមានម៉ាស 5kg និងមានទម្ងន់ 49N នៅលើផ្ទៃផែនដី ឯនៅលើផ្ទៃព្រះចន្ទវាមានម៉ាស 5kg ដដែល ឯទម្ងន់វាមានតែ 8N ប៉ុណ្ណោះ ។

# 3. ច្បាប់ទី 2 ញូតុន

ច្បាប់ទី 1 ញូតុនបានពន្យល់ថា បើអង្គធាតុមួយមិនរងនូវកម្លាំងណាមួយឬរងនូវកម្លាំងផ្តួបមានអំពើលើវាស្មើសូន្យ បើវានៅនឹងថ្កល់ វានៅនឹងថ្កល់ដដែល បើវាធ្វើចលនា ចលនានោះជាចលនាត្រង់ស្មើដោយល្បឿនថេរ ។ ឯច្បាប់ទី 2 ញូតុននឹងពន្យល់ពីហេតុការណ៍ដែលកើតមានឡើង កាលណាអង្គធាតុមួយរងនូវកម្លាំងផ្តួបដែលមានអំពើលើវាមិនស្មើសូន្យ ។

ឧបមាអ្នកទាញអង្គធាតុមួយមានម៉ាស $m$ ដោយកម្លាំង $\vec{F}_1$ អង្គធាតុនោះមានសំទុះ $\vec{a}_1$ បន្ទាប់មកអ្នកទាញអង្គធាតុនោះដោយកម្លាំង $\vec{F}_2 = 2\vec{F}_1$ អង្គធាតុនោះមានសំទុះ $\vec{a}_2 = 2\vec{a}_1$ និងបន្ទាប់មកទៀត បើអ្នកទាញអង្គធាតុដដែលនោះដោយកម្លាំង $\vec{F}_3 = 3\vec{F}_1$ អង្គធាតុនោះមានសំទុះ $\vec{a}_3 = 3\vec{a}_1$ ។




*រូបទី 1.38*

បើយើងធ្វើផលធៀប $\frac{F_1}{a_1}$ $\frac{F_2}{a_2}$ $\frac{F_3}{a_3}$

យើងបាន $\frac{F_1}{a_1} = \frac{F_2}{a_2} = \frac{F_3}{a_3}$ = ថេរ

តាមការសង្កេតនេះយើងសន្និដ្ឋានដូចតទៅ :សំទុះនៃវត្ថុមួយសមាមាត្រទៅនឹងកម្លាំងផ្តួបដែលមានអំពើលើវា ។ តាមការសន្និដ្ឋាននេះ និងតាមចំណុច (2-2) គេបានច្បាប់ទី 2 ញូតុន ។

> ***ច្បាប់ទី 2*** *: សំទុះនៃអង្គធាតុមួយសមាមាត្រទៅនឹងកម្លាំងផ្តួបដែលមានអំពើលើវា ហើយច្រាសសមាមាត្រនឹងម៉ាសរបស់វា ។*

តាមច្បាប់ទី 2 ញូតុន យើងអាចសរសេរទំនាក់ទំនងរវាងម៉ាស កម្លាំង និងសំទុះ :

$\vec{F} = m\vec{a}$ ឬ $F = ma$ ( $\vec{F}$ និង $\vec{a}$ មានទិសដៅដូចគ្នា )

សមីការខាងលើនេះជាកន្សោមវិចទ័រ ហើយកន្សោមនេះសមមូលទៅនឹងសមីការដែលបានមកពីធ្វើចំណោលកែងលើអ័ក្សកូអរដោនេ : $\vec{F}_x = m\vec{a}_x$ , $\vec{F}_y = m\vec{a}_y$ ។

ក្នុងប្រព័ន្ធ SI ខ្នាតកម្លាំងគិតជាញូតុន (N) ។ **មួយញូតុន(1N) ជាកម្លាំងមានអំពើលើអង្គធាតុដែលមានម៉ាស** 1kg **បង្កើតសំទុះ** $1m/s^2$ ។ ដូច្នេះ $1N = 1kg \cdot m/s^2$ គេបានសំទុះ $a = \frac{1kg \cdot m/s^2}{1kg} = 1m/s^2$ ។

ឧបករណ៍សម្រាប់វាស់កម្លាំងគឺជញ្ជីងរ៉ឺសរ ឬឌីណាម៉ូម៉ែត(រូបទី *1.39*) ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

***ឧទាហរណ៍ទី 1 :*** ក្មេងប្រុសម្នាក់រុញប្រអប់មួយដែលមានម៉ាស 10kg ដោយកម្លាំង 20N ។ តើសំទុះនៃប្រអប់ស្មើនឹងប៉ុន្មាន ? កកិតអាចចោលបាន ។

**✍ ដំណោះស្រាយ**

- សំទុះ $a$ នៃប្រអប់

  តាមច្បាប់ទី2 ញូតុន : $F = ma \quad \Rightarrow \quad a = \frac{F}{m}$

  ដោយ $m = 10\text{kg}$ និង $F = 20\text{N}$

  យើងបាន $a = \frac{20\text{N}}{10\text{kg}} = 2.0\text{m/s}^2$

  ដូច្នេះ $\boxed{a = 2.0\text{m/s}^2}$ ។

***ឧទាហរណ៍ទី 2 :*** រថយន្តមួយមានម៉ាស $1.0 \times 10^3\text{kg}$ មានចលនាស្ទុះស្មើដោយចាប់ផ្តើមពីល្បឿនសូន្យទៅល្បឿន 20m/s ក្នុងរយៈ $10s$ ។ គណនាកម្លាំងម៉ាស៊ីនដែលរថយន្តបញ្ចេញដើម្បីឱ្យវាទៅមុខ ។ កម្លាំងកកិតអាចចោលបាន ។

**✍ ដំណោះស្រាយ**

- សំទុះនៃរថយន្ត

  ដោយរថយន្តមានចលនាស្ទុះស្មើ យើងគណនាសំទុះតាមទំនាក់ទំនង

  $a = \frac{v - v_0}{t}$

  ដោយ $v = 20\text{m/s}$ , $v_0 = 0$ និង $t = 10\text{s}$

  $a = \frac{20\text{m/s} - 0\text{m/s}}{10\text{s}} = 2.0\text{m/s}^2$

  ដូច្នេះ $\boxed{a = 2.0\text{m/s}^2}$ ។

- កម្លាំងដែលម៉ាស៊ីនរថយន្តបញ្ចេញ

  តាមច្បាប់ទី2 ញូតុន : $F = ma$

  ដោយ $m = 1.0 \times 10^3\text{kg}$ និង $a = 2.0\text{m/s}^2$

  យើងបាន $F = 1.0 \times 10^3\text{kg} \times 2.0\text{m/s}^2$

  ដូច្នេះ $\boxed{F = 2.0 \times 10^3\text{N}}$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 4. កម្លាំងទំនាញផែនដីឬទម្ងន់

យើងដឹងយ៉ាងច្បាស់ថា គ្រប់វត្ថុទាំងអស់ត្រូវបានទាញដោយផែនដី ។កម្លាំងផែនដីទាញវត្ថុដែលមានទិសដៅតម្រង់មករកផ្ចិតផែនដីហៅថា **កម្លាំងទំនាញផែនដីឬទម្ងន់វត្ថុ** $\vec{W}$ ។

យើងបានឃើញនៅមេរៀនមុន អំពីពិសោធន៍ទន្លាក់សេរីនៃវត្ថុដែលមានសំទុះ $\vec{g}$ ហើយសំទុះនោះមានទិសដៅតម្រង់មកផ្ចិតផែនដី ។ អនុវត្តច្បាប់ទី 2 ញូតុន $\vec{F} = m\vec{a}$ ចំពោះទន្លាក់សេរីនៃវត្ថុដែលមានម៉ាស $m$ និងមានសំទុះ $\vec{a} = \vec{g}$ និង $\vec{F} = \vec{W}$ គេបាន $\vec{W} = m\vec{g}$ ។

ទំហំនៃទម្ងន់វត្ថុមួយតាងដោយ $W = mg$ $g$ ហៅថាសំទុះទំនាញផែនដី ។ សំទុះនេះថយចុះកាលណាវត្ថុកាន់តែឆ្ងាយពីផ្ចិតផែនដី ។ ដោយសារសំទុះទំនាញផែនដី $g$ អាស្រ័យនឹងទីកន្លែង ដូច្នេះទម្ងន់ប្រែប្រួលតាមទីតាំងភូមិសាស្ត្រដែរ ។ នៅត្រង់រយៈកម្ពស់ទឹកសមុទ្រ អង្គធាតុមួយមានទម្ងន់ធំជាងនៅរយៈកម្ពស់កន្លែងផ្សេងៗទៀត ។

*ឧទាហរណ៍ :* វត្ថុមួយមានម៉ាស 70.0kg ។ ទម្ងន់របស់វានៅកន្លែងដែលសំទុះទំនាញផែនដី $g = 9.80\text{m/s}^2$ គឺ $W = mg = 686\text{N}$ ។ នៅលើកំពូលភ្នំដែល $g = 9.77\text{m/s}^2$ ទម្ងន់របស់វាមានតែ 684N តែប៉ុណ្ណោះ ។

### ភាពខុសគ្នារវាងម៉ាសនិងទម្ងន់

<table>
<tr><th>ទម្ងន់</th><th>ម៉ាស</th></tr>
<tr><td>


***រូបទី 1.39 ឌីណាម៉ូម៉ែត***

- ជាកម្លាំងទំនាញផែនដី ។
- មានទាំងទំហំនិងទិសដៅ ។
- មានខ្នាតជាញូតុន (N) ។
- ប្រែប្រួលទៅតាមទីកន្លែង ។
- វាស់ដោយឌីណាម៉ូម៉ែត ។
</td><td>


***រូបទី 1.40 ជញ្ជីងរ៉ូប៊ែវ៉ាល់***

- ជាបរិមាណរូបធាតុដែលមាននៅក្នុងអង្គធាតុ ។
- មានតែទំហំគ្មានទិសដៅ ។
- មានខ្នាតជាគីឡូក្រាម (kg) ។
- មានទំហំថេរគ្រប់ទីកន្លែង ។
- ថ្លឹងដោយជញ្ជីងប្រើកូនរ៉ូប៊ែវ៉ាល់ឬជញ្ជីងអេឡិចត្រូនិច ។
</td></tr>
</table>

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 5. ច្បាប់ទី 3 ញូតុន

បើអ្នកសង្កត់ជ្រុងសៀវភៅដោយមេដៃ សៀវភៅនោះច្រានវិញដោយបន្សល់នូវស្នាមទ្រុតៗលើមេដៃអ្នក ។ បើអ្នកសង្កត់យ៉ាងខ្លាំង សៀវភៅនោះច្រានវិញក៏ខ្លាំងដែរ ហើយស្នាមទ្រុតលើមេដៃក៏ធំជាងមុន ។ នេះជាពិសោធន៍យ៉ាងងាយដែលបង្ហាញអំពីច្បាប់ទី 3 ញូតុន ។

គេមានសំភារៈដូចតទៅ : ឌីណាម៉ូម៉ែតពីរ កូនរទេះពីរ ដែកមួយដុំ មេដែកមួយ ។ យើងភ្ជាប់ចុងម្ខាងនៃឌីណាម៉ូម៉ែតទៅនឹងបង្គោលហើយចុងម្ខាងទៀតភ្ជាប់នឹងកូនរទេះដែលផ្ទុកដុំដែក ។ ចំណែកឯឌីណាម៉ូម៉ែតមួយផ្សេងទៀតភ្ជាប់នឹងចុងម្ខាងទៅនឹងបង្គោល ហើយចុងម្ខាងទៀតភ្ជាប់នឹងកូនរទេះដែលផ្ទុកមេដែក ។ យើងសង្កេតឃើញកូនរទេះទាំងពីរទាញគ្នាទៅវិញទៅមកធ្វើឱ្យរ៉ឺសរនៃឌីណាម៉ូម៉ែតលូតវែង ។ យើងអានគំនូសក្រិតនៃឌីណាម៉ូម៉ែតទាំងពីរ យើងឃើញឌីណាម៉ូម៉ែតចង្អុលតម្លៃលេខស្មើគ្នា ។




***រូបទី 1.41 អំពើទៅវិញទៅមករវាងមេដែកនិងដុំដែក***

> ***ច្បាប់ទី 3*** *: បើវត្ថុពីរមានអំពើទៅវិញទៅមក(អំពើនិងប្រតិកម្ម)ដោយកម្លាំង $\vec{F}_{12}$ ដែលបញ្ចេញដោយវត្ថុទី1 ទៅលើវត្ថុទី2 មានទំហំស្មើគ្នា និងមានទិសដៅផ្ទុយពីកម្លាំង $\vec{F}_{21}$ ដែលបញ្ចេញដោយវត្ថុទី2 មកលើវត្ថុទី1 ។ គេសរសេរ : $\vec{F}_{12} = -\vec{F}_{21}$ ។*

ច្បាប់ទី 3 ញូតុនបានបង្ហាញលក្ខណៈសំគាល់ទាំង 4 នៃកម្លាំង :

- ទី 1 : ជានិច្ចកាលកម្លាំងកើតមានឡើងជាគូ ។ គូកម្លាំងនោះហៅថា **អំពើ** និង**ប្រតិកម្ម** ។
- ទី 2 : អំពើនិងប្រតិកម្មមាន**ទំហំស្មើគ្នា** ។
- ទី 3 : អំពើនិងប្រតិកម្មមានទិសដៅផ្ទុយគ្នា (កម្លាំងទាំងពីរមានទិសដៅផ្ទុយគ្នា) ។
- ទី 4 : អំពើនិងប្រតិកម្មមានអំពើលើអង្គធាតុផ្សេងគ្នា ។

***ឧទាហរណ៍ :*** កម្លាំងដែលមានអំពើលើអង្គធាតុក្នុងចលនាទន្លាក់សេរីគឺ $\vec{W} = m\vec{g}$ ដែលជាកម្លាំងទំនាញរបស់ផែនដីទៅលើអង្គធាតុនោះ ។ កម្លាំងប្រតិកម្មគឺជាកម្លាំងដែលអង្គធាតុមានអំពើលើផែនដី $\vec{W}' = -\vec{W}$ ។ កម្លាំងប្រតិកម្ម $\vec{W}'$ នេះទាញផែនដីឆ្ពោះទៅជិតអង្គធាតុដូចគ្នានិងកម្លាំងមានអំពើ $\vec{W}$ ទាញអង្គធាតុតម្រង់មករកផែនដីដែរ ។ យើងមាន $W = mg$ ( $m$ ជាម៉ាសអង្គធាតុ $g$ ជាសំទុះ ទំនាញផែនដី) និង $W' = Ma$ ( $M$ ជាម៉ាសផែនដី $a$ ជាសំទុះរបស់ផែនដី) ។

តាមច្បាប់ទី 3 ញូតុន យើងបាន $W = W' \Leftrightarrow mg = Ma$

យើងទាញបាន $a = \frac{m}{M}g$ ដោយ $(M \gg m)$

យើងបាន $\frac{m}{M} \approx 0 \Rightarrow a \approx 0$ ។ ហេតុនេះ សំទុះរបស់ផែនដីមានតម្លៃតូចអាចចោលបាន ។

## 6. អនុវត្តន៍ច្បាប់ញូតុន

ដើម្បីដោះស្រាយលំហាត់ដែលទាក់ទងនឹងច្បាប់ញូតុនអ្នកត្រូវចងចាំដូចតទៅ :

- កំណត់ប្រព័ន្ធដែលមានចលនា ដោយបញ្ជាក់ម៉ាសរបស់វត្ថុនីមួយៗ ។
- គូសដ្យាក្រាមតាងកម្លាំងទាំងអស់ដែលមានអំពើលើវត្ថុនោះ ។ ចំពោះប្រព័ន្ធដែលមានវត្ថុជាច្រើន គូសដ្យាក្រាមតាងកម្លាំងទាំងឡាយដែលមានអំពើលើវត្ថុនីមួយៗ ។
- សង់អ័ក្សកូអរដោនេសម្រាប់វត្ថុនីមួយៗ រួចធ្វើចំណោលកែងកម្លាំងលើអ័ក្សទាំងនោះ ។ ធ្វើតុល្យភាពកម្លាំងក្រៅទាំងអស់ដែលមានអំពើលើប្រព័ន្ធ ។
- អនុវត្តច្បាប់ទី 2 របស់ញូតុន $F = ma$ ក្នុងសមាសភាពកម្លាំងទាំងអស់ ។
- ទាញចេញពីច្បាប់ញូតុន ដោះស្រាយសមីការកូអរដោនេជាអក្សរដែលមានបម្រាប់និងអញ្ញាត ។ អ្នកអាចរំលឹក និងសរសេរសមីការផ្សេងៗដែលមានទំនាក់ទំនងនឹងអញ្ញាត រួចអ្នកធ្វើដំណោះស្រាយសមីការទាំងនោះ រហូតដល់អ្នកបានសមីការមួយដែលអង្គម្ខាងមានតែអញ្ញាតនិងអង្គម្ខាងទៀតមានសុទ្ធតែបម្រាប់ ។ ផ្ទៀងផ្ទាត់ទំហំនិងខ្នាតរបស់អង្គខាងឆ្វេងនិងខាងស្តាំនៃសមីការស្មើគ្នា ។
- អនុវត្តជាលេខដោយប្រើខ្នាតក្នុងប្រព័ន្ធអន្តរជាតិ និងសរសេរលទ្ធផលជាលេខមានន័យ ។

***ឧទាហរណ៍ទី 1 :*** ធុងមួយមានម៉ាស $m$ ដាក់លើផ្ទៃរលោង(កកិតអាចចោលបាន)នៃប្លង់ទេរ មួយដែលបង្កើតបានមុំ $\theta$ ជាមួយប្លង់ដេកដូច(រូបទី *1.42*) ។ ចូរសិក្សាចលនាធុងក្រោយពីវាត្រូវបានគេលែង ។



***រូបទី** 1.42*

**ដំណោះស្រាយ**

ដោយយើងដឹងកម្លាំងមានអំពើលើធុង យើងអាចអនុវត្តច្បាប់ទី 2 ញូតុនដើម្បីកំណត់សំទុះវា ។ យើងគូសគំនូសតាងកម្លាំង(រូបទី *1.43*) ។



***រូបទី** 1.43*

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

**កម្លាំងដែលមានអំពើលើថុងគី**

- កម្លាំងកែង $\vec{N}$ ដែលបញ្ចេញដោយប្លង់ទេរទៅលើថុង និងមានទិសកែងនឹងប្លង់ទេរ ។
- កម្លាំងទំនាញផែនដីទៅលើថុង $m\vec{g}$ ដែលមានទិសឈរ និងទិសដៅពីលើចុះមកក្រោម ។
- ចំពោះលំហាត់អំពីប្លង់ទេរ ត្រូវជ្រើសរើសអ័ក្សកូអរដោនេ គឺអ័ក្ស $\overrightarrow{OX}$ តាមបណ្តោយប្លង់ទេរ និងអ័ក្ស $\overrightarrow{OY}$ កែងនឹងប្លង់ទេរ(រូបទី *2.12*) ។ បន្ទាប់មកយើងបំបែកកម្លាំងទំនាញផែនដីជា $m\vec{g}\sin\theta$ តាមទិសដៅវិជ្ជមាននៃអ័ក្ស $\overrightarrow{OX}$ និង $m\vec{g}\cos\theta$ តាមទិសដៅអវិជ្ជមានអ័ក្ស $\overrightarrow{OY}$ ។
- អនុវត្តច្បាប់ទី 2 ញូតុន ក្នុងកូអរដោនេ

$$F_x = mg\sin\theta = ma_x \qquad (1)$$

$$F_y = N - mg\cos\theta = ma_y = 0 \text{ ព្រោះ}(a_y = 0) \qquad (2)$$

តាមទំនាក់ទំនង (1) យើងឃើញសំទុះតាមបណ្តោយប្លង់ទេរបានមកពីកម្លាំងផ្តុំតាមអ័ក្ស $\overrightarrow{OX}$ នៃកម្លាំងទំនាញផែនដី : $a_x = g\sin\theta$ (3)

**សំគាល់** :សំទុះផ្តុំនេះមិនអាស្រ័យនឹងម៉ាសនៃអង្គធាតុទេ វាអាស្រ័យតែនឹងមុំនៃប្លង់ទេរនិង $g$ តែប៉ុណ្ណោះ ។

តាមទំនាក់ទំនង (2) គឺ $F_y = mg\cos\theta$ បានមកពីការធ្វើចំណោលកែងកម្លាំងទំនាញផែនដីលើអ័ក្សលើ $\overrightarrow{OY}$ និងកម្លាំង N ដែលបញ្ចេញដោយប្លង់ទេរទៅលើថុង $N = mg\cos\theta$ ។ ដោយ $g$ និង $\theta$ ថេរ យើងបាន $a_x = g\sin\theta$ ថេរ មានន័យថាចលនារបស់ថុងជាចលនាស្មុះស្មើ ។

យើងអាចសរសេរសមីការចលនាតាមអ័ក្ស $\overrightarrow{OX}$ :$\Delta x = x_f - x_i = v_{0x}t + \frac{1}{2}a_x t^2$

បើ $\Delta x = d$ និង $v_{0x} = 0$

យើងបាន $d = \frac{1}{2}a_x t^2 \Rightarrow t = \sqrt{\frac{2d}{g\sin\theta}}$ (4)

ដោយប្រើសមីការ $v^2_{xf} - v^2_{xi} = 2a(x_f - x_i)$ និង $v_{xi} = 0$

យើងបាន $v^2_{xf} = 2a_x d \Leftrightarrow v_{xf} = \sqrt{2a_x d} = \sqrt{2gd\sin\theta}$ (5)

ពីសមីការ (4) និង (5) យើងឃើញថារយៈពេល $t$ ដែលចាំបាច់ឱ្យចល័តផ្លាស់ទីដល់ក្រោមដោយល្បឿនស្រេច $v_{xf}$ និងសំទុះ $a_x$ មិនអាស្រ័យនឹងម៉ាសថុងទេ ។ នេះជាវិធីយ៉ាងងាយក្នុងការវាស់ $g$ នៃចលនាតាមប្លង់ទេរ ដោយវាស់មុំ $\theta$ នៃប្លង់ទេរ ចម្ងាយចរ $d$ តាមបណ្តោយប្លង់ទេរ និងរយៈពេលនៃបំលាស់ទីនេះ ។ តាមទំនាក់ទំនង (4) យើងអាចគណនាតម្លៃ $g$ ។

***ឧទាហរណ៍ទី2 :*** កាលណាវត្ថុពីរមានម៉ាសមិនស្មើគ្នា ចងភ្ជាប់គ្នាតាមរយៈខ្សែដែលឆ្លងកាត់រ៉ក ។ កកិតរវាងរ៉ក និងខ្សែអាចចោលបាន ។ ម៉ាសខ្សែនិងម៉ាសរ៉កអាចចោលបាន ។ ប្រព័ន្ធដែលបានរៀបរាប់នេះហៅថា **ម៉ាស៊ីនអាត់វូត ។** កំណត់សំទុះវត្ថុទាំងពីរនិងតំណឹងខ្សែ ។



***រូបទី** 1.44 **ម៉ាស៊ីនអាត់វូត***

✍ **ដំណោះស្រាយ**

បើយើងកំណត់ប្រព័ន្ធដែលមានវត្ថុទាំងពីរ យើងគួរកំណត់កម្លាំងក្នុងនៃប្រព័ន្ធ (តំណឹងខ្សែ) ។ យើងត្រូវកំណត់ឱ្យបានច្បាស់នូវប្រព័ន្ធពីរ ប្រព័ន្ធនីមួយៗសម្រាប់វត្ថុមួយ និងអនុវត្តច្បាប់ទី2ញូតុនលើវត្ថុនីមួយៗ ។ ដ្យាក្រាមគំនូសតាងកម្លាំងចំពោះវត្ថុទាំងពីរបានបង្ហាញក្នុង (រូបទី *1.45*) ។ ចំពោះវត្ថុនីមួយៗរងនូវកម្លាំងពីរ កម្លាំងទំនាញផែនដីដែលមានទិសដៅចុះក្រោមនិងតំណឹងខ្សែដែលមានទិសដៅឡើងលើ ។

យើងត្រូវបញ្ជាក់សញ្ញាឱ្យបានច្បាស់ ដូចជាក្នុងលំហាត់នេះ យើងឃើញខ្សែបត់បែនកាលណាវាឆ្លងកាត់រ៉ក ។ ក្នុង(រូបទី 1.45) វត្ថុទី1ផ្លាស់ទីឡើងលើ ឯវត្ថុទី2ផ្លាស់ទី ចុះក្រោម ។ ដូច្នេះបើយើងកំណត់ទិសដៅវិជ្ជមានឡើងលើសម្រាប់វត្ថុទី1 យើងត្រូវកំណត់ទិសដៅវិជ្ជមានសម្រាប់វត្ថុទី2 គឺចុះក្រោម ។ ជាមួយនឹងសញ្ញាសន្មតត្រូវអនុវត្តលើកម្លាំងដែលមានអំពើលើវត្ថុនីមួយៗ :



***រូបទី** 1.45*

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

- ចំពោះអង្គធាតុទី 1 យើងបាន

$$T - m_1 g = m_1 a \qquad (1)$$

- ចំពោះអង្គធាតុទី 2 យើងបាន

$$m_2 g - T = m_2 a \qquad (2)$$

បូក (1) និង (2) យើងបាន

$$a = \left(\frac{m_2 - m_1}{m_1 + m_2}\right) g \qquad (3)$$

ជំនួស (3) ក្នុង (1) យើងបាន

$$T = \left(\frac{2m_1 m_2}{m_1 + m_2}\right) g \qquad (4)$$

អនុវត្តជាលេខ $m_1 = 1.0\text{kg}$ , $m_2 = 2.0\text{kg}$ និង $g = 9.80\text{m/s}^2$

ជំនួសតម្លៃទាំងនោះក្នុង (3) យើងបាន

$$a = \left(\frac{2.0 - 1.0}{1.0 + 2.0}\right) \frac{\text{kg}}{\text{kg}} \times 9.80\text{m/s}^2$$

ដូចនេះ $\boxed{a = 3.27\text{m/s}^2}$ ។

និងក្នុង (4) យើងបាន

$$T = \left(\frac{2 \times 1.0 \times 2.0}{1.0 + 2.0}\right) \text{kg} \times 9.80\text{m/s}^2$$

ដូច្នេះ $\boxed{T \approx 13.1\text{N}}$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## មេរៀនសង្ខេប

- កម្លាំងជាបុព្វហេតុដែលធ្វើឱ្យអង្គធាតុបម្រុងមានចលនា មានចលនា ខូចទ្រង់ទ្រាយ បញ្ឈប់ ឬផ្លាស់ប្តូរទិសដៅចលនារបស់អង្គធាតុ ។
- កម្លាំងមានពីរ ៖ កម្លាំងប៉ះនិងកម្លាំងពីចម្ងាយ ។
- ខ្នាតនៃកម្លាំងគឺញូតុន ។ មួយញូតុន(1N) ជាកម្លាំងមានអំពើលើអង្គធាតុដែលមានម៉ាស 1kg បង្កើតសំទុះ $1m/s^2$ ។
- កម្លាំងជាទំហំវ៉ិចទ័រ ដើម្បីរកកម្លាំងផ្គួបគេធ្វើផលបូកវ៉ិចទ័រ $\vec{F} = \vec{F}_1 + \vec{F}_2$ ។
- ច្បាប់ទី 1 ញូតុនឬច្បាប់និចលភាព ៖ បើអង្គធាតុមួយមិនរងអំពើនៃកម្លាំងផ្សេងៗទេ ឬវារងតែកម្លាំងផ្គួបស្មើនឹងសូន្យ បើវានៅនឹងថ្កល់វានៅនឹងដដែល តែបើវាមានចលនា ចលនានោះជាចលនាត្រង់ស្មើ ។
- ច្បាប់ទី 2 ញូតុន ៖ សំទុះនៃវត្ថុមួយសមាមាត្រទៅនឹងកម្លាំងផ្គួបដែលមានអំពើលើវា និងច្រាសសមាមាត្រនឹងម៉ាសវា ។ $\vec{F} = m\vec{a}$ បើ $F$ = ថេរ $\Leftrightarrow a$ = ថេរ ។
- ម៉ាសជាទំហំដែលកំណត់និចលភាពនៃវត្ថុ ។ ខ្នាតម៉ាសគឺ គីឡូក្រាម (kg) ។
- កម្លាំងទំនាញរបស់ផែនដីលើវត្ថុហៅថាទម្ងន់ ។ ខ្នាតទម្ងន់គឺ ញូតុន (N) ។
- ច្បាប់ទី 3 ញូតុន ៖ បើវត្ថុពីរមានអំពើទៅវិញទៅមក កម្លាំង $\vec{F}_{12}$ ដែលបញ្ចេញដោយវត្ថុទី 1 ទៅលើវត្ថុទី 2 មានទំហំស្មើគ្នានិងមានទិសដៅផ្ទុយនឹងកម្លាំង $\vec{F}_{21}$ ដែលបញ្ចេញដោយវត្ថុទី 2 មកលើវត្ថុទី 1 ៖ $\vec{F}_{12} = -\vec{F}_{21}$ ។

## សំណួរនិងលំហាត់

1. កម្លាំងគឺជាអ្វី ? កម្លាំងមានខ្នាតជាអ្វី ?
2. ចូរពោលច្បាប់និចលភាព ។
3. តើម៉ាសនិងទម្ងន់នៃអង្គធាតុដូចគ្នាឬទេ ? ពីព្រោះអ្វី ?
4. រថយន្តមួយផ្លាស់ទីត្រង់ដោយល្បឿនថេរ ។ តើកម្លាំងផ្គួបដែលមានអំពើលើរថយន្តមានតម្លៃស្មើនឹងប៉ុន្មាន ?

**5.** ស្ត្រីម្នាក់មានម៉ាស 50.0kg ។ តើស្ត្រីនោះមានទម្ងន់ប៉ុន្មាន ? បើគេដឹងថាសំទុះទំនាញផែនដីស្មើនឹង $9.80\text{m/s}^2$ ។

**6.** កម្លាំងពីរមានអំពើលើវត្ថុមួយមានម៉ាស 4.0kg ។ បើ $F_1 = 20.0\text{N}$ និង $F_2 = 15.0\text{N}$ ចូរគណនា :




ក. កម្លាំងផ្គួបដែលមានអំពើលើវត្ថុនោះ ។

ខ. សំទុះនៃវត្ថុនោះ ។

**7.** អេឡិចត្រុងមួយមានម៉ាស $9.11 \times 10^{-31}\text{kg}$ ធ្វើចលនាត្រង់ដោយល្បឿនដើម $2.0 \times 10^5\text{m/s}$ និងផ្លាស់ទីបាន 5.0cm ។ គេដឹងថាសំទុះនៃអេឡិចត្រុងថេរនិងល្បឿនស្រេចគឺ $6.0 \times 10^5\text{m/s}$ ។

ក. កំណត់កម្លាំងដែលមានអំពើលើអេឡិចត្រុង ។

ខ. ប្រៀបធៀបកម្លាំងនេះនិងទម្ងន់របស់អេឡិចត្រុង ។ គេឱ្យ $g = 9.80\text{m/s}^2$ ។

**8.** ឈើមួយដុំរាងប្រលេពីប៉ែតកែងបានរអិលដោយគ្មានកកិតចុះតាមបណ្ដោយប្លង់ទេរ(ដូចរូប) ។ មុំរវាងប្លង់ទេរនិងប្លង់ដេកគឺ $\theta = 30°$ ។ ដុំឈើនោះចាប់ផ្ដើមផ្លាស់ទីពី $A$ ចុះក្រោមតាមបណ្ដោយប្លង់ទេរបានប្រវែង $d = 2.0\text{m}$ ។




ក. គូសដ្យាក្រាមតាងឱ្យកម្លាំងដែលមានអំពើលើដុំថ្មនោះ ។

ខ. គណនាសំទុះនៃដុំឈើនោះ ។

គ. គណនាល្បឿននៅខណៈដែលដុំឈើនោះមកដល់ចំណុច$B$ ។ គេយក $g = 9.80\text{m/s}^2$ ។

**9.** គេភ្ជាប់អង្គធាតុពីរដោយខ្សែដែលឆ្លងកាត់រ៉កមួយ (កកិតរវាងខ្សែនិងរ៉កអាចចោលបាន) ដូចរូប រួចគេលែងវត្ថុទាំងនោះដោយល្បឿនដើមស្មើសូន្យ ។ គេឱ្យ $m_1 = 2.0\text{kg}$ , $m_2 = 5.0\text{kg}$ និង $\theta = 60°$ ។




ក. គណនាសំទុះនៃអង្គធាតុ ។

ខ. គណនាតំណឹងខ្សែដែលចងភ្ជាប់អង្គធាតុទាំងពីរ ។

គ. គណនាល្បឿនរបស់អង្គធាតុនីមួយៗក្រោយពីចេញដំណើរបានរយៈពេល2.0s ។គេយក $g = 9.80\text{m/s}^2$ ។

youtube.com/moeys khru.moeys.gov.kh facebook.com/moeys.gov.kh

មេរៀនទី

# 3 កម្មន្ត ថាមពល និងអានុភាព

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពន្យល់យ៉ាងច្បាស់ពីកម្មន្ត ថាមពល អានុភាព និងទំនាក់ទំនងរវាងទំហំទាំងនោះ ។
- ❒ បង្ហាញឱ្យឃើញថាផ្ទៃក្រឡាក្រោមក្រាបនៃដ្យាក្រាមតាង(កម្លាំង - បំលាស់ទី)គឺជាកម្មន្ត ។
- ❒ អនុវត្តកម្មន្ត ថាមពល និងអានុភាពបានយ៉ាងត្រឹមត្រូវក្នុងជីវភាពប្រចាំថ្ងៃ ។

## 1. កម្មន្តបង្កើតដោយកម្លាំងថេរ

### 1.1 ផលគុណស្កាលែ




***រូបទី*** *1.46*

ផលគុណស្កាលែនៃវ៉ិចទ័រ គឺជារបៀបធ្វើលេខគុណនៃវ៉ិចទ័រដែលគេឃើញមានក្នុងការអនុវត្តរូបវិទ្យា ។ ចំពោះផលគុណស្កាលែនៃពីរវ៉ិចទ័រ គេអាចសង់ចំណោលកែងនៃវ៉ិចទ័រមួយតាមទិសដៅនៃវ៉ិចទ័រមួយទៀតនិងធ្វើលេខគុណរវាងតម្លៃលេខនៃវ៉ិចទ័រទីមួយនិងតម្លៃលេខនៃវ៉ិចទ័រចំណោលកែងនោះ ។ កន្សោមនេះមានទម្រង់ $\boxed{\vec{a}\cdot\vec{b} = ab\cos\theta}$ ដែល $a$ និង $b$ ជាតម្លៃរៀងគ្នានៃ $\vec{a}$ និង$\vec{b}$ ហើយθ ជាមុំផ្គុំរវាងវ៉ិចទ័រ $\vec{a}$ និង$\vec{b}$ ។ តម្លៃនៃចំណោលកែងវ៉ិចទ័រ $\vec{b}$ គឺ $b\cos\theta$ ។

- បើ $\theta = 0°$ គេបាន $\vec{a}\cdot\vec{b} = ab$ និងផលគុណស្កាលែមានតម្លៃអតិបរមា ។
- បើ $\theta = 90°$ គេបាន $\vec{a}\cdot\vec{b} = ab\times 0 = 0$ ។

***ឧទាហរណ៍ទី****1* : វ៉ិចទ័រ $\vec{a}$ និង $\vec{b}$ មានទំហំរៀងគ្នា 3 ឯកតា និង 5 ឯកតា ។ តើមុំផ្គុំរវាងវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ មានតម្លៃស្មើនឹងប៉ុន្មាន បើផលគុណស្កាលែ $\vec{a}$ និង $\vec{b}$ ស្មើនឹងសូន្យ , 15 ឯកតានិង –15 ឯកតា ?

**ដំណោះស្រាយ**

- មុំផ្គុំរវាងវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ បើផលគុណស្កាលែរវាង $\vec{a}$ និង $\vec{b}$ ស្មើនឹង 0

  $\vec{a}\cdot\vec{b} = ab\cos\theta = 0$ ដោយ $a = 3$ ឯកតានិង $b = 5$ ឯកតា នោះ $ab \neq 0$

  យើងបាន $\cos\theta = 0 \Rightarrow \boxed{\theta = 90^\circ}$ ។

- មុំផ្គុំរវាងវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ បើផលគុណស្កាលែរវាង $\vec{a}$ និង $\vec{b}$ ស្មើនឹង 15 ឯកតា

  $\vec{a}\cdot\vec{b} = ab\cos\theta = 15$ ឯកតា ដោយ $ab = 3\times 5 = 15$ ឯកតា

  យើងបាន $\cos\theta = 1 \Rightarrow \boxed{\theta = 0^\circ}$ ។

- មុំផ្គុំរវាងវ៉ិចទ័រ $\vec{a}$ និង $\vec{b}$ បើផលគុណស្កាលែរវាង $\vec{a}$ និង $\vec{b}$ ស្មើនឹង –15 ឯកតា

  $\vec{a}\cdot\vec{b} = ab\cos\theta = -15$ ឯកតា ដោយ $ab = 3\times 5 = 15$ ឯកតា

  យើងបាន $\cos\theta = -1 \Rightarrow \boxed{\theta = 180^\circ}$ ។

## 1.2 កម្មន្តបង្កើតដោយកម្លាំងថេរ

មេរៀនមុនយើងបានបង្ហាញអំពីបញ្ញត្តិ បំលាស់ទី វ៉ិចទ័រល្បឿន សំទុះ និងកម្លាំង ។ ក្នុងមេរៀននេះយើងនឹងសិក្សាបញ្ញត្តិថ្មីមួយទៀតគឺកម្មន្ត ។



*រូបទី 1.47* **បុរសម្នាក់រុញជញ្ជាំង**



*រូបទី 1.48* **ស្ត្រីម្នាក់កំពុងរុញកូនរទេះ**

(រូបទី *1.47*) បង្ហាញពីបុរសម្នាក់កំពុងប្រើកម្លាំងរុញប្រឆាំងនឹងជញ្ជាំងរឹង ចំណែក(រូបទី *1.48*) បង្ហាញពីស្ត្រីម្នាក់កំពុងរុញកូនរទេះសម្រាប់ដាក់ឥវ៉ាន់សំដៅទៅទិសខាងកើត ។ ស្ត្រីនោះបានបំពេញកម្មន្ត ។ ចំណែកបុរសមិនបានបំពេញកម្មន្តទេ ព្រោះជញ្ជាំងនៅនឹងដដែល ។ ក្នុងរូបវិទ្យាគេថា កម្មន្តបានធ្វើលើវត្ថុមួយ កាលណាវត្ថុនោះផ្លាស់ទីតាមទិសដៅនៃកម្លាំង ។ ដូច្នេះកម្មន្ត គឺជាទំនាក់ទំនងរវាងបំលាស់ទីនិងកម្លាំងដែលជាបុព្វហេតុធ្វើឱ្យមានបំលាស់ទីនោះ ។

តាមការបង្ហាញនេះ គេអាចកំណត់និយមន័យកម្មន្ត :

> កម្មន្តបង្កើតដោយកម្លាំងថេរ គឺជាផលគុណរវាងកម្លាំងក្នុងទិសដៅបំលាស់ទីនិងទំហំនៃបំលាស់ទីនោះ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

កាលណាកម្លាំង $\vec{F}$ មានអំពើលើវត្ថុមួយហើយធ្វើឱ្យវត្ថុនោះមានបំលាស់ទី $\vec{d}$ តាមទិសដៅនៃកម្លាំង នោះគេអាចសរសេរ ៖



រូបទី 1.49

$$W = Fd\cos\theta$$

$W$ ៖ កម្មន្តធ្វើឡើងដោយកម្លាំងថេរ(ជាទំហំស្កាលែ)គិតញូតុនម៉ែត $(\mathrm{N \cdot m})$ ឬស៊ូល(J) ។

$F$ ៖ កម្លាំងថេរគិតជាញូតុន (N) ។

$d = AB$ ៖ បំលាស់ទី(ជាទំហំវ៉ិចទ័រ)គិតជាម៉ែត (m) ។

$\theta$ ៖ មុំផ្គុំរវាងកម្លាំង $\vec{F}$ និងបំលាស់ទី $\vec{d}$ ។

តាមរូបមន្តខាងលើជាផលគុណស្កាលែ ដូចនេះរូបមន្តកម្មន្តតាងដោយ $W = \vec{F} \cdot \vec{d}$ ។ បើ $F = 1\mathrm{N}$ និង $d = 1\mathrm{m} \Rightarrow W = 1\mathrm{Nm} = 1\mathrm{J}$

ក្នុងប្រព័ន្ធ SI ខ្នាតនៃកម្មន្តគឺស៊ូល (J) ។ **មួយស៊ូល(1J) ជាកម្មន្តដែលធ្វើឡើងដោយកម្លាំងមួយញូតុន(1N) ក្នុងទិសដៅនៃបំលាស់ទីធ្វើឱ្យវត្ថុផ្លាស់ទីបានចម្ងាយមួយម៉ែត** (1m) ។

- បើ $\theta = 0° \Rightarrow W = Fd > 0$
- បើ $0° < \theta < 90° \Rightarrow W = Fd\cos\theta > 0$
- បើ $\theta = 90° \Rightarrow W = Fd\cos\theta = 0$
- បើ $90° < \theta < 180° \Rightarrow W = Fd\cos\theta < 0$
- បើ $\theta = 180° \Rightarrow W = -Fd < 0$

**សំគាល់** ៖ បើ $W > 0$ គេហៅថាកម្មន្តចលករ និង $W < 0$ គេហៅថាកម្មន្តទប់ ។

**នេះជាឧទាហរណ៍ខ្លះៗបង្ហាញពីកម្លាំងដែលមិនបានបំពេញកម្មន្ត**


*រូបទី 1.50 ក្មេងប្រុសម្នាក់កំពុងកាន់ដុំឈើ*


*រូបទី 1.51 ក្មេងស្រីម្នាក់កំពុងកាន់សៀវភៅ*

កម្លាំង $\vec{F}$ ដែលមានអំពើទៅលើដុំឈើមួយ(រូបទី 1.50) មានទិសដៅឡើងលើ គឺគ្មានកម្មន្តទេ ពីព្រោះកម្លាំងតាមទិសដៅនៃបំលាស់គឺស្មើសូន្យ ។ចំណែកឯ(រូបទី 1.51)គ្មានកម្មន្តដែលធ្វើឡើងដោយកម្លាំងទេ ព្រោះកម្លាំងនោះមិនបានធ្វើឱ្យសៀវភៅផ្លាស់ទី ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

***ឧទាហរណ៍ទី***2: (រូបទី *1.52* ) បានបង្ហាញពីមនុស្សម្នាក់កំពុងរុញកូនរទេះមួយនៅក្នុងផ្សារទំនើប ។ បើគាត់បញ្ចេញកម្លាំង 30.0N ទៅលើកូនរទេះក្នុងទិសដៅនៃបំលាស់ទីនោះ កូនរទេះផ្លាស់ទីបានចម្ងាយ 5.00m ។ គណនាកម្មន្តដែលបានបំពេញដោយកម្លាំងលើកូនរទេះ ។



***រូបទី*** *1.52*

**ដំណោះស្រាយ**

- កម្មន្តដែលបានបំពេញដោយកម្លាំងលើកូនរទេះ

  ដោយ $F = 30.0\text{N}$ និង$d = 5.00\text{m}$

  យើងបាន $W = Fd = 30.0\text{N} \times 5.00\text{m} = 150\text{Nm}$

  $$\boxed{W = 150\text{J}}$$

***ឧទាហរណ៍ទី*** *3* : ដើម្បីឱ្យវត្ថុ $m$ មួយផ្លាស់ទីពី $A$ ទៅ $B$ ដែល $AB = 5\text{m}$ គេត្រូវប្រើកម្លាំង $F = 20\text{N}$ ។




***រូបទី*** *1.53*

ក. ចូរគូសក្រាបតាង (កម្លាំង - បំលាស់ទី) ។

ខ. តាមក្រាបនេះ ចូរគណនាផ្ទៃក្រឡារបស់ចតុកោណដែលមានជ្រុងស្មើនឹង $F$ និង $AB$ ។

គ. គណនាកម្មន្តដែលបានធ្វើនោះ ។

**ដំណោះស្រាយ**

ក. ក្រាបតាង (កម្លាំង - បំលាស់ទី) (ដូចរូបខាងស្តាំ)




***រូបទី*** *1.54*

ខ. ផ្ទៃក្រឡារបស់ចតុកោណដែលមានជ្រុងស្មើនឹង

$F$ និង $AB = x$ ដូច្នេះ $S = FAB = Fx$

$S = 20\text{N} \times 5\text{m} = 100\text{Nm}$

គ. កម្មន្តដែលបានធ្វើ

$W = Fx = 20\text{N} \times 5\text{m} = 100\text{N} \cdot \text{m}$

ដូច្នេះ $W = 100\text{J}$ ។

តាមចម្លើយ (ខ) និង (គ) យើងឃើញថា **ផ្ទៃក្រឡាក្រោមក្រាបតាង**(កម្លាំង - បំលាស់ទី) **ជាកម្មន្ត** ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 2. ថាមពលស៊ីនេទិច និងទ្រឹស្តីបទកម្មន្ត – ថាមពល

ថាមពលគឺជាសមត្ថភាពនៃអង្គធាតុដើម្បីធ្វើកម្មន្ត ។ ក្នុងប្រព័ន្ធ SI ខ្នាតនៃថាមពលគឺស៊ូល (J) ដូចខ្នាតកម្មន្តដែរ ។

### 2.1 ថាមពលស៊ីនេទិច

ថាមពលស៊ីនេទិច គឺជាថាមពលកើតមានឡើង នៅពេលអង្គធាតុមានចលនា ហើយថាមពលនេះ អាស្រ័យនឹងល្បឿនចលនានិងម៉ាសនៃអង្គធាតុនោះ ។

សមីការថាមពលស៊ីនេទិចគឺ

$$\boxed{K = \frac{1}{2}mv^2}$$

$K$ ជាថាមពលស៊ីនេទិចគិតជាស៊ូល (J)

m ម៉ាសនៃអង្គធាតុគិតជាគីឡូក្រាម(kg)

$v$ ល្បឿននៃអង្គធាតុគិតជាម៉ែត្រក្នុងមួយវិនាទី (m/s) ។



តាមសមីការ $K = \frac{1}{2}mv^2$ យើងអាចសន្និដ្ឋានថា វត្ថុពីរមានម៉ាសស្មើគ្នាធ្វើចលនាដោយល្បឿនខុសគ្នា វត្ថុមានល្បឿនលឿនជាងគេ មានថាមពលស៊ីនេទិចធំជាង ។ ស្រដៀងគ្នានេះដែរ ចំពោះវត្ថុពីរមានម៉ាសខុសគ្នា ធ្វើចលនាដោយល្បឿនដូចគ្នា វត្ថុមានម៉ាសធំជាង មានថាមពលស៊ីនេទិចធំជាង ។

***ឧទាហរណ៍ទី 4*** : គ្រាប់កាំភ្លើងមួយមានម៉ាស $2.0 \times 10^{-2}$kg ផ្លាស់ទីដោយល្បឿន $1.2 \times 10^{3}$m/s ។ គណនាថាមពលស៊ីនេទិចរបស់វា ។

**✍ ដំណោះស្រាយ**

- គណនាថាមពលស៊ីនេទិចរបស់វា

តាមរូបមន្ត $K = \frac{1}{2}mv^2$

ម៉ាសគ្រាប់កាំភ្លើង $2.0 \times 10^{-2}$kg

ល្បឿនគ្រាប់កាំភ្លើង $1.2 \times 10^{3}$m/s

យើងបាន $K = \frac{1}{2} \times 2.0 \times 10^{-2}\text{kg} \times (1.2 \times 10^{3}\text{m/s})^2 = 1.4 \times 10^{4}\text{J}$

ដូច្នេះ $\boxed{K = 1.4 \times 10^{4}\text{J}}$ ។

## 2.2 ទ្រឹស្ដីបទកម្មន្ត - ថាមពល




រូបទី 1.55

ឧបមាអង្គធាតុមួយរងនូវកម្លាំងផ្ដួបថេរហើយផ្លាស់ទីបានចម្ងាយ $d$ ដោយល្បឿនដើម $\vec{v}_0$ និងល្បឿនស្រេច $\vec{v}$ ។

កម្មន្តដែលធ្វើដោយកម្លាំងផ្ដួបគឺ

$W = Fd = mad$ ( ព្រោះ $F = ma$ ) (1)

តាមមេរៀនទី 1 យើងមាន

$$d = \bar{v}t \quad \text{តែ} \quad \bar{v} = \frac{v_0 + v}{2}$$

យើងបាន $$d = \frac{1}{2}(v_0 + v)t \quad (2)$$

និង $$a = \frac{v - v_0}{t} \quad (3)$$

$v_0$ ជាល្បឿននៅខណៈ $t = 0$ និង $v$ ជាល្បឿននៅខណៈ $t$ ។

ដោយជំនួស (2) និង (3) ក្នុង (1)

គេបាន $\boxed{W = \frac{1}{2}mv^2 - \frac{1}{2}mv_0^2}$

ដូច្នេះគេតាង $K_f = \frac{1}{2}mv^2$ ជាថាមពលស៊ីនេទិចនៅខណៈ $t$ និង $K_i = \frac{1}{2}mv_i^2$ ជាថាមពលស៊ីនេទិចនៅខណៈ $t = 0$ និង $W$ ជាកម្មន្តនៃកម្លាំងផ្ដួប ។

តាមទំនាក់ទំនងខាងលើ គេសរសេរ $\boxed{W = K_f - K_i}$ ។

### ទ្រឹស្ដីបទកម្មន្ត - ថាមពលស៊ីនេទិច

*បម្រែបម្រួលថាមពលស៊ីនេទិច $\Delta K$ នៃអង្គធាតុមួយរវាងខណៈពីរស្មើនឹងផលបូកកម្មន្ត $W$ នៃកម្លាំងក្រៅទាំងអស់ដែលមានអំពើលើអង្គធាតុនោះ ។ គេបាន $W = K_f - K_i$ ។*

# 3. អានុភាព



រូបទី 1.56

រថយន្តពីរមានម៉ាសដូចគ្នា ប៉ុន្តែរថយន្តទី 1 ប្រើម៉ាស៊ីនស៊ីឡាំងបួន និងទី 2 ប្រើម៉ាស៊ីនស៊ីឡាំងប្រាំបី ។ រថយន្តទាំងពីរឡើងចំណោតនៃភ្នំតូចមួយ ។ រថយន្តទី 2 ប្រើរយៈពេលខ្លីជាងរថយន្តទី 1 ដើម្បីឡើងដល់កំពូលភ្នំ ។ រថយន្តទាំងពីរបានឡើងដល់កំពូលភ្នំដូចគ្នា មានន័យថារថយន្តទាំងពីរបានបំពេញកម្មន្តស្មើគ្នា ។ ប៉ុន្តែផលធៀបរវាងកម្មន្តនិងរយៈពេលដែលរថយន្តទាំងពីរបានបំពេញពុំស្មើគ្នាទេ ។ ផលធៀបរវាងកម្មន្តនិងរយៈពេល ហៅថា **អានុភាព** ។ ដូច្នេះរថយន្តទី 2 មានអានុភាពធំជាងរថយន្តទី 1 ។

បើកម្លាំងក្រៅមួយមានអំពើលើវត្ថុមួយនិងកម្មន្តដែលបានបំពេញដោយកម្លាំងនោះក្នុងរយៈពេល $\Delta t$ គឺ $\Delta W$ ។

អានុភាពមធ្យមដែលបានចំណាយក្នុងរយៈពេលនោះគឺ $\bar{P} = \frac{\Delta W}{\Delta t}$ ។

ក្នុងទំនាក់ទំនង $\bar{P} = \frac{\Delta W}{\Delta t}$ បើ $\Delta t$ ខិតទៅរកសូន្យ នោះ $\Delta W$ ខិតទៅសូន្យដែរ យើងបាន $\frac{\Delta W}{\Delta t}$ ខិតទៅរកតម្លៃកម្រិតមួយ ។ តម្លៃកម្រិតនេះគឺជា**អានុភាព** ខណៈតាងដោយ $P$ ។

ដូច្នេះ $\bar{P} = \frac{\Delta W}{\Delta t}$ ដោយ $\Delta W = F\Delta x$

គេបាន $\bar{P} = F\frac{\Delta x}{\Delta t}$ តែ $\frac{\Delta x}{\Delta t} = \bar{v}$

បើ $\Delta t$ ខិតទៅសូន្យ នោះ $\Delta x$ ខិតទៅសូន្យ យើងបាន $\frac{\Delta x}{\Delta t}$ ខិតទៅរកតម្លៃកម្រិតស្មើនឹងល្បឿនខណៈ ។ ដូច្នេះអានុភាពខណៈ $\boxed{P = Fv}$ ឬ $\boxed{P = \vec{F}\cdot\vec{v}}$ ។

*ដូច្នេះ អានុភាពខណៈ $P$ នៃកម្លាំងមួយស្មើនឹងផលគុណស្កាលែនៃកម្លាំង $\vec{F}$ និងវ៉ិចទ័រល្បឿនខណៈ $\vec{v}$ នៅខណៈនោះ ។*

- បើ $\vec{v}$ ជាវ៉ិចទ័រល្បឿនមធ្យម គេបាន $P$ ជាអានុភាពមធ្យម ។
- បើ $\vec{v}$ ជាវ៉ិចទ័រល្បឿនខណៈ គេបាន $P$ ជាអានុភាពខណៈ ។

ក្នុងទំនាក់ទំនង $\bar{P} = \frac{\Delta W}{\Delta t}$ បើ $\Delta W = 1J$ និង $\Delta t = 1s \Rightarrow \bar{P} = 1J/s$ ។ ស៊ូលក្នុងមួយវិនាទីហៅថា **វ៉ាត់** (W) ( **ជេម វ៉ាត់** ជាអ្នកបង្កើតម៉ាស៊ីនប្រើចំហាយទឹក) ។

ទំនាក់ទំនង $P = Fv$ បើ $F = 1N = 1kgm/s^2$ និង $v = 1m/s \Rightarrow P = 1kgm^2/s^3$

ដូច្នេះ $\boxed{1W = 1J/s = (J)/1kgm^2/s^3}$ ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

អានុភាពជាអត្រានៃការបំប្លែងថាមពលពីទម្រង់មួយទៅទម្រង់មួយទៀត ។យើងអាចពិនិត្យកំសៀវអគ្គិសនីពីរមានអានុភាពរៀងគ្នាគឺ 1000W និង 500W ។ បើយើងចាក់ទឹកចូលទៅក្នុងកំសៀវអគ្គិសនីទាំងពីរដោយចំណុះស្មើគ្នា នោះកំសៀវអគ្គិសនីដែលមានអានុភាពអគ្គិសនី 1000W នឹងបំប្លែងថាមពលអគ្គិសនីទៅជាថាមពលកម្ដៅធំជាងពីរដងធៀបនឹងកំសៀវអគ្គិសនីដែលមានអានុភាព 500W ។ នេះមានន័យថា ដើម្បីដាំទឹកពុះ កំសៀវអគ្គិសនីដែលមានអានុភាព 1000W ចំណាយពេលតែពាក់កណ្ដាលធៀបនឹងកំសៀវអគ្គិសនីដែលមានអានុភាព500W ។ ដូច្នេះកំសៀវអគ្គិសនីដែលមានអានុភាព1000W ពិតជាមានអានុភាពធំជាងកំសៀវអគ្គិសនីដែលមានអានុភាព 500W ។

បើយើងតាង $W$ ជាកម្មន្ត $t$ ជារយៈពេល និង $P$ ជាអានុភាព ។ យើងបាន

$$P = \frac{W}{t} \quad \Rightarrow \quad W = Pt$$

បើ $P = 1\text{kW} = 1000\text{W}$ និង $t = 1\text{h} = 3600\text{s} \quad \Rightarrow \quad W = 1\text{kWh}$

ដូចនេះ $1\text{kWh} = 3.60 \times 10^{6}\text{J}$ ។

ដូច្នេះ **គីឡូវ៉ាត់ម៉ោង** គឺជាខ្នាតថាមពលមិនមែនជាខ្នាតអានុភាពទេ ។ នៅពេលអ្នកទទួលវិក្កយបត្រអគ្គិសនី អ្នកចំណាយឱ្យក្រុមហ៊ុនអគ្គិសនីនូវថាមពលអគ្គិសនីដែលអ្នកបានប្រើក្នុងរយៈពេលនោះ ។ **ថាមពល**គឺជាផលគុណរវាងអានុភាពនិងរយៈពេលនៃដំណើរការ ។

***ឧទាហរណ៍ទី 5 :*** អំពូលអគ្គិសនីមួយមានអានុភាព 300W ត្រូវបានគេយកទៅបំភ្លឺក្នុងរយៈពេល 12h ។ដើម្បីបំភ្លឺអំពូលនេះ គេត្រូវចំណាយថាមពលអគ្គិសនី $0.30\text{kW} \times 12\text{h} = 3.6\text{kWh}$ ។

## 4. ថាមពលប៉ូតង់ស្យែល

ថាមពលប៉ូតង់ស្យែល ជាថាមពលនៃអង្គធាតុមួយដែលអាស្រ័យនឹងទីតាំងឬស្ថានភាពរបស់វា ។

***ឧទាហរណ៍ទី 6 :*** គេលើកអង្គធាតុពីរមានម៉ាសប៉ុនគ្នាឡើងលើផុតពីដីឱ្យបានកម្ពស់ $h_1$ និង $h_2 = 2h_1$ (រូបទី *1.57*) ។ អង្គធាតុដែលស្ថិតនៅកម្ពស់ $h_1$ មានថាមពលប៉ូតង់ស្យែលទំនាញដី $U_1$ និងអង្គធាតុដែលស្ថិតនៅកម្ពស់ $h_2$ មានថាមពលប៉ូតង់ស្យែលទំនាញដី $U_2 = 2U_1$ ។



***រូបទី*** *1.57*

អង្គធាតុមួយមានម៉ាស $m$ ត្រូវគេលើកឡើងលើតាមទិសឈររហូតដល់កម្ពស់ $h$ ។ កម្មន្តដែលធ្វើឡើងដោយកម្លាំង $\vec{F}$ គឺ $W = Fh$ តែ $F = mg$ នោះគេបាន $W = mgh$ ។

ដូច្នេះដើម្បីលើកវត្ថុមួយដែលមានម៉ាស $m$ ឱ្យបានកម្ពស់ $h$ វាត្រូវការកម្មន្តមួយស្មើ $mgh$ ។ នៅត្រង់កម្ពស់ $h$ នោះ វត្ថុនោះត្រូវមានសមត្ថភាពដើម្បីធ្វើកម្មន្តមួយស្មើនឹង $mgh$ ។

ដូច្នេះ **ថាមពលប៉ូតង់ស្យែលនៃទំនាញផែនដីរបស់វត្ថុមួយនៅជិតផ្ទៃផែនដីគឺ ជាផលគុណរវាងទម្ងន់ $mg$ និងកម្ពស់ $h$ ដែលវត្ថុនោះតាំងនៅ** ។ ក្នុងករណីនេះ ថាមពលប៉ូតង់ស្យែលទំនាញផែនដី $\boxed{U = mgh}$

$m$ គិតជា kg , $g$ គិតជា $m/s^2$ , $h$ គិតជា m , $U$ គិតជា J ។

***ឧទាហរណ៍ទី** 7 :* ស្គរសមួយកញ្ចប់មានម៉ាស 5.00kg ត្រូវបានគេលើកតាមទិសឈរបានកម្ពស់ 10.0m ដោយល្បឿនថេរមួយ ។ តើស្គរសមានថាមពលប៉ូតង់ស្យែលដែនទំនាញផែនដីប៉ុន្មាន ? គេឱ្យសំទុះទំនាញផែនដី $g = 9.80m/s^2$ ។

**ដំណោះស្រាយ**

- ថាមពលប៉ូតង់ស្យែលដែនទំនាញផែនដីនៃស្គរ

  តាមនិយមន័យ $U = mgh$

  ដោយ $m = 5.00kg$ , $g = 9.80m/s^2$ និង $h = 10.0m$

  យើងបាន $U = 5.00 \times 9.80 \times 10.0$

  ដូច្នេះ $U = 490J$ ។

***ឧទាហរណ៍ទី** 8:* បន្ទប់នៃជណ្ដើរយន្តមួយមានម៉ាស500kg ផ្លាស់ទីចុះដោយសំទុះថេរ $\vec{a} = \frac{\vec{g}}{5}$ និងមានល្បឿនដើម $v = 5.00m/s$ ។ បន្ទប់នេះចុះបានចម្ងាយ $d = 16.0m$ ។




***រូបទី** 1.58 **ជណ្ដើរយន្ត***

ក. គណនាកម្មន្តនៃកម្លាំងទំនាញផែនដីដែលមានអំពើលើបន្ទប់ជណ្ដើរយន្តក្នុងបំលាស់ទីនោះ ។

ខ. គណនាកម្មន្តនៃតំណឹងខ្សែកាបដែលមានអំពើលើបន្ទប់ជណ្ដើរយន្តក្នុងបំលាស់ទីនោះ ។

គ. គណនាកម្មន្តផ្ទួប ។

ឃ. គណនាថាមពលស៊ីនេទិចរបស់បន្ទប់ជណ្ដើរយន្តនៅខណៈវាចុះបាន 16.0m ។

គេយក $g = 9.80m/s^2$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## ✍ ដំណោះស្រាយ




រូបទី 1.59

ក. គណនាកម្មន្តនៃកម្លាំងទំនាញផែនដី

យើងតាងបន្ទប់នៃជណ្តើរយន្តដោយចំណុចមួយ ។

កម្លាំងដែលមានអំពើលើបន្ទប់ជណ្តើរយន្តគឺ

- កម្លាំងទំនាញផែនដី $\vec{F} = m\vec{g}$ (1)
- តំណឹងខ្សែ $\vec{T}$ (2)

គណនាកម្មន្តនៃកម្លាំងទំនាញផែនដី

តាមរូបមន្ត $W_g = Fd\cos\theta$ តែ $\theta = 0° \Rightarrow \cos\theta = 1$

ដូច្នេះ $W_g = Fd = mgd$

ដោយ $m = 500\text{kg}$ , $g = 9.80\text{m/s}^2$ និង $d = 16.0\text{m}$

យើងបាន $W_g = 500 \times 9.80 \times 16.0$

ដូច្នេះ $\boxed{W_g = 784 \times 10^2\text{J} = 78.4\text{kJ}}$

ខ. គណនាកម្មន្តនៃតំណឹងខ្សែកាប

អនុវត្តច្បាប់ទី 2 ញូតុនចំពោះទំនាក់ទំនង (1) និង (2)

យើងបាន $m\vec{g} + \vec{T} = m\vec{a}$ ជាម៉ូឌុល $mg - T = ma$

យើងទាញបាន $T = m(g - a)$

គណនាកម្មន្តនៃតំណឹងខ្សែកាប

តាមរូបមន្ត $W_T = Td\cos\theta = m(g - a)d\cos\theta$ តែ $\theta = 180° \Rightarrow \cos\theta = 1$

ដោយ $m = 500\text{kg}$ , $g = 9.80\text{m/s}^2$ , $d = 16.0\text{m}$ និង $a = \frac{g}{5}$

$$W_T = m\left(g - \frac{g}{5}\right)d\cos\theta = m\left(\frac{4g}{5}\right)d\cos\theta$$

អនុវត្តជាលេខ $W_T = 500\text{kg} \times \frac{4 \times 9.80\text{m/s}^2}{5} \times 16.0\text{m} \times (-1)$

ដូច្នេះ $\boxed{W_T = -627 \times 10\text{J} = -63.0\text{kJ}}$

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

**គ.** គណនាកម្មន្តនៃកម្លាំងផ្ទប

តាមរូបមន្ត $W = W_g + W_T$

យើងបាន $W = 78400 - 62720$

ដូច្នេះ $\boxed{W = 157 \times 10\text{J} = 16.0\text{kJ}}$

**ឃ.** គណនាថាមពលស៊ីនេទិចរបស់បន្ទប់ជណ្ដើរយន្តនៅខណៈវាចុះបាន 16.0m

តាមទ្រឹស្ដីបទកម្មន្ត - ថាមពលយើងបាន

$$W = \Delta K = K_f - K_i \quad \Rightarrow \quad K_f = K_i + W$$

ដោយ $K_i = \frac{1}{2}mv^2 = \frac{1}{2}500 \times (5.00)^2 = 6250\text{J}$ និង $W = 15680\text{J}$

យើងបាន $K_f = 6250 + 15680$

ដូច្នេះ $\boxed{K_f = 21930\text{J} \approx 22.0\text{kJ}}$ ។

## មេរៀនសង្ខេប

- ផលគុណស្កាលែរវាងវ៉ិចទ័រពីរ $\vec{a}$ និង $\vec{b}$ គឺ $\vec{a} \cdot \vec{b} = ab\cos\theta$ ។
- កម្មន្តនៃកម្លាំងមួយគឺជាផលគុណរវាងកម្លាំងនោះក្នុងទិសដៅបំលាស់និងបំលាស់ទីនោះ ។
- កម្មន្តជាទំហំស្កាលែ ។ ដូច្នេះកម្មន្ត $W$ នៃកម្លាំង $\vec{F}$ ដែលធ្វើឱ្យអង្គធាតុផ្លាស់ទីបាន $\overrightarrow{AB}$ $(AB = d)$ គឺ $W = Fd\cos\theta$ ។
- មួយស៊ូល = មួយញូតុនម៉ែត្រ ឬ $1\text{J} = 1\text{N} \cdot \text{m}$ ។
- ថាមពលស៊ីនេទិច $K = \frac{1}{2}mv^2$ ។
- ទ្រឹស្ដីបទកម្មន្ត - ថាមពល $W = \Delta K = K_f - K_i$ ។
- អានុភាពមធ្យម $\bar{P} = \frac{\Delta W}{\Delta t}$
- អានុភាព $P = Fv$ ឬ $P = \vec{F} \cdot \vec{v}$ ។
- $1\text{W} = 1\text{J/s} = 1\text{kgm}^2/\text{s}^3$ ។
- តាមទំនាក់ទំនង $W = Pt$ យើងបាន $1\text{kWh} = 3.6 \times 10^6\text{J}$ ។
- ថាមពលប៉ូតង់ស្យែល $U = mgh$ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## សំណួរនិងលំហាត់

1. ស្ត្រីម្នាក់ទូលល្អីដាក់ចេកពេញ ។ គាត់ធ្វើដំណើរសំដៅទៅផ្សារដើម្បីលក់ចេក ។ តើកម្លាំងដែលគាត់ទូលនេះបានបំពេញកម្មន្តឬទេ ? ព្រោះអ្វី ?

2. ចូរពោលទ្រឹស្តីបទកម្មន្ត - ថាមពល ។

3. បើអេឡិចត្រុងមួយ (ម៉ាស $m_c = 9.11 \times 10^{-31}$kg ) មានថាមពលស៊ីនេទិច $6.7 \times 10^{19}$J តើអេឡិចត្រុងមានល្បឿនស្មើនឹងប៉ុន្មាន ?

4. ត្រាក់ទ័រមួយទាញរ៉ឺម៉កដោយកម្លាំងថេរ 1500N តាមទិសដៅនៃចលនា ។ គណនាកម្មន្តនៃកម្លាំងនោះក្នុងបម្លាស់ទី 100m ។

5. កម្លាំង 5.0N មានអំពើលើអង្គធាតុមួយមានម៉ាស 25kg ដែលកំពុងនៅស្ងៀម ។ ចូរគណនា
   ក. កម្មន្តនៃកម្លាំងដែលមានអំពើលើអង្គធាតុនោះក្នុងរយៈពេល $3s$ ។
   ខ. អានុភាពខណៈដែលរយៈពេលស្មើនឹង $3s$

6. ដុំថ្មមួយមានម៉ាស $m$ = 100kg ធ្លាក់ពីកំពស់ 200m ធៀបនឹងផ្ទៃដី ។
   ក. គណនាកម្មន្តនៃទម្ងន់ក្នុងទន្លាក់ 200m នេះ ។
   ខ. គណនាថាមពលស៊ីនេទិចនៅខណៈដែលវាធ្លាក់បានកម្ពស់ 100m ។

7. រថយន្តមួយមានម៉ាស $m$ = 1000kg ស្ថិតនៅស្ងៀម ។ បន្ទាប់មកវាផ្លាស់ទីក្រោមអំពើនៃកម្លាំងផ្ទួប $\vec{F}$ ដែលមានទិសដៅស្របនឹងគន្លងនិងផ្លាស់ទីបាន 1000m ក្នុងរយៈពេល $t$ = 32s ។
   ក. កំណត់សំទុះរថយន្ត ។ គេសន្មតថាសំទុះនោះថេរ ។
   ខ. គណនាល្បឿនរថយន្តនៅខណៈដែលរថយន្តផ្លាស់ទីបាន 1000m ។
   គ. រកថាមពលស៊ីនេទិចនៃរថយន្តនៅខណៈ $t$ = 32s និងគណនាកម្លាំងផ្ទួបដែលមានអំពើលើរថយន្តនោះ ។
   ឃ. គណនាអានុភាពនៃកម្លាំង $\vec{F}$ នៅខណៈ $t$ = 10s ។

មេរៀនទី

# 4 សម្ពាធនៃសន្ទនីយស្តាទិច

**ចប់មេរៀននេះ សិស្សអាច**

- ❒ គណនាសម្ពាធបានត្រឹមត្រូវ ។
- ❒ បង្ហាញពីភាពខុសគ្នារវាងសម្ពាធបរិយាកាស សម្ពាធឧស្ម័ន និងសម្ពាធនៅជម្រៅណាមួយ ។
- ❒ បង្ហាញពីគោលការណ៍ប៉ាស្កាល់និងគោលការណ៍អាកស៊ីម៉ែត ។
- ❒ បង្ហាញថា ហេតុអ្វីបានជាអង្គធាតុខ្លះលិចនិងអណ្តែតក្នុងអង្គធាតុរាវ ។

យើងបានសិក្សានៅថ្នាក់ទី ៨រួចមកហើយថា អង្គធាតុរាវនិងឧស្ម័នអាចហូរបាន ដោយហេតុនេះហើយទើបយើងហៅអង្គធាតុទាំងនោះថា **សន្ទនីយ** ។ ក្នុងមេរៀននេះ យើងនឹងសិក្សាអំពី**សម្ពាធ**និងសន្ទនីយស្តាទិចបន្តពីថ្នាក់ទី ៨ ។

## 1. សម្ពាធបរិយាកាសនិងសម្ពាធឧស្ម័ន

### 1.1 សម្ពាធ

សម្ពាធគឺជាកម្លាំងសង្កត់ក្នុងមួយខ្នាតនៃផ្ទៃ : $P = \frac{F}{A}$

ក្នុងប្រព័ន្ធ SI ខ្នាត $F$ កម្លាំងគិតជា (N) ; $A$ ផ្ទៃគិតជា ($m^2$) ; $P$ សម្ពាធគិតជា ($N/m^2$) ឬ Pa (ប៉ាស្កាល់) ។

### 1.2 អត្ថិភាពនៃសម្ពាធបរិយាកាស

សម្ពាធបរិយាកាសមានតម្លៃធំសម្បើម តែគេមិនអាចដឹងបានយ៉ាងជាក់ស្តែងទេព្រោះថា វត្ថុមួយដែលស្ថិតនៅក្នុងខ្យល់រមែងទទួលកម្លាំងសង្កត់ពីគ្រប់ទិស ។ គេប្រមាណឃើញថា តួខ្លួនមនុស្សម្នាក់ដែលមានផ្ទៃ $1.50m^2$ រងកម្លាំងសង្កត់របស់បរិយាកាស $15 \times 10^4$N ដោយយើងគ្មានដឹងខ្លួនថាបានទទួលកម្លាំងនេះផង ។ បានជាយើងមិនដឹង ព្រោះកម្លាំងខ្យល់ដែលនៅក្នុងរាងកាយយើងទប់ទល់នឹងកម្លាំងសង្កត់របស់ខ្យល់ពីក្រៅ ។

**ពិសោធន៍ :** យើងចាក់ទឹកបំពេញកែវមួយ ។ បន្ទាប់មក យើងយកក្រដាសមួយបន្ទះមកខ្ទប់មាត់កែវ ហើយផ្កាប់មាត់ចុះក្រោម ។ យើងដកដៃចេញ យើងឃើញថា ទឹកមិនធ្លាក់ចេញពីកែវឡើយ ។ ហេតុអ្វីបានជាបន្ទះក្រដាសមិនធ្លាក់ចុះ ? គេអាចពន្យល់បានថា ទម្ងន់ទឹកសង្កត់ក្រដាសចុះក្រោមតែខ្យល់ខាងក្រៅក៏មានកម្លាំងមួយច្រានពីក្រោមឡើងលើវិញដែរហើយ កម្លាំងច្រាននេះធំជាងទម្ងន់ទឹក ។



*រូបទី* 1.60

បើគេបង្វិលកែវជុំវិញខ្លួនវា គេសង្កេតឃើញថាក្រដាសមិនធ្លាក់ទេ ។ ដូច្នេះសម្ពាធបរិយាកាសមានអំពើលើអង្គធាតុទាំងឡាយគ្រប់ទិសទាំងអស់ ។



*រូបទី* 1.61

ឥឡូវតើនឹងទៅជាយ៉ាងដូចម្ដេចបើគេបង្កើនបរិមាណទឹករហូតដល់ទម្ងន់ខិតទៅរកតម្លៃសង្កត់របស់បរិយាកាស ?

ពិសោធន៍បង្ហាញថា កម្លាំងសង្កត់របស់ខ្យល់អាចទប់កម្ពស់សសរទឹកបានប្រហែល 10m ។ ពេលនោះគេបាន : $W = F$ ។

ឬ $$mg = 1P_{at} \times A$$

ដូចនេះ $\boxed{1P_{at} = \frac{mg}{A}}$ ( $P_{at}$ ជាសម្ពាធបរិយាកាស)



*រូបទី* 1.62

នៅពេលដែលគេប្រើ បារតជំនួសទឹក(បារតមានម៉ាសមាឌ $1.359 \times 10^4 \text{kg/m}^3$ ) នោះកម្ពស់សសរបារតមានតម្លៃប្រហែល 760mm ។

## 1.3 បារ៉ូម៉ែតបារត

បារ៉ូម៉ែត ជាឧបករណ៍សម្រាប់វាស់សម្ពាធបរិយាកាសដែលរកឃើញដោយលោកតូរីសែលី Torricelli (1608-1647) ។



*រូបទី* 1.63

បារ៉ូម៉ែតធ្វើឡើងពីបំពង់កែវមួយប្រវែងប្រហែលមួយម៉ែតហើយមានអង្កត់ផ្ចិត 3mm ។ គេបំពេញបំពង់កែវនេះដោយបារតរួចគេយកវាទៅផ្កាប់ក្នុងជើងបារតមួយ ។ ពិសោធន៍បង្ហាញថាដំបូងបារតហូរធ្លាក់ចុះក្រោម ព្រោះកម្លាំងនៃបរិយាកាសតូចជាងទម្ងន់នៃបារតហើយបន្ទាប់មក

បារតលែងធ្លាក់ ពេលនោះទម្ងន់នៃសសរបារតស្មើនឹងកម្លាំងនៃបរិយាកាស ។ ជាលទ្ធផលគេវាស់កម្ពស់សសរបារតឃើញ $h = 760\text{mm}$ ។

យើងយកចំណុចពីរ : ចំណុច $M$ នៅក្នុងបំពង់និងចំណុច$N$ នៅក្រៅបំពង់ ។ យើងអាចសរសេរ សម្ពាធត្រង់ $M$ = សម្ពាធត្រង់ $N$ ។

សម្ពាធត្រង់ $N$ ជាសម្ពាធបរិយាកាស ($P_{at}$) ហើយសម្ពាធត្រង់ $M$ ជាសម្ពាធរបស់សសរបារតក្នុងបំពង់ ព្រោះផ្នែកខាងលើជាសុញ្ញកាស ។

ដូច្នេះ គេអាចយកម្ពស់សសរបារតដើម្បីវាស់សម្ពាធបរិយាកាស ។ សម្ពាធដែលត្រូវនឹងកម្ពស់សសរបារត 760mm ហៅថា មួយអាត់ម៉ូស្វ៊ែរ (1at) :

$$\boxed{1\text{at} = 760\text{mmHg}}$$

$$1\text{at} = 1.013 \times 10^5 \text{N/m}^2 \quad \text{ឬ} \quad 1.013 \times 10^5 \text{Pa}$$

ដូចនេះ $1\text{at} = 101\text{kPa}$ ។

ក្នុងឧតុនិយមជួនកាលសម្ពាធបរិយាកាសត្រូវបានគិតជា **បា** (bar) : $1\text{bar} = 10^5\text{Pa} \cong 1\text{at}$ ។

## 1.4 ការវាស់សម្ពាធឧស្ម័ន

ដើម្បីវាស់សម្ពាធឧស្ម័នគេប្រើឧបករណ៍មួយហៅថា **ម៉ាណូម៉ែត**(Manometer) ។ ម៉ាណូម៉ែតធ្វើឡើងពីបំពង់កែវរាង $U$ សម្រាប់ផ្ទុកអង្គធាតុរាវដូចជា បារត ទឹកឬប្រេង ។ នៅពេលដែលម៉ាណូម៉ែតមិនទាន់បញ្ចូលឧស្ម័នមានតែសម្ពាធបរិយាកាស$P_{at}$ ទេ ដែលមានអំពើលើផ្ទៃស្រលះនៃអង្គធាតុរាវត្រង់ $A$ និង $B$ ដែលជាហេតុធ្វើឱ្យនីវ៉ូត្រង់ $A$ និង $B$ ស្មើគ្នា ។ នៅពេលដែលគេបញ្ចូលឧស្ម័នទៅក្នុងម៉ាណូម៉ែតឧស្ម័នបានបង្កើតសម្ពាធមួយទៅលើផ្ទៃនៃអង្គធាតុរាវត្រង់ $B$ ។ ប្រសិនបើសម្ពាធនេះធំជាងសម្ពាធបរិយាកាស នោះវាធ្វើឱ្យកម្ពស់អង្គធាតុរាវត្រង់ $B$ ធ្លាក់ចុះ ។ ក្នុងស្ថានភាពលំនឹងសម្ពាធ ត្រង់ $B$ និង $C$ ត្រូវតែស្មើគ្នា ព្រោះវាស្ថិតនៅកម្ពស់ស្មើគ្នា ។ សម្ពាធឧស្ម័នត្រង់ $B$ អាចសរសេរ : $P_B$ = សម្ពាធបរិយាកាស + សម្ពាធអង្គធាតុរាវដែលមានកម្ពស់ $AC$

$$\boxed{P_B = P_{at} + \rho g h}$$ ( $h$ ប្រវែង $AC$ , $\rho$ ម៉ាសមាឌអង្គធាតុរាវ )




*រូបទី 1.64 ម៉ាណូម៉ែត*

facebook.com/moeys.gov.kh
youtube.com/moeys
groupmoeys.gov.kh

## 2. សម្ពាធអាស្រ័យនឹងជម្រៅ



រូបទី 1.65

ឧបមាថាផើងមួយត្រូវបានដាក់អង្គធាតុរាវដែលមានម៉ាសមាឌ $\rho$ និងកម្ពស់ $h$ ។ ផ្ទៃស្រលះនៃអង្គធាតុរាវប៉ះនឹងខ្យល់ដែលមានសម្ពាធ $P_{at}$ ។ បើ $A$ ជាផ្ទៃនៃអង្គធាតុរាវ កម្លាំងបរិយាកាសដែលសង្កត់ផ្ទៃលើគឺ $F = P_{at} \cdot A$ ។

នៅបាតផើងកម្លាំងសង្កត់ទៅលើវាត្រូវស្មើនឹងកម្លាំងសង្កត់នៃកម្លាំងបរិយាកាសបូកនឹងទម្ងន់នៃអង្គធាតុរាវ ។

យើងដឹងហើយថា ម៉ាសរបស់អង្គធាតុរាវ $m = \rho V$ ហើយ $V = hA$

គេបានទម្ងន់របស់អង្គធាតុរាវ

$$W = mg = \rho V g = \rho(hA)g$$

កម្លាំងសង្កត់ទៅលើបាតផើង

$$F' = F + W = P_{at} \cdot A + \rho h A g$$

សម្ពាធនៅបាតផើង

$$P = \frac{F'}{A} = \frac{P_{at} \cdot A + \rho h A g}{A} = P_{at} + \rho g h$$

ដូចនេះ $\boxed{P = P_{at} + \rho g h}$ ។

រូបមន្តខាងលើនេះអាចអនុវត្តបានចំពោះគ្រប់អង្គធាតុរាវទាំងអស់ដែលមានម៉ាសមាឌ $\rho$ និងស្ថិតក្រោមសម្ពាធបរិយាកាស $P_{at}$ ។

**សម្គាល់ :** លទ្ធផលខាងលើបង្ហាញថា សម្ពាធក្នុងអង្គធាតុរាវកើនឡើងទៅតាមជម្រៅ ។ ដោយហេតុនេះហើយទើបក្នុងសំណង់ទំនប់ គេត្រូវធ្វើផ្នែកក្រោមឱ្យក្រាស់ជាងផ្នែកលើ ។

### 2.1 គោលការណ៍គ្រឹះអ៊ីដ្រូស្តាទិច



រូបទី 1.66

ទំនាក់ទំនង $P = P_{at} + \rho g h$ អាចអនុវត្តបានគ្រប់ពីរចំណុចនៅក្នុងអង្គធាតុរាវដែលមានជម្រៅខុសគ្នា $h$ :

សម្ពាធត្រង់ចំណុចទី 1

$$P_1 = P_{at} + \rho g h_1$$

សម្ពាធត្រង់ចំណុចទី 2

$P_2 = P_{at} + \rho g h_2$

ផលសងសម្ពាធរវាងចំណុចទាំងពីរ

$$P_2 - P_1 = P_{at} + \rho g h_2 - P_{at} - \rho g h_1$$

$$= \rho g h_2 - \rho g h_1 = \rho g(h_2 - h_1)$$

តែ $h_2 - h_1 = h$ យើងបាន $P_2 - P_1 = \rho g h$

ដូច្នេះ $\boxed{P_2 = P_1 + \rho g h}$ ។

***ឧទាហរណ៍*** ប្រអប់មួយមានកម្ពស់ $h = 20.00\text{cm}$ ស្ថិតក្នុងអង្គធាតុរាវដែលមានម៉ាសមាឌ $\rho$ ។ គេដឹងថា សម្ពាធផ្នែកខាងលើមានតម្លៃ $P_1 = 105.0\text{kPa}$ ហើយផ្នែកខាងក្រោម $P_2 = 106.8\text{kPa}$ ។ តើម៉ាសមាឌអង្គធាតុរាវមានតម្លៃស្មើនឹងប៉ុន្មាន ?

អនុវត្តតាមទំនាក់ទំនងគ្រឹះ

$P_2 = P_1 + \rho g h$

យើងបាន

$$\rho = \frac{P_2 - P_1}{gh}$$

$$\rho = \frac{106.8 \times 10^5 - 105.0 \times 10^5}{9.81 \times 0.200} = 920\text{kg/m}^3$$




*រូបទី 1.67*

## 2.2 គោលការណ៍ប៉ាស្កាល់

រំលឹកឡើងវិញអំពីសម្ពាធក្នុងអង្គធាតុរាវដែលមានម៉ាសមាឌ $\rho$ ហើយនៅពីលើមានសម្ពាធបរិយាកាស $P_{at}$ ។ សម្ពាធនៅជម្រៅ $h$ គឺ $P = P_{at} + \rho g h$

ឥឡូវឧបមាថាសម្ពាធបរិយាកាសបានកើនពី $P_{at}$ ទៅ $P_{at} + \Delta P$ នោះសម្ពាធនៅជម្រៅ $h$ អាចសរសេរ : $P = P_{at} + \Delta P + \rho g h = (P_{at} + \rho g h) + \Delta P$

ដូចនេះកាលណាគេបង្កើនសម្ពាធនៅលើផ្ទៃនៃអង្គធាតុរាវនូវបរិមាណ $\Delta P$ បរិមាណសម្ពាធនេះត្រូវបានបញ្ជូនទៅគ្រប់ទីកន្លែងនៃអង្គធាតុរាវនូវបរិមាណដូចគ្នា ។

**គោលការណ៍ប៉ាស្កាល់** : កាលណាសម្ពាធខាងក្រៅត្រូវបានបញ្ជូនទៅក្នុងអង្គធាតុរាវដែលបិទជិត អង្គធាតុរាវបញ្ជូនសម្ពាធនោះទៅគ្រប់ទិសទីដោយបរិមាណស្មើៗគ្នា ។

គោលការណ៍ប៉ាស្កាល់នេះត្រូវបានយកមកអនុវត្តក្នុងឃ្នាបអ៊ីដ្រូលិច ។ឃ្នាបនេះធ្វើឡើងពីស៊ីឡាំងពីរមួយមានមុខកាត់ $A_1$ ហើយមួយទៀតមានមុខកាត់ $A_2$ ដែល$A_2 > A_1$ ។ ស៊ីឡាំងភ្ជាប់គ្នាដោយបំពង់មួយហើយគេចាក់អង្គធាតុរាវទៅក្នុងស៊ីឡាំងរួចគេបិទមាត់វាដោយពីស្តុងពីរ ។ ដំបូងពីស្តុងទាំងពីរស្ថិតនៅកម្រិតកម្ពស់ស្មើគ្នា ។



រូបទី 1.68

ឥឡូវយើងធ្វើឱ្យមានកម្លាំងមួយ $\vec{F}_1$ សង្កត់ទៅលើពីស្តុង តូចដែលធ្វើឱ្យមានកំណើនសម្ពាធក្នុងស៊ីឡាំងនេះនូវបរិមាណ : $\Delta P = \dfrac{F_1}{A_1}$ ។

តាមគោលការណ៍ប៉ាស្កាល់កំណើនសម្ពាធនេះត្រូវបានបញ្ជូនទៅស៊ីឡាំងទីពីរនូវបរិមាណដូចគ្នា ។ កម្លាំងដែលមានអំពើលើពីស្តុងធំគឺ : $F_2 = (\Delta P)A_2$ ហើយ $\Delta P = \dfrac{F_1}{A_1}$

ដូច្នេះគេបាន $F_2 = F_1 \cdot \dfrac{A_2}{A_1} > F_1$ (ព្រោះ $A_2 > A_1$ )

ឧបមាថា $A_2$ ធំជាង $A_1$ 100 ដង នោះយើងបានកម្លាំង $F_2$ ធំជាងកម្លាំង $F_1$ 100 ដងដែរ ។

ដូចនេះយើងឃើញថា គេអាចប្រើកម្លាំង $\overrightarrow{F_1}$ មួយដែលមានតម្លៃតូច ដើម្បីបង្កើតកម្លាំង $\overrightarrow{F_2}$ មួយខ្លាំងជាងមុនច្រើនដង ។

## 3. ការអនុវត្តសម្ពាធនិងគោលការណ៍អាកស៊ីម៉ែត

### 3.1 គោលការណ៍អាកស៊ីម៉ែតនិងកម្លាំងដំណោល

ហេតុការណ៍ដែលសម្ពាធក្នុងអង្គធាតុរាវកើនទៅតាមជម្រៅនាំឱ្យមានផលវិបាកសំខាន់ៗជាច្រើន ។ក្នុងចំណោមផលវិបាកនោះមានហេតុការណ៍មួយសំខាន់គឺកម្លាំងដំណោលត្រង់ទៅលើរបស់អង្គធាតុរាវមានអំពើលើអង្គធាតុរឹងដែលលិចនៅក្នុងវា ។ដើម្បីឱ្យឃើញពីដើមកំណើតនៃកម្លាំងដំណោលនេះ យើងឧបមាថាប្រអប់មួយមានរាងជាគូបហើយមានទ្រនុង$L$ ត្រូវបានជ្រមុជទាំងស្រុងទៅក្នុងអង្គធាតុរាវដែលមានម៉ាសមាឌ $\rho$ ។ អង្គធាតុរាវដែលព័ទ្ធជុំវិញប្រអប់បញ្ចេញកម្លាំងសង្កត់កែងទៅនឹងផ្ទៃប្រអប់គ្រប់ទិស ។ កម្លាំងតាមទិសដេកដែលសង្កត់ពីឆ្វេងនិងពីស្តាំជាកម្លាំងពីរស្មើគ្នា ។ ដូច្នេះ កម្លាំងទាំងនេះមិនមានឥទ្ធិពលអ្វីទៅលើប្រអប់ទេ ។ ចំណែកកម្លាំងតាមទិសឈរ ជាកម្លាំងមិនស្មើគ្នាទេ ។ គួរកត់សំគាល់ថាកម្លាំងសង្កត់ចុះក្រោមមានតម្លៃតូចជាងកម្លាំងដោលឡើងលើ ព្រោះសម្ពាធផ្នែកខាងលើតូចជាងសម្ពាធផ្នែកខាងក្រោម ។



រូបទី 1.69

បើ $P_1$ ជាសម្ពាធផ្នែកខាងលើគេបាន ៖

$F_1 = P_1 \cdot A = P_1 L^2$ ដែល $A = L^2$

ចំណែកសម្ពាធ $P_2$ ផ្នែកខាងក្រោមគឺ

$P_2 = P_1 + \rho g L$

កម្លាំងដំណោលពីក្រោមឡើងលើគឺ

$F_2 = P_2 \cdot A = (P_1 + \rho g L)L^2 = P_1 L^2 + \rho g L^3$

បើយើងតាង $\vec{F}_b$ ជាកម្លាំងដំណោលត្រង់ឈរ

គេបាន ៖ $F_b = F_2 - F_1 = P_1 L^2 + \rho g L^3 - P_1 L^2 = \rho g L^3$

កត់សំគាល់ថា $L^3$ គឺជាមាឌនៃប្រអប់ហើយ $F_b = \rho g V$ ជាទម្ងន់នៃអង្គធាតុរាវដែលមានមាឌស្មើនឹងមាឌប្រអប់ ។ដូចនេះកម្លាំងដំណោលមានតម្លៃស្មើនឹងទម្ងន់នៃអង្គធាតុរាវដែលញែកវាចេញ ។

**គោលការណ៍អាកស៊ីម៉ែត** ៖ *អង្គធាតុរឹងមានមាឌ $V$ ជ្រមុជក្នុងអង្គធាតុរាវនឹងថ្កល់ដែលមានម៉ាសមាឌ $\rho$ ទទួលពីអង្គធាតុរាវនោះនូវដំណោលឈរមួយមានទិសដៅពីក្រោមឡើងលើហើយមានតម្លៃ ៖* $\boxed{F_b = \rho g V}$ ។

**សម្គាល់** ៖ រូបមន្តនេះក៏អាចអនុវត្តបានចំពោះអង្គធាតុដែលលិចដោយភាគដែល $V$ តាងឱ្យមាឌនៃផ្នែកលិច ។

## 3.2 អង្គធាតុលិចទាំងស្រុង

ក្នុងផ្នែកនេះយើងសិក្សាពីការអនុវត្តនូវគោលការណ៍ដំណោលអាកស៊ីម៉ែត ។ យើងចាប់ផ្ដើមពីអង្គធាតុដែលលិចទាំងស្រុងទៅក្នុងអង្គធាតុរាវ ហើយខាងក្រោយយើងសិក្សាលើអង្គធាតុអណ្ដែត ។

**វង្វាស់ម៉ាសមាឌមនុស្ស** ៖ មនុស្សម្នាក់មានទម្ងន់ 720.0N នៅក្នុងខ្យល់ត្រូវបានជ្រមុជទៅក្នុងធុងទឹក ។ មនុស្សនោះអង្គុយក្នុងសង្រែកខ្សែ (ម៉ាសខ្សែអាចចោលបាន) ហើយថ្កក់ទៅនឹងជញ្ជីងមួយដែលយើងអាចវាស់ទម្ងន់ទំនងវាបាន ។បន្ទាប់ពីបញ្ចេញដង្ហើមឱ្យអស់ហើយមនុស្សនោះត្រូវជ្រមុជទាំងស្រុងទៅក្នុងទឹក ហើយទម្ងន់ទំនងរបស់គាត់គឺ 34.3N ។ ចូររកមាឌនិងម៉ាសមាឌរបស់មនុស្ស ។



***រូបទី*** *1.70*

នៅក្នុងទឹកមនុស្សរងនូវកម្លាំងបីគឺ ទម្ងន់ពិត $\vec{W}$ ទម្ងន់ទំនង $\vec{W}_a$ និងដំណោលអាកស៊ីម៉ែត $\vec{F}_b$ ។

តាមលំនឹងគេបាន : $W_a + F_b - W = 0$

តែ$F_b = \rho g V \quad \Rightarrow \quad W_a + \rho g V - W = 0$

$$\Rightarrow \quad V = \frac{W - W_a}{\rho g}$$

**អនុវត្តន៍ជាលេខ :** $W = 720.0\text{N}$ , $W_a = 34.3\text{N}, \rho = 1000\text{kg/m}^3$ និង $g = 9.80\text{m/s}^2$

$$V = \frac{720.0 - 34.3}{1000 \times 9.80} = 6.99 \times 10^{-2}\text{m}^3$$

$$\boxed{V = 6.99 \times 10^{-2}\text{m}^3}$$

ទម្ងន់មនុស្ស : $W = \rho' V g \quad \Rightarrow \quad \rho' = \frac{W}{Vg}$

$$\rho' = \frac{720.0}{6.99 \times 10^{-2} \times 9.80} = 1050\text{kg/m}^3$$

$$\rho' = 1050\text{kg/m}^3 = 1.05 \times 10^3\text{kg/m}^3$$

$$\boxed{\rho' = 1.05 \times 10^3\text{kg/m}^3}$$

**សម្គាល់ :** ម៉ាសមាឌមនុស្សមានតម្លៃធំជាងម៉ាសមាឌទឹក ដែលជាហេតុធ្វើឱ្យមនុស្សលិចទាំងស្រុងទៅក្នុងទឹក ។

## 3.3 អង្គធាតុអណ្តែត

កាលណាអង្គធាតុមួយអណ្តែត កម្លាំងដំណោលដែលមានអំពើលើវាមានតម្លៃស្មើនឹងទម្ងន់របស់អង្គធាតុ ។ ឧទាហរណ៍យើងទម្លាក់ដុំឈើយឺតៗចូលទៅក្នុងផើងទឹក ។ ជាដំបូងមានតែបរិមាណទឹកតិចតួចបានញែកចេញ ហើយកម្លាំងដំណោលមានតម្លៃស្មើនឹងមួយភាគនៃទម្ងន់របស់ដុំឈើ(រូបទី *1.71*)ដែរ ។ បើយើងបន្តទម្លាក់តទៅទៀត វាធ្លាក់ចុះកាន់តែជ្រៅហើយទឹកដែលញែកចេញកាន់តែច្រើន ជាហេតុធ្វើឱ្យដំណោលកាន់តែធំ ។



***រូបទី*** *1.71*

ចុងបញ្ចប់យើងឃើញថា នៅខណៈណាមួយដុំឈើចាប់ផ្ដើមអណ្ដែតដូច (រូបទី *1.72*) ។ក្នុងករណីនេះកម្លាំងដំណោលមានតម្លៃស្មើនឹងទម្ងន់របស់ដុំឈើ ។ នេះមានន័យថា ខណៈនោះទម្ងន់របស់ទឹកដែលញែកចេញមានតម្លៃស្មើនឹងទម្ងន់របស់ដុំឈើ ។

***ជាទូទៅវត្ថុមួយអាចអណ្ដែតបាន លុះត្រាតែវាញែកនូវបរិមាណអង្គធាតុរាវស្មើនឹងទម្ងន់របស់វា ។***




***រូបទី** 1.72*

youtube.com/moeys

********************************************************************************

## អំណានបន្ថែម



krou.moeys.gov.kh

រឿងព្រេងនិទានមួយតំណាលថា មានមហាក្សត្រិយ៍នៃនគរ **ស៊ីរ៉ាគូស** ព្រះនាម **អ៊ីយេរ៉ុង** ទ្រង់មានបំណងចង់បូជាមកុដមាសថ្វាយព្រះអាទិទេពទ្រង់បានប្រគល់ឱ្យជាងទងម្នាក់ធ្វើមកុដនោះ ។ ដោយសង្ស័យថា ជាងទងបានយកប្រាក់មកកាឡៃ ទ្រង់ក៏បានបញ្ជាឱ្យហៅ **អាកស៊ីម៉ែត**មក ហើយសួរថា តើលោកអាចបង្ហាញឱ្យឃើញថា ជាងទងពិតជាក្លែងបន្លំមែនឬទេ ដោយកុំប៉ះពាល់ឱ្យខូចមកុដនោះឡើយ ? **អាកស៊ីម៉ែត** បានខិតខំរិះគិតពីរឿងនេះអស់រយៈពេលយ៉ាងយូរ ។ ថ្ងៃមួយនៅពេលមុជទឹកក្នុងអាង លោកបានសម្គាល់ឃើញថា វាមានទំនាក់ទំនងរវាងដំណោលនិងមាឌនៃវត្ថុដែលញែកចេញ ។ វត្ថុដែលធ្វើពីមាសត្រូវតែធ្វើឱ្យទឹកដែលញែកចេញមានមាឌតូចជាងមាឌទឹកដែលវត្ថុធ្វើអំពីប្រាក់ទម្ងន់ស្មើគ្នា។ ដោយរំភើបខ្លាំងពេកចំពោះរបកគំហើញនេះ **អាកស៊ីម៉ែត**បានស្ទុះចេញពីអាងទឹកទៅដល់ផ្លូវទាំងខ្លួនស្រាតនលល ហើយស្រែកយ៉ាងខ្លាំងៗថា "អឺរេកា ! អឺរេកា ! អឺរេកា ! (ខ្ញុំបានរកឃើញហើយៗៗ) " ។

facebook.com/moeys.gov.kh

# ពិសោធន៍សម្ពាធក្នុងអង្គធាតុរាវ

## 1. វត្ថុបំណង

បង្ហាញថា សម្ពាធក្នុងអង្គធាតុរាវអាស្រ័យនឹងជម្រៅនិងគណនាសម្ពាធនៅជម្រៅណាមួយតាមពិសោធន៍ជាក់ស្ដែង ។

## 2. សម្ភារៈ

- បំពង់ប្លាស្ទិចថ្លារាងជាស៊ីឡាំង (ប្រហោងសងខាង) ប្រវែងប្រហែល 30cm និងអង្កត់ផ្ចិតក្នុងប្រហែល 5cm (យ៉ាងណាកុំឱ្យតូចពេក) ។
- បន្ទាត់ក្រិត ជញ្ជីង ទឹក ស្កុត់ និងដុំថ្ម ឬឃ្លីស៊ីម៉ង់ត៍មានអង្កត់ផ្ចិតប្រហែល 4cm ។
- ជើងប្លាស្ទិចថ្លារាងជាស៊ីឡាំងឬប្រលេពីប៉ែតកែងដែលមានអង្កត់ផ្ចិតប្រហែល 20cm និងកម្ពស់ប្រហែល 25cm ។
- បន្ទះប្លាស្ទិចស្ដើងសម្រាប់ធ្វើបាតស៊ីឡាំង ។

## 3. ការដំឡើងនិងដំណើរការពិសោធ




- ចាក់ទឹកបំពេញជើងស៊ីឡាំងឱ្យបានជិតពេញជើង ។
- យកបន្ទាត់តូចមកដាក់បញ្ឈរ រួចបិទភ្ជាប់នឹងជញ្ជាំងផ្នែកខាងក្រៅនៃស៊ីឡាំងដោយប្រើស្កុត់ដូចរូប ។
- ថ្លឹងម៉ាសដុំថ្មនិងបន្ទះបាតស៊ីឡាំង ។
- ដាក់ដុំថ្មចូលទៅក្នុងស៊ីឡាំង
- យកបន្ទះប្លាស្ទិចមកដាក់បាំងជាប់និងប្រហោងម្ខាងនៃស៊ីឡាំង រួចដាក់ចូលទៅក្នុងជើងដែលមានទឹកដោយសង្កត់ឱ្យបាតស៊ីឡាំងនោះលិចចូលទៅក្នុងទឹកនូវជម្រៅ *a* ណាមួយ ។
- បន្ទាប់ពីដាក់ដុំថ្មរួច បន្តការសង្កត់ស៊ីឡាំងឱ្យស្ថិតនៅជម្រៅ *a* ដដែល ពេលនោះបន្ទះប្លាស្ទិចនិងដុំថ្មពុំធ្លាក់ចូលទៅក្នុងទឹកទេ ។ នេះបង្ហាញថាកម្លាំងដំណោលរបស់ទឹកមានតម្លៃធំជាងទម្ងន់ដុំថ្ម និងបន្ទះបាតស៊ីឡាំង ។




youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

- សាកល្បងឱ្យស៊ីឡាំងងើបឡើងតិចៗរហូតដល់ជម្រៅ $a'$ ណាមួយ ($a' < a$) ដែលពេលនោះបាតស៊ីឡាំងនិងដុំថ្មបានចាប់ផ្តើមធ្លាក់ចូលទៅក្នុងទឹក ។ ទីតាំងនោះសំគាល់ដោយ $A$ ដូចរូប ។
- ធ្វើតាមលំនាំខាងលើឡើងវិញ ហើយស្រង់ទិន្នន័យចូលក្នុងលទ្ធផលខាងក្រោម ។

**4. លទ្ធផល**

- ម៉ាសដុំថ្ម $m_1$ និងម៉ាសបន្ទះ $m_2$ តាង $m = m_1 + m_2 = \ldots \text{kg}$
- ជម្រៅ : $a' = h_2 - h_1 = \ldots \text{cm}$
- អង្កត់ផ្ចិតស៊ីឡាំង : $D = \ldots \text{cm}$
- ត្រង់ទីតាំង $A$ កម្លាំងដំណោលរបស់ទឹកទប់ទល់ជាមួយនឹងទម្ងន់ដុំថ្ម $W_1$ ទម្ងន់បន្ទះបាត $W_2$ និងកម្លាំងសង្កត់របស់បរិយាកាស $F_{at}$ ($F = W_1 + W_2 + F_{at}$)
- សម្ពាធនៅជម្រៅ $a'$ :

$$P = \frac{F}{A} = \frac{W_1 + W_2 + F_{at}}{A} = \frac{W_1 + W_2}{A} + P_{at}$$

$P = \ldots\ldots\ldots\ldots\ldots\ldots\ldots\ldots$

5. **សន្និដ្ឋាន**

លទ្ធផលពិសោធន៍បង្ហាញថា សម្ពាធក្នុងទឹកអាស្រ័យនឹងជម្រៅមានន័យថា បើជម្រៅកាន់តែជ្រៅនោះ សម្ពាធទឹកកាន់តែខ្លាំង ហើយគេអាចគណនាសម្ពាធទឹកនៅជម្រៅណាមួយតាមពិសោធន៍ដូចខាងលើ ។

**6. សំណួរពិភាក្សា**







**ក.** នៅត្រង់ជម្រៅ $a$ ដុំថ្ម និងបន្ទះបាតស៊ីឡាំងមិនធ្លាក់ចូលទៅក្នុងទឹកទេ ហេតុអ្វី ? ចូរពន្យល់ ។

**ខ.** នៅជម្រៅ $a'$ ដុំថ្ម និងបន្ទះបាតស៊ីឡាំងធ្លាក់ចូលទៅក្នុងទឹក ។ ហេតុអ្វី ? ចូរពន្យល់ ។ ។

**គ.** នៅជម្រៅ $a'$ ដដែល បើគេបង្កើនផ្ទៃឱ្យធំជាងមុនបីដង $3A$ តើដុំថ្មនិងបន្ទះបាតធ្លាក់ចុះឬទេ ? ចូរពន្យល់ ?

**ឃ.** បើគេបន្ថយផ្ទៃស៊ីឡាំងអោយតូចជាងមុនបីដង តើនៅជម្រៅណាដែលដុំថ្មចាប់ផ្តើមធ្លាក់ ?

## មេរៀនសង្ខេប

- សម្ពាធគឺកម្លាំងសង្កត់ក្នុងមួយខ្នាតនៃផ្ទៃ $P = \frac{F}{A}$ ។
- សម្ពាធក្នុងអង្គធាតុរាវដែលមានម៉ាសមាឌ ρ និងជម្រៅ $h$ : $P = P_{at} + \rho gh$ ។
- សម្ពាធរវាងចំណុចពីរក្នុងអង្គធាតុរាវដែលមានជម្រៅខុសគ្នា $h$ : $P_2 = P_1 + \rho gh$ ។
- បារ៉ូម៉ែតជាឧបករណ៍សម្រាប់វាស់សម្ពាធបរិយាកាស : $1atm = 760\text{mmHg}$ ។
- **គោលការណ៍ប៉ាស្កាល់** : កាលណាសម្ពាធខាងក្រៅត្រូវបានបញ្ជូនទៅលើអង្គធាតុរាវដែលបិទជិត អង្គធាតុរាវបញ្ជូនទៅគ្រប់ទិសទីដោយបរិមាណសម្ពាធស្មើៗគ្នា ។
- **គោលការណ៍អាកស៊ីម៉ែត** : អង្គធាតុរឹងដែលមានមាឌ $V$ ជ្រមុជក្នុងអង្គធាតុរាវនឹងថ្កល់ដែលមានម៉ាសមាឌ ρ ទទួលពីអង្គធាតុរាវនោះនូវដំណោលឈរមួយពីក្រោមទៅលើហើយមានតម្លៃ : $F_b = \rho gV$ ។
- អង្គធាតុលិចទាំងស្រុងកាលណាម៉ាសមាឌវាធំជាងម៉ាសមាឌទឹក ។
- អង្គធាតុមួយអាចអណ្តែតបាន លុះត្រាតែវាញែកនូវបរិមាណនៃអង្គធាតុរាវស្មើនឹងទម្ងន់របស់វា ។

## សំណួរនិងលំហាត់

1. តើសម្ពាធជាអ្វី ?
2. តើសម្ពាធបរិយាកាសមានទំហំស្មើនឹងប៉ុន្មាន ?
3. គេប្រើឧបករណ៍អ្វីសម្រាប់វាស់សម្ពាធបរិយាកាស ?
4. តើសម្ពាធអង្គធាតុរាវប្រែប្រួលដូចម្តេច ?
5. ចូរពោលអំពីគោលការណ៍ប៉ាស្កាល់ ។
6. តើគោលការណ៍ប៉ាស្កាល់ត្រូវបានយកទៅអនុវត្តក្នុងឧបករណ៍អ្វីខ្លះ ?
7. តើកម្លាំងដែលធ្វើឱ្យវត្ថុមួយអណ្តែតឡើងលើហៅថា កម្លាំងអ្វី ?
8. តើអ្នកប្រាជ្ញឈ្មោះអ្វី រកឃើញដំណោលទៅលើវត្ថុដែលលិចក្នុងទឹក ? គេឱ្យឈ្មោះដំណោលនោះថាដូចម្តេច ?
9. ចូរពោលគោលការណ៍អាកស៊ីម៉ែត ។
10. តើអង្គធាតុរឹងមួយអាចអណ្តែតលើអង្គធាតុរាវមួយបានត្រូវមានលក្ខខណ្ឌដូចម្តេច ?

## ? សំណួរនិងលំហាត់ជំពូក1

**I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :**

**1.** តើមួយណាជាទំហំវ៉ិចទ័រ ?

☐ក. រយៈពេល ☐ខ. ចម្ងាយចរ ☐គ. ម៉ាស ☐ឃ. សំទុះ ។

**2.** កាលណាគេនិយាយអំពីបំលាស់ទី គេត្រូវបញ្ជាក់ពី :

☐ក. តម្លៃ ☐ខ. ទិសដៅ ☐គ. ទិសនិងទិសដៅ ☐ឃ. តម្លៃនិងទិសដៅ ។

**3.** គេចោលបាល់មួយតាមទិសឈរត្រង់ឡើងលើដោយល្បឿន $1.5\text{m/s}$ និងដោយសំទុះថេរដែលមានតម្លៃ $10\text{m/s}^2$ ។ តើរយៈពេលប៉ុន្មានដែលបាល់ឡើងដល់កម្ពស់ខ្ពស់បំផុត ?

☐ក. $t = 0.15\text{s}$ ☐ខ. $t = 1.50\text{s}$ ☐គ. $t = 15\text{s}$ ☐ឃ. $t = 150\text{s}$ ។

**4.** វត្ថុមួយធ្លាក់ដោយសេរី ។ នេះជាការអនុវត្តច្បាប់របស់ញូតុន

☐ក. ទី 1 ☐ខ. ទី 2 ☐គ. ទី 3 ☐ឃ. ទី 1 និងទី 2 ។

**5.** ដ្យាក្រាមតាងកម្លាំងទាំង4 ដែលមានអំពើលើអង្គធាតុមួយដូចរូប ។

កម្លាំងផ្គួបនៃកម្លាំងទាំង4 គឺ :




☐ក. 5N ទៅខាងឆ្វេង ☐ខ. 5N ទៅខាងស្តាំ

☐គ. 10N ទៅខាងស្តាំ ☐ឃ. 15N ទៅខាងឆ្វេង ។

**6.** មួយញូតុនស្មើនឹង

☐ក. $1\text{kg} \times \text{m/s}^2$ ☐ខ. $1\text{kg} \times \text{m/s}$

☐គ. $1\text{kg} \times \text{m} \times \text{s}^2$ ☐ឃ. $1\text{kg} \times \text{m} \times \text{s}$ ។

**7.** រូបមន្តនៃកម្មន្តរបស់កម្លាំង $F$ ក្នុងបំលាស់ទី $d$ គឺ :

☐ក. $W = Fd\sin\theta$ ☐ខ. $W = Fd\cos\theta$

☐គ. $W = \frac{F}{d}\sin\theta$ ☐ឃ. $W = \frac{F}{d}\cos\theta$ ។

**8.** វត្ថុមួយមានម៉ាស $m$ ស្ថិតនៅកម្ពស់ $h$ ពីផ្ទៃដី ។ តើវត្ថុនោះមានថាមពលបម្រុងជាថាមពលអ្វី ?

☐ក. ថាមពលគីមី ☐ខ. ថាមពលពន្លឺ

☐គ. ថាមពលស៊ីនេទិច ☐ឃ. ថាមពលប៉ូតង់ស្យែល ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

9. កម្លាំងសង្កត់ក្នុងមួយខ្នាតផ្ទៃហៅថា

☐ ក. ដង់ស៊ីតេ ☐ ខ. សម្ពាធ

☐ គ. កម្លាំងដំណោល ☐ ឃ. គោលការណ៍ប៉ាស្កាល់ ។

10. សម្ពាធបរិយាកាសនៅត្រង់នីវូសមុទ្រស្មើនឹង

☐ ក. $1.01 \times 10^5 N/m^2$ ☐ ខ. $0N/m^2$

☐ គ. $1.01 \times 10^4 N/m^2$ ☐ ឃ. $2 \times 10^5 N/m^2$ ។

11. សម្ពាធបរិយាកាសមានតម្លៃ 100kPa ។ តើកម្លាំងដែលបញ្ចេញដោយសម្ពាធបរិយាកាសមកលើផ្ទៃចតុកោណកែងមួយដែលមានបណ្តោយ 0.5m និងទទឹង 0.4m ស្មើនឹងប៉ុន្មាន ?

☐ ក. 20N ☐ ខ. 2 000N

☐ គ. 200N ☐ ឃ. 20 000N ។

## II. បំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. បំលាស់ប្តូរទីតាំងចល័តពីទីតាំងមួយទៅទីតាំងមួយទៀតហៅថា . . . . . . . . ។
2. រ៉ិចទ័រល្បឿនជាបម្រែបម្រួល . . . . . . . . . . ។
3. មេគុណប្រាប់ទិសនៃបន្ទាត់ប៉ះខ្សែកោងតាង(បំលាស់ទី - ពេល)ហៅថា . . . . . . ។
4. សមីការពេលនៃចលនាត្រង់ប្រែប្រួលស្មើសរសេរ . . . . . . . . ។
5. កម្លាំងជាបុព្វហេតុដែលធ្វើឱ្យអង្គធាតុ . . . . . . . . . . . . . . . . . . . . . ។
6. ញូតុនជាកម្លាំងមានអំពើលើអង្គធាតុដែលមានម៉ាស 1kg បង្កើតសំទុះ . . . . . . ។
7. ផលគុណរវាងកម្លាំងក្នុងទិសដៅបំលាស់ទី និងទំហំនៃបំលាស់ទីនោះគឺជា . . . . ។
8. . . . . . . . . គឺជាសមត្ថភាពនៃអង្គធាតុដើម្បីធ្វើកម្មន្ត ។
9. អានុភាពគឺជាផលធៀបរវាង . . . . . . និង . . . . . . ។
10. សម្ពាធគឺជា . . . . . . . . ក្នុង . . . . . . នៃផ្ទៃ ។
11. សម្ពាធបរិយាកាសត្រូវបានគិតជា . . . . ហើយគេវាស់វាដោយឧបករណ៍ឈ្មោះ . . . . ។
12. សម្ពាធក្នុងអង្គធាតុរាវប្រែប្រួលទៅតាម . . . . . ។ គេអាចគណនាសម្ពាធក្នុងអង្គធាតុរាវនៅជម្រៅ $h$ តាមរូបមន្ត . . . . . ។
13. ឃ្នាបអ៊ីដ្រូលិច និងប្រាំងអ៊ីដ្រូលិច គឺជាការអនុវត្តគោលការណ៍ . . . . . . . ។ គោលការណ៍នោះសម្តែងថា . . . . . . . . . . . . . . ។
14. អង្គធាតុរឹងមួយអាចអណ្តែតបានលើផ្ទៃនៃអង្គធាតុរាវមួយបាន លុះត្រាតែវាញែកអង្គធាតុរាវស្មើនឹង . . . . . . វា ។

## III. លំហាត់

1. វត្ថុមួយមានម៉ាស $m = 3.00\text{kg}$ បានផ្លាស់ទីក្នុងប្លង់មួយដែលមានកូអរដោនេ $x = 4t^2 - 1$ និង $y = 2t^2 + 2$ ដែល $x$ , $y$ គិតជា m និង $t$ គិតជា s ។

   ក. កំណត់ល្បឿនដើមនៃវត្ថុ

   ខ. រកទំហំនៃកម្លាំងដែលមានអំពើលើវត្ថុតាមទិសដៅ $x$ និង $y$

   គ. គណនាកម្លាំងផ្គួបដែលមានអំពើលើវត្ថុនោះ ។

2. ថូផ្កាមួយធ្លាក់តាមបង្អួចនៃអគារមួយដែលមានកម្ពស់ 20.0m ពីផ្ទៃដី ។ ថូនោះមានម៉ាស $m = 1.00\text{kg}$ ។ គេមិនគិតកម្លាំងទប់នៃខ្យល់ ។ គេឱ្យ $g = 9.80\text{m/s}^2$ ។ កំណត់

   ក. ល្បឿនថូនៅខណៈដែលថូធ្លាក់ដល់ដី

   ខ. រយៈពេលទន្លាក់

   គ. ថាមពលស៊ីនេទិចនៅខណៈដែលថូធ្លាក់ដល់ដី ។

3. វត្ថុមួយមានម៉ាស $m = 100\text{kg}$ ស្ថិតនៅកម្ពស់ 3.00m ពីដី ។ នៅពេលធ្លាក់វត្ថុ $A$ បានទាញវត្ថុ $B$ មួយទៀតមានម៉ាស $M = 490\text{kg}$ ឱ្យរអិលដោយគ្មានកកិតលើប្លង់ដេកយ៉ាងវែងមួយ ។ $A$ និង $B$ តភ្ជាប់គ្នាដោយខ្សែឆ្មារកាត់តាមចង្អូររ៉កមួយ ។ ម៉ាសរបស់រ៉កអាចចោលបាន ។ គេឱ្យ $g = 9.80\text{m/s}^2$ ។ គណនា

   ក. សំទុះនៃប្រព័ន្ធ

   ខ. រយៈពេលទន្លាក់នៃវត្ថុ $A$

   គ. កម្មន្តនៃទម្ងន់របស់វត្ថុ $A$ ក្នុងរយៈពេលនៃទន្លាក់ ។

4. មុខកាត់នៃពីស្តុងពីររបស់ឃ្នាបអ៊ីដ្រូលិចមានតម្លៃតាមរៀង $8\text{cm}^2$ និង $120\text{cm}^2$ ។ តើដំណោលដែលច្រានទៅលើពីស្តុងធំមានតម្លៃស្មើនឹងប៉ុន្មាន បើកម្មករម្នាក់ប្រើកម្លាំង 3000N ទៅលើពីស្តុងតូចតាមឃ្នាស់មួយ?

5. អង្គធាតុមួយមានម៉ាស 200g ហើយមានម៉ាសមាឌ $7800\text{kg/m}^3$ ។ គេពន្លិចវាទៅក្នុងទឹក ។ រក

   ក. តម្លៃនៃកម្លាំងដំណោលអាកស៊ីម៉ែត ?

   ខ. ទម្ងន់ទំនងរបស់អង្គធាតុដែលលិចទាំងស្រុង ?

6. សាឡាងមួយមានរាងប្រលេពីប៉ែតកែងមានបណ្តោយ 20m និងទទឹង 3m ។ កាលណាគេផ្ទុកពេញ ទឹកឡើងមកនៅត្រឹម 50cm ពីគែមលើរបស់វា ។ កាលណាវាគ្មានបន្ទុកទឹកមកនៅត្រឹម 1.10m ពីគែមវា ។ តើទម្ងន់បន្ទុកស្មើនឹងប៉ុន្មាន ?

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

# ជំពូក 2 ទែម៉ូឌីណាមិច



មនុស្ស សត្វ រុក្ខជាតិ ជាពិសេសអ្វីៗដែលមានជីវិតនៅលើផែនដីនេះ ត្រូវការថាមពលកម្ដៅជាចាំបាច់ ។ ហេតុដូចនេះហើយបានជាអ្នកប្រាជ្ញវិទូ ខិតខំស្រាវជ្រាវសិក្សាពីលំនាំ និងបុព្វហេតុនៃកម្ដៅ ដែលឱ្យឈ្មោះថា ទែម៉ូឌីណាមិច ។ តើទែម៉ូឌីណាមិចក្នុងជំពូកនេះសិក្សាពីអ្វីខ្លះ ?

**មេរៀនទី 1 : សីតុណ្ហភាព**

**មេរៀនទី 2 : ទ្រឹស្ដីស៊ីនេទិចនៃឧស្ម័ន**

**មេរៀនទី 3 : កម្ដៅ**

មេរៀនទី

# 1 សីតុណ្ហភាព

youtube.com/moeys

**ចប់មេរៀននេះ សិស្សអាច**

- ❒ ញែកច្បាស់ពីភាពខុសគ្នារវាងសីតុណ្ហភាពនិងកម្ដៅ ។
- ❒ ពន្យល់បានច្បាស់លាស់ពីរបៀបក្រិតមាត្រដ្ឋានសីតុណ្ហភាព ។
- ❒ គណនាលំហាត់បានត្រឹមត្រូវឥតខ្ចោះ ។

## 1. សីតុណ្ហភាពនិងកម្ដៅ

យើងបានសិក្សារួចមកហើយថា កម្រិតក្ដៅឬត្រជាក់នៃអង្គធាតុមួយសំគាល់ដោយសីតុណ្ហភាព ។ នៅថ្នាក់នេះយើងចង់បង្ហាញពីភាពខុសគ្នារវាងសីតុណ្ហភាពនិងកម្ដៅ ។

ចូរអ្នកធ្វើការសង្កេតលើការចាក់ទឹកក្ដៅពីកំសៀវឬឆ្នាំងចូលទៅក្នុងពែងឬចាន ។សីតុណ្ហភាពនៃតំណក់ទឹកតូចៗដែលខ្ទាតចេញពីពែងមកប៉ះដៃអ្នក ដូចគ្នានឹងសីតុណ្ហភាពទឹកនៅក្នុងពែងដែរ ព្រោះទឹកក្ដៅចេញពីកំសៀវតែមួយ ។ ប៉ុន្តែបើអ្នកយកទឹកក្ដៅក្នុងពែងទាំងអស់មកចាក់លើដៃអ្នកនោះ អ្នកនឹងមានអារម្មណ៍ថា ក្ដៅជាងតំណក់ទឹកក្ដៅតូចៗដែលខ្ទាតត្រូវដៃអ្នក តើហេតុអ្វី ? ព្រោះថាថាមពលកម្ដៅក្នុងពែងទឹកក្ដៅធំជាងថាមពលកម្ដៅក្នុងតំណក់ទឹកក្ដៅ ។ ដូច្នេះ បើគេនិយាយពីសីតុណ្ហភាពនោះ សំដៅទៅលើកម្រិតក្ដៅឬកម្រិតត្រជាក់របស់អង្គធាតុ ។ បើគេនិយាយពីកម្ដៅនោះគឺសំដៅទៅលើបរិមាណថាមពលកម្ដៅដែលផ្ទេរពីអង្គធាតុក្ដៅទៅអង្គធាតុត្រជាក់ ។



***រូបទី*** *2.1*

## 2. មាត្រដ្ឋានសីតុណ្ហភាព

មាត្រដ្ឋានសីតុណ្ហភាពនីមួយៗត្រូវប្រើក្នុងការអនុវត្តផ្សេងៗ ដូច្នេះចាំបាច់យើងត្រូវចេះពីរបៀបក្រិតរបស់វា ។

ដើម្បីក្រិតមាត្រដ្ឋានសីតុណ្ហភាព អ្នកត្រូវអនុវត្តដូចតទៅ ៖

- ជ្រើសរើសសារធាតុ ( សារធាតុដែលត្រូវប្រើដើម្បីវាស់សីតុណ្ហភាព) ។

- ជ្រើសរើសចំណុចនឹងពីរ គឺចំណុចនឹងទាបបំផុតនិងចំណុចនឹងខ្ពស់បំផុតដែលជាកម្រិតនៃភាពត្រជាក់និងកម្រិតនៃភាពក្តៅ ។
- ចែកកម្រិតសីតុណ្ហភាពរវាងចំណុចពីរជាប្រលោះក្រិតតូចៗហើយស្មើៗគ្នា ធ្វើយ៉ាងនេះដើម្បីឱ្យសារធាតុវាស់សីតុណ្ហភាពប្រែប្រួលទៀងទាត់ជាក់លាក់ នៅពេលដែលសីតុណ្ហភាពផ្លាស់ប្តូរ ។

## 2.1 មាត្រដ្ឋានសីតុណ្ហភាពសតភាគឬសែលស្យ៊ុស

នៅក្នុងសកលលោកសព្វថ្ងៃ គេនិយមប្រើមាត្រដ្ឋានសតភាគឬមាត្រដ្ឋានសែលស្យ៊ុស ។ ក្នុងមាត្រដ្ឋាននេះ គេយកចំណុចទឹកសុទ្ធកករលាយជាចំណុចសូន្យ (ចំណុចនឹងទាប) គេសរសេ 0°C និងចំណុចចំហាយនៃទឹកសុទ្ធពុះជាចំណុច 100°C (ចំណុចនឹងខ្ពស់បំផុត) ។

គេចែកចន្លោះពី 0 ដល់ 100 ជា 100 ប្រលោះក្រិតស្មើៗគ្នាដែលមួយប្រលោះក្រិតមានតម្លៃស្មើនឹងមួយអង្សាសែលស្យ៊ុស គេសរសេរ (1°C) ។

## 2.2 ការគណនាសីតុណ្ហភាពនៅលើមាត្រដ្ឋានសតភាគឬសែលស្យ៊ុស

ក្នុងទែម៉ូម៉ែតបារត មាឌបារតប្រែប្រួលទៅតាមសីតុណ្ហភាព ។ ដូចនេះយើងអាចវាស់បម្រែបម្រួលនៃមាឌបារតជាបម្រែបម្រួលនៃសីតុណ្ហភាពនោះ មានន័យថា យើងវាស់បម្រែបម្រួលប្រវែងនៃសសរបារត បើមុខកាត់របស់វាថេរ ។

$\ell_0$ ជានីវ៉ូនៃអង្គធាតុរាវនៅក្នុងកណ្តក់នៃទែម៉ូម៉ែតដែលកំពុងត្រាំក្នុងទឹកសុទ្ធកករលាយ (រូបទី *2.2* ក) ។ $\ell_{100}$ ជានីវ៉ូនៃអង្គធាតុរាវពេលត្រាំក្នុងចំហាយទឹកសុទ្ធកំពុងពុះ(រូបទី *2.2* ខ) ហើយ $\ell_t$ ជានីវ៉ូនៃអង្គធាតុរាវពេលដាក់នៅសីតុណ្ហភាព $t$ (រូបទី *2.2* គ) ។ គេអាចគណនាតម្លៃសីតុណ្ហភាព$t$ ដោយប្រើវិធីសមាមាត្រ (រូបទី *2.2* ឃ) ។




*រូបទី 2.2*

តាមសមាមាត្រយើងបានសមីការដូចខាងក្រោម :

$$t = \frac{\ell_t - \ell_0}{\ell_{100} - \ell_0} \times 100 \;\; (°C) \qquad (1)$$

***ឧទាហរណ៍*** **:** គេធ្វើពិសោធន៍លើទែម៉ូម៉ែតបារតមួយដោយឃើញ $\ell_0 = 5cm$ , $\ell_{100} = 25cm$ ។ តើសីតុណ្ហភាព $t$ ស្មើនឹងប៉ុន្មាន ?

ក. នៅពេល $\ell_t$ ស្មើនឹង 14cm

ខ. នៅពេល $\ell_t$ ស្មើនឹង 3cm ។

**ដំណោះស្រាយ**

ក. នៅពេល $\ell_t$ ស្មើនឹង 14cm

តាមរូបមន្ត : $t = \frac{\ell_t - \ell_0}{\ell_{100} - \ell_0} \times 100(°C)$

ដោយ : $\ell_0 = 5cm$ , $\ell_{100} = 25cm$ , $\ell_t = 14cm$

$$t = \frac{14 - 5}{25 - 5} \times 100(°C) = 45°C$$

ខ. នៅពេល $\ell_t$ ស្មើនឹង 3cm

$$t = \frac{3 - 5}{25 - 5} \times 100(°C) = -10°C$$

## 2.3 ទែម៉ូម៉ែតឧស្ម័ននិងមាត្រដ្ឋានសីតុណ្ហភាពដាច់ខាតឬកែលវិន

ចំពោះចំណុចនេះ យើងពុំបានពណ៌នាពីទែម៉ូម៉ែតឧស្ម័នទេ ។ ឥឡូវយើងប្រៀបធៀបសីតុណ្ហភាពវាស់ដោយទែម៉ូម៉ែតឧស្ម័នដែលមានឧស្ម័នផ្សេងៗគ្នាស្ថិតក្រោមសម្ពាធដើមផ្សេងៗគ្នា ។ ពិសោធន៍នេះបង្ហាញថា អំណានទែម៉ូម៉ែតសឹងតែមិនអាស្រ័យនឹងប្រភេទឧស្ម័នដែលយកមកប្រើ ។




***រូបទី*** *2.3*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

ប្រសិនបើយើងបន្លាយក្រាប (បន្ទាត់)ដូចបង្ហាញ(រូបទី 2.3) ឆ្ពោះទៅកាន់សីតុណ្ហភាពអវិជ្ជមាន (ទៅកាត់អ័ក្ស$T$) ត្រង់ចំណុចមួយដែលត្រូវគ្នានឹងចំណុច $P = 0$ នោះ យើងបានរកឃើញសីតុណ្ហភាព $T = -273.15°C$ ហើយសីតុណ្ហភាព នេះបានរកឃើញដូចៗគ្នាចំពោះឧស្ម័នទាំងអស់ ។ ធម្មតាយើងមិនអាចពិនិត្យ ឬសង្កេតលក្ខខណ្ឌសម្ពាធត្រង់ចំណុចសូន្យនេះបានទេ ព្រោះនៅសីតុណ្ហភាពដ៏ទាបនេះឧស្ម័នមិនអាចរក្សាភាពសុទ្ធរបស់វាយូរបានទេ ។ តែទោះជាយ៉ាងនេះក៏ដោយ យើងប្រើតម្លៃ $T = -273.15°C$ នេះជាតម្លៃគ្រឹះនៃមាត្រដ្ឋានសីតុណ្ហភាពដាច់ខាត ដែលចំណុចសូន្យរបស់វាស្មើនឹង $-273.15°C$ ។ ប៉ុន្តែសូន្យលើមាត្រដ្ឋាននេះហៅថា សូន្យដាច់ខាត ។ មួយប្រលោះក្រិតលើមាត្រដ្ឋានដាច់ខាតស្មើនឹងមួយប្រលោះក្រិតនៅលើមាត្រដ្ឋានសតភាគដែរ ។ ដូចនេះដើម្បីរកសីតុណ្ហភាពកែលវិនឬសីតុណ្ហភាពដាច់ខាត យើងត្រូវបន្ថែមតម្លៃ 273.15 លើតម្លៃសីតុណ្ហភាពសែលស៊ីុសនោះ ។

យើងបានរូបមន្ត : $T = t + 273.15 \Rightarrow \boxed{t = T - 273.15}$

$T$ ជាសីតុណ្ហភាពដាច់ខាតគិតជាកែលវិន (K), $t$ ជាសីតុណ្ហភាពសែលស៊ីុសគិតជា (°C) ។

ដោយសារតែចំណុចកកនិងចំណុចចំហាយពិបាកធ្វើពិសោធន៍ មាត្រដ្ឋានសីតុណ្ហភាពដាច់ខាតដែលមានមូលដ្ឋានលើចំណុចលំនឹងមួយបានអនុម័តក្នុងឆ្នាំ 1954 ដោយគណៈកម្មការអន្តរជាតិស្តីពីរង្វាស់និងទម្ងន់ ។ទិន្នន័យនៃចំណុចនឹងដែលទាក់ទងជាមួយសារធាតុមួយចំនួនដូចបង្ហាញក្នុងតារាងខាងក្រោមត្រូវបានគេជ្រើសរើសយក " ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក " (Triple point of water) ជាសីតុណ្ហភាពយោងសម្រាប់មាត្រដ្ឋានថ្មីនេះ ។

ចំណុចនឹងរួមមួយនៃភាពទាំងបីរបស់ទឹក ជាចំណុចប្រសព្វមួយនៃសីតុណ្ហភាពនិងសម្ពាធដែលភាពទាំងបី (រឹង រាវ និងឧស្ម័ន) មានលំនឹងរួមគ្នា ។ ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹកនេះកើតឡើងត្រង់សីតុណ្ហភាពប្រហែល 0.01°C និងសម្ពាធ 4.58mmHg ។ នៅលើមាត្រដ្ឋានថ្មីដែលប្រើខ្នាតកែលវិន នោះសីតុណ្ហភាពទឹកត្រង់ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹកគឺ 273.16K ។

**សម្គាល់ :** ចំពោះខ្នាតកែលវិនពុំមានសញ្ញាអង្សាទេ (°) ។ មាត្រដ្ឋានសីតុណ្ហភាពដាច់ខាតចាស់គឺផ្អែកលើចំណុចកកនិងចំណុចចំហាយរបស់ទឹក ។ ចំណែកឯមាត្រដ្ឋានសីតុណ្ហភាពថ្មីនេះផ្អែកលើចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក ។ ប៉ុន្តែមាត្រដ្ឋានទាំងពីរនេះមានតម្លៃសឹងតែស្មើគ្នា ។ មាត្រដ្ឋានសីតុណ្ហភាពដាច់ខាតថ្មីនេះ គេហៅផងដែរថា មាត្រដ្ឋានកែលវិនដែលប្រើខ្នាតសីតុណ្ហភាពដាច់ខាតក្នុងប្រព័ន្ធ SI គឺកែលវិន(K)ត្រូវកំណត់ដោយ$\frac{1}{273.16}$ នៃផលសងរវាងសូន្យដាច់ខាតនិងសីតុណ្ហភាពរបស់ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក ។

## តារាងចំណុចលំនឹងនៃសីតុណ្ហភាព

| ចំណុចលំនឹង | សីតុណ្ហភាព (°C) | សីតុណ្ហភាព K |
|---|---|---|
| • ចំណុចនឹងមួយនៃភាពទាំងបីរបស់អ៊ីដ្រូសែន | –259.34 | 13.81 |
| • ចំណុចរំពុះរបស់អ៊ីដ្រូសែន | –252.87 | 20.28 |
| • ចំណុចនឹងមួយនៃភាពទាំងបីរបស់ណេអុង | –246.048 | 27.102 |
| • ចំណុចនឹងមួយនៃភាពទាំងបីរបស់អុកស៊ីសែន | –218.789 | 54.361 |
| • ចំណុចរំពុះរបស់អុកស៊ីសែន | –182.962 | 90.188 |
| • ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក | 0.01 | 273.16 |
| • ចំណុចរំពុះរបស់ទឹក | 100.00 | 373.15 |

***ឧទាហរណ៍ទី1*** : ចូរកំណត់សីតុណ្ហភាពកែលវិនដែលត្រូវនឹង –10°C , 0°C , 100°C ។

**ដំណោះស្រាយ**

- បើសីតុណ្ហភាពសតភាគ (សែលស៊្យុស) $t = -10°C$

  សីតុណ្ហភាពដាច់ខាតគឺ : $T = t + 273 = -10 + 273 = 263K$
- បើសីតុណ្ហភាពសតភាគ (សែលស៊្យុស) $t = 0$

  សីតុណ្ហភាពដាច់ខាតគឺ : $T = 0 + 273 = 273K$
- បើសីតុណ្ហភាពសតភាគ (សែលស៊្យុស) $t = 100$

  សីតុណ្ហភាពដាច់ខាតគឺ : $T = 100 + 273 = 373K$ ។

***ឧទាហរណ៍ទី2*** **:** នៅថ្ងៃមួយសីតុណ្ហភាពឡើងដល់ 40°C តើនៅក្នុងមាត្រដ្ឋានសីតុណ្ហភាពកែលវិនស្មើនឹងប៉ុន្មាន ?

**ដំណោះស្រាយ**

គេមាន $t = 40°C$

តាមរូបមន្ត : $T = t + 273$

ដូចនេះសីតុណ្ហភាពកែលវិនគឺ : $T = 40 + 273K$

ដូច្នេះ $T = 313K$ ។

## មេរៀនសង្ខេប

- កម្រិតក្តៅឬកម្រិតត្រជាក់នៃអង្គធាតុមួយត្រូវបានគេហៅថា សីតុណ្ហភាព ។
- កម្តៅគឺជាបរិមាណកម្តៅដែលផ្ទេរពីអង្គធាតុក្តៅទៅអង្គធាតុត្រជាក់ជាង ។
- ដើម្បីគណនាសីតុណ្ហភាពនៅលើមាត្រដ្ឋានសតភាគត្រូវអនុវត្តតាមទំនាក់ទំនង

$$t(°\text{C}) = \frac{\ell_t - \ell_0}{\ell_{100} - \ell_0} \times 100$$ ។

- មាត្រដ្ឋានកែលវិន $T = t + 273.15$ ។
- ចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក(រឹង រាវ និងឧស្ម័ន) ជាចំណុចប្រសព្វមួយនៃសីតុណ្ហភាព និងសម្ពាធដែលភាពទាំងបីនេះមានលំនឹងរួមគ្នា ។

## សំណួរនិងលំហាត់

1. តើអ្វីទៅជាសីតុណ្ហភាព ? អ្វីទៅជាកម្តៅ ?
2. តើអ្វីជាចំណុចនឹងមួយនៃភាពទាំងបីរបស់ទឹក (Triple point of water) ?
3. តើសូន្យដាច់ខាតមានន័យដូចម្តេច ?
4. ចូរសរសេរសមីការទូទៅរបស់សីតុណ្ហភាពសម្រាប់មាត្រដ្ឋានសតភាគ ។
5. ចូរសរសេរសមីការបង្ហាញពីទំនាក់ទំនងមាត្រដ្ឋានសតភាគនិងមាត្រដ្ឋានកែលវិន ។
6. គណនាសីតុណ្ហភាពដាច់ខាតដែលត្រូវនឹង –5°C , 3°C , 20°C , 60°C ។
7. កុមារម្នាក់គ្រុនក្តៅមានសីតុណ្ហភាព 40°C ។ គណនាសីតុណ្ហភាពដាច់ខាតរបស់កុមារនោះ ។
8. នៅប្រទេសកម្ពុជាក្នុងឆ្នាំមួយនោះសីតុណ្ហភាពធ្លាក់ចុះដល់ 16°C ។ ចូរគិតជាសីតុណ្ហភាពកែលវិន ។
9. នាពាក់កណ្តាលរដូវរងា នៅមហាសមុទ្រអង់តាក់ទិចសីតុណ្ហភាពមានតម្លៃ 186K ។ ចូរគិតសីតុណ្ហភាពនេះជាសែលស៊ីស ។
10. ទែម៉ូម៉ែតបារតមួយត្រូវបានដាក់ចូលទៅក្នុងតម្រាំទឹកកកដែលចាប់ផ្តើមរលាយ ពេលនោះបារតលូតបានប្រវែង 25mm ។ នៅពេលគេដាក់ទែម៉ូម៉ែតចូលក្នុងទឹកកំពុងពុះដែលចំហាយស្ថិតក្រោមសម្ពាធ 1atm ពេលនោះបារតលូតបានប្រវែង 200mm ។ គណនាសីតុណ្ហភាព $t$ នៅពេលដែលបារតមានប្រវែង 95mm ។

មេរៀនទី

# 2 ទ្រឹស្តីស៊ីនេទិចនៃរូបធាតុ

**ចប់មេរៀននេះ សិស្សអាច**

❒ ពណ៌នាពីភាពទាំងបីនៃរូបធាតុនិងទម្រង់របស់វា ។

❒ ពណ៌នាពីចលនានៃម៉ូលេគុល ។

## 1. ភាពនៃរូបធាតុ

ក្នុងមេរៀននេះយើងបានសិក្សារួចម្ដងមកហើយ ដូច្នេះយើងគ្រាន់តែរំលឹកពីលក្ខណៈនៃភាពផ្សេងៗគ្នារបស់រូបធាតុប៉ុណ្ណោះ ។

| ភាពនៃរូបធាតុ | លក្ខណៈ |
|---|---|
|  ភាពរឹង (ទឹកកក) | - រូបរាងនិងមាឌថេរ(ច្បាស់លាស់ ជាក់លាក់)<br>- ជាធម្មតាមានភាពរឹងហើយមាំ<br>- ត្រូវការកម្លាំងធំដើម្បីប្តូររូបរាង<br>- ម៉ាសមាឌធំ<br>- មិនអាចបណ្ណែនបាន |
|  ភាពរាវ (ទឹក) | - រូបរាងមិនកំណត់តែមាឌថេរ<br>- ម៉ាសមាឌធំ<br>- មិនអាចបណ្ណែនបាន |
|  ភាពជាឧស្ម័ន(ខ្យល់) | - រូបរាងនិងមាឌប្រែប្រួលមិនកំណត់<br>- ម៉ាសមាឌតូច<br>- អាចបណ្ណែនបាន |

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 2. គំរូម៉ូលេគុលស៊ីនេទិចនៃរូបធាតុ

យើងដឹងហើយថា រូបធាតុទាំងអស់ផ្សំឡើងពីភាគល្អិតតូចៗជាច្រើន ហៅថា អាតូមឬក្រុមអាតូមចងសម្ព័ន្ធគ្នា ហៅថា ម៉ូលេគុល ។ ក្នុងអង្គធាតុសុទ្ធម៉ូលេគុលដូចគ្នាទាំងអស់ ។ ដូចនេះ ម៉ូលេគុលនៃរូបធាតុមួយជាភាគល្អិតតូចបំផុតនៃរូបធាតុនោះ ដែលអាចស្ថិតនៅជាភាពសេរីដោយគ្មានបាត់លក្ខណៈសម្គាល់នៃរូបធាតុទេ ។ ម៉ូលេគុលទាំងអស់នេះធ្វើចលនាដោយឥតសណ្តាប់ធ្នាប់ នេះគឺជាគំរូម៉ូលេគុលស៊ីនេទិចនៃរូបធាតុ ។ ពាក្យស៊ីនេទិចនេះជាភាសាក្រិចមានន័យថា “ធ្វើចលនា” ដូចនេះ យើងសិក្សាចលនាម៉ូលេគុលនៃរូបធាតុដោយប្រើគំរូម៉ូលេគុលស៊ីនេទិចតាមតារាងប្រៀបធៀបខាងក្រោម :

| ភាពនៃរូបធាតុ | ការតម្រៀបនៃភាគល្អិត | ចលនានៃភាគល្អិត |
|---|---|---|
|  គំរូម៉ូលេគុលនៃអង្គធាតុរឹង | -ចងសម្ព័ន្ធយ៉ាងមាំនិងស្ថិតនៅជិតគ្នាបំផុតយ៉ាងទៀងទាត់ ។ នេះគឺសម្រាប់អង្គធាតុរឹងដែលមានម៉ាសមាឌធំ ។ | - រញ្ជួយតិចៗឥតឈប់ឈរសងខាងទីតាំងលំនឹងភ្ជាប់គ្នាដោយសម្ព័ន្ធអន្តរម៉ូលេគុល ។នេះពន្យល់ថាអង្គធាតុរឹងមានមាឌនិងរាងជាក់លាក់ ។ |
|  គំរូម៉ូលេគុលនៃអង្គធាតុរាវ | - ផ្តុំគ្នាជាក្រុមៗបង្កើតបានជាម៉ូលេគុលដែលនៅឃ្លាតពីគ្នាជាងម៉ូលេគុលអង្គធាតុរឹងនេះពន្យល់ពីអង្គធាតុរាវមានម៉ាសមាឌធំនិងមានទំនោរដើម្បីបង្កើតជាតំណក់ទឹក ។ | -ក្រុមម៉ូលេគុលនីមួយៗធ្វើចលនាដោយសេរី ហើយអាចរមៀលលើគ្នាបាន ប៉ុន្តែចលនានេះគឺស្ថិតក្នុងដែនកំណត់នៃឧបករណ៍ដែលផ្ទុកវា ។ នេះជាមូលហេតុធ្វើអោយវាមានមាឌមិនប្រែប្រួលនិងដូចមាឌរបស់អង្គធាតុដែលផ្ទុកវា ។ |
|  គំរូម៉ូលេគុលនៃឧស្ម័ន | - ម៉ូលេគុលរបស់វានៅឆ្ងាយពីគ្នា មានរាងនិងមាឌមិនច្បាស់លាស់ ហើយប្រែប្រួលទៅតាមវត្ថុនិងលំហដែលវាតាំងនៅ ។ នេះសម្រាប់ឧស្ម័នដែលមានម៉ាសមាឌតូច ។ | - ម៉ូលេគុលនៃឧស្ម័នមានចលនារញ្ជួយយ៉ាងខ្លាំងឥតឈប់ឈរគ្មានសណ្តាប់ធ្នាប់ ។ ដោយសារគម្លាតឆ្ងាយនៃម៉ូលេគុលនេះកម្លាំងទាញចូលរវាងម៉ូលេគុលសឹងតែគ្មាន ។ នេះពន្យល់ពីមូលហេតុដែលឧស្ម័នមានមាឌនិងរាងមិនជាក់លាក់ហើយអាចបណ្តែនបាន ។ |

## 3. ភស្តុតាងចលនាម៉ូលេគុល

យើងបានដឹងថា នៅចន្លោះម៉ូលេគុលមានលំហជានិច្ច ទោះបីមានអំពើនៃកម្លាំងផ្សេងៗក៏ដោយ ។ ម៉ូលេគុលនៃអង្គធាតុរាវនិងឧស្ម័នមានកម្លាំងទំនាញចូល(កម្លាំងបញ្ចាប់)ខ្សោយ ។ ដូច្នេះបាតុភូតបន្សាយនៃម៉ូលេគុលកើតឡើងយ៉ាងរហ័សចំពោះអង្គធាតុទាំងពីរនេះ ។ បាតុភូតបន្សាយនេះ គឺបញ្ជាក់ពីចលនារបស់ម៉ូលេគុល ប៉ុន្តែយើងពុំបានលើកយកមកសិក្សាក្នុងមេរៀននេះទេ ព្រោះបានសិក្សានៅថ្នាក់ក្រោមរួចមកហើយ ។ ហេតុនេះយើងលើកយកតែចលនាប្រោនមកសិក្សា ដើម្បីបញ្ជាក់ពីភស្តុតាងចលនានៃម៉ូលេគុលតែប៉ុណ្ណោះ ។

### ពិសោធន៍ចលនាប្រោន

1. **វត្ថុបំណង** :បង្ហាញឱ្យឃើញច្បាស់ថា ម៉ូលេគុលនៃអង្គធាតុមានចលនាឥតឈប់ឈរ ។
2. **សម្ភារៈពិសោធ** :មីក្រូទស្សន៍ បន្ទះឡាម ឡាមែល (Cover glass) ទឹកដោះគោនៅមួយកំប៉ុង ឬមួយកញ្ចប់ ទឹកមួយពែង ។
3. **ដំណើរការពិសោធ**

- ដំឡើងឧបករណ៍ដូចក្នុងរូប ។
- យកបំពង់បឺតជ្រលក់ក្នុងកំប៉ុងទឹកដោះគោនៅ លៃយ៉ាងណាឱ្យបានជាប់ទឹកដោះគោមួយតំណក់ រួចយកទៅពាសឱ្យបានស្តើងលើបន្ទះកែវថ្លា ។
- យកទឹកមួយតំណក់មកដាក់លាយនឹងទឹកដោះគោដែលមាននៅលើបន្ទះកែវស្រាប់ ។



*រូបទី 2.4 ពិនិត្យចលនាប្រោន*

- យកបន្ទះឡាមែលគ្របពីលើល្បាយទឹកដោះគោនិងទឹកដូចរូប រួចយកទៅពិនិត្យនឹងមីក្រូទស្សន៍ ។
- កែតម្រូវមីក្រូទស្សន៍យ៉ាងណាឱ្យមើលឃើញម៉ូលេគុលនៃល្បាយបានច្បាស់ ។

## 4. សំណួរពិភាក្សា

- តាមរយៈមីក្រូទស្សន៍ តើអ្នកសង្កេតឃើញអ្វី ?
- តើម៉ូលេគុលនៃល្បាយមានចលនាដែរឬទេ ?

## 5. សន្និដ្ឋាន

តាមការសង្កេត យើងឃើញមានចំណុចខ្មៅតូចៗដែលមានចលនារញ្ជួយនិងរំកិលផងហើយផ្លាស់ទីឥតសណ្តាប់ធ្នាប់ ។ ចំណុចខ្មៅតូចៗនេះ យើងសន្និដ្ឋានថា ជាម៉ូលេគុលនៃល្បាយ ។

លទ្ធផលដែលយើងទទួលបាននេះជាភស្តុតាងនៃចលនារបស់ម៉ូលេគុល ។

### មេរៀនសង្ខេប

- រូបធាតុមានភាពបីគឺ រឹង រាវ និងឧស្ម័ន ។
- ម៉ូលេគុលអង្គធាតុរឹងមានចលនារញ្ជួយតិចសងខាងទីតាំងលំនឹង ។
- ម៉ូលេគុលអង្គធាតុរាវមានចលនាដោយសេរីហើយអាចរមៀលលើគ្នាបាន ។
- ម៉ូលេគុលឧស្ម័ន ធ្វើចលនារញ្ជួយយ៉ាងខ្លាំងឥតឈប់ឈរនិងគ្មានសណ្តាប់ធ្នាប់ ។
- លទ្ធផលពិសោធន៍ចលនាប្រោនផ្តល់នូវភស្តុតាងចលនានៃម៉ូលេគុល ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថា ទ្រឹស្តីស៊ីនេទិចនៃម៉ូលេគុល ?
2. តើការបំបែករូបធាតុមួយជាភាគល្អិតមានព្រំដែនដែរឬទេ ?
3. ចូរពន្យល់ពីមូលហេតុអង្គធាតុរឹងមានមាឌនិងរាងជាក់លាក់ ។
4. ចូរពន្យល់ពីមូលហេតុឧស្ម័នមានមាឌនិងរាងមិនកំណត់ ។
5. ចូរពណ៌នាពីការតម្រៀបម៉ូលេគុលនៃភាពទាំងបីរបស់រូបធាតុ ។

មេរៀនទី

# 3 កម្ដៅ

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពន្យល់ពីកម្ដៅបានយ៉ាងក្បោះក្បាយនិងត្រឹមត្រូវ ។
- ❒ កំណត់និយមន័យចំណុះកម្ដៅនិងកម្ដៅម៉ាសព្រមទាំងអាចគណនាលំហាត់ដោយប្រើរូបមន្ត $Q = mc\Delta T$ ។
- ❒ ពណ៌នាពី រលាយ កំណក រំពុះ និងកំណញើស ។
- ❒ គណនាកម្ដៅឡាតង់រលាយនិងកម្ដៅឡាតង់បង្ហួតដោយប្រើរូបមន្ត: $L_f = \ell_f \times m$ , $L_v = \ell_v \times m$ ។

## 1. កម្ដៅ

នៅក្នុងមេរៀនកម្ដៅនិងសីតុណ្ហភាព យើងដឹងថាកម្ដៅជាថាមពលដែលបានផ្ទេរពីអង្គធាតុក្ដៅទៅអង្គធាតុដែលត្រជាក់ជាង ។ ជាការពិតណាស់ ពេលយើងដាំទឹក គឺយើងកំពុងផ្ដល់ថាមពលកម្ដៅទៅឱ្យទឹក ហើយថាមពលដែលយើងផ្ដល់នោះវាមិនបានបាត់បង់ទេ គឺគ្រាន់តែបំប្លែងទៅជាថាមពលផ្សេងៗទៀត ។ ក្នុងករណីនេះ ថាមពលកម្ដៅដែលផ្ដល់ឱ្យទឹកត្រូវបំប្លែងជាថាមពលក្នុងរបស់ម៉ូលេគុលទឹក ។ ថាមពលកម្ដៅក្នុងនេះមានទម្រង់ពីរ គឺថាមពលប៉ូតង់ស្យែលនិងថាមពលស៊ីនេទិច ។ ដូច្នេះ ថាមពលកម្ដៅជារង្វាស់បម្រែបម្រួលថាមពលក្នុងសរុបរបស់អង្គធាតុ ។

## 2. ចំណុះកម្ដៅ

ប្រសិនបើយើងកម្ដៅទឹក 100g និង 1000g ពីសីតុណ្ហភាព 30°C ដល់ 60°C ដោយប្រើប្រភពកម្ដៅដូចគ្នា(ប្រភពកម្ដៅតែមួយ) យើងនឹងឃើញថាទឹកដែលមានម៉ាស 1000g ត្រូវការបរិមាណកំដៅ 10 ដងធំជាងទឹកដែលមានម៉ាស 100g ដើម្បីឱ្យវាមានសីតុណ្ហភាពដូចគ្នា ។




*រូបទី* 2.5

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

តាមលំនាំនៃពិសោធន៍បង្ហាញថា បរិមាណកម្តៅចាំបាច់សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាពនៃអង្គធាតុមួយ គឺអាស្រ័យនឹងម៉ាសនៃអង្គធាតុនោះ ។ នេះហៅថាចំណុះកម្តៅ ។

ដូច្នេះ ចំណុះកម្តៅជាបរិមាណកម្តៅចាំបាច់សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាព 1K ឬ 1°C នៃអង្គធាតុមួយ ។ និមិត្តសញ្ញាចំណុះកម្តៅតាងដោយ $C$ ហើយមានខ្នាតគិតជាស៊ូលក្នុងមួយកែលវិន (J/K) ឬស៊ូលក្នុងមួយអង្សាសែលស៊ីុស J/°C ។ ដូច្នេះយើងអាចនិយាយថាទឹក 1000g មានចំណុះកម្តៅធំជាងទឹក 100g 10 ដង ។

តាមគណិតវិទ្យាយើងអាចបង្ហាញកន្សោមចំណុះកម្តៅដូចខាងក្រោម :

$$C = \frac{Q}{\Delta T}$$

$C$ ចំណុះកម្តៅគិតជា (J/K) ឬ (J/°C) , $Q$ បរិមាណកម្តៅដែលទឹកស្រូបឬបញ្ចេញគិតជា (J) និង $\Delta T$ បម្រែបម្រួលសីតុណ្ហភាពគិតជា (K) ឬ (°C) ។

***ឧទាហរណ៍ 1 :*** ក្នុងពិសោធន៍ទឹក100g ត្រូវការបរិមាណកម្តៅ 12600J ដើម្បីបង្កើនសីតុណ្ហភាពពី 30°C ទៅ 60°C ។ គណនា

ក. ចំណុះកម្តៅរបស់ទឹកដែលមានម៉ាស 100g ។

ខ. ចំណុះកម្តៅរបស់ទឹកដែលមានម៉ាស 1000g ។

គ. បរិមាណកម្តៅដែលទឹក 100g ស្រូបយក ដើម្បីដំឡើងសីតុណ្ហភាពពី 30°C ទៅ 40°C ។

**✍ ដំណោះស្រាយ**

ក. គណនាចំណុះកម្តៅរបស់ទឹក

តាមរូបមន្ត $C = \frac{Q}{\Delta T}$ ដោយបរិមាណកម្តៅផ្តល់ឱ្យ $Q = 12600\text{J}$ និង

កំណើនសីតុណ្ហភាព $\Delta T = 60°C - 30°C = 30°C$

ដូចនេះ ចំណុះកម្តៅរបស់ទឹក $C = \frac{12600}{30} = 420\text{J}/°C$ ។

ខ. យើងដឹងថាទឹក 1000g ស្មើនឹង 10 ដងនៃម៉ាសទឹក 100g ដូច្នេះចំណុះកម្តៅទឹក 1000g គឺ $10 \times C$ ចំណុះកម្តៅនៃទឹក 100g ស្មើនឹង $10 \times 420\text{J}/°C = 4200\text{J}/°C$ ។

គ. តាមរូបមន្ត : $C = \frac{Q}{\Delta T} \Rightarrow Q = C\Delta T$

អនុវត្តជាលេខ $C = 420\text{J}/°C$ , $\Delta T = 40°C - 30°C$

$$Q = 420 \times 10 = 4200\text{J} ។$$

***ឧទាហរណ៍ 2*** :ស្ព័សំណមួយត្រូវការបរិមាណកម្ដៅ $1.152\times10^5$J ដើម្បីដំឡើងសីតុណ្ហភាព ពី 25°C ទៅ 61°C ។ តើស្ព័សំណនោះមានចំណុះកម្ដៅស្មើនឹងប៉ុន្មាន ?

**ដំណោះស្រាយ**

បរិមាណកម្ដៅផ្ដល់ឱ្យ $Q = 1.152\times10^5\text{J}$

បម្រែបម្រួលសីតុណ្ហភាព $\Delta T = 61°\text{C} - 25°\text{C} = 36°\text{C}$

តាមរូបមន្ត $C = \dfrac{Q}{\Delta T}$

អនុវត្តជាលេខ $C = \dfrac{1.152\times10^5\text{J}}{36°\text{C}} = 3.2\times10^3\text{J}/°\text{C}$ ។

ដូច្នេះ អង្គធាតុផ្សេងគ្នាមានចំណុះកម្ដៅផ្សេងគ្នាដែរ ។

## 2.1 កម្ដៅម៉ាស

**និយមន័យ** : កម្ដៅម៉ាសនៃអងគ្គធាតុរឹងឬរាវ ជាបរិមាណកម្ដៅចាំបាច់ដែលត្រូវផ្ដល់ឱ្យអង្គធាតុ 1kg ដើម្បីដំឡើងសីតុណ្ហភាពវា 1K ឬ 1°C ។

គេតាងនិមិត្តសញ្ញាកម្ដៅម៉ាសដោយ **c** ដែលមានរូបមន្ត :

$$c = \frac{C}{m} = \frac{1}{m}\left(\frac{Q}{\Delta T}\right)$$

$c$ កម្ដៅម៉ាសគិតជា (J/kg · °C)

$C$ ចំណុះកម្ដៅគិតជា (J/K) ឬ (J/°C)

$m$ ម៉ាសសារធាតុគិតជា (kg)

$Q$ បរិមាណកម្ដៅដែលទឹកស្រូបបានគិតជា (J)

$\Delta T$ បម្រែបម្រួលសីតុណ្ហភាពគិតជា (K) ឬ (°C) ។

តាមរូបមន្តនេះ $c = \dfrac{C}{m} = \dfrac{1}{m}\left(\dfrac{Q}{\Delta T}\right)$ (ដោយ $C = mc$ )

យើងអាចសរសេរ : $\boxed{Q = m\times c\times\Delta T}$ ។

***សម្គាល់*** : $\Delta T$ ត្រូវតែវិជ្ជមាន ព្រោះកម្ដៅបានផ្ទេរពីតំបន់ដែលមានសីតុណ្ហភាពខ្ពស់ទៅតំបន់ដែលមានសីតុណ្ហភាពទាប ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

### តារាងកម្តៅម៉ាសនៃសារធាតុខ្លះៗ

| សារធាតុ | កម្តៅម៉ាស$(J/kg\cdot°C)$ | សារធាតុ | កម្តៅម៉ាស $(J/kg\cdot°C)$ |
|---|---|---|---|
| សំណ | $1.3\times10^2$ | ដែក | $4.7\times10^2$ |
| បារត | $1.4\times10^2$ | អាលុយមីញ៉ូម | $9.1\times10^2$ |
| ស័ង្កសី | $3.8\times10^2$ | សូដ្យូម | $1.23\times10^3$ |
| កែវ (មកុដ) | $8.4\times10^2$ | ទឹកកក $-10°C$ | $2.22\times10^3$ |
| ទង់ដែង | $4\times10^2$ | ទឹក | $4.19\times10^3$ |

នៅពេលយើងនិយាយថា កម្តៅម៉ាសទឹក $c = 4200(J/kg\cdot°C)$ មានន័យថា ដើម្បីបង្កើនសីតុណ្ហភាពទឹក 1kg ឱ្យបាន 1°C វាត្រូវការកម្តៅ 4200J ។ ប៉ុន្តែបើយើងផ្តល់កម្តៅ 4200J ទៅឱ្យទង់ដែង 1kg នោះវាកើនសីតុណ្ហភាពបាន $\Delta T = \dfrac{Q}{mc} = \dfrac{4200}{1\times400} = 10.5°C$ ។

តាមការប្រៀបធៀបនេះយើងអាចសន្និដ្ឋានបានថា សារធាតុដែលមានកម្តៅម៉ាសតូចជាងកើនសីតុណ្ហភាពលឿនជាងសារធាតុដែលមានកម្តៅម៉ាសធំជាងប្រសិនបើកម្តៅផ្តល់ឱ្យស្មើគ្នា។

***ឧទាហរណ៍ :*** ឧបករណ៍បំភាយកម្តៅអគ្គិសនីមួយបានផ្តល់អានុភាព 50W ឱ្យដុំលោហៈដែលមានម៉ាស 0.60kg ដើម្បីបង្កើនសីតុណ្ហភាព 20°C ទៅ 45°C ក្នុងរយៈពេល 90s ។ គណនាកម្តៅម៉ាសរបស់ដុំលោហៈនោះ ។

**✍ ដំណោះស្រាយ**

យើងសន្មតថា បរិមាណកម្តៅដែលផ្តល់ឱ្យត្រូវបានដុំលោហៈស្រូបយកទាំងអស់

តាមសម្មតិកម្មយើងបាន

$P = 50W$ , $\Delta T = 45°C - 20°C = 25°C$ , $t = 90s$ និង $m = 0.60kg$

កម្តៅផ្តល់ដោយឧបករណ៍បំភាយកម្តៅ : $P\times t = 50\times90 = 4500J$

កម្តៅស្រូបដោយដុំលោហៈ : $Q = mc\Delta T$

តាមការសន្មតយើងបាន :កម្តៅផ្តល់ដោយឧបករណ៍បំភាយកម្តៅ= កម្តៅស្រូបដោយដុំលោហៈ

យើងបាន $Pt = mc\Delta T \Rightarrow c = \dfrac{Pt}{m\Delta T}$ ឬ $c = \dfrac{4500}{0.60\times25} = 300J/kg\cdot°C$

ដូចនេះកម្តៅម៉ាសដុំលោហៈស្មើនឹង $300J/kg\cdot°C$ ។

## 3. រលាយ កំណក រំពុះ កំណជាញើស និងរំហួត

### 3.1 រលាយនិងកំណក

យើងបានសិក្សាពីថ្នាក់មុនម្តងរួចមកហើយ ដូច្នេះយើងគ្រាន់តែរំលឹកឡើងវិញខ្លះៗ ។ ក្នុងមេរៀននេះយើងនឹងសិក្សាស៊ីជម្រៅនៅថ្នាក់ទី 11 ។

#### ក. រលាយ

ពេលដែលអង្គធាតុរឹងមួយកំពុងផ្លាស់ប្តូរភាពពីរឹងទៅរាវ យើងហៅលក្ខណៈបំលាស់ប្តូរនេះថា **ការរលាយ** ។ ចំពោះសារធាតុសុទ្ធរលាយកើតឡើងនៅសីតុណ្ហភាពកំណត់មួយ ។ សីតុណ្ហភាពកំណត់នេះជាចំណុចរលាយនៃសារធាតុ ។

តារាងចំណុចរលាយនៃសារធាតុខ្លះៗ



*រូបទី 2.6*

| សារធាតុ | ចំណុចរលាយ(°C) |
|---|---|
| អ៊ីដ្រូសែន | –259 |
| អុកស៊ីសែន | –218 |
| អេទីលអាល់កុល | –117 |
| បារត | –39 |
| ទឹកកក | 0 |

| សារធាតុ | ចំណុចរលាយ(°C) |
|---|---|
| ផូស្វរ | 44 |
| ស្ពាន់ធ័រ | 114 |
| សំណប៉ាហាំង | 232 |
| សំណ | 327 |
| សង្កសី | 420 |
| អាលុយមីញ៉ូម | 660 |
| ប្រាក់ | 960 |
| មាស | 160 |
| ទង់ដែង | 1080 |
| តង់ស្តែន | 3370 |

## ពិសោធន៍កំណត់ចំណុចរលាយ

**1. វត្ថុបំណង :** កំណត់ចំណុចរលាយរបស់ទឹកកកនិងសិក្សាពីបម្រែបម្រួលសីតុណ្ហភាពពេលទឹកកករលាយ ។

**2. សំភារៈពិសោធន៍ :** ដុំទឹកកកនៅសីតុណ្ហភាព $-5°C$ ទែម៉ូម៉ែត ជើងទម្រ ចង្ក្រានហ្គាស បំពង់កែវ ក្រូណូម៉ែត ។

**3. ដំណើរការពិសោធ**

- យកដុំទឹកកកមកបំបែកជាដុំតូចៗ រួចដាក់ចូលក្នុងបំពង់កែវ ។
- ដាក់ទែម៉ូម៉ែតថ្មមៗចូលទៅក្នុងកំទេចទឹកកករហូតដល់វាមានលំនឹង ប៉ុន្តែធ្វើយ៉ាងណាកុំឱ្យប៉ះនឹងបំពង់កែវ ។
- វាស់សីតុណ្ហភាពដើមរបស់ទឹកកក ហើយចាប់ផ្តើមដុតកម្តៅបំពង់កែវដោយចង្ក្រានហ្គាស ។
- វាស់សីតុណ្ហភាពមួយនាទីម្តងៗរហូតដល់ទឹកកករលាយអស់និងសីតុណ្ហភាពឡើងដល់ $20°C$ ។




*រូបទី 2.7*

- សង់ក្រាបតាង(សីតុណ្ហភាព-ពេល) រួចរកចំណុចរលាយរបស់ទឹកកក ។

**4. លទ្ធផលពិសោធន៍ :** យើងទទួលបានក្រាបដូចខាងក្រោម :




*រូបទី 2.8*

## 5. សន្និដ្ឋាន

តាមក្រាបយើងសង្កេតឃើញថា ៖

- សីតុណ្ហភាពនៃទឹកកក (រឹង) កើនឡើងពី –5°C ទៅ 0°C ដូចបង្ហាញតាមខ្សែត្រង់ *AB* គឺមានបម្រែបម្រួលសីតុណ្ហភាព ។
- នៅសីតុណ្ហភាព 0°C ទឹកកករលាយតាងដោយខ្សែត្រង់ *BC* ទឹកកករលាយដោយសារវាស្រូបកម្តៅ ។ ក្នុងរយៈពេលរលាយគ្មានបម្រែបម្រួលសីតុណ្ហភាព ។




*រូបទី 2.9*

- ពេលទឹកកករលាយអស់សីតុណ្ហភាពទឹក (រាវ) កើនឡើងពី 0°C ទៅ 20°C តាងដោយខ្សែត្រង់ *CD* ។ តាមការពិសោធនេះយើងអាចកំណត់បានចំណុចរលាយរបស់ទឹកកកគឺ 0°C ។ ក្នុងកំឡុងពេលទឹកកករលាយពីភាពរឹងទៅភាពរាវគ្មានបម្រែបម្រួលសីតុណ្ហភាពទេ ទោះបីយើងនៅតែដុតកម្តៅទៀតក៏ដោយ ។ តើកម្តៅនោះបាត់ទៅណា ? សំណួរនេះយើងអាចបកស្រាយតាមគំរូម៉ូលេគុលស៊ីនេទិចនៃរូបធាតុ ។
- ក្នុងកំឡុងពេលទឹកកក (អង្គធាតុរឹង)រលាយថាមពលកម្តៅដែលផ្តល់ឱ្យពុំបានដំឡើងសីតុណ្ហភាពទេ ព្រោះទឹកកក (អង្គធាតុរឹង) ត្រូវស្រូបយកកម្តៅនោះដើម្បីធ្វើកម្មន្តក្នុងការបំបែកសម្ព័ន្ធអន្តរម៉ូលេគុលនៃអង្គធាតុរឹង ។




*រូបទី 2.10*

- នៅពេលម៉ូលេគុលមានថាមពលគ្រប់គ្រាន់ក៏ផ្តាច់ខ្លួនចេញពីសម្ព័ន្ធអន្តរម៉ូលេគុល ហើយអាចធ្វើចលនាចេញពីទីតាំងលំនឹងដើមរបស់វា ។ យើងនិយាយថាអង្គធាតុរឹងបានរលាយ ។ កម្តៅដែលអង្គធាតុស្រូបដោយគ្មានការផ្លាស់ប្តូរសីតុណ្ហភាពហៅថា កម្តៅឡាតង់រលាយ ។

## ខ. កំណក

ដំណើរផ្លាស់ប្តូរភាពពីរាវទៅរឹងហៅថា **កំណក** ។ តាមច្បាប់រលាយនិងកំណកបានចែងថា ក្រោមសំពាធដដែលសីតុណ្ហភាពរលាយដូចគ្នានិងសីតុណ្ហភាពកំណក ។ ឧទាហរណ៍ : ទឹកចាប់ផ្តើមកក នៅសីតុណ្ហភាព 0°C ហើយវាចាប់ផ្តើមរលាយវិញក៏នៅសីតុណ្ហភាព 0°C ដែរ ។

យើងយកណាប់តាលីន (ថ្នាំកន្លាត)ដាក់ក្នុងបំពង់គ្រិតប្រហែល 1/3 នៃជម្រៅបំពង់ រួចកៀប បំពង់គ្រិតទៅនឹងជើងទម្រនិងត្រាំបំពង់នេះក្នុងកែវទឹកដែលកំពុងដាំរហូតដល់ណាប់តាលីនរលាយ អស់ ។ យើងដាក់ទែម៉ូម៉ែតចូលក្នុងបំពង់ ហើយពេលសីតុណ្ហភាពណាប់តាលីនឡើងដល់ 90°C យក បំពង់ណាប់តាលីនដែលមានទែម៉ូម៉ែតក្នុងនោះចេញពីកែវទឹកក្តៅហើយយកទៅត្រាំក្នុងកែវទឹកត្រជាក់ វិញម្តង រួចចាប់ផ្តើមកត់ត្រាសីតុណ្ហភាពរបស់ណាប់តាលីនរាល់នាទី រហូតដល់វាចុះប្រហែល 79°C យើងសង្កេតឃើញថា ណាប់តាលីនចាប់ផ្តើមកក ពេលនោះសីតុណ្ហភាពនៅថេរ រហូតដល់ណាប់ តាលីនកកអស់ទើបសីតុណ្ហភាពរបស់វាធ្លាក់ចុះបន្តទៀត ។

**ក្រាបតាងឱ្យដំណើរផ្លាស់ភាពពីរាវទៅកករបស់ណាប់តាលីន**




រូបក

រូបខ

***រូបទី** 2.11*

តាមក្រាបយើងអាចបកស្រាយបានថា គន្លងនៃខ្សែ $AB$ បង្ហាញពីតំហយចុះសីតុណ្ហភាពរបស់ណាប់តាលីនរាវ ។ ខ្សែ $BC$ បង្ហាញពីលំនឹងសីតុណ្ហភាពរបស់ណាប់តាលីនកំពុងកក ។ ក្នុងកំឡុងពេលនេះគ្មានការផ្លាស់ប្តូរសីតុណ្ហភាពទេ ទោះបីមានការបាត់បង់ថាមពលកម្តៅដោយមជ្ឈដ្ឋានជុំវិញក៏ដោយ ។ខ្សែ $CD$ បង្ហាញពីតំហយចុះសីតុណ្ហភាពណាប់តាលីននៅពេលវាកកអស់ ។ ផ្អែកលើពិសោធន៍នេះ យើងអាចសន្និដ្ឋានបានថា ចំណុចកំណករបស់ណាប់តាលីននៅសីតុណ្ហភាព 80°C ដែលជាសីតុណ្ហភាពថេរ ក្នុងពេលណាប់តាលីនផ្លាស់ប្តូរភាពពីរាវទៅរឹង ។

## 3.2 រំពុះ កំណជាញើស និងរំហួត

យើងបានសិក្សារួចមកហើយថា បង្ហួតចែកចេញជាពីរគឺ រំពុះ និងរំហួត ។

### ក. រំពុះនិងកំណជាញើស

- **រំពុះ**

គេកម្តៅអង្គធាតុរាវរហូតក្លាយជាចំហាយស្ថិតនៅសីតុណ្ហភាពកំណត់មួយ គេហៅបម្រែបម្រួលភាពនេះថា **រំពុះ** ។ ក្នុងរយៈពេលអង្គធាតុរាវកំពុងពុះ យើងសង្កេតឃើញថាគ្មានបម្រែបម្រួលសីតុណ្ហភាពទេ ។ សីតុណ្ហភាពពិសេសនេះហៅថាសីតុណ្ហភាពរំពុះឬចំណុចរំពុះនៃអង្គធាតុរាវ (រូបទី *2.12*) ។



***រូបទី*** *2.12*

**តារាងចំណុចរំពុះនៃសារធាតុខ្លះ**

| សារធាតុ | ចំណុចរំពុះ (°C) |
|---|---|
| អ៊ីដ្រូសែន | –253 |
| អុកស៊ីសែន | –183 |
| អេទែរ | 35 |
| អាល់កុល | 79 |
| ទឹកសុទ្ធ | 100 |
| បារត | 357 |

- **កំណជាញើស**

ជាការបំប្លែងពីភាពចំហាយទៅជាញើស ។ យើងផ្កាប់កែវត្រជាក់ពីលើកែវបាឡុងដែលមានទឹកកំពុងពុះកញ្ជ្រោល ។ ចំហាយទឹកហើរឡើងប៉ះកែវត្រជាក់កជាញើសជាតំណក់ទឹកហើយធ្លាក់ចុះ (រូបទី *2.12*) ។ ដើម្បីកំណត់រកចំណុចរំពុះ(ចំណុចកំណក)របស់សារធាតុមួយ យើងត្រូវដាំទឹករហូតដល់វាពុះ(ដូចក្នុងពិសោធរលាយនិងកំណកដែរ) ។ ក្រាបតាងឱ្យសីតុណ្ហភាពនិងរយៈពេលបង្ហាញដូច(រូបទី *2.13*) ។



***រូបទី*** *2.13*

តាមក្រាបយើងសង្កេតឃើញថា

- សីតុណ្ហភាពទឹកកើនឡើងរហូតដល់ 100°C តាងដោយខ្សែ *xy* ។ មានបម្រែបម្រួលសីតុណ្ហភាព (ពេលទឹកស្រូបកម្ដៅ) ។
- សីតុណ្ហភាពនៅនឹង 100°C ដដែល ពេលទឹកពុះរហូតដល់ក្លាយជាចំហាយដូចបង្ហាញតាមគន្លង *yz* ។ សីតុណ្ហភាព 100°C នេះគឺចំណុចរំពុះនៃទឹក ហើយក្នុងពេលប្ដូរភាពពីទឹកទៅចំហាយ គ្មានការផ្លាស់ប្ដូរសីតុណ្ហភាពទេ ទោះបីជាកម្ដៅត្រូវស្រូបក៏ដោយ ។ តើកម្ដៅបាត់ទៅណា ? ចម្ងល់នេះយើងអាចបកស្រាយបានតាមគំរូម៉ូលេគុលស៊ីនេទិចនៃរូបធាតុដូចរូប ។
- កម្ដៅដែលផ្ដល់ឱ្យបន្ត ពេលទឹកកំពុងពុះនោះគឺមិនបានដំឡើងសីតុណ្ហភាពវាទេ គ្រាន់តែជាកម្ដៅដើម្បីធ្វើកម្មន្តញែកម៉ូលេគុលឱ្យឃ្លាត និងដាច់ចេញពីសម្ព័ន្ធរបស់វា ហើយក្លាយទៅជាចំហាយតែប៉ុណ្ណោះ ។



***រូបទី** 2.14*

## ខ. រំហួត

តើអ្នកធ្លាប់បានសង្កេតមើលទេក្នុងការរស់នៅរាល់ថ្ងៃ នៅពេលភ្លៀងជំបូលផ្ទះសើម លុះដល់ភ្លៀងរាំងមួយរយៈ ទឹកក៏រីងហួតស្ងួតអស់ដោយហេតុអ្វី ? នេះមិនខុសពីអ្នកយកទឹកដាក់ក្នុងចានទាបចោលហាលខ្យល់យូរៗទៅទឹកនឹងហួតអស់ ។ បាតុភូតនេះហៅថា **រំហួត** ។ ដូច្នេះរំហួតជាការបង្ហួតនៃអង្គធាតុរាវឱ្យក្លាយជាចំហាយដោយគ្មានរំពុះ ។ តើរំហួតខុសពីរំពុះដូចម្ដេចបើដំណើរការរបស់វាពីភាពរាវទៅភាពជាឧស្ម័នដូចគ្នា?

**តារាងប្រៀបធៀបពីភាពខុសគ្នារវាងរំពុះនិងរំហួត**

| **រំពុះ** | **រំហួត** |
|---|---|
| • កើតឡើងនៅសីតុណ្ហភាពថេរ<br>• ដំណើរការលឿន<br>• កើតឡើងក្នុងអង្គធាតុរាវ<br>• មានពពុះកើតឡើងក្នុងអង្គធាតុរាវ<br>• សីតុណ្ហភាពថេរក្នុងរយៈពេលកំពុងពុះ<br>• កម្ដៅផ្ដល់ឱ្យដោយប្រភពដុតកម្ដៅ ។ | • កើតឡើងនៅសីតុណ្ហភាពណាមួយមិនកំណត់<br>• ដំណើរការយឺត<br>• កើតឡើងនៅលើផ្ទៃអង្គធាតុរាវតែប៉ុណ្ណោះ<br>• គ្មានពពុះកើតឡើងក្នុងអង្គធាតុរាវ<br>• សីតុណ្ហភាពអាចប្រែប្រួល<br>• កម្ដៅផ្ដល់ឱ្យដោយមជ្ឈដ្ឋានជុំវិញ ។ |

# 4. កម្តៅឡាតង់រលាយនិងកម្តៅឡាតង់បង្ហួត

## 4.1 កម្តៅឡាតង់រលាយ

ប្រសិនបើយើងដាក់ដុំទឹកកកតូច និងដុំទឹកកកធំលើតុ នោះយើងសង្កេតឃើញថា ដុំទឹកកកធំនឹងចំណាយពេលក្នុងការរលាយយូរជាងដុំទឹកកកតូច ។ នេះដោយសារដុំទឹកកកធំមានកម្តៅឡាតង់រលាយធំ បើធៀបនឹងដុំទឹកកកតូច ។




***ដុំទឹកកកធំមានកំដៅរលាយឡាតង់ធំជាងដុំទឹកកកតូច***

***រូបទី*** *2.15*

ដូចនេះកម្តៅឡាតង់រលាយរបស់អង្គធាតុរឹងជាកម្តៅចាំបាច់ដើម្បីប្តូរពីភាពរឹងទៅភាពរាវឬច្រាសមកវិញ ដោយគ្មានការផ្លាស់ប្តូរសីតុណ្ហភាព ។

ដុំទឹកកកធំមានកម្តៅឡាតង់រលាយធំហើយវាចំណាយពេលយូរក្នុងការរលាយ កម្តៅឡាតង់រលាយមានខ្នាតជាស៊ូល គេសរសេរ $L_f$(J) ។ ដើម្បីគណនាកម្តៅឡាតង់រលាយ យើងត្រូវស្គាល់ពីកម្តៅម៉ាសឡាតង់រលាយ ។ កម្តៅម៉ាសឡាតង់រលាយ $\ell_f$ នៃសារធាតុរឹងមួយ ជាថាមពលកម្តៅចាំបាច់ដើម្បីបំលាស់ប្តូរភាពនៃសារធាតុដែលមានម៉ាស 1kg ពីភាពរឹងទៅភាពរាវឬច្រាសមកវិញដោយគ្មានបំលាស់ប្តូរសីតុណ្ហភាព ។ កម្តៅម៉ាសឡាតង់រលាយមានខ្នាតគិតជា (J/kg) ពីនិយមន័យខាងលើ គេអាចសរសេររូបមន្ត កម្តៅឡាតង់រលាយ:

$$L_f = \ell_f \times m$$

$L_f$ កម្តៅឡាតង់រលាយគិតជា (J), $\ell_f$ កម្តៅម៉ាសឡាតង់រលាយគិតជា (J/kg) និងម៉ាសអង្គធាតុគិតជា (kg) ។

***ឧទាហរណ៍ :*** ទឹកកកមួយដុំមានម៉ាស 150g ប្រសិនបើកម្តៅម៉ាសឡាតង់រលាយនៃទឹកកកនេះ 340000J/kg ។ ចូររកកម្តៅឡាតង់រលាយ ។

✍ **ដំណោះស្រាយ**

តាមរូបមន្ត $L_f = \ell_f \times m$

អនុវត្តជាលេខ

$m = 150\text{g} = 0.150\text{kg}$ និង $\ell_f = 340000\text{J/kg} = 340\text{KJ/kg}$

$L_f = 340000 \times 0.150 = 51000\text{J} = 51 \times 10^3\text{J}$

$L_f = 51000\text{J} = 51\text{KJ}$ ។

## 4.2 កម្តៅឡាតង់បង្ហួត

កម្តៅឡាតង់បង្ហួត $L_v$ នៃសារធាតុគឺថាមពលកម្តៅចាំបាច់ដើម្បីបង់ក្លាយវាពីភាពរាវទៅចំហាយ ឬច្រាសមកវិញដោយគ្មានបម្រែបម្រួលសីតុណ្ហភាព ។ កម្តៅឡាតង់បង្ហួតមានខ្នាតគិតជាស៊ូល (J) ។

កម្តៅម៉ាសឡាតង់បង្ហួត $\ell_v$ នៃសារធាតុមួយជាថាមពលកម្តៅចាំបាច់ដែលផ្តល់ឱ្យសារធាតុមួយគីឡូក្រាម (1kg) ដើម្បីបង់ក្លាយវាទៅជាចំហាយនៅសីតុណ្ហភាពដដែលនោះ ។ កម្តៅម៉ាសឡាតង់បង្ហួតមានខ្នាតគិតជាស៊ូលក្នុងមួយគីឡូក្រាម J/kg ។ តាមនិយមន័យ គេអាចសរសេររូបមន្តកម្តៅឡាតង់បង្ហួត:

$$L_v = \ell_v \times m$$

$L_v$ កម្តៅឡាតង់បង្ហួតគិតជា (J) , $\ell_v$ កម្តៅម៉ាសឡាតង់បង្ហួតគិតជា (J/kg) និង $m$ ម៉ាសអង្គធាតុគិតជា (1kg) ។

***ឧទាហរណ៍ :*** ចំហាយទឹកដែលបាញ់ចេញពីបំពង់យន្តហោះប្រតិកម្មនៅសីតុណ្ហភាព 100°C ត្រូវបាញ់ទៅលើដុំទឹកកកនៅសីតុណ្ហភាព $0°C$ ។ ចំហាយទឹកខ្លះកកជាទឹក និងផ្នែកនៃទឹកកកខ្លះត្រូវរលាយ ។ ចំហាយដែលកកបង្កើតជាទឹកដែលមានម៉ាស 0.40kg នៅសីតុណ្ហភាព 0°C ។ គណនា

ក. កម្តៅបញ្ចេញដោយចំហាយដែលមានម៉ាសផ្លាស់ប្តូរជាទឹកនៅសីតុណ្ហភាព 100°C

ខ. កម្តៅបញ្ចេញដោយទឹក ពេលវាចុះត្រជាក់ចំពោះសីតុណ្ហភាពទឹកកក ។ គេឱ្យកម្តៅម៉ាសឡាតង់បង្ហួតទឹក 2200KJ/kg និងកម្តៅម៉ាសទឹកស្មើនឹង 4.2KJ/kg · °C ។

### ✍ ដំណោះស្រាយ

ក. កម្តៅដែលបញ្ចេញចំហាយស្មើនឹងកម្តៅឡាតង់បង្ហួតនៃដុំទឹកកក

តាមរូបមន្ត $L_v = m \times \ell_v$

ចំហាយទឹកកកមានម៉ាស 0.40kg និងកម្តៅម៉ាសឡាតង់បង្ហួតទឹក 2200KJ/kg

$L_v = 0.40 \times 2200 = 880000\text{J} = 880 \times 10^3\text{J}$

$L_v = 880\text{KJ}$ ។

ខ. ចំហាយចុះត្រជាក់ពី 100°C មក 0°C

យើងបាន $\Delta T = 100°\text{C} - 0°\text{C} = 100°\text{C}$

ដូច្នេះ កម្តៅបញ្ចេញ $Q = mc\Delta T = 0.40 \times 4.2 \times 100 = 168 \times 10^3\text{J}$

$Q = 168\text{KJ}$ ។

## មេរៀនសង្ខេប

- ចំណុះកម្ដៅជាបរិមាណកម្ដៅចាំបាច់សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាព1K ឬ 1°C របស់អង្គធាតុមួយ ។ រូបមន្តចំណុះកម្ដៅ $C = \frac{Q}{\Delta T}$ ។
- កម្ដៅម៉ាសនៃអង្គធាតុរឹងឬរាវ ជាបរិមាណកម្ដៅចាំបាច់ដែលត្រូវផ្ដល់ឱ្យអង្គធាតុ 1kg សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាព 1K ឬ 1°C ។
  រូបមន្ត : $c = \frac{C}{m} = \frac{1}{m}\left(\frac{Q}{\Delta T}\right)$ ។
- រលាយជាដំណើរផ្លាស់ភាពពីអង្គធាតុរឹងទៅអង្គធាតុរាវ ។
- កំណកជាដំណើរផ្លាស់ភាពពីអង្គធាតុរាវទៅអង្គធាតុរឹង ។
- រំពុះជាការបង្កួតយ៉ាងរហ័សនៃអង្គធាតុរាវឱ្យកើតជាពពុះចំហាយដែលលេចចេញពីផ្ទៃអង្គធាតុរាវនោះ ។
- កំណជាញើស ជាបំលែងពីភាពជាចំហាយទៅជាញើស ។
- រំហួតជាដំណើរផ្លាស់ភាពពីរាវទៅឧស្ម័នដោយគ្មានឆ្លងកាត់រំពុះ ។

## សំណួរនិងលំហាត់

**1.** ដូចម្ដេចហៅថាចំណុះកម្ដៅ ?

**2.** ចូរសរសេររូបមន្តចំណុះកម្ដៅ ។

**3.** អ្នកដាំទឹក $1\ell$ ក្នុងឆ្នាំងមួយ និងទឹក $3\ell$ ក្នុងឆ្នាំងមួយទៀតរហូតដល់ពុះ ។ ទឹកទាំងនោះមានសីតុណ្ហភាពដើមដូចគ្នា ។ តើទឹកក្នុងឆ្នាំងណាត្រូវការធ្យូងច្រើនជាងគេ ?

**4.** បើគេលាយទឹកពុះ និងទឹកត្រជាក់ គេបានទឹកក្ដៅឧណ្ហៗ ព្រោះអ្វី ? ចូរពន្យល់ ?

**5.** ឧបករណ៍បំភាយកម្ដៅមួយផ្ដល់កម្ដៅនូវអានុភាព 1000W ត្រូវដាក់ត្រាំក្នុងទឹកកកដែលមានម៉ាស 2kg នៅសីតុណ្ហភាព 0°C ។ ទឹកកករលាយអស់ក្នុងរយៈពេល 1020 វិនាទី ។ គណនាកម្ដៅម៉ាសឡាតង់រលាយរបស់ទឹកកក ។ តើអ្នកសន្មតដូចម្ដេចដើម្បីដោះស្រាយបាន ?

## សំណួរនិងលំហាត់ជំពូក 2

**I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :**

1. កាលណាគេផ្តល់ថាមពលកម្តៅស្មើនឹងកម្តៅម៉ាសឡាតង់រលាយឱ្យសារធាតុមួយសារធាតុនោះនឹង :

☐ក. រលាយ ☐ខ. ហួត ☐គ. កក ☐ឃ. កជាញើស ។

2. តើទឹកសុទ្ធពុះក្រោមសម្ពាធបរិយាកាសធម្មតាស្ថិតនៅសីតុណ្ហភាពណា ?

☐ក. 0K ☐ខ. 100K ☐គ. 273K ☐ឃ. 373K ។

3. ពេលយើងចាក់អេទែរលើដៃ យើងមានអារម្មណ៍ថាដៃយើងត្រជាក់នេះមកពី :

☐ ក. អេទែរកំពុងហួតវាផ្តល់ឱ្យកម្តៅឡាតង់រំហួតមកដៃ

☐ ខ. អេទែរកំពុងហួតបានស្រូបយកកម្តៅពីដៃ

☐ គ. អេទែរត្រជាក់ជាងដៃ

☐ ឃ. ចំណុចរំពុះនៃអេទែរខ្ពស់ជាងសីតុណ្ហភាពក្នុងរាងកាយ ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. កម្រិតក្តៅកម្រិតត្រជាក់នៃអង្គធាតុមួយហៅថា .......................... ។

2. ................. ជាបរិមាណថាមពលកម្តៅដែលផ្ទេរពីអង្គធាតុក្តៅទៅអង្គធាតុត្រជាក់ជាង ។

3. ចំណុចប្រសព្វមួយនៃសីតុណ្ហភាពនិងសម្ពាធដែលភាពទាំងបីមានលំនឹងរួមគ្នាហៅថា ............ ។

4. ទ្រឹស្តីដែលពន្យល់ថា ភាគល្អិតតូចនៃរូបធាតុធ្វើចលនាឥតឈប់ឈរហើយមានអំពើទៅវិញទៅមកជាទ្រឹស្តី............................ ។

5. បរិមាណកម្តៅចំបាច់សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាព1K ឬ1°C ហៅថា ................... ។

6. បរិមាណកម្តៅចំបាច់ដែលត្រូវផ្តល់ឱ្យអង្គធាតុ 1kg សម្រាប់ដំឡើងឬតំហាយសីតុណ្ហភាព1K ឬ 1°C ហៅថា ................... ។

7. ............................. នៃអង្គធាតុជាសីតុណ្ហភាពកំណត់មួយដែលពេលនោះ អង្គធាតុបំប្លែងពីភាពរឹងទៅភាពរាវ ។

8. ក្រោមសម្ពាធដដែលសីតុណ្ហភាព..................... ដូចគ្នានឹងសីតុណ្ហភាព..................... ។

**III. លំហាត់**

1. គេចង់ដាំទឹក 0.8kg នៅសីតុណ្ហភាព 25°C ឱ្យពុះ ។ តើគេត្រូវការបរិមាណកម្តៅប៉ុន្មានស៊ូល ?
(កម្តៅម៉ាសទឹក $c = 4190\mathrm{J/kg}$ )

**2.** គេចង់ដាំទឹក 0.300kg ឱ្យសីតុណ្ហភាពឡើងពី 20°C ទៅ 100°C ។

ក. គណនាបរិមាណកម្ដៅដែលត្រូវផ្ដល់ឱ្យទឹកនោះ ។

ខ. ឥឡូវគេយកចង្ក្រានអគ្គិសនីមួយដែលផ្ដល់កម្ដៅ 418.5J ក្នុងមួយវិនាទីមកដាំទឹកនោះ តើគេត្រូវប្រើរយៈពេលប៉ុន្មាន បើគេឧបមាថាកម្ដៅចេញពីចង្ក្រានត្រូវទឹកស្រូបយកទាំងអស់ ?

**3.** រូបខាងស្ដាំនេះបង្ហាញពីក្រាបនៃសីតុណ្ហភាពនិងពេលដែលបានមកពីការដុតកម្ដៅក្រោមអង្គធាតុរឹង ។ ចូរពន្យល់អ្វីកើតឡើងចំពោះថាមពលកម្ដៅដែលផ្ដល់ឱ្យក្នុងផ្នែក $AB$ , $BC$ , $CD$ និង $DE$ នៃក្រាប ។




**4.** គណនាបរិមាណកម្ដៅដែលចាំបាច់សម្រាប់រំលាយដែក 100kg នៅសីតុណ្ហភាពរលាយរបស់វា ។ គេឱ្យកម្ដៅម៉ាសឡាតង់រលាយរបស់ដែក = 276KJ/kg ។

**5.** ផើងទទេមួយធ្វើពីស្ពាន់មានម៉ាស 50g នៅសីតុណ្ហភាព 10°C ។ គេចាក់ទឹក 20g នៅសីតុណ្ហភាព 50°C ចូលផើងនេះ គេបានសីតុណ្ហភាពសម្រេច 42°C ។ គណនាកម្ដៅម៉ាសនៃស្ពាន់ ។

**6.** គេដាក់ដុំសំណប៉ាហាំង 0.3kg លើដុំទឹកកកមួយដុំនៅសីតុណ្ហភាព 0°C ម៉ាសទឹកកកដែលរលាយស្មើនឹង 18.5g ។ គណនាសីតុណ្ហភាពនៃដុំសំណប៉ាហាំង ។ គេឱ្យកម្ដៅម៉ាសនៃសំណប៉ាហាំង 226.0J/kg · °C កម្ដៅម៉ាសឡាតង់រលាយនៃទឹកកក 335000J/kg ។

**7.** គណនាបរិមាណកម្ដៅដែលចាំបាច់សម្រាប់បង្ហួតទឹក 50g ដោយដឹងថាសីតុណ្ហភាពដើមនៃទឹកគឺ 0°C ហើយសីតុណ្ហភាពរំពុះនៃទឹក 100°C ។ កម្ដៅម៉ាសឡាតង់បង្ហួតនៃទឹក $2.3 \times 10^6$J/kg ។

**8.** គណនាម៉ាសនៃចំហាយទឹកនៅសីតុណ្ហភាព 100°C ដែលត្រូវបញ្ចេញដើម្បីឱ្យទឹក 0.5kg នៅសីតុណ្ហភាព 18°C ឡើងសីតុណ្ហភាពដល់ 40°C ។

**9.** គេដឹងថាបើគេយកទង់ដែង 400g នៅសីតុណ្ហភាព 100°C ទៅដាក់ក្នុងទឹក 500g នៅសីតុណ្ហភាព 6°C គេបានសីតុណ្ហភាពសម្រេច 10°C ។កំណត់ម៉ាសនៃទង់ដែង ។ កម្ដៅម៉ាសទឹកស្មើនឹង 4200J/kg · °C ។

**10.** គណនាបរិមាណកម្ដៅដែលចាំបាច់ដើម្បីធ្វើឱ្យទឹក 325g ឡើងសីតុណ្ហភាពពី 18°C ទៅ 50°C កម្ដៅម៉ាសទឹក 4200J/kg · °C ។

# ជំពូក 3 អគ្គិសនីនិងម៉ាញេទិច



youtube.com/moeys

facebook.com/moeys.gov.kh

អគ្គិសនីមានតួនាទីយ៉ាងសំខាន់ក្នុងបច្ចេកទេស និងជីវភាពរស់នៅប្រចាំថ្ងៃ ។ គេប្រើប្រាស់ចរន្តអគ្គិសនីសម្រាប់ បំភ្លឺ កម្តៅ វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ទូរលេខ . . . ។ល ។

តើអគ្គិសនីជាអ្វី ? មានប្រភពមកពីណា ? ត្រូវបានបញ្ជូនដូចម្តេច? ដឹកនាំតាមរបៀបណា ?

**មេរៀនទី 1 : អេឡិចត្រូស្តាទិច**

**មេរៀនទី 2 : ចរន្តជាប់និងម៉ាញេទិច**

**មេរៀនទី 3 : ចរន្តឆ្លាស់**

មេរៀនទី

# 1 អេឡិចត្រូស្តាទិច

## ចប់មេរៀននេះ សិស្សអាច

- ❒ ធ្វើពិសោធន៍អេឡិចត្រូស្តាទិច ។
- ❒ បង្ហាញពីអន្តរកម្មរវាងបន្ទុកអគ្គិសនី ។
- ❒ រៀបរាប់ពីរបាយបន្ទុកអគ្គិសនីលើផ្ទៃនៃអង្គធាតុចម្លង ។
- ❒ អនុវត្តអេឡិចត្រូស្តាទិចក្នុងជីវភាពរាល់ថ្ងៃ ។

## 1. ដើមកំណើតនៃអេឡិចត្រូស្តាទិច

នៅ 600 ឆ្នាំមុនគ្រឹស្តសករាជ ជនជាតិក្រិកបានរកឃើញជ័រឈើម្យ៉ាងយកទៅខាត់និងរោមសត្វ ជ័រឈើនោះអាចឆក់ទាញវត្ថុស្រាលៗឱ្យមកតោងជាប់នឹងវា ។សព្វថ្ងៃគេថាជ័រឈើអាចផ្ទុកបន្ទុកអគ្គិសនី ។

នៅពេលដែលអ្នកដោះស្បែកជើង(ជើងស្ងួត)ចេញរួចដើរកាត់កម្រាលព្រំនីឡុងមួយ ជើងរបស់អ្នកនឹងផ្ទុកបន្ទុកអគ្គិសនី ។ ម្យ៉ាងទៀត បើអ្នកយកក្រាសជ័រមួយទៅសិតសក់(ស្ងួត) នៅពេលមានអាកាសធាតុក្តៅស្ងួត ក្រាសជ័រនោះក៏ផ្ទុកបន្ទុកអគ្គិសនីដែរ ។

### 1.1 ការបង្ហាញពីបន្ទុកអគ្គិសនី

#### ក. ពិសោធន៍អេឡិចត្រូស្តាទិច

កាលណាគេយកបំពង់ជ័រទៅខាត់នឹងរោមសត្វ វាអាចផ្ទុកបន្ទុកអគ្គិសនី ។ ដូចគ្នាដែរ កាលណាគេយកចង្កឹះកែវទៅខាត់នឹងសំពត់សូត្រ ចង្កឹះនោះក៏ផ្ទុកបន្ទុកអគ្គិសនីដែរ ។ គេដឹងពីបាតុភូតនេះដោយសារ គេយកចង្កឹះទាំងពីរដែលខាត់រួចទៅដាក់ក្បែរវត្ថុស្រាលៗ (ដូចជាកម្ទេចក្រដាស) វាអាចឆក់ទាញវត្ថុទាំងអស់នោះឱ្យតោងជាប់នៅនឹងចុងរបស់វា ។



*រូបទី3-1 បំពង់ប៊ិចខាត់រួចឆក់ទាញកម្ទេចក្រដាស*

## ខ. បំណកស្រាយ

គេដឹងថាអេឡិចត្រុងកើតមាននៅគ្រប់សារធាតុទាំងអស់ ព្រោះសារធាតុកើតពីអាតូមច្រើន ។ នៅក្នុងអាតូមមានណ្វៃយ៉ូដែលផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន និងអេឡិចត្រុងផ្ទុកបន្ទុកអគ្គិសនីអវិជ្ជមានវិលជុំវិញណ្វៃយ៉ូ(រូបទី 3.2.ខ) ។



(ក)អាតូមបាត់បង់អេឡិចត្រុង (ខ)អាតូមណឺត (គ)អាតូមចំណេញអេឡិចត្រុង

រូបទី 3.2

កាលណាគេយកចង្កឹះកែវទៅខាត់នឹងសំពត់សូត្រឬយកបំពង់បឺតជ័រទៅខាត់នឹងសំពត់ឡែន គេឃើញមានបណ្តូរអេឡិចត្រុងរវាងចង្កឹះកែវ និងសំពត់សូត្រឬរវាងបំពង់បឺតជ័រ និងសំពត់ឡែន ធ្វើឱ្យចង្កឹះកែវខ្វះអេឡិចត្រុងបានផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន(រូបទី 3.2.ក) ។ ចំណែកសំពត់សូត្រផ្ទុកបន្ទុកអគ្គិសនីអវិជ្ជមាន ។ ដូចគ្នាដែរ ចំពោះបំពង់បឺតលើសអេឡិចត្រុងបានផ្ទុកបន្ទុកអគ្គិសនីអវិជ្ជមាន (រូបទី 3.2 - គ) ចំណែកសំពត់ឡែនផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន ។

## គ. អន្តរកម្មរវាងបន្ទុកអគ្គិសនី



រូបទី 3.3.ក



រូបទី 3.3.ខ

គេយកចង្កឹះ $A$ មួយដែលខាត់រួចទៅដាក់ក្បែរចង្កឹះ $B$ មួយដែលខាត់រួច គេឃើញវាច្រានគ្នាចេញ (រូបទី 3.3 .ក) ។ បន្ទាប់មកគេយកចង្កឹះ $A$ ដែលខាត់រួចទៅដាក់ក្បែរចង្កឹះ $C$ ដែលខាត់រួច គេឃើញវាទាញគ្នាចូល(រូបទី 3.3 .ខ ) ។

តាមពិសោធន៍នេះ គេអាចដឹងថាចង្កឹះ $A$ និងចង្កឹះ $B$ ផ្ទុកបន្ទុកអគ្គិសនីសញ្ញាដូចគ្នា ។ ចំណែកឯចង្កឹះ $A$ និងចង្កឹះ $C$ ផ្ទុកបន្ទុកអគ្គិសនីដែលមានសញ្ញាផ្ទុយគ្នា ។ នេះបង្ហាញថាបន្ទុកអគ្គិសនីមានពីរប្រភេទគឺ បន្ទុកអគ្គិសនីវិជ្ជមាន (+)និងបន្ទុកអគ្គិសនីអវិជ្ជមាន(-) ។

តាមការសន្មត :

- បន្ទុកអគ្គិសនីវិជ្ជមានកើតមាននៅចុងចង្កឹះកែវខាត់នឹងសំពត់សូត្រ ។
- បន្ទុកអគ្គិសនីអវិជ្ជមានកើតមាននៅចុងបំពង់ជ័រ(អេបូនីត)ខាត់នឹងសំពត់ឡែនឬរោមសត្វ ។

គេអាចធ្វើពិសោធន៍ដូចគ្នា កាលណាគេយកចង្កឹះជ័រ(ប្លាស្ទិច)ពីរដែលខាត់រួចទៅដាក់ក្បែរគ្នា គេឃើញវាច្រានគ្នាចេញ(រូបទី *3.4.*ក) ហើយបើគេយកចង្កឹះកែវដែលខាត់រួចទៅដាក់ក្បែរចង្កឹះប្លាស្ទិចដែលខាត់រួចវិញ គេឃើញវាទាញគ្នាចូល(រូបទី *3.4.*ខ) ។




*(ក)ចង្កឹះប្លាស្ទិចពីរខាត់នឹងសំពត់ឡែនច្រានគ្នាចេញ* *(ខ)ចង្កឹះប្លាស្ទិចខាត់រួចនិងចង្កឹះកែវខាត់រួចទាញគ្នាចូល*

*រូបទី 3.4*

តាមការពិសោធន៍នេះ គេអាចទាញនូវការសន្និដ្ឋានថា : បន្ទុកអគ្គិសនីដែលមានសញ្ញាដូចគ្នាច្រានគ្នាចេញ ហើយបន្ទុកអគ្គិសនីដែលមានសញ្ញាផ្ទុយគ្នាទាញគ្នាចូល ។

គេអាចសន្និដ្ឋានបានថា កាលណាគេយកចង្កឹះមួយទៅដាក់ក្បែរចង្កឹះកែវដែលខាត់រួច បើវាទាញគ្នាចូល គេដឹងថាចង្កឹះនោះផ្ទុកបន្ទុកអគ្គិសនីអវិជ្ជមាន (-) ។ ដូចគ្នាដែរ បើគេយកចង្កឹះមួយទៅដាក់ក្បែរចង្កឹះជ័រ(ប្លាស្ទិច) បើវាទាញគ្នាចូល គេសន្និដ្ឋានបានថា ចង្កឹះនោះផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន ។

## 1.2 អគ្គិសនីកម្ម

**អគ្គិសនីកម្ម** គឺជាអំពើដែលធ្វើអង្គធាតុឬវត្ថុមួយផ្ទុកបន្ទុកអគ្គិសនី ។ អគ្គិសនីកម្មមានបីប្រភេទ: អគ្គិសនីកម្មដោយកកិត អគ្គិសនីកម្មដោយប៉ះ និងអគ្គិសនីកម្មដោយឥទ្ធិពល ។

### ក. អគ្គិសនីកម្មដោយកកិត

គឺជាអំពើដែលធ្វើអង្គធាតុឬវត្ថុមួយផ្ទុកបន្ទុកអគ្គិសនីដោយសារកកិត ។ ឧទាហរណ៍ :កាលណាគេយកចង្កឹះកែវទៅខាត់នឹងសំពត់សូត្រឬចង្កឹះជ័រទៅខាត់នឹងសំពត់ឡែន គេឃើញមានបន្ទុកអគ្គិសនីកើតឡើងលើចង្កឹះកែវ ឬចង្កឹះជ័រ និងនៅលើសំពត់សូត្រ ឬសំពត់ឡែន ។

### ខ. អគ្គិសនីកម្មដោយប៉ះ

គឺជាអំពើដែលធ្វើអង្គធាតុឬវត្ថុមួយផ្ទុកបន្ទុកអគ្គិសនីដោយយកអង្គធាតុ ឬវត្ថុមួយផ្ទុកបន្ទុកអគ្គិសនីរួចទៅដាក់ឱ្យប៉ះនឹងអង្គធាតុណឺតមួយហើយធ្វើឱ្យអង្គធាតុណឺតនោះផ្ទុកបន្ទុកអគ្គិសនីដែរ ។

***ឧទាហរណ៍ :*** កាលណាគេយកចង្កឹះកែវមួយដែលខាត់រួចទៅដាក់ក្បែរស្វ៊ែលោហៈណឺតមួយស្ថិតនៅលើទម្រអ៊ីសូឡង់ឈរមួយ(រូបទី *3.5.*ក) ។ បន្ទាប់មកគេដាក់ចង្កឹះកែវនោះឱ្យប៉ះនឹងស្វ៊ែលោហៈ (រូបទី*3.5.*ខ) ។ ក្រោយពីប៉ះគ្នារួចគេឃើញចង្កឹះកែវនោះត្រូវបានច្រានគ្នាចេញ(រូបទី *3.5.*គ) ។ ដូច្នេះគេសន្និដ្ឋានថា ស្វ៊ែលោហៈផ្ទុកបន្ទុកអគ្គិសនីមានសញ្ញាដូចគ្នានឹងបន្ទុកអគ្គិសនីនៃចង្កឹះកែវ ។




*រូបទី 3.5 អគ្គិសនីកម្មដោយប៉ះ*

## គ. អគ្គិសនីកម្មដោយឥទ្ធិពល

គេយកចង្កឹះជ័រ(ប្លាស្ទិច)មួយដែលខាត់រួចទៅដាក់ក្បែរស្វ៊ែលោហៈមួយណឺត ។ បន្ទុកអវិជ្ជមាននៃចង្កឹះជ័របានច្រានអេឡិចត្រុងមួយចំនួនពីផ្ទៃឈមឱ្យទៅផ្តុំគ្នានៅលើផ្ទៃម្ខាងទៀត ជាហេតុនាំឱ្យនៅលើផ្ទៃទាំងពីរមានបន្ទុកអគ្គិសនីវិជ្ជមាននិងអវិជ្ជមាន (រូបទី *3.6.* ក) ។ បន្ទាប់មកគេភ្ជាប់ផ្ទៃម្ខាងដែលមានបន្ទុកអគ្គិសនីអវិជ្ជមានទៅដីដោយខ្សែចម្លងមួយ (រូបទី *3.6.* ខ) ។ ពេលនោះអេឡិចត្រុងនៅលើផ្ទៃនោះបានផ្លាស់ទីចូលទៅក្នុងដីធ្វើឱ្យនៅលើផ្នែកនៃ**ផ្ទៃនោះណឺត** ។ គេផ្តាច់ខ្សែពីដីរួចទាញចង្កឹះជ័រចេញឆ្ងាយ ស្វ៊ែលោហៈបានផ្ទុកអគ្គិសនីវិជ្ជមានរាយស្មើគ្នានៅលើផ្ទៃទាំងមូល (រូបទី *3.6.* គ) ។




*រូបទី 3.6 អេឡិចត្រុងផ្លាស់ទី*

# 1.3 អេឡិចត្រូទស្សន៍

## ក. ទម្រង់នៃអេឡិចត្រូទស្សន៍

អេឡិចត្រូទស្សន៍កើតពីប្រអប់កែវមួយដែលនៅផ្នែកខាងលើមានគម្របអ៊ីសូឡង់មួយ ។ នៅចំកណ្តាលនៃគម្របនោះគេចោះរន្ធមួយសម្រាប់ដាក់ទ្រនាប់អ៊ីសូឡង់និងចង្កឹះអាលុយមីញ៉ូម ។នៅចុងខាងលើនៃចង្កឹះនោះមានស្វ៊ែលោហៈ ឬថាសលោហៈមួយ ហើយនៅចុងខាងក្រោមមានសន្លឹកអាលុយមីញ៉ូមពីរឬសន្លឹកមាសពីរដាក់ស្របគ្នា(រូបទី *3.7*) ។




*រូបទី 3.7 អេឡិចត្រូទស្សន៍*

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## ខ. របៀបប្រើ



រូបទី 3.8

កាលណាគេយកអង្គធាតុមួយទៅដាក់ឱ្យប៉ះនឹងថាសលោហៈរបស់អេឡិចត្រូទស្កូប ពេលនោះបើគេឃើញសន្លឹកអាលុយមីញ៉ូមញែកចេញពីគ្នា គេថាអង្គធាតុនោះផ្ទុកបន្ទុកអគ្គិសនី(រូបទី *3.8.* ក) ។

ដើម្បីឱ្យសន្លឹកអាលុយមីញ៉ូមរួមចូលគ្នាវិញ គេត្រូវយកអង្គធាតុមួយទៀតដែលផ្ទុកបន្ទុកអគ្គិសនីដែលមានសញ្ញាផ្ទុយគ្នាទៅដាក់ឱ្យប៉ះនឹងថាសលោហៈឬយកម្រាមដៃទៅដាក់ឱ្យប៉ះនឹងថាសលោហៈនោះជាការស្រេច(រូបទី *3.8.* ខ) ។



រូបទី 3.9

គេអាចប្រើអេឡិចត្រូទស្កូបដើម្បីបង្ហាញពីវត្តមាននៃបន្ទុកអគ្គិសនីវិជ្ជមាន ។ ដំបូងគេផ្ទុកអេឡិចត្រូទស្កូបឱ្យមានបន្ទុកអគ្គិសនីវិជ្ជមាន(រូបទី *3.9.* ក) ។ បន្ទាប់មកគេយកចង្កឹះមួយផ្ទុកបន្ទុកអគ្គិសនីដែលគេពុំស្គាល់សញ្ញាទៅដាក់ក្បែរស្វៃលោហៈនៃអេឡិចត្រូទស្កូបបើគេឃើញសន្លឹកអាលុយមីញ៉ូមញែកខ្លាំងជាងមុនគេអាចដឹងថា ចង្កឹះនោះមានបន្ទុកអគ្គិសនីវិជ្ជមាន(រូបទី *3.9.* ខ) ។

# 2. របាយបន្ទុកអគ្គិសនីលើផ្ទៃនៃអង្គធាតុចម្លង

កាលណាគេផ្ទុកបន្ទុកអគ្គិសនីឱ្យអង្គធាតុមួយដែលមានផ្ទៃស្មើសាច់ (ដូចជាស្វ៊ៃឬផ្ទៃរាប) គេឃើញបន្ទុកអគ្គិសនីបានរាយស្មើគ្នានៅលើផ្ទៃនោះ(រូបទី *3.10.* ក) ។

បន្ទុកអគ្គិសនីមិនរាយនៅលើផ្ទៃផតទេ វារាយតែនៅលើផ្ទៃប៉ោង (រូបទី *3.10.* ខ) ។

ចំពោះអង្គធាតុចម្លងមិនស្មើសាច់ដែលមានផ្ទៃកំណោងខុសគ្នា បន្ទុកអគ្គិសនីផ្តុំគ្នាយ៉ាងច្រើននៅលើផ្ទៃដែលកោងខ្លាំង (រូបទី *3.10* ឃ) ។



រូបទី 3.10

# 3. ការអនុវត្តខ្លះៗនៃអេឡិចត្រូស្តាទិច

## 3.1 ការសំអាតធាតុពុលចេញពីល្បាយផ្សែងនិងធូលី

ការអនុវត្តដ៏សំខាន់មួយ គឺការសំអាតល្បាយផ្សែងនិងធូលីចេញពីស្ថានីយថាមពលធ្យូងថ្មដ៏ធំទំនើបមួយ ដោយប្រើម៉ាស៊ីនអេឡិចត្រូស្តាទិច ។ ប្រសិនបើល្បាយផ្សែងនិងធូលីមិនអាចសំអាតបានទេ នោះវាត្រូវបានផ្ទេរចូលទៅក្នុងបរិយាកាសដែលជាមូលហេតុបង្កឱ្យមានជាតិពុលនៅក្នុងខ្យល់ ។ (រូបទី *3.11*) ខាងក្រោមបង្ហាញពីការភ្ជាប់ម៉ាស៊ីនអេឡិចត្រូស្តាទិចទៅនឹងរបាំងបំពង់ផ្សែងដើម្បីចាប់យកផេះនិងធូលីពីឧស្ម័នសំណល់ដែលហូរចូលទៅក្នុងបរិយាកាសតាមបំពង់ ។ ម៉ាស៊ីននេះធ្វើឡើងពីប្រព័ន្ធខ្សែចម្លងនិងបន្ទះសំប៉ែតៗជាច្រើន ។ ប្រព័ន្ធខ្សែត្រូវបានផ្ទុកបន្ទុកអគ្គិសនីអវិជ្ជមាន ដូច្នេះវាអាចផ្ទុកបន្ទុកអវិជ្ជមានឱ្យផេះនៅពេលដែលផេះឆ្លងកាត់ ។ ចំណែកឯបន្ទះវិញមាននាទីជាអ្នកប្រមូល ត្រូវបានផ្ទុកបន្ទុកអគ្គិសនីវិជ្ជមានដើម្បីទាញនិងប្រមូលផេះ ។ បន្ទាប់មកបន្ទះត្រូវបានក្រឡុក ដើម្បីសំអាតផេះដែលប្រមូលបាននោះនិងត្រូវបានប្រើប្រាស់ជាអនុផល ។ បច្ចេកទេសនៃការបង្កើតម៉ាស៊ីនអេឡិចត្រូស្តាទិចនេះ គឺមានសារៈសំខាន់ផងដែរចំពោះរោងចក្រផលិត ដែកថែប ស៊ីម៉ង់ត៍ និងឧស្សាហកម្មគីមីដែលបញ្ចេញល្បាយឧស្ម័នពុលដ៏ច្រើនសន្ធឹកសន្ធាប់តាមបំពង់ផ្សែង ។




***រូបទី 3.11 ម៉ាស៊ីនអេឡិចត្រូស្តាទិចដែលភ្ជាប់ទៅនឹងបំពង់ផ្សែង***

## 3.2 ជនិតាតង់ស្យុងខ្ពស់

ជនិតាវ៉ាន់ឌឺក្រាហ្វ ( Van de Graaff) គឺជាជនិតាអេឡិចត្រូស្តាទិចដែលមានប្រយោជន៍យ៉ាងខ្លាំង ។ វាអាចបង្កើតផលសងប៉ូតង់ស្យែល ឬតង់ស្យុងលើសពី 14 លានវ៉ុល ។ វាត្រូវបានគេប្រើនៅក្នុងការស្រាវជ្រាវនុយក្លេអ៊ែដើម្បីពន្លឿនភាគល្អិតផ្ទុកបន្ទុកអគ្គិសនី(រូបទី *3.12* ) ។



***រូបទី 3.12 ជនិតាវ៉ាន់ឌឺក្រាហ្វ***

facebook.com/moeys.gov.kh

## 3.3 ការបាញ់ស្រ្បៃ

ម៉ាស(តួរថយន្ត)ត្រូវបានប្រើជាទូទៅនៅក្នុងផលិតកម្មរថយន្ត ។ ការបាញ់ស្រ្បៃអេឡិចត្រូស្តាទិចត្រូវបានគេផ្ទុកនូវបន្ទុកផ្ទុយគ្នា។ ការនេះធ្វើឱ្យការបាញ់ថ្នាំមានភាពជាប់យូរអង្វែង ហើយចំពោះរាល់ផ្នែកគៀនៗនៃវត្ថុត្រូវធានានូវស្រទាប់ថ្នាំស្មើសាច់ល្អ ។ វិធីនេះគឺមានប្រសិទ្ធិភាពទទួលបានផលខ្ពស់និងអាចសន្សំសំចៃបានយ៉ាងខ្លាំង(រូបទី *3.13*) ។



***រូបទី 3.13 ការបាញ់ស្រ្បៃ***

# 4. បាតុភូតអេឡិចត្រូស្តាទិចក្នុងជីវភាពរាល់ថ្ងៃ

## 4.1 អគ្គិសនីកម្មក្នុងខ្លួនមនុស្ស

ខ្លួនរបស់អ្នកជាអង្គធាតុចម្លងអគ្គិសនីហើយងាយផ្ទុកបន្ទុកអគ្គិសនី បើអ្នកដោះឬស្លៀកសម្លៀកបំពាក់ ។សកម្មភាពនេះធ្វើឱ្យមានការប៉ះកកិតរវាងសម្លៀកបំពាក់ជាមួយនឹងស្បែករបស់អ្នក ។ ការប៉ះនេះធ្វើឱ្យអេឡិចត្រុងខ្លះផ្លាស់ទីពីផ្ទៃមួយទៅផ្ទៃមួយទៀត ។ **ឧទាហរណ៍** អ្នកអាចចំណេញអេឡិចត្រុងកាលណាអ្នកដោះអាវយឺតរបស់អ្នកចេញ ។ បើសំណើមបរិយាកាសខ្ពស់ អេឡិចត្រុងទាំងនេះបានហូរចេញយ៉ាងលឿនពីអ្នកទៅក្នុងបរិយាកាស ។ បើសំណើមបរិយាកាសទាប អ្នកអាច លើសបន្ទុកជាច្រើនដែលផលសងប៉ូតង់ស្យែលរវាងខ្លួនរបស់អ្នកនិងមជ្ឈដ្ឋានជុំវិញគឺ5kV ឬច្រើនជាង ។ បើអ្នកប៉ះនឹងក្តារចុចកុំព្យូទ័រក្នុងខណៈដែលអ្នកផ្ទុកបន្ទុកបែបនេះ បន្ទុកដែលលើសនៅលើខ្លួនរបស់អ្នកអាចហូរចូលទៅក្នុងបំណែកសៀគ្វីនៃកុំព្យូទ័រ ដែលជាហេតុធ្វើឱ្យបន្ទុកលើសចំណុះ ហើយអាចឆេះបាន ។

មានឧទាហរណ៍ច្រើនរាប់មិនអស់ក្នុងការប៉ះរវាងមនុស្សម្នាក់ និងសារធាតុផ្សេងៗជាច្រើនប្រភេទដែលធ្វើឱ្យមនុស្សផ្ទុកបន្ទុកអគ្គិសនីយ៉ាងខ្ពស់ មនុស្សអាចផ្ទេរបន្ទុកទាំងនោះដោយមានព្រាតផ្កាភ្លើង ។ ការរំអិលរបស់កុមារចុះតាមផ្លូវរអិលធ្វើអំពីប្លាស្ទិចនៅថ្ងៃដែលមានអាកាសធាតុស្ងួតត្រូវបានគេវាស់ឃើញថាមានប៉ូតង់ស្យែលប្រហែលជា 60kV ។ បើកុមារនោះដើរទៅជិតអង្គធាតុចម្លងណាមួយ ( ដូចជាមនុស្សម្នាក់ផ្សេងទៀត ) កុមារប្រហែលជានឹងផ្ទេរបន្ទុកទៅកាន់អង្គធាតុនោះដោយព្រាតផ្កាភ្លើងយ៉ាងខ្លាំង ។ បន្ទេរផ្កាភ្លើងបែបនេះនឹងបង្កឱ្យមានគ្រោះមហន្តរាយដល់បន្ទប់វះកាត់ក្នុងមន្ទីរពេទ្យនៅកន្លែងដែលមានវត្តមានឧស្ម័នដែលងាយឆេះ(ដូចជា ឧស្ម័ន Anesthetic gas) ។ ដើម្បីបន្ទេរបន្ទុកចេញ ក្រុមវះកាត់ត្រូវពាក់ស្បែកជើងធ្វើពីអង្គធាតុចម្លង ហើយឈរនៅលើកម្រាលអង្គធាតុចម្លង ។ បន្ទេរផ្កាភ្លើងក៏អាចបង្កឱ្យមានអគ្គីភ័យផងដែរនៅស្ថានីយឥន្ធនៈចាក់សាំងដោយខ្លួនឯង កាលណាអ្នកចាក់សាំងបានអង្គុយលើពូកឡានដើម្បីរង់ចាំទម្រាំដល់សាំងពេញធុង ។ ការប៉ះជាមួយនឹងពូកឡានធ្វើឱ្យអ្នកចាក់សាំងមានបន្ទុកយ៉ាងច្រើនដែលផ្កាភ្លើងអាចកើតមានឡើងរវាងម្រាមដៃនិងក្បាលស្នប់ កាលណាអ្នកចាក់សាំងត្រលប់ទៅដកក្បាលស្នប់ចេញពីធុងសាំងឡាន ។ផ្កាភ្លើងអាចបញ្ឆេះចំហាយសាំងដែលនៅជុំវិញក្បាលស្នប់ ។

## 4.2 ផ្លេកបន្ទោរ


រូបទី 3.14 ប្រដាប់ការពាររន្ទះ

ជាទូទៅគេអាចមើលឃើញពន្លឺភ្លែតៗនៃផ្លេកបន្ទោរមុន និងក្នុងពេលផ្គរលាន់ ។ នេះបណ្ដាលមកពីបរិមាណអគ្គិសនីដ៏សន្ធឹកសន្ធាប់បង្កឡើងក្នុងដុំពពកដ៏ធំ ។ ដុំពពកទាំងនេះត្រូវបានផ្ទុកបន្ទុកអគ្គិសនីដោយកកិតរវាង ម៉ូលេគុលទឹកនៅក្នុងដុំពពកជាមួយនឹងម៉ូលេគុលខ្យល់ ។ នៅពេលដែលបន្ទុកនៃដុំពពកមានបរិមាណធំគ្រប់គ្រាន់ វាអាចធ្វើឱ្យខ្យល់ក្លាយជាអ៊ីយ៉ុង ដែលពេលនោះផ្ដល់នូវផ្លូវចម្លងសម្រាប់ផ្ទេរបរិមាណបន្ទុកអគ្គិសនីដ៏ធំទៅកាន់វត្ថុដែលនៅជិតបំផុតឬចុងស្រួចបំផុតទៅលើដី ។ នេះពន្យល់ពីមូលហេតុដែលថាហេតុអ្វីបានជាមានគ្រោះថ្នាក់ខ្លាំងចំពោះការហែលក្នុងទឹកសមុទ្រ ការលេងនៅក្នុងស្រែ ចម្ការឬការជ្រកក្រោមដើមឈើ ពេលដែលមានព្យុះភ្លៀង ។ កងទាហានសាងសង់ត្រង់សេ ( លេណដ្ឋាន )នៅលើកំពូលភ្នំ គឺពុំដែលប្រើស័ង្កសីជាដំបូលសម្រាប់ជ្រកពេលដែលមានផ្គរភ្លៀងឡើយ ។ដើម្បីការពារការខូចខាតសំណង់ធំៗពីផ្លេកបន្ទោរនិងរន្ទះ គេប្រើអង្គធាតុចម្លងផ្លេកបន្ទោរ ។ គោលបំណងនៃការប្រើអង្គធាតុចម្លងផ្លេកបន្ទោរ(រូប*3.14*)គឺដើម្បីផ្ដល់ផ្លូវសម្រាប់បន្ទេរបរិមាណអេឡិចត្រុងដ៏ច្រើននៅក្នុងខ្យល់ពីកំពូលនៃអគារទៅដី ។ តាមមធ្យោបាយនេះឱកាសនៃការបាញ់របស់រន្ទះ(អំឡុងពេលផ្ទេរបន្ទុកភ្លាមៗ ) ត្រូវបានកាត់បន្ថយ ។

## 4.3 ចំហេះឬបន្ទុះ

ចំហេះឬបន្ទុះអាចកើតមានឡើងកាលណាបន្ទុកអគ្គិសនីស្ដាទិចដែលបង្កើតដោយកកិតបានកើតមានហួសប្រមាណ ។

**ឧទាហរណ៍** : បន្ទុកអគ្គិសនីស្ដាទិចត្រូវបានកើនឡើងច្រើនទៅៗនៅលើយន្តហោះ ក្នុងពេលកំពុងហោះហើរនិងនៅលើរថយន្តដឹកប្រេងធំៗដែលកំពុងបើកជាដើម ។

ការការពារទុកជាមុន វានឹងធ្វើឱ្យយើងចៀសផុតពីគ្រោះថ្នាក់ដោយចៃដន្យបាន ។ ក្នុងករណីយន្តហោះខាងលើ កង់ទាំងអស់របស់វាផលិតឡើងពីកៅស៊ូដែលជាអង្គធាតុចម្លងអគ្គិសនីខ្សោយ ដូច្នេះវាអាចធ្វើឱ្យបរិមាណបន្ទុកដែលបង្កើតឡើងដោយកកិតលើយន្តហោះក្នុងពេលកំពុងហោះហើរនោះអាចត្រូវបានផ្ទេរអស់ដោយគ្មានគ្រោះថ្នាក់ នៅពេលដែលយន្តហោះនោះចុះប៉ះនឹងដី ។

## មេរៀនសង្ខេប

- បន្ទុកអគ្គិសនីមាន2ប្រភេទ គឺបន្ទុកអគ្គិសនីវិជ្ជមាននិងបន្ទុកអគ្គិសនីអវិជ្ជមាន ។
- បន្ទុកអគ្គិសនីដែលមានប្រភេទដូចគ្នាច្រានគ្នាចេញហើយមានប្រភេទផ្ទុយគ្នាទាញគ្នាចូល ។
- អគ្គិសនីកម្មមានបីប្រភេទ : អគ្គិសនីកម្មដោយកកិត អគ្គិសនីកម្មដោយប៉ះ និងអគ្គិសនីកម្មដោយឥទ្ធិពល ។
- អេឡិចត្រូទស្សន៍ជាឧបករណ៍ប្រើសម្រាប់ឱ្យគេដឹងថា តើអង្គធាតុមួយផ្ទុកបន្ទុកអគ្គិសនីឬនៅ ។
- ចំពោះអង្គធាតុមិនស្មើសាច់ដែលមានផ្ទៃកំណោងខុសគ្នា បន្ទុកអគ្គិសនីផ្តុំគ្នាយ៉ាងច្រើននៅលើផ្ទៃស្រួចខ្លាំង ។
- បាតុភូតអេឡិចត្រូស្តាទិចយកទៅប្រើក្នុងឧបករណ៍ខ្លះដូចជាប្រដាប់ការពាររន្ទះ ជនិតាវ៉ាន់ឌឺក្រាហ្វ . . . ។
- ក្នុងជីវភាពរាល់ថ្ងៃ បាតុភូតអេឡិចត្រូស្តាទិចយកទៅប្រើដើម្បីសំអាតចេញនៃល្បាយផ្សែងនិងធូលីចេញពីអណ្តូងរ៉ែ និងការបាញ់ស្រ្បៃ ។

## សំណួរនិងលំហាត់

1. តើអេឡិចត្រូស្តាទិចសិក្សាពីអ្វី ?
2. ដូចម្តេចដែលហៅថាអង្គធាតុណឺត ?
3. ចូរពន្យល់ពីអគ្គិសនីកម្មដោយកកិត អគ្គិសនីកម្មដោយប៉ះ និងអគ្គិសនីកម្មដោយឥទ្ធិពល ។
4. តើបន្ទុកអគ្គិសនីមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
5. តើបន្ទុកអគ្គិសនីមានអំពើទៅវិញទៅមកដូចម្តេច ? (ចំពោះអង្គធាតុមានបន្ទុកអគ្គិសនី)
6. ចំពោះអង្គធាតុចម្លងស្មើសាច់ តើបន្ទុកអគ្គិសនីរាយដូចម្តេច ?
7. តើបន្ទុកអគ្គិសនីរាយនៅលើផ្ទៃផតដែរឬទេ ?
8. ចំពោះអង្គធាតុចម្លងមិនស្មើសាច់ តើបន្ទុកអគ្គិសនីច្រើនផ្តុំគ្នានៅត្រង់ណា ?
9. ចូរពិណនាអំពីអេឡិចត្រូទស្សន៍និងបម្រើបម្រាស់វា ។

**10.** គេមានស្វ៊ែលោហៈ $B$ មួយណឹតដាក់ក្បែរស្វ៊ែ $A$ មួយផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន ។ តើគេប្រើវិធីដូចម្តេច ដើម្បីឱ្យស្វ៊ែលោហៈ $B$ មានបន្ទុកអគ្គិសនីអវិជ្ជមានដោយពុំមានកំណែប្រែបន្ទុកអគ្គិសនីនៃស្វ៊ែ $A$ ។

**11.** តើអ្នកអាចបង្កើតបន្ទុកអគ្គិសនីទាំងពីរប្រភេទបានយ៉ាងដូចម្តេច? បើសិនជាគេឱ្យចង្កឹះកែវមួយ ចង្កឹះអេបូនីតមួយ រោមសត្វ និងសំពត់សូត្រទៅដល់អ្នក ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 2 ចរន្តជាប់និងម៉ាញេទិច

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពន្យល់ពីធម្មជាតិនៃចរន្តអគ្គិសនី ។
- ❒ ពោលនិយមន័យចរន្តជាប់ ។
- ❒ វាស់អាំងតង់ស៊ីតេចរន្តនិងតង់ស្យុង ។
- ❒ បង្ហាញដែនម៉ាញេទិចបង្កើតដោយចរន្តនិងស្ប៉ិចម៉ាញេទិច ។
- ❒ បង្ហាញពីការបន្ស៊ីមេដែក ។

## 1. ចរន្តជាប់

### 1.1 ធម្មជាតិចរន្តអគ្គិសនី

#### ក. បន្ទុកអគ្គិសនីនិងចរន្តអគ្គិសនី

ក្នុងមេរៀនមុនយើងបានសិក្សាអំពីអ៊ីសូឡង់អគ្គិសនីដែលអាចត្រូវបានផ្ទុកបន្ទុកអគ្គិសនីដោយការខាត់ឬកកិត ។ ចំពោះអ៊ីសូឡង់ផ្ទុកបន្ទុកអគ្គិសនីត្រមោច បន្ទុកអគ្គិសនីលើផ្ទៃរបស់វាមិនផ្លាស់ទីទេ ។ គេថាវាជាអគ្គិសនីស្តាទិច ។ ប៉ុន្តែបើគេភ្ជាប់វាដោយអង្គធាតុចម្លងណាមួយ ពេលនោះបន្ទុកអគ្គិសនីទាំងនោះនឹងផ្លាស់ទី ។

នៅពេលបន្ទុកអគ្គិសនីផ្លាស់ទី គេថាចរន្តអគ្គិសនីត្រូវបានបង្កើតឡើង ។ ក្នុងករណីនេះ គឺចរន្តអគ្គិសនីផ្លាស់ទីពីអង្គធាតុដែលមានបន្ទុកអគ្គិសនីវិជ្ជមានទៅអង្គធាតុដែលមានបន្ទុកអគ្គិសនីអវិជ្ជមានឬដី ។ ផ្ទុយទៅវិញអេឡិចត្រុងផ្លាស់ទីពីអង្គធាតុដែលមានបន្ទុកអគ្គិសនីអវិជ្ជមានទៅអង្គធាតុដែលមានបន្ទុកអគ្គិសនីវិជ្ជមាន ។ ប៉ុន្តែគេពុំអាចផលិតចរន្តជាប់ពីអគ្គិសនីស្តាទិចបានទេព្រោះបរិមាណបន្ទុកអគ្គិសនីស្តាទិចដែលកើតមាននៅលើផ្ទៃកកិតនោះមានតែចំនួនតិចតួចប៉ុណ្ណោះ ។ ដូច្នេះចរន្តអគ្គិសនីនឹងកើតមានឡើងតែក្នុងរយៈពេលយ៉ាងខ្លី ។ម្យ៉ាងទៀតចរន្តដែលបានមកពីអគ្គិសនីស្តាទិចនោះគឺពុំគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ឡើយ ។

## ខ. ជនិតាចរន្តជាប់

អ្នកវិទ្យាសាស្ត្រជនជាតិអ៊ីតាលី លោក **អាឡេសង់ដ្រូវ៉ុលតា** ( Alessandro Volta ) បានបង្កើតជនិតាមួយក្នុងចំណោមជនិតាដំបូងរបស់គាត់ ។

បន្ទាប់ពីជនិតានេះត្រូវបានបង្កើតឡើង ការស្រាវជ្រាវអំពីអគ្គិសនីក៏ត្រូវបានអភិវឌ្ឍន៍ហើយយើងអាចប្រើប្រាស់ចរន្តជាប់បាន ។ ជនិតានោះកើតឡើងពីអេឡិចត្រូតពីរធ្វើពីលោហៈដែលពុំស្គាល់ឈ្មោះត្រូវបានដាក់ចូលទៅក្នុងអេឡិចត្រូលីតណាមួយដែលមានសូលុយស្យុងអគ្គិសនី ។ ជាមួយនឹងអេឡិចត្រូតនិងអេឡិចត្រូលីតសមស្របផលសងប៉ូតង់ស្យែល ឬចរន្តអគ្គិសនីកើតមានឡើងរវាងអេឡិចត្រូតទាំងពីរដែលជាផលនៃប្រតិកម្មគីមី(រូបទី *3.15*) ជនិតានេះបានបំប្លែងថាមពលប៉ូតង់ស្យែលគីមីឱ្យទៅជាថាមពលអគ្គិសនី ។ ពេលនោះអេឡិចត្រុងផ្លាស់ទីពីអេឡិចត្រូតអវិជ្ជមាន(B)ឆ្លងកាត់ខ្សែចម្លងនិងអំពូលឆ្ពោះទៅអេឡិចត្រូត(A) ។ បំលាស់ទីនោះបង្កើតជាលំហូរអេឡិចត្រុងក្នុងខ្សែចម្លង ។ អេឡិចត្រូត(A)ជាអាណូតសម្គាល់ដោយសញ្ញា (+)ហើយអេឡិចត្រូត (B) គឺជាកាតូតសម្គាល់ដោយសញ្ញា (-) ។ អេឡិចត្រុងឆ្លងកាត់ខ្សែចម្លងពី B (-)ទៅ A (+) ។ គេថាជនិតានេះបានផ្តល់នូវចរន្តជាប់ (DC) ។




**រូបទី 3.15 ចរន្តអគ្គិសនីក្នុងអេឡិចត្រូលីត**

## គ. និយមន័យ

ចរន្តជាប់ជាចរន្តនៃបន្ទុកអគ្គិសនីដែលផ្លាស់ទីឆ្លងកាត់ខ្សែចម្លងតាមទិសដៅកំណត់មួយ ។

តាមនិយមន័យគេសរសេរ :

$$I = \frac{Q}{t}$$

$Q$ ជាបរិមាណអគ្គិសនីដែលឆ្លងកាត់មុខកាត់នៃអង្គធាតុចម្លងគិតជាគូឡំ ($C$)

$t$ ជារយៈពេលដែលចរន្តឆ្លងកាត់មុខកាត់នៃខ្សែចម្លងគិតជាវិនាទី (s)

$I$ ជាអាំងតង់ស៊ីតេចរន្តគិតជាគូឡុំក្នុងមួយវិនាទី (C/s) ឬអំពែ (A) ។

បរិមាណអគ្គិសនីនេះស្មើនឹងបរិមាណអគ្គិសនីដែលធ្វើឱ្យ $n$ អេឡិចត្រុងផ្លាស់ទីឆ្លងកាត់មុខកាត់នៃអង្គធាតុចម្លង : $Q = n|-e|$ ដែល $-e$ ជាបន្ទុកអគ្គិសនីនៃអេឡិចត្រុង $-e = -1.6 \times 10^{-19}$C ។

ចរន្តអគ្គិសនីកើតមានក្នុងលោហៈ ក្នុងអេឡិចត្រូលីតនិងក្នុងសឺមីកុងឌុចទ័រប្រភេទ **p** និង **n** ៖
- ក្នុងលោហៈចរន្តអគ្គិសនីជាចរន្តនៃអេឡិចត្រុងសេរី ។
- ក្នុងអេឡិចត្រូលីតចរន្តអគ្គិសនីជាចរន្តនៃអ៊ីយ៉ុង ។
- ក្នុងសឺមីកុងឌុចទ័រប្រភេទ **n** ចរន្តអគ្គិសនីជាចរន្តនៃអេឡិចត្រុងដែលនៅសល់ (លើស) ។
- ក្នុងសឺមីកុងឌុចទ័រប្រភេទ **p** ចរន្តអគ្គិសនី ជាលំហូរនៃរន្ធ (បន្ទុកវិជ្ជមាន) ។

## 1.2 ទិសដៅនៃចរន្ត

គេអាចកំណត់ទិសដៅនៃចរន្តតាមវិធីដូចខាងក្រោម ៖

កាលណាគេភ្ជាប់ម៉ូទ័រចរន្តជាប់ (DC) មួយនៅប៉ូលនៃជនិតា គេឃើញម៉ូទ័រនោះវិល ។ ប៉ុន្តែទិសដៅរង្វិលនៃម៉ូទ័រ អាស្រ័យនឹងការដែលគេភ្ជាប់ម៉ូទ័រទៅនឹងប៉ូលជនិតា ព្រោះថាជនិតាមានប៉ូលពីរគឺប៉ូល(+) និង (-)ហើយម៉ូទ័រមានខ្សែពីរ គឺខ្សែខៀវនិងខ្សែក្រហម ។កាលណាគេភ្ជាប់ខ្សែក្រហមទៅនឹងប៉ូល (+) ហើយខ្សែខៀវទៅនឹងប៉ូល (-)នៃជនិតា ពេលនោះម៉ូទ័រវិលតាមទិសដៅដូច(រូបទី *3.16*.ក) ។ ផ្ទុយទៅវិញ បើគេភ្ជាប់ខ្សែក្រហមទៅនឹងប៉ូល(-)ហើយខ្សែខៀវទៅនឹងប៉ូល (+) នៃជនិតានោះម៉ូទ័រនឹងវិលតាមទិសដៅបញ្ច្រាសពីមុនដូច(រូបទី *3.16*.ខ) ។ ត្រង់នេះបញ្ជាក់ថា លំហូរនៃចរន្តជាប់(DC) ប្រព្រឹត្តិទៅតាមទិសដៅតែមួយប៉ុណ្ណោះ ។ ឧបករណ៍អគ្គិសនីភាគច្រើនដំណើរការដោយប្រើប្រាស់ចរន្តជាប់មានដូចជា នាឡិកា ទូរស័ព្ទដៃ វិទ្យុ ម៉ាញេ . . . ព្រោះវាមានប៉ូល(+) និងប៉ូល (-) ។ បើសិននៅពេលប្រើ គេភ្ជាប់ប៉ូលនៃឧបករណ៍ទាំងនោះពុំបានត្រឹមត្រូវជាមួយនឹងប៉ូលនៃជនិតាទេ ពេលនោះឧបករណ៍មិនដំណើរការឬអាចឆេះខូចក៏មាន ព្រោះទិសដៅនៃចរន្តបានកំណត់យ៉ាងច្បាស់លាស់ក្នុងឧបករណ៍ទាំងនោះ ។



***រូបទី*3.16 *ទិសដៅចរន្តអគ្គិសនី***

វិធីមួយទៀត គេសាកល្បងបង្ហាញទិសដៅនៃចរន្តជាប់នេះដោយប្រើឌីយ៉ូតបន្សាយពន្លឺឬអំពូល (LED) ដោយឱ្យចរន្តជាប់(DC) ឆ្លងកាត់វាតាមរយៈការបណ្តូរប៉ូលនៃជនិតា ។ឌីយ៉ូតបន្សាយពន្លឺមានជើងពីរ គឺជើងដែលវែងរបស់ឌីយ៉ូតគឺអាណូត ហើយជើងដែលខ្លីគឺកាតូត ។

កាលណាគេភ្ជាប់អាណូត(ខ្សែក្រហម)ទៅនឹងប៉ូល (+) ហើយកាតូត(ខ្សែខៀវ)ទៅនឹងប៉ូល(-) នៃជនិតា រួចគេបិទកុងតាក់ គេឃើញឌីយ៉ូតបន្សាយពន្លឺឆេះភ្លឺ(រូបទី *3.17*.ក) ។ ប៉ុន្តែបើគេត្រឡប់ប៉ូល

នៃជនិតាវិញ គេឃើញឌីយ៉ូតនោះមិនបន្សាយពន្លឺទេ(រូបទី 3.17.ខ)។ តាមការពិសោធនេះ គេអាចធ្វើការសន្និដ្ឋានថា ចរន្តអគ្គិសនីមានទិសដៅពីប៉ូល (+) ទៅប៉ូល (-) នៃជនិតា។ ចំណែកអេឡិចត្រុងវិញមានទិសដៅផ្ទុយពីទិសដៅសន្មតនៃចរន្ត។




រូបទី3.17 ឌីយ៉ូតកំណត់ទិសដៅចរន្តអគ្គិសនី

## 1.3 រង្វាស់នៃចរន្តអគ្គិសនី

### ក. ការបង្ហាញពីអំពែម៉ែត




រូបទី3.18 អំពែម៉ែត

អំពែម៉ែតជាឧបករណ៍ប្រើសម្រាប់វាស់អាំងតង់ស៊ីតេចរន្តអគ្គិសនីនិងមាននិមិត្តសញ្ញា (A) ។

ដើម្បីគណនាអាំងតង់ស៊ីតេចរន្ត គេត្រូវស្គាល់សញ្ញាណដូចតទៅ:

$n_0$ តាងចំនួនប្រលោះក្រិតសរុប

$n$ តាងចំនួនប្រលោះក្រិតដែលទ្រនិចចង្អុល

$Cal$ តាងកាលីប

$I$ តាងអាំងតង់ស៊ីតេចរន្ត

តាមពិសោធន៍បញ្ជាក់ថា លំងាកនៃអំពែម៉ែតសមាមាត្រនឹងអាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់។

គេបានទំនាក់ទំនង :$\frac{I}{Cal} = \frac{n}{n_0}$ ដូច្នេះ $\boxed{I = Cal \times \frac{n}{n_0}}$ ។

### ខ. របៀបប្រើអំពែម៉ែត

ដើម្បីវាស់អាំងតង់ស៊ីតេចរន្តអគ្គិសនីដែលឆ្លងកាត់អង្គធាតុចម្លងណាមួយ គេត្រូវ :

- តអំពែម៉ែតជាស៊េរីជាមួយនឹងរេស៊ីស្តរ $R$ ។ (ចូរប្រុងប្រយ័ត្នកុំភ្ជាប់វាទៅនឹងប្រភពដូចជាថ្មពិលឬអាគុយដោយផ្ទាល់ ព្រោះវាអាចធ្វើឱ្យអំពែម៉ែតនេះឆេះខូច)។
- ភ្ជាប់អំពែម៉ែតដោយឱ្យចរន្តចូលតាមប៉ូល(+) និងចេញតាមប៉ូល(-)នៃឧបករណ៍ បើពុំដូច្នេះទេទ្រនិចរបស់វានឹងងាកបញ្ច្រាស។
- ជ្រើសរើសកាលីបឱ្យបានសមស្រប។
- បិទកុងតាក់និងអានតម្លៃចង្អុលនៃទ្រនិចអំពែម៉ែត។

***ឧទាហរណ៍ :*** អំពែម៉ែតមួយមានកាលីបដូចតទៅនេះ : 5A , 1A , 0.1A , 10mA , 5mA ។

អំពែម៉ែតនោះមានប្រលោះក្រិតសរុប $n_0 = 100$ នៅពេលពិសោធន៍ គេបានស្រង់លទ្ធផលដាក់នៅក្នុងតារាងដូចខាងក្រោម ៖



***រូបទី 3.19 អំពែម៉ែត***

| កាលីប | 5A | 1A | 100mA | 5mA |
|---|---|---|---|---|
| ប្រលោះក្រិត | 24 | 98 | 63.5 | 15 |

គណនាអាំងតង់ស៊ីតេចរន្តចំពោះពិសោធន៍នីមួយៗ

តាមរូបមន្ត : $I = Cal\frac{n}{n_0}$

ចំពោះ 5A គេបាន : $I_1 = 5\text{A} \times \frac{24}{100} = 1.2\text{A}$

ចំពោះ 1A គេបាន : $I_2 = 1\text{A} \times \frac{98}{100} = 0.98\text{A}$

ចំពោះ 100mA គេបាន : $I_3 = 100\text{mA} \times \frac{63.5}{100} = 5\text{mA}$

ចំពោះ 5mA គេបាន : $I_4 = 5\text{mA} \times \frac{15}{100} = 0.75\text{mA}$

## គ. បង្គុំរេស៊ីស្តរជាសេរីនិងជាខ្នែង

- **រេស៊ីស្តរតជាសេរី**




***រូបទី 3.20 រេស៊ីស្តរតជាសេរី***

តាមពិសោធន៍ដូច(រូបទី 3.20. ក)អំពែម៉ែត $A_1$ , $A_2$ និង $A_3$ ចង្អុលតម្លៃដូចគ្នាៗត្រង់ទីតាំងទាំងបីនៃសៀគ្វី ។ គេអាចទាញច្បាប់មួយថា “ អាំងតង់ស៊ីតេចរន្តមានតម្លៃដូចគ្នាៗ នៅគ្រប់ចំណុចទាំងអស់នៃសៀគ្វី ” ។

- **រេស៊ីស្ដរតជាខ្នែង**

ថ្នាំងនៃចរន្តជាចំណុចប្រសព្វនៃបណ្ដាញច្រើន ។

ចំណុច $P$ និង $Q$ ហៅថាថ្នាំងនៃបណ្ដាញ ។




រូបទី 3.21 **រេស៊ីស្ដរតជាខ្នែង**

$R_1$ និង $R_2$ តជាខ្នែងដែលអាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_1$ ចង្អុលដោយអំពែម៉ែត $(A_1)$ ហើយអាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់ $R_2$ ចង្អុលដោយអំពែម៉ែត $(A_2)$ ។ ចំណែកអាំងតង់ស៊ីតេចរន្តដើមចង្អុលដោយអំពែម៉ែត $(A)$ ។

គេបានផ្ទៀងផ្ទាត់ឃើញថា : $I = I_1 + I_2$

ច្បាប់អាំងតង់ស៊ីតេ : " អាំងតង់ស៊ីតេចរន្តដើមស្មើនឹងផលបូកអាំងតង់ស៊ីតេចរន្តបែង" ។

គេអាចសរសេរ : $\boxed{I = I_1 + I_2 + \ldots + I_n}$ ។

## 1.4 ការបង្ហាញនិងរង្វាស់តង់ស្យុង

### ក. ការបង្ហាញតង់ស្យុង




រូបទី 3.22 **រង្វាស់តង់ស្យុងនៃកំណាត់សៀគ្វី**

កាលណាគេធ្វើឱ្យចរន្តអគ្គិសនីឆ្លងកាត់រេស៊ីស្ដរ $R_1$ ពី $M$ ទៅ $N$ នោះរវាងចំណុច $M$ និង $N$ មានតង់ស្យុង $V_{MN}$ ។

### ខ. វ៉ុលម៉ែត

ក្នុងការប្រតិបត្តិដើម្បីវាស់តង់ស្យុងរវាងចុងទាំងពីរនៃរេស៊ីស្ដរណាមួយ គេប្រើវ៉ុលម៉ែតទ្រនិចឬមុលទីម៉ែតលេខ ។ វ៉ុលម៉ែតមានគោលពីរគឺ គោល( + )និងគោល (–) និងមាននិមិត្តសញ្ញា $(V)$ រេស៊ីស្តង់របស់វាមានតម្លៃធំណាស់ស្ទើរតែគ្មានចរន្តឆ្លងកាត់ ។ ដូច្នេះគេអាចប្រើវ៉ុលម៉ែតជាមួយនឹងប្រភពអគ្គិសនីបានដោយផ្ទាល់ ។ ចំណែករេស៊ីស្តង់ខាងក្នុងនៃអំពែម៉ែតវិញមានតម្លៃតូចណាស់ ។ ដូច្នេះគេមិនអាចតអំពែម៉ែតជាខ្នែងជាមួយនឹងប្រភពដោយផ្ទាល់បានទេ ។

### គ. របៀបប្រើវ៉ុលម៉ែត

ដើម្បីវាស់តង់ស្យុងរវាងគោលទាំងពីរនៃថ្មពិលឬ រេស៊ីស្ដរណាមួយ គេត្រូវ :

- តវ៉ុលម៉ែតជាខ្នែងជាមួយនឹងគោលទាំងពីរនៃថ្មពិលឬរេស៊ីស្ដរនោះ ។
- ភ្ជាប់វាដោយឱ្យចរន្តចូលតាមគោល ( + ) និងចេញតាមគោល (–) ។

យើងអានតម្លៃលេខដែលយើងវាស់បាននៅលើមុខរបស់វាដូចគ្នានឹងអំពែម៉ែតដែរ ។

យើងអាចគណនាតង់ស្យុងបានតាមរូបមន្ត :

$$V = Cal \times \frac{n}{n_0}$$

$n$ ជាចំនួនប្រលោះក្រិត

$n_0$ ជាចំនួនប្រលោះក្រិតសរុប

$Cal$ កាលីបនៃវ៉ុលម៉ែត

$V$ ជាតង់ស្យុងគិតជា V ។

***ឧទាហរណ៍ :*** វ៉ុលម៉ែតមួយមានកាលីប 10V , 5V , 3V ។ វ៉ុលម៉ែតនោះមានប្រលោះក្រិតសរុប $n_0 = 100$ នៅពេលពិសោធន៍គេឃើញទ្រនិចមានលំងាក 25 ប្រលោះក្រិត 80 ប្រលោះក្រិតនិង 15 ប្រលោះក្រិត ។

គណនាតង់ស្យុងដែលវាស់បានដោយប្រើកាលីបនីមួយៗ

- ចំពោះកាលីប 10V ទ្រនិចងាកបាន 25 ប្រលោះក្រិត
  គេបាន : $V_1 = 10\text{V} \times \frac{25}{100} = 2.5\text{V}$
- ចំពោះកាលីប 5V ទ្រនិចងាកបាន 80 ប្រលោះក្រិត
  គេបាន : $V_2 = 5\text{V} \times \frac{80}{100} = 4\text{V}$
- ចំពោះកាលីប 3V ទ្រនិចងាកបាន 15 ប្រលោះក្រិត
  គេបាន : $V_3 = 3\text{V} \times \frac{15}{100} = 0.45\text{V}$ ។

## ឃ. ច្បាប់បូកតង់ស្យុង

គេមានរេស៊ីស្តរពីរ $R_1$ និង $R_2$ តជាស៊េរី ។ វ៉ុលម៉ែត $V_1$ វាស់តង់ស្យុង $V_{MP}$ នៃរេស៊ីស្តរ $R_1$ វ៉ុលម៉ែត $V_2$ វាស់តង់ស្យុង $V_{PN}$ នៃរេស៊ីស្តរ $R_2$ និងវ៉ុលម៉ែត $V$ វាស់តង់ស្យុង $V_{MN}$ នៃរេស៊ីស្តរពីរ ។

គេបាន : $V_{MN} = V_{MP} + V_{PN}$ ។




***រូបទី 3.23 ផលបូកតង់ស្យុងនៃរេស៊ីស្តរតជាស៊េរី***

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

# 2. ម៉ាញេទិច

## 2.1 ដែនម៉ាញេទិចបង្កើតដោយចរន្តអគ្គិសនី

### ក. ដែនម៉ាញេទិចនៃចរន្តត្រង់

ខ្សែចម្លងត្រង់មួយត្រូវបានដាក់ទម្លុះក្រដាសកាតុងត្រង់ចំណុចកណ្ដាល $O$ ។ គេធ្វើឱ្យចរន្តអគ្គិសនី $I$ ឆ្លងកាត់ខ្សែចម្លង ។ ចរន្តនោះបានបង្កើតនៅជុំវិញវានូវដែនម៉ាញេទិច ។ ដើម្បីពិនិត្យមើលទិស និងទិសដៅនៃដែនម៉ាញេទិចត្រង់ចំនុច $M$ មួយក្នុងដែន គេដាក់ត្រីវិស័យមួយនៅត្រង់ $M$ នោះត្រីវិស័យនោះវិលបានបន្តិចហើយក៏មានលំនឹង ។ ប៉ូលជើង $N$ នៃត្រីវិស័យនោះចង្អុលទិសដៅនៃវ៉ិចទ័រដែនម៉ាញេទិច $\vec{B}$ ។ ដូច្នេះដែនម៉ាញេទិច $\vec{B}$ នៅត្រង់ $M$ មាន :

- ទិសកែងនឹងប្លង់ដែលកើតឡើងរវាងខ្សែចម្លងនិងខ្សែទម្រ $SN$ ។
- ទិសដៅឱ្យតាមវិធានកណ្ដាប់នៃស្ដាំដែលមេដៃចង្អុលតាម $I$ និងទិសដៅរបស់ $\vec{B}$ ដូចទិសដៅរបស់ម្រាមដៃដែលក្ដាប់(រូបទី 3.24) ។



**រូបទី 3.24 ដែនម៉ាញេទិចនៃចរន្តត្រង់**

បើគេយកកម្ទេចដែកទៅរោយនៅលើក្រដាសកាតុង គេឃើញកម្ទេចដែកតម្រៀបគ្នាជារង្វង់បន្តបន្ទាប់គ្នានិងមានផ្ចិតរួម ។ គេសន្និដ្ឋានថាខ្សែដែនម៉ាញេទិចមានរាងជារង្វង់ ទិសដៅនៃខ្សែដែនម៉ាញេទិចត្រូវបានកំណត់ទៅតាមទិសដៅនៃវ៉ិចទ័រដែន ។ សំណុំខ្សែដែនម៉ាញេទិចហៅថា **ស្ប៉ិចម៉ាញេទិច** ។

### ខ. ដែនម៉ាញេទិចនៃចរន្តវង់

ខ្សែចម្លងមួយត្រូវបានដាក់ទម្លុះក្រដាសកាតុងត្រង់2ចំណុច $P$ និង $Q$ ។បន្ទាប់មក គេធ្វើឱ្យចរន្តអគ្គិសនីឆ្លងកាត់ខ្សែចម្លង ចរន្តនោះបានបង្កើតជុំវិញវានូវដែនម៉ាញេទិច ។

ដើម្បីកំណត់ទិសដៅនៃដែនម៉ាញេទិចត្រង់ផ្ចិត $O$ គេដាក់ត្រីវិស័យមួយនៅត្រង់ $O$ ។ ពេលនោះប៉ូលជើងនៃត្រីវិស័យចង្អុលទិសដៅនៃវ៉ិចទ័រដែន $\vec{B}$ ត្រង់ផ្ចិត $O$ ។ បើគេរោយកម្ទេចដែកនៅលើកាតុង គេឃើញកម្ទេចដែកតម្រៀបគ្នាជារង្វង់ជាប់ៗគ្នាមានផ្ចិតរួម $P$ និង$Q$ ។



**រូបទី 3.25 ដែនម៉ាញេទិចនៃចរន្តវង់**

គេឃើញមានខ្សែដែនតែមួយគត់ត្រង់ផ្ចិត $O$ នៃខ្សែចម្លងវង់ជាបន្ទាត់ ។ គេអាចបង្ហាញទិសដៅដែនម៉ាញេទិចតាមមួយបែបទៀតដោយប្រើវិធាន មុខត្បូង $S$ និងមុខជើង $N$ (រូបទី 3.25) ។ ទិសដៅនៃខ្សែដែនចូលតាមមុខត្បូងហើយចេញតាមមុខជើង(រូបទី 3.26) ។

- មុខត្បូងជាមុខដែលគេមើលចំឃើញចរន្តមានទិសដៅតាមទិសដៅទ្រនិចនាឡិកា(រូបទី 3.26 ក) ។
- មុខជើងជាមុខដែលគេមើលចំឃើញចរន្តមានទិសដៅផ្ទុយពីទិសដៅទ្រនិចនាឡិកា(រូបទី 3.26 ខ) ។



**រូបទី** 3.26

## គ. ដែនម៉ាញេទិចនៃសូលេណូអ៊ីត

សូលេណូអ៊ីតជាបូប៊ីនត្រូវបានបង្កើតពីខ្សែចម្លងមួយយ៉ាងវែងរុំជាស្ពៀស្មើសាច់លើស៊ីឡាំងមួយដែលមានប្រវែងបណ្តោយធំជាងកាំរបស់វាចាប់ពី 5 ដងឡើងទៅ ។



**រូបទី** 3.27

កាលណាគេធ្វើឱ្យចរន្តឆ្លងកាត់សូលេណូអ៊ីតនោះ វាបានបង្កើតនៅក្នុងសូលេណូអ៊ីតនូវដែនម៉ាញេទិច $\vec{B}$ ។

បើគេរោយកម្ទេចដែកនៅលើក្រដាសកាតុងគេឃើញកម្ទេចដែកតម្រៀបគ្នាជាជួរ គេសន្និដ្ឋានថា ខ្សែដែនម៉ាញេទិចនៅក្នុងសូលេណូអ៊ីតជាបន្ទាត់ស្របៗគ្នា(រូបទី 3.27) ។ ដែនម៉ាញេទិចក្នុងសូលេណូអ៊ីតជាដែនម៉ាញេទិចឯកសណ្ឋាន ។

ទិសដៅនៃវ៉ិចទ័រដែនម៉ាញេទិច$\vec{B}$ ក្នុងសូលេណូអ៊ីតអាចរកតាមវិធានមុខត្បូង$S$ និងមុខជើង $N$ ឬតាមវិធានដៃស្តាំដែលម្រាមដៃក្តាប់ទិសដៅនៃចរន្ត និង $\vec{B}$ មានទិសដៅដូចទិសដៅរបស់មេដៃ ។ គេអាចប្រដូចស្ពិចម៉ាញេទិចដែលបង្កើតដោយសូលេណូអ៊ីតទៅនឹងរបាយមេដែក(រូបទី 3.28) ។



**រូបទី** 3.28 **ដែនម៉ាញេទិចនៃរបាមេដែក**

## 2.2 ទំនាក់ទំនងរវាងដែនម៉ាញេទិច $B$ និងអាំងតង់ស៊ីតេចរន្ត $I$

គេយកតែក្នុងករណីសូលេណូអ៊ីតមកសិក្សាដោយស៊កបញ្ចូលស្នូលដែកមួយនៅក្នុងសូលេណូអ៊ីត គេធ្វើពិសោធន៍ដូចតទៅនេះ :

- គេស៊កស្នូលដែកទៅក្នុងសូលេណូអ៊ីត រួចគេយកវាទៅដាក់ក្បែរម្ទុលដែក ។ ពេលដែលគេធ្វើឱ្យចរន្តឆ្លងកាត់ សូលេណូអ៊ីត គេឃើញស្នូលដែកនោះបានឆក់កម្ទេចដែកមកតោងជាប់ចុងរបស់វាដូច(រូបទី 3.29. ក) ។
- គេរក្សាចំនួនជុំ និងស្នូលដែកឱ្យនៅដដែលដូច(រូបទី 3.29. ក) ប៉ុន្តែគេដំឡើងអាំងតង់ស៊ីតេចរន្ត គេឃើញស្នូលដែកនោះឆក់កម្ទេចដែកច្រើនជាងមុនដូច(រូបទី 3.29. ខ) ។ ត្រង់នេះបង្ហាញថា ដែនម៉ាញេទិចក្នុងស្នូលដែកនោះកើនឡើង ។
- គេរក្សាអាំងតង់ស៊ីតេចរន្តនិងស្នូលដែកឱ្យនៅដដែលដូច (រូបទី 3.29. ក) រួចគេបន្ថែមចំនួនជុំ គេក៏ឃើញស្នូលដែកនោះឆក់កម្ទេចដែកច្រើនជាងមុនដែរ ។ ត្រង់នេះក៏បង្ហាញថាដែនម៉ាញេទិចក្នុងស្នូលដែកកើនឡើងដូច(រូបទី 3.29. គ) ។
- គេរក្សាអាំងតង់ស៊ីតេចរន្ត និងចំនួនជុំឱ្យនៅដដែល ប៉ុន្តែគេប្តូរស្នូលដែក គេឃើញស្នូលដែកឆក់ទាញកម្ទេចដែកមានចំនួនខុសគ្នាដែរ ។



រូបទី 3.29

តាមពិសោធន៍ខាងលើនេះ គេអាចធ្វើការសន្និដ្ឋានថា ដែនម៉ាញេទិចក្នុងស្នូលដែកអាស្រ័យនឹងអាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់ ចំនួនជុំនៃរបុំខ្សែចម្លងនិងធម្មជាតិនៃស្នូលដែក ។

## 2.3 បន្ស៊ីនិងបន្សាបមេដែក

### ក. បន្ស៊ីមេដែក

- **បន្ស៊ីមេដែកដោយប៉ះ**

កាលណាគេយករូបធាតុដែលមិនទាន់ក្លាយជាមេដែក (ដូចជាដែកថែប)ទៅដាក់ឱ្យប៉ះឬត្រូវបង្ខិតទៅជិតប៉ូលនៃមេដែកអចិន្ត្រៃយ៍វាត្រូវបានឆក់ទាញទៅរកមេដែក ហើយក្លាយជាមេដែកដោយខ្លួនឯង ។ គេថារូបធាតុត្រូវបានបន្ស៊ីទៅជាមេដែក ។



របារមេដែកអចិន្ត្រៃយ៍ របារដែកថែបក្លាយជាមេដែក

**រូបទី 3.30 ការបន្ស៊ីមេដែក**

- **បន្សុីមេដែកដោយត្រដុស**

គេប្រើចុងនៃមេដែកមួយទៅត្រដុសពីលើរបារដែកថែបដែលមិនទាន់ក្លាយជាមេដែកពីចុងម្ខាងទៅចុងម្ខាងទៀតជាច្រើនដងទៅតាមទិសដៅតែមួយដោយប្រើប៉ូលដដែល(ក្នុងករណីនេះគឺគេប្រើប៉ូលជើង N) របស់មេដែកអចិន្ត្រៃយ៍ដូច(រូបទី *3.31*) ពេលនោះរបារមេដែកថែបក៏ក្លាយជាមេដែក ។




***រូបទី** 3.31 **ការបន្សុីមេដែកដោយត្រដុស***

## ខ. បន្សាបម៉ាញេទិចនៃមេដែក

បន្សាបលក្ខណៈម៉ាញេទិចនៃមេដែក គឺជាដំណើរការបំបាត់ដែនម៉ាញេទិចឱ្យចេញពីមេដែក ។ វិធីខ្លះៗក្នុងការបន្សាបលក្ខណៈម៉ាញេទិចរបស់មេដែកមាន ការដុតកម្ដៅ ដំ និងការប្រើចរន្តឆ្លាស់ ។

**វិធីដុតកម្ដៅ**

បើយើងកម្ដៅមេដែកឱ្យក្ដៅខ្លាំងដោយប្រើអណ្ដាតភ្លើងប៊ុនសិន មេដែកនឹងបាត់លក្ខណៈម៉ាញេទិចយ៉ាងលឿន ។ នេះដោយសារកំណើនលំញ័ររបស់អាតូមមេដែកដែលបណ្ដាលឱ្យមេដែកតូចៗបាត់បង់នូវការតម្រៀបជាជួររបស់វា ។ ពេលនោះលក្ខណៈម៉ាញេទិចត្រូវបានបំបាត់ ។

**វិធីដំ**

ការដំដោយប្រើញញួរបណ្ដាលឱ្យមេដែកតូចបាត់ការតម្រៀបគ្នាជាជួររបស់វា ហើយធ្វើឱ្យវាបាត់បង់លក្ខណៈម៉ាញេទិច ។

**វិធីប្រើចរន្តអគ្គិសនី**

ជាវិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការបំបាត់លក្ខណៈម៉ាញេទិចដោយយកមេដែកទៅ ដាក់ទៅក្នុងសូលេណូអ៊ីតដែលភ្ជាប់ទៅនឹងចរន្តឆ្លាស់(ប្រភពចរន្តឆ្លាស់)ហើយមេដែកត្រូវទាញចេញយឺតៗពីសូលេណូអ៊ីតដែលមានចរន្តឆ្លាស់ឆ្លងកាត់ ពេលនោះលក្ខណៈម៉ាញេទិចរបស់វាត្រូវបានបំបាត់ ។

# 2.4 ប៉ូលនៃមេដែក

កាលណាគេរោយម្ជុលដែកថែបទៅលើរបារមេដែកមួយ គេឃើញម្ជុលទាំងនោះត្រូវបានឆក់ទាញដោយចុងទាំងពីររបស់មេដែក ។ យើងហៅចុងទាំងពីរនោះជាប៉ូលរបស់មេដែក ។



***រូបទី** 3.32 **បង្ហាញពីទីតាំងរបស់ប៉ូលមេដែក***

## ក. ប៉ូលជើងនិងប៉ូលត្បូង



រូបទី 3.33 របារមេដែករិលដោយសេរី

គេធ្វើឱ្យរបារមេដែករិលដោយសេរីនៅក្នុងខ្យល់ ។

កាលណារបារមេដែកនៅនឹងចុងម្ខាងរបស់វាចង្អុលទៅរកប៉ូលជើងនៃផែនដី ។ គេហៅចុងនោះថា ប៉ូលជើងរបស់របារមេដែក ។ ចំណែកប៉ូលម្ខាងទៀតហៅថាប៉ូលត្បូង ។ គេតាងប៉ូលជើងដោយអក្សរ N និងប៉ូលត្បូងដោយអក្សរ S ។

គេអាចកំណត់ប៉ូលជើងនៃមេដែកដោយលាបពណ៌ក្រហមហើយប៉ូលត្បូងដោយលាបពណ៌ខៀវ ។

តាមពិសោធន៍យើងឃើញថា មេដែកពីរមានឈ្មោះប៉ូលដូចគ្នា ច្រានគ្នាចេញហើយមានឈ្មោះប៉ូលផ្ទុយគ្នាទាញគ្នាចូល ។

## ខ. ទ្រឹស្តីម៉ាញេទិច

បើគេយករបារមេដែកស្តើងមួយទៅកាត់វាជាបីកំណាត់តូចៗ គេសង្កេតឃើញកំណាត់នីមួយៗរបស់មេដែកមានប៉ូល N និង S ដូចរូបខាងក្រោមនេះ :



រូបទី 3.34 កំណាត់នីមួយៗ នៃរបារមេដែកថែបគឺមេដែក

ដូច្នេះបើគេបន្តកាត់ផ្នែកនីមួយៗ ឱ្យកាន់តែតូចទៅៗ វានៅតែមានលក្ខណៈម៉ាញេទិចដដែល ។គេអាចសន្មតថា មេដែកដើមផ្សំឡើងពីមេដែកតូចៗដែលមានប៉ូល N ចង្អុលតាមទិសដៅតែមួយដូច(រូបទី 3.34 ក) ។



(ក)
របារមេដែកមានលក្ខណៈម៉ាញេទិច

តាមរូបនេះមេដែកតូចៗនៅខាងចុងរបារមេដែកញែកចេញពីគ្នាដោយសារតែវាច្រានគ្នាទៅវិញទៅមករវាងប៉ូលដូចគ្នា ។

ចំពោះរបារមេដែកមិនមានលក្ខណៈម៉ាញេទិច គេថាមេដែកតូចៗចង្អុលតាមទិសដៅឥតសណ្តាប់ធ្នាប់(រូបទី 3.34 ខ) ។

ពេលនេះផលម៉ាញេទិចផ្តួបនៃមេដែកតូចទាំងអស់ត្រូវលុបបំបាត់ ។


(ខ)
របារមេដែកគ្មានលក្ខណៈម៉ាញេទិច

## មេរៀនសង្ខេប

- ចរន្តជាប់ជាចរន្តនៃបន្ទុកអគ្គិសនីដែលផ្លាស់ទីឆ្លងកាត់ខ្សែចម្លងតាមទិសដៅកំណត់មួយ ។
- ចរន្តអគ្គិសនីកើតមានក្នុងលោហៈ អេឡិចត្រូលីតនិងក្នុងសីមីកុងឌុចទ័រប្រភេទ $p$ និង $n$ ។ អាំងតង់ស៊ីតេចរន្តអគ្គិសនីឱ្យតាមរូបមន្ត : $I = \frac{Q}{t}$ តែ $Q = n \times e$ ។
- ចរន្តអគ្គិសនីមានទិសដៅតាមទិសដៅបំលាស់ទីនៃបន្ទុកអគ្គិសនីវិជ្ជមានឬតាមទិសដៅផ្ទុយពីទិសដៅបំលាស់ទីនៃអេឡិចត្រុងសេរី ។ គេអាចនិយាយថាចរន្តអគ្គិសនីមានទិសដៅពីប៉ូល(+)ទៅប៉ូល (– ) នៃជនិតា ។
- គេគណនាអាំងតង់ស៊ីតេដែលវាស់បានដោយប្រើអំពែម៉ែត តាមរូបមន្ត

  $$\boxed{I = Cal\frac{n}{n_0}}$$ ។

- ក្នុងករណីអង្គធាតុចម្លងតជាខ្នែង គេបានអាំងតង់ស៊ីតេចរន្តដើមស្មើនឹងផលបូកអាំងតង់ស៊ីតេចរន្តបែង : $\boxed{I = I_1 + I_2 + \ldots + I_n}$ ។
- គេគណនាតង់ស្យុងដែលវាស់បានដោយប្រើអំពែម៉ែត តាមរូបមន្ត :

  $$\boxed{V = Cal\frac{n}{n_0}}$$ ។

- ក្នុងករណីអង្គធាតុចម្លងតជាសេរី គេបានច្បាប់តង់ស្យុង : $\boxed{V = V_1 + V_2 + \ldots + V_n}$ ។
- កាលណាចរន្តឆ្លងកាត់ខ្សែចម្លង នោះនៅជុំវិញវាមានដែនម៉ាញេទិច ។ ដើម្បីកំណត់ទិសដៅនៃដែនម៉ាញេទិច គេប្រើវិធានដៃស្តាំ ឬវិធានមុខត្បូង $(S)$ និងមុខជើង $(N)$ នៃត្រីវិស័យ ។
- ស្ប៉ិចម៉ាញេទិច គឺជាសំណុំខ្សែដែនម៉ាញេទិចជុំវិញខ្សែចម្លងឆ្លងកាត់ដោយចរន្តឬមេដែក ។
- ដើម្បីបង្កើនដែនម៉ាញេទិចនៃសូលេណូអ៊ីតមួយ គេត្រូវបង្កើន អាំងតង់ស៊ីតេ ចំនួនជុំនៃរបុំខ្សែចម្លងនិងប្តូរធម្មជាតិនៃស្នូលដែក ។
- ដែនម៉ាញេទិចបង្កើតដោយចរន្ត មានដែនម៉ាញេទិចចរន្តត្រង់ ដែនម៉ាញេទិចចរន្តវង់និងដែនម៉ាញេទិចនៃចរន្តឆ្លងកាត់សូលេណូអ៊ីត ។
- ដើម្បីកំណត់ទិសដៅនៃដែនម៉ាញេទិចត្រង់ចំណុចណាមួយគេត្រូវប្រើត្រីវិស័យ ព្រោះប៉ូលជើង N នៃត្រីវិស័យកំណត់ទិសដៅនៃវ៉ិចទ័រដែនត្រង់ចំណុចនោះ ។

## សំណួរនិងលំហាត់

1. តើធម្មជាតិនៃចរន្តអគ្គិសនីក្នុងលោហៈ ក្នុងអេឡិចត្រូលីតជាចរន្តអ្វី ?
2. ចូរអ្នកឱ្យនិយមន័យចរន្តអគ្គិសនីជាប់ ។
3. តើគេកំណត់ទិសដៅនៃចរន្តជាប់ដោយវិធីណាខ្លះ ?
4. តើគេប្រើឧបករណ៍អ្វីដើម្បីវាស់អាំងតង់ស៊ីតេចរន្ត ?
5. ចូរអ្នកឱ្យពំនោលច្បាប់អាំងតង់ស៊ីតេចរន្ត ។
6. តើបន្ទុកចល័តក្នុងលោហៈមានអ្វីខ្លះ ? តើវាផ្លាស់ទីតាមទិសដៅណាកាលណាគេឱ្យចរន្តឆ្លងកាត់លោហៈនោះ ?
7. ថ្មពិលអគ្គិសនីមួយបានបញ្ចេញចរន្តអគ្គិសនីដែលមានអាំងតង់ស៊ីតេ $I = 0.2\text{A}$ ក្នុងរយៈពេល 24h ។ តើបរិមាណអគ្គិសនីដែលឆ្លងកាត់ថ្មពិលមានតម្លៃស្មើនឹងប៉ុន្មាន ?
8. គេឱ្យសៀគ្វីមួយដូចរូប ។គេវាស់តង់ស្យុងដោយប្រើវ៉ុលម៉ែត

   $V_{AO} = 12V$ , $V_{CO} = 10V$ , $V_{AB} = 20V$

   កំណត់តង់ស្យុង $V_{AC}$ , $V_{BO}$ , $V_{BC}$ ។




9. ចូរអ្នកពណ៌នាពីដែនម៉ាញេទិចចរន្តត្រង់ ។
10. ចូរអ្នកពណ៌នាពីដែនម៉ាញេទិចចរន្តរង្វង់ ។
11. ចូរអ្នកពណ៌នាពីដែនម៉ាញេទិចនៃសូលេណូអ៊ីត ។
12. បើគេយកស្នូលដែកមួយទៅស៊កបញ្ចូលក្នុងសូលេណូអ៊ីតមួយឆ្លងកាត់ដោយចរន្ត តើស្នូលដែកនោះអាចឆក់កម្ទេចដែកបានដែរឬទេ ?
13. តើដែនម៉ាញេទិចក្នុងស្នូលដែកដាក់ក្នុងសូលេណូអ៊ីតឆ្លងកាត់ដោយចរន្តអាស្រ័យនឹងអ្វីខ្លះ?
14. តើមេដែកមានលក្ខណៈអ្វីបានជាអាចឆក់កម្ទេចដែក ?
15. តើសារធាតុអ្វីខ្លះ ដែលគេអាចបន្សុំវាទៅជាមេដែក ហើយសារធាតុអ្វីខ្លះដែលមិនអាចបន្សុំទៅជាមេដែក ។
16. តើសារធាតុណាដែលអាចបន្សុំវាឱ្យទៅជាមេដែកអចិន្ត្រៃយ៍ ?
17. តើដែកសុទ្ធអាចបន្សុំវាឱ្យទៅជាមេដែកអចិន្ត្រៃយ៍ដែរឬទេ ? ព្រោះអ្វី ?
18. បើគេយកមេដែកស្តើងមួយទៅកាត់ជាបីកំណាត់ តើកំណាត់នីមួយៗរបស់មេដែកមានប៉ូល N និង S ដែរឬទេ ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

19. ចូរអ្នកបញ្ជាក់ពីការបន្ទុំមេដែកដោយប្រើវិធីត្រដុស ។

20. តើគេប្រើវិធីអ្វីខ្លះ ដើម្បីបន្សាបមេដែក?

21. តើត្រូវធ្វើដូចម្តេចដើម្បីបង្ហាញពីស្ប៉ិចម៉ាញេទិចនៃរបារមេដែក ?

22. ចូរអ្នកបញ្ជាក់ពីស្ប៉ិចម៉ាញេទិចនៃសូលេណូអ៊ីតទាំងក្នុងទាំងក្រៅ ។

23. តើគេត្រូវមានវិធានអ្វីខ្លះ ដើម្បីកំណត់ទិសដៅនៃដែនម៉ាញេទិចក្នុងសូលេណូអ៊ីត ?

24. អង្គធាតុចម្លងមួយឆ្លងកាត់ដោយចរន្ត $I = 5.9\text{A}$ ។ គណនាបរិមាណអគ្គិសនីដែលឆ្លងកាត់មុខកាត់នៃអង្គធាតុចម្លងក្នុងរយៈពេល $t = 12.2\text{s}$ ។

25. រកចំនួនអេឡិចត្រុងដែលឆ្លងកាត់ផ្ទៃមុខកាត់នៃអង្គធាតុចម្លងមួយ ដែលអាំងតង់ស៊ីតេចរន្ត $I = 2\text{mA}$ ឆ្លងកាត់ក្នុងរយៈពេល $t = 16\times10^{-6}\text{s}$ ។ គេឱ្យ $e = 1.6\times10^{-19}\text{C}$ ។

26. គេឱ្យខ្សែចម្លងទង់ដែងមួយមានប្រវែង $L = 50\text{cm}$ និងមានអង្កត់ផ្ចិត $d = 1\text{mm}$ ។ ម៉ាសមាឌនៃទង់ដែង $\rho = 8900\text{kg/m}^3$ ។

ក. គណនាម៉ាសនៃខ្សែទង់ដែង ។

ខ. គេសន្មតថាមួយអាតូមទង់ដែងមានអេឡិចត្រុងសេរីមួយឆ្លងកាត់ខ្សែចម្លង ។ គេដឹងថា $63.5\text{g}$ នៃទង់ដែងមាន $6\times10^{23}$ អាតូមទង់ដែង ។គណនាចំនួនអេឡិចត្រុង $n$ ក្នុងខ្សែចម្លង ។

គ. គណនាបរិមាណបន្ទុកអគ្គិសនី $Q$ សរុបក្នុងខ្សែចម្លង ។

27. គេធ្វើឱ្យជើងវិភាគមួយមានសូលុយស្យុងស៊ូតដំណើរការអស់រយៈពេល $t = 10\text{mm}$ ។ អាំងតង់ស៊ីចរន្តមានតម្លៃ $I = 1.2\text{A}$ ។ គណនាបរិមាណអគ្គិសនីឆ្លងកាត់ជើងវិភាគ ។

28. ទិសដៅនៃចរន្តអគ្គិសនីត្រូវឱ្យដូចរូបខាងក្រោម :

ក. ប្រាប់ប៉ូលនៃជនិតា ។

ខ. ចូរបង្ហាញទិសដៅបំលាស់ទីនៃអេឡិចត្រុងក្នុងខ្សែចម្លង ។




29. គេឱ្យសៀគ្វីមួយដូចរូប ។ គេវាស់ : $V_3 = 24\text{V}$ , $V_{BC} = 8\text{V}$

កំណត់តម្លៃតង់ស្យុង $V_{AB}$ និង $V_{PN}$ ។




youtube.com/moeys
www.moeys.gov.kh
facebook.com/moeys.gov.kh

**30.** គេឱ្យសៀគ្វីមួយដូចរូប ។ គេស្គាល់ $V_{AB} = 3.5\text{V}$ , $V_{BC} = 5.2\text{V}$ $V_{FE} = 2.7\text{V}$ ។

**ក.** គណនាតង់ស្យុង $V_{BE}$ និង $V_{ED}$

**ខ.** ទាញរកទិសដៅចរន្តក្នុងឌីប៉ូល $BE$ ។




youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 3 ចរន្តឆ្លាស់

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពោលនិយមន័យនៃចរន្តឆ្លាស់ *AC* ។
- ❒ ពន្យល់ពីគ្រោះថ្នាក់និងការឆក់ដោយចរន្តអគ្គិសនី ។
- ❒ ពន្យល់ពីគោលការណ៍ត្រង់ស្វូ ។
- ❒ រៀបរាប់ពីជនិតា *AC* ។

## 1. ធម្មជាតិនៃចរន្តឆ្លាស់

### 1.1 ភាពខុសគ្នារវាងចរន្តជាប់ *DC* និងចរន្តឆ្លាស់ *AC*

គេយកឌីយ៉ូតពីរ(*LED*) *A* និង *B* ទៅតជាខ្នែងដោយដាក់វាបញ្ច្រាសប៉ូលគ្នា រួចយកចុងទាំងពីរនៃបង្គុំទៅភ្ជាប់និងបាតឺរី (រូបទី 3.35.ក) ។ ពេលនោះគេឃើញឌីយ៉ូត *B* បន្សាយពន្លឺហើយឌីយ៉ូត *A* ពុំបន្សាយពន្លឺទេ ។ ចរន្តជាប់ *DC* បង្ហាញនូវលទ្ធផលនេះដូចដែលយើងបានសិក្សារួចមកហើយក្នុងមេរៀនមុន ។ ប៉ុន្តែបើគេភ្ជាប់ចុងទាំងពីរនៃបង្គុំប្រព័ន្ធឌីយ៉ូតទៅនិងឌីណាម៉ូនៃទោចក្រយានដែលផ្តល់នូវចរន្តឆ្លាស់*AC* វិញ គេឃើញឌីយ៉ូតទាំងពីរបន្សាយពន្លឺ(រូបទី 3.35.ខ) ។



*រូបទី 3.35 ឌីណាម៉ូទោចក្រយាន*

កាលណាល្បឿនរង្វិលយឺត គេសង្កេតឃើញថាឌីយ៉ូតមួយមិនភ្លឺទេនៅពេលដែលឌីយ៉ូតមួយទៀតកំពុងភ្លឺ ហើយឌីយ៉ូតមួយទៀតភ្លឺពេលដែលឌីយ៉ូតមួយទៀតមិនភ្លឺ ។ ត្រង់នេះបង្ហាញថាចរន្តអគ្គិសនីផ្តល់ដោយឌីណាម៉ូទោចក្រយានពុំមានទិសដៅតែមួយដូចចរន្តជាប់ទេ ប៉ុន្តែទិសដៅបំលាស់ទីរបស់វាត្រូវប្តូរគ្រប់ខណៈ ។

ដូច្នេះគេថាចរន្តនេះជាចរន្តឆ្លាស់ដែលគេតាងដោយ *AC* ។ ចរន្តអគ្គិសនីដែលផ្តល់ដោយរោងចក្រអគ្គិសនីផ្គត់ផ្គង់ឱ្យយើងប្រើប្រាស់សព្វថ្ងៃក៏ជាចរន្ត*AC* ដែរ ។

## 1.2 ជនិតាឯកទិស$DC$ និងចរន្តឆ្លាស់$AC$

ដើម្បីផលិតចរន្តឆ្លាស់ $AC$ ក្នុងរោងចក្រអគ្គិសនី គេត្រូវការតួប៊ីនដែលរ៉ូទ័រជាមេដែក វិល ជុំវិញរបុំខ្សែចម្លង(បូប៊ីន)(រូបទី 3.35. ខ) ។

ជនិតានេះបង្កើតចរន្ត $AC$ កាលណារ៉ូទ័រវិល ។ នៅខណៈណាមួយដែលរ៉ូទ័រកំពុងវិលទិសដៅនៃចរន្តអាំងឌុីប្តូរ កាលណាប៉ូលនៃមេដែកប្តូរ (ទិសដៅនៃចរន្តប្តូរទៅតាមប៉ូលនៃមេដែក) ។លំយោលតង់ស្យុងនិងចរន្តជាអនុគមន៍ស៊ីនុយសូអ៊ីតនៃពេល ។ **ដូច្នេះប្រេកង់រង្វិលនៃរ៉ូទ័រដូចគ្នានឹងប្រេកង់លំយោលនៃចរន្ត ។ នៅប្រទេសកម្ពុជាប្រេកង់លំយោលនៃតង់ស្យុងនិងចរន្តស្មើនឹង 50Hz ។**

យើងអាចបង្ហាញតង់ស្យុងនេះដូចខាងក្រោម :




*រូបទី3.36 ទំនាក់ទំនងទីតាំងរង្វិលនៃមេដែកធៀបនិងតង់ស្យុងដែលបង្កើត*

តង់ស្យុងដែលបង្កើតមានតម្លៃអតិបរមា $V_o = E_o$ កាលណាមេដែក (រ៉ូទ័រ)វិល ស្របនឹងបូប៊ីនហើយវាមានតម្លៃ 0 កាលណាប្លង់មេដែកកែងនិងបូប៊ីន(រូបទី 3.35. ខ) ។

ទំនាក់ទំនងរវាងប្រេកង់រង្វិល $f$ និងខួប $T$ : $\boxed{f = \frac{1}{T}}$

$T$ ខួបគិតជាវិនាទី (s) និង $f$ ប្រេកង់គិតជាអ៊ែក (Hz) ។

- ប្រសិនបើគេបង្កើនចំនួនជុំនៃបូប៊ីនរុំលើស្នូលដែក2ដង តែរក្សាប្រេកង់រង្វិលមេដែក(រ៉ូទ័រ) នៅដដែលនោះតង់ស្យុងបញ្ចេញ $V$ មានរាងជារលកស៊ីនុយសូអ៊ីត ហើយមានអំព្លីទុតស្មើនឹង2ដងនៃអំព្លីទុតអតិបរិមាដែរដូចរូបខាងក្រោម :




*រូបទី3.37 បង្កើនចំនួនជុំ 2 ដង អំព្លីទុតកើន 2 ដងដែរ*

- ប្រសិនបើគេបង្កើនប្រេកង់រង្វិលរបស់រ៉ូទ័រ 2 ដង ប៉ុន្តែរក្សាចំនួនជុំឱ្យនៅដដែល ពេលនោះ អំព្លីទុតនៃតង់ស្យុងបញ្ចេញក៏កើនឡើង 2 ដងដែរដូចរូបខាងក្រោម :




***រូបទី 3.38 បង្កើនប្រេកង់ 2 ដង អំព្លីទុតកើន 2 ដងដែរ***

ក្រៅពីការបង្កើនប្រេកង់រង្វិលនៃម៉ូទ័រនិងចំនួនជុំខ្សែដែលរុំលើស្នូលដែក តង់ស្យុងដែលបង្កើតដោយជនិតាចរន្តឆ្លាស់ *AC* ក៏អាចកើនឡើងបានដែរ កាលណាគេប្រើមេដែកដែលមានដែនម៉ាញេទិចខ្លាំងជាងមុន ។

## 1.3 ការអនុវត្តចរន្តឆ្លាស់ *AC*

កាលណាចរន្ត *AC* ឆ្លងកាត់បូប៊ីនមួយ បូប៊ីនបានបង្កើតដែនម៉ាញេទិចនៅជុំវិញវា ។ ប៉ុន្តែទិសដៅនៃដែនម៉ាញេទិចនេះខុសពីទិសដៅនៃដែនអេឡិចត្រូមេដែកដែលបង្កើតដោយចរន្តជាប់ *DC* ពោលគឺទិសដៅដែនម៉ាញេទិចបង្កើតដោយចរន្តឆ្លាស់ ប្តូរឆ្លាស់គ្នាជាបន្តបន្ទាប់ទៅតាមបម្រែបម្រួលប្រេកង់នៃចរន្តឆ្លាស់ *AC* ។

ឧបករណ៍កត់ត្រាពេលបង្ហាញដូចរូបនេះបានប្រើម្តងរួចមកហើយក្នុងពិសោធន៍ទន្លាក់សេរី ។ ឧបករណ៍នេះផ្សំឡើងដោយបូប៊ីនមានស្នូលដែកនិងរបារដែកមួយ ។ កាលណាគេធ្វើឱ្យចរន្តឆ្លាស់ *AC* ដែលមានប្រេកង់ 50Hz ឆ្លងកាត់បូប៊ីនដែលមានស្នូលដែកវាក្លាយទៅជាអេឡិចត្រូមេដែក ។ គេឃើញរបារដែករលាស់ដោយប្រេកង់ដូចគ្នានឹងប្រេកង់លំយោលនៃចរន្ត *AC* ដែរ ។




***រូបទី*** *3.39*

ឧបករណ៍អគ្គិសនីផ្សេងៗទៀតដូចជាកណ្តឹងរោទិ៍អគ្គិសនីក៏មានដំណើរការស្រដៀងគ្នានឹងឧបករណ៍កត់ត្រាពេលនេះដែរ ។ ការអនុវត្តចរន្ត *AC* ផ្សេងទៀត គឺបង្កើតតង់ស្យុងដោយប្រើត្រង់ស្វូឬជុំភ្លើង ។

youtube.com/moeys
facebook.com/moeys.gov.kh

# 2. មុខងារនៃត្រង់ស្វូ

## 2.1 បង្គុំត្រង់ស្វូ

ត្រង់ស្វូ ផ្សំឡើងពីរបុំខ្សែចម្លងរុំលើស្នូលដែក(ស៊ុម) ដែលមានបន្ទះស្តើងៗដាក់តម្រៀបជាប់ៗគ្នាហើយខណ្ឌគ្នាដោយអ៊ីសូឡង់ ។ ស៊ុមដែកនេះមាននាទីបន្ថយកម្តៅនៅពេលចរន្តឆ្លងកាត់វា ។ នៅលើមុខឈមពីរនៃស៊ុមមានរបុំខ្សែចម្លងពីរដែលបង្កើតបានជាបូប៊ីនពីរដែលបូប៊ីនទី 1 ជារបុំបឋមនិងបូប៊ីនទី 2 ជារបុំមធ្យម ។




***រូបទី*** *3.40* ***ត្រង់ស្វូ***

ត្រង់ស្វូ ជាឧបករណ៍ដំឡើងឬតំហាយតង់ស្យុងឆ្លាស់ *AC* ពីតង់ស្យុងឆ្លាស់ទាបឱ្យទៅតង់ស្យុងឆ្លាស់ខ្ពស់ឬប្តូរពីតង់ស្យុងឆ្លាស់ខ្ពស់ឱ្យទៅជាតង់ស្យុងឆ្លាស់ទាប ។ ត្រង់ស្វូដែលដំឡើងតង់ស្យុងឆ្លាស់ពីទាបទៅតង់ស្យុងឆ្លាស់ខ្ពស់ ហៅថា **ស្វួកវ៉ុលទ័រ** ។ រីឯត្រង់ស្វូដែលតំហាយតង់ស្យុងឆ្លាស់ពីខ្ពស់ទៅតង់ស្យុងឆ្លាស់ទាប ហៅថា **ស្វូវ៉ុលទ័រ** ។

## 2.2 គោលការណ៍ដំណើរការ

ត្រង់ស្វូ បំប្លែងថាមពលអគ្គិសនីដែលផ្តល់ដោយរបុំបឋមទៅឱ្យរបុំមធ្យមដោយអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិចនៅចន្លោះបូប៊ីនទាំងពីរ ។

នៅរបុំបឋមតង់ស្យុងឆ្លាស់ដែលផ្តល់ឱ្យ ធ្វើឱ្យមានបម្រែបម្រួលដែនម៉ាញេទិចដែលបង្កើតឱ្យមានកម្លាំងអគ្គិសនីចលករនៅរបុំមធ្យម ។

ត្រង់ស្វូដំឡើងតង់ស្យុងជាផ្នែកមួយដែលកម្លាំងអគ្គិសនីចលករឬតង់ស្យុងនៅរបុំមធ្យមធំជាងរបុំបឋម ។ ផ្ទុយទៅវិញ ត្រង់ស្វូតំហាយតង់ស្យុងជាផ្នែកមួយដែលមានកម្លាំងអគ្គិសនីចលករឬតង់ស្យុងនៅរបុំបឋមធំជាងរបុំមធ្យម ។ គេបាន :

$$\boxed{\frac{V_s}{V_p} = \frac{N_s}{N_p}}$$

$V_s$ ជាតង់ស្យុងរបុំមធ្យម និង $V_p$ ជាតង់ស្យុងរបុំបឋមគិតជាវ៉ុល V

$N_s$ ជាចំនួនជុំ(ចំនួនស្ពៀ)របុំមធ្យម និង $N_p$ ជាចំនួនជុំ(ចំនួនស្ពៀ)របុំបឋម ។

- បើ $\frac{N_s}{N_p} > 1$ ត្រង់ស្វូដំឡើងតង់ស្យុងហៅថា **ស្វួកវ៉ុលទ័រ** ។
- បើ $\frac{N_s}{N_p} < 1$ ត្រង់ស្វូតំហាយតង់ស្យុងហៅថា **ស្វូវ៉ុលទ័រ** ។

## 2.3 អានុភាពបញ្ជូនក្នុងត្រង់ស្វូ

ចំពោះត្រង់ស្វូផ្តល់ទិន្នផល 100% មានន័យថា ថាមពលដែលផ្តល់ឱ្យទៅរបុំបឋមត្រូវបានបញ្ជូនទាំងអស់ទៅឱ្យរបុំមធ្យមដោយគ្មានបង់ខាតថាមពល ។

តាមគោលការណ៍រក្សាថាមពលគេបាន : $I_pV_p = I_sV_s$

ដោយ $P = VI$ គេអាចសរសេរ : $\dfrac{V_s}{V_p} = \dfrac{N_s}{N_p} = \dfrac{I_p}{I_s}$ ។

***ឧទាហរណ៍ 1:*** ត្រង់ស្វូមួយត្រូវបានប្រើដើម្បីផ្តល់តង់ស្យុង 12V ទៅឱ្យរថភ្លើងក្មេងលេងមួយ ។ តង់ស្យុងនេះផ្តល់អាំងតង់ស៊ីតេចរន្ត 0.8A ។ គណនាអាំងតង់ស៊ីតេចរន្តនៅរបុំបឋម បើតង់ស្យុងឆ្លាស់ $AC$ របស់ប្រភពគឺ 240V ។

**ដំណោះស្រាយ**

តាមច្បាប់រក្សាថាមពល

គេបាន : $I_pV_p = I_sV_s \Rightarrow I_p = \dfrac{I_sV_s}{V_p}$

អនុវត្តន៍ជាលេខ : $I_s = 0.8\text{A}$ , $V_s = 12\text{V}$ , $V_p = 240\text{V}$

គេបាន : $I_p = \dfrac{0.8 \times 12}{240} = 0.04\text{A}$

## 3. ការបញ្ជូនអានុភាពអគ្គិសនី

ការបញ្ជូននិងចែកចាយថាមពលអគ្គិសនីពីស្ថានីយទៅតាមគេហដ្ឋានតែងតែមានការបាត់បង់ថាមពលតាមខ្សែបណ្តាញ(ថាមពលកម្តៅឬផលស៊ូល $I^2R$ ) ។

ដើម្បីកាត់បន្ថយកំហាតថាមពល មធ្យោបាយទី 1 គឺត្រូវប្រើខ្សែដែលមានរេស៊ីស្តង់ $R$ តូច ពេលនោះអានុភាពបាត់បង់ក៏តិចតួចដែរ ។ មធ្យោបាយទី 2 គឺត្រូវបន្ថយចរន្តតាមរយៈការប្រើប្រាស់ត្រង់ស្វូដំឡើងតង់ស្យុងពេលបញ្ជូនអានុភាព ។

បើ $P_e$ ជាអានុភាពអគ្គិសនីបញ្ចេញត្រូវបានផ្តល់ដោយតង់ស្យុង $V$ ដែលភ្ជាប់ទៅខ្សែបណ្តាញដែលមានរេស៊ីស្តង់សរុប $R$ នោះចរន្ត $I$ ក្នុងខ្សែបណ្តាញគឺ :

$$I = \frac{P_e}{V}$$

$I$ អាំងតង់ស៊ីតេចរន្តគិតជាអំពែ (A) , $V$ តង់ស្យុងគិតជាវ៉ុល (V) និង $P_e$ អានុភាពអគ្គិសនីគិតជាវ៉ាត់ (W) ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

អានុភាពបាត់បង់ឱ្យតាមរូបមន្ត :

$$P_j = I^2R = \left(\frac{P_e}{V}\right)^2 \times R$$

$I$ អាំងតង់ស៊ីតេចរន្តគិតជាអំពែ (A) , $V$ តង់ស្យុងគិតជាវ៉ុល (V) ,$R$ រេស៊ីស្តង់អគ្គិសនីគិតជា (Ω) និង $P_e$ អានុភាពអគ្គិសនីគិតជាវ៉ាត់ (W) ។

***ឧទាហរណ៍ :*** ស្ថានីយអគ្គិសនីមួយអាចបញ្ចេញអានុភាព 100kW នៅតង់ស្យុង 20000V ទៅដល់រោងចក្រមួយដោយខ្សែកាបដែលមានរេស៊ីស្តង់សរុប $R = 5\Omega$ ។ គណនា :

ក. ចរន្តដែលឆ្លងកាត់ខ្សែបណ្តាញ

ខ. អានុភាពខាតបង់ក្នុងខ្សែបណ្តាញ ។

**ដំណោះស្រាយ**

ក. គណនាអាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់ខ្សែបណ្តាញ

គេបាន : $I = \frac{P_e}{V}$

អនុវត្តន៍ជាលេខ :$P_e = 10^5 W$ , $V = 2 \times 10^4$V

គេបាន : $I = \frac{10^5}{2 \times 10^4} = \frac{10}{2} = 5A$

ខ. អានុភាពខាតបង់ : $P_j = I^2R = (5)^2 \times 5 = 25 \times 5 = 125$W ។

## 4. សុវត្ថិភាពនៃការប្រើប្រាស់ចរន្តអគ្គិសនីក្នុងផ្ទះ

ទោះបីចរន្តអគ្គិសនីមានសារសំខាន់ក្នុងជីវភាពប្រចាំថ្ងៃយ៉ាងណាក៏ដោយ វាក៏ផ្តល់នូវគ្រោះថ្នាក់យ៉ាងខ្លាំងណាស់ដែរ ។ កំហុសឆ្គងក្នុងការតចរន្តអគ្គិសនីក្នុងឧបករណ៍ប្រើប្រាស់ឬសៀគ្វីអាចបណ្តាលឱ្យឆក់និងធ្វើឱ្យអ្នកប្រើប្រាស់ស្លាប់បាន ។

### ដើម្បីរក្សាសុវត្ថិភាព អ្នកប្រើប្រាស់ត្រូវប្រុងប្រយ័ត្នដូចខាងក្រោម :

- មិនត្រូវប៉ះពាល់គ្រឿងអគ្គិសនីនៅពេលដៃសើម ។
- មិនត្រូវប្រើគ្រឿងអគ្គិសនីច្រើនព្រមគ្នាដោយតភ្ជាប់ទៅនឹងឆ្នាប់ចរន្តតែមួយទេ ព្រោះវាបណ្តាលឱ្យខ្សែចម្លងឡើងក្តៅរលាយស្រោមអ៊ីសូឡង់ហើយប៉ះគ្នាបង្កើតឱ្យមានអគ្គីភ័យ ។
- មិនត្រូវឈរក្បែរបណ្តាញខ្សែកាបអគ្គិសនីពេលមានភ្លៀងផ្គរទេ ព្រោះខ្សែកាបអាចធ្លាក់ចុះទៅប៉ះនឹងដីសើមហើយអាចឆក់អ្នកបាន ។

youtube.com/moeys kroo.moeys.gov.kh facebook.com/moeys.gov.kh

- មុននឹងតចរន្តអគ្គិសនីទៅឧបករណ៍អគ្គិសនីណាមួយត្រូវផ្តាច់ចរន្តជាមុនសិន ។
- សៀគ្វីក្នុងផ្ទះត្រូវតែប្រើភុយស៊ីបឬឌីសុងទ័រសម្រាប់ផ្តាច់ចរន្ត កាលណាមានបាតុភូតឆ្លងភ្លើងណាមួយកើតឡើង ។

## មេរៀនសង្ខេប

- ចរន្តឆ្លាស់ជាចរន្តដែលប្រែប្រួលទិសដៅទៅតាមពេល ។
- ទំនាក់ទំនងខួបនិងប្រេកង់ឱ្យដោយរូបមន្ត : $f = \frac{1}{T}$

  $T$ ខួបនៃលំយោលគិតជា វិនាទី $(s)$ និង $f$ ប្រេកង់នៃលំយោលគិតជាអ៊ែក (Hz) ។
- ទិសដៅដែនម៉ាញេទិចបង្កើតដោយចរន្តឆ្លាស់ប្តូរឆ្លាស់គ្នាជាបន្តបន្ទាប់ទៅតាមបម្រែបម្រួលនៃចរន្តឆ្លាស់ $AC$ ។
- ត្រង់ស្វូដែលមានតង់ស្យុងនៅរបុំមធ្យមធំជាងតង់ស្យុងនៅរបុំបឋមហៅថា ត្រង់ស្វូដំឡើងតង់ស្យុងឬសួករ៉ុលទ័រ ។ ចំណែកឯត្រង់ស្វូដែលមានតង់ស្យុងនៅរបុំមធ្យមតូចជាងតង់ស្យុងនៅរបុំបឋមហៅថាត្រង់ស្វូតំហាយតង់ស្យុង ឬ សូវ៉ុលទ័រ ។
- ទំនាក់នងរវាងតង់ស្យុង ចំនួនស្ពៀ និងចរន្តនៅរបុំបឋមនិងមធ្យម

$$\frac{V_s}{V_p} = \frac{n_s}{n_p} = \frac{I_p}{I_s}$$

- មានវិធីពីរយ៉ាងដើម្បីកាត់បន្ថយកំហាតថាមពល :
  - បន្ថយរេស៊ីស្តង់ខ្សែឱ្យតូច( មានន័យថាប្រើខ្សែដែលមានមុខកាត់ធំ) ។
  - បន្ថយចរន្តតាមរយៈការប្រើត្រង់ស្វូដំឡើងតង់ស្យុង នៅពេលបញ្ជូនអានុភាពតាមបណ្តាញខ្សែកាប ។

## សំណួរនិងលំហាត់

1. ដូចម្តេចហៅថាចរន្តឆ្លាស់ ?
2. តើចរន្តជាប់និងចរន្តឆ្លាស់ខុសគ្នាដូចម្តេច ?
3. តើចរន្តឆ្លាស់ផ្អែកទៅលើបាតុភូតអ្វី ?
4. តើឌីយ៉ូតបន្សាយពន្លឺអាចឱ្យគេកំណត់ទិសដៅនៃចរន្តជាប់បានដែរឬទេ ?
5. ដើម្បីផលិតចរន្តឆ្លាស់ $AC$ ក្នុងរោងចក្រអគ្គិសនី តើគេត្រូវការផ្អែកអ្វីខ្លះ ?

6. តើប្រេកង់នៃរង្វិលរបស់រ៉ូទ័រនិងប្រេកង់នៃចរន្តដូចគ្នាដែរឬទេ ?

7. តើប្រេកង់នៃចរន្តឆ្លាស់និងខួបមានទំនាក់ទំនងដូចម្តេច ?

8. បើគេបង្កើនចំនួនជុំនៃបូប៊ីន 2 ដងដោយរក្សាប្រេកង់ឱ្យនៅដដែល តើតង់ស្យុងមានអំពីទុតប្រែប្រួលដូចម្តេច ?

9. បើគេបង្កើនប្រេកង់រង្វិលរបស់រ៉ូទ័រ តើតង់ស្យុងបញ្ចេញកើនឡើងដែរឬទេ ?

10. តើចរន្តឆ្លាស់ $AC$ មានការអនុវត្តក្នុងឧបករណ៍អគ្គិសនីអ្វីខ្លះ ?

11. តើឧបករណ៍កត់ត្រា(ពេល-ចម្ងាយចរ)ក្នុងមេរៀនពិសោធន៍ទន្លាក់សេរីផ្សំឡើងដោយអ្វីខ្លះ? ហើយមានដំណើរការដូចម្តេច ?

12. តើត្រង់ស្វូប្រើសម្រាប់ធ្វើអ្វី ?

13. តើគេសំគាល់ដូចម្តេច ទើបដឹងថា ត្រង់ស្វូមួយជាស្ទូករ៉ុលទ័រឬស្ទូរ៉ុលទ័រ ?

14. ចូរអ្នករៀបរាប់ពីសុវត្ថិភាពនៃការប្រើប្រាស់ចរន្តអគ្គិសនីក្នុងផ្ទះ ?

15. គណនាប្រេកង់នៃតង់ស្យុងឆ្លាស់ដែលមានខួប : 0.02s , 0.1ms , 100ms ។

16. ត្រង់ស្វូមួយដំឡើងតង់ស្យុងពី 12V ទៅ 240V ។

ក. តើត្រង់ស្វូនោះជាស្ទូករ៉ុលទ័រឬស្ទូរ៉ុលទ័រ ?

ខ. រកចំនួនស្ពៀនៅរបុំបឋម បើចំនួនស្ពៀនៅរបុំមធ្យមស្មើនឹង $n_2 = 2000$ ។

## សំណួរនិងលំហាត់ជំពូក 3

**I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :**

1. ចង្កឹះកែវផ្ទុកបន្ទុកអគ្គិសនីវិជ្ជមាន ពេលខាត់នឹងសំពត់សូត្ររួចផ្ទុកបន្ទុកអគ្គិសនីវិជ្ជមានព្រោះ :

☐ ក. ទទួលប្រូតុង ☐ ខ. ទទួលអេឡិចត្រុង

☐ គ. បាត់បង់អេឡិចត្រុង ☐ ឃ. ទទួលប្រូតុងនិងបាត់បង់អេឡិចត្រុង ។

2. ប្រសិនបើ បាល់ជ័រមួយត្រូវបានច្រានចេញដោយចង្កឹះកៅស៊ូ ។ បាល់ជ័រនិងចង្កឹះកែវ

☐ ក. ផ្ទុកបន្ទុកមានសញ្ញាផ្ទុយគ្នា ☐ ខ. ផ្ទុកបន្ទុកមានសញ្ញាដូចគ្នា

☐ គ. គ្មានផ្ទុកបន្ទុកអគ្គិសនីទាំងពីរ ☐ ឃ. មានផ្ទុកបន្ទុកអគ្គិសនីតែមួយ ។

3. ចរន្តអគ្គិសនីឆ្លងកាត់អំពូល 0.2A ។ គេឱ្យចរន្តឆ្លងកាត់អំពូលរយៈពេល 2h បន្ទុកអគ្គិសនីសរុបឆ្លងកាត់មានតម្លៃ

☐ ក. 1640C ☐ ខ. 1460C ☐ គ. 1440C ☐ ឃ. 1540C ។

4. បើបន្ទុកអគ្គិសនី 30C ឆ្លងកាត់ខ្សែចម្លងអស់រយៈពេល 2mn អាំងតង់ស៊ីតេឆ្លងកាត់ខ្សែចម្លងមានតម្លៃ

☐ ក. 0.5A ☐ ខ. 0.25A ☐ គ. 1A ☐ ឃ. 1.5A ។

**II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. បំពង់បឺតជ័រខាត់នឹងសំពត់ឡែនបានផ្ទុកបន្ទុកអគ្គិសនី........................ហើយមានសញ្ញាផ្ទុយគ្នា......................................... ។

2. អង្គធាតុពីរផ្ទុកបន្ទុកអគ្គិសនីមានសញ្ញាផ្ទុយគ្នា...............................................ហើយមានសញ្ញាផ្ទុយគ្នា................................ ។

3. បំលាស់ទីអេឡិចត្រុងសេរីមានទិសដៅ ............................ពីទិសដៅនៃចរន្តអគ្គិសនី ។

4. ត្រង់ស្វូមួយជាឧបករណ៍ដំឡើងតង់ស្យុងកាលណា...................................ហើយជាឧបករណ៍តំហាយតង់ស្យុងកាលណា...................................... ។

**III. លំហាត់**

1. គេមានបីចំណុច $A, B, C$ នៃសៀគ្វីអគ្គិសនីមួយ ។ គេវាស់តង់ស្យុង $V_{AB} = +10V$ និង $V_{BC} = +6V$ ។ គណនាតង់ស្យុង $V_{BA}$, $V_{CB}$, $V_{CA}$ ។

2. គេមានបួនចំណុច $M, N, P, Q$ នៃសៀគ្វីអគ្គិសនីមួយ ។ គេវាស់តង់ស្យុង $V_{MP} = -5V$ , $V_{NQ} = +10V$ , $V_{MQ} = 16V$ ។ គណនាតង់ស្យុង $V_{MN}$, $V_{NP}$, $V_{PQ}$ ។

3. តើត្រង់ស្វូមួយមានចំនួនស្ពៀ $n_1 = 500$ នៅរបុំបឋម និង $n_2 = 2000$ នៅរបុំមធ្យម ។
   ក. ត្រង់ស្វូនេះជាស្វូករ៉ុលទ័រឬស្វ៊ូរ៉ុលទ័រ ។
   ខ. គណនាតង់ស្យុងប្រសិទ្ធនៅរបុំមធ្យម បើគេឱ្យតង់ស្យុងប្រសិទ្ធនៅរបុំបឋម $V_p = 12V$ ។

4. ត្រង់ស្វូមួយមានចំនួនស្ពៀ $n_1$ នៅរបុំបឋមនិង $n_2$ នៅរបុំមធ្យមដែលគេឱ្យផលធៀប $n_2/n_1 = 4$ ។
   ក. គណនាតង់ស្យុងប្រសិទ្ធនៅរបុំមធ្យម បើគេឱ្យតង់ស្យុងប្រសិទ្ធនៅរបុំបឋម $V_p = 120V$
   ខ. រកចំនួនជុំនៅរបុំមធ្យម បើគេឱ្យចំនួនជុំនៅរបុំបឋម $n_1 = 100$ ។

5. ត្រង់ស្វូមួយមានតង់ស្យុងប្រសិទ្ធ $V_p$ នៅរបុំបឋមនិង $V_s$ នៅរបុំមធ្យមដែលគេឱ្យផលធៀប $\frac{V_s}{V_p} = 2$ ។
   ក. រកចំនួនជុំនៅរបុំបឋម បើចំនួនជុំរបុំមធ្យម $n_2 = 200$ ។
   ខ. រកតង់ស្យុងនៅរបុំបឋម បើតង់ស្យុងនៅរបុំមធ្យមស្មើនឹង $V_s = 480V$ ។

# ជំពូក 4 អុបទិច



ហេតុអ្វីបានជាយើងសិក្សាអុបទិច ? អុបទិចសិក្សានូវរាល់បាតុភូតទាំងឡាយណាដែលទាក់ទងទៅនឹងពន្លឺមានន័យថាយើងសិក្សាពីអ្វីដែលមើលឃើញដោយភ្នែក ។

នៅក្នុងជំពូកនេះយើងសិក្សាពីប្រភពនិងដំណាលនៃពន្លឺ (ចំណាំងផ្លាត ចំណាំងបែរនិងចំណាំងផ្លាតទាំងស្រុង)។ ការសិក្សានេះធ្វើឱ្យយើងស្គាល់នូវកំណាកំណើតនៃរូបភាព និងដំណើរប្រព្រឹត្តនៃឧបករណ៍អុបទិចសំខាន់ៗខ្លះដូចជា កែវពង្រីក មីក្រូទស្សន៍ កែវយិត ឬកែវឆ្លុះជាដើម ។

### មេរៀនទី 1 : ធម្មជាតិនិងដំណាលពន្លឺ

### មេរៀនទី 2 : ឡង់ទី

facebook.com/moeys krou.moeys.gov.kh

មេរៀនទី

# 1 ធម្មជាតិនិងដំណាលនៃពន្លឺ

**ចប់មេរៀននេះ សិស្សអាច**

- ❒ ពន្យល់បានពីចំណាំងផ្លាតនិងចំណាំងបែរនៃពន្លឺ ។
- ❒ បកស្រាយបានពីល្បឿនពន្លឺ ។
- ❒ អនុវត្តពីចំណាំងផ្លាត និងចំណាំងបែរ (កញ្ចក់ ទឹក បន្ទះមុខ ស្រប . . .) ។
- ❒ ធ្វើការពិសោធពីចំណាំងផ្លាតនិងចំណាំងបែរនៃពន្លឺដែលទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ ។

## 1. ធម្មជាតិនៃពន្លឺ

អង្គធាតុទាំងឡាយណាដែលបន្សាយពន្លឺជាប្រភពនៃពន្លឺ ។ ប្រភពពន្លឺចែកចេញជាពីរគឺ ប្រភពពន្លឺធម្មជាតិ ( ដូចជាពន្លឺព្រះអាទិត្យ ពន្លឺផ្កាយ និងចំហេះ ) និងប្រភពពន្លឺសិប្បនិម្មិត ដូចជាអំពូលវង្គំ អំពូលភ្លុយអ៊ីរ អំពូលឌីយ៉ូត...និងពិលឡាស៊ែរជាដើម ។ ព្រះអាទិត្យជាប្រភពមួយដែលបញ្ចេញពន្លឺយ៉ាងសំខាន់បំផុត ។ វត្ថុឬសរីរាង្គដែលមានភាពរួសជាមួយនឹងពន្លឺគេហៅថាគ្រឿងទទួលពន្លឺ ដូចជា ភ្នែក ហ្វីលថតរូប ថ្មពិលព្រះអាទិត្យ ... ជាដើម ។

ពន្លឺមានលក្ខណៈពីរយ៉ាងគឺ លក្ខណៈជារលក និងជាគ្រាប់ល្អិត(ផង់) ។ ពន្លឺដាលក្នុងមជ្ឈដ្ឋានថ្លាស្មើសាច់និងសុញ្ញាកាសជាខ្សែត្រង់ ។ ល្បឿនរបស់វាអាស្រ័យទៅនឹងមជ្ឈដ្ឋានដំណាលនិងពន្លឺដាលឆ្លងកាត់សុញ្ញាកាសគ្មានបាត់បង់អ្វីទេ ។

## 2. រង្វាស់ល្បឿនពន្លឺ

អ្នកវិទ្យាសាស្ត្រទី 1 ដែលព្យាយាមរកឃើញនូវរង្វាស់ល្បឿនពន្លឺគឺលោក **កាលីលេ** ។ គាត់បានសន្និដ្ឋានថាល្បឿនពន្លឺមានតម្លៃយ៉ាងធំអតិបរមា ។ គេអាចវាស់ល្បឿនពន្លឺបានតាមវិធីពីរយ៉ាងគឺ វិធីរ៉េម៉េរ និងវិធីហ្វីហ្សូ ។

## 2.1 វិធីរ៉េមើរ

ក្នុងឆ្នាំ 1675 តារាវិទូជនជាតិដាណឺម៉ាក ( Danish astronomer ) ម្នាក់ឈ្មោះ **អូលី រ៉េមើរ** (Ole Roemer) (1644-1710) បានសម្រេចដោយជោគជ័យលើការរកឃើញនូវល្បឿនពន្លឺ ប៉ុន្តែបានត្រឹមតែតម្លៃប្រហាក់ប្រហែលប៉ុណ្ណោះ ។ លោក រ៉េមើរ បានធ្វើការសង្កេតទៅលើគន្លងចលនារបស់តារារណប $I_0$ នៃភពផ្កាយព្រហស្បតិ៍មួយ(រូបទី*4.1*)ហើយកំណត់ជាលើកដំបូងជាមួយនឹងបម្រែបម្រួលខួបក្នុងរយៈពេល 22 នាទីត្រូវនឹងចម្ងាយចរ $2.83 \times 10^{11}\text{m}$ ។ តាមរយៈទិន្នន័យនេះនៅឆ្នាំ 1676 លោក **រ៉េមើរ** បានប្រកាសថាល្បឿនពន្លឺមានតម្លៃ $2.14 \times 10^{8}\text{m/s}$ ។




***រូបទី 4-1 រង្វាស់ល្បឿនពន្លឺ***

## 2.2 វិធីហ្វីហ្សូ

ក្នុងឆ្នាំ1849 រង្វាស់ល្បឿនពន្លឺក្នុងមន្ទីរពិសោធន៍ត្រូវបានបង្កើតជាលើកដំបូង ដោយអ្នកវិទ្យាសាស្ត្រជនជាតិបារាំងម្នាក់ឈ្មោះ ហ្វីហ្សូ (Armand H.L. Fizeau) (1819-1896) សម្ភារៈដែលគាត់បានប្រើក្នុងការធ្វើពិសោធន៍នេះមានប្រភពពន្លឺកញ្ចក់និងកង់មានធ្មេញដែលអាចបង្វិលបាន(រូបទី*4.2*) ។មុនដំបូងគាត់បានដាក់ប្រភពពន្លឺឱ្យឆ្លងកាត់ប្រឡោះធ្មេញរបស់កង់ដាលទៅដល់កញ្ចក់រួចផ្លាតត្រលប់មកវិញទន្ទឹមនឹងនោះគាត់បង្វិលកង់ដោយល្បឿនរង្វិលរបស់កង់តម្រូវសមស្របទៅនឹងការចាំងផ្លាតរបស់ពន្លឺពីកញ្ចក់ត្រឡប់មកវិញអាចឆ្លងកាត់ប្រឡោះធ្មេញបាន ។ បន្ទាប់មកទៀតគាត់វាស់ទំហំល្បឿនរបស់កង់វិល(ល្បឿនមុំ)និងចម្ងាយពីកង់វិលទៅកញ្ចក់ ។ ដោយទាញចេញពីការពិសោធនេះ លោក **ហ្វីហ្សូ** បានសន្និដ្ឋានថាល្បឿនពន្លឺមានតម្លៃ $c = 3.13 \times 10^{8}\text{m/s}$ ។ បច្ចុប្បន្ននេះល្បឿនពន្លឺក្នុងសុញ្ញកាសមានតម្លៃគឺ : $c = 299792458\text{m/s}$ ។




*រូបទី 4-2*

# 3. ចំណាំងផ្លាតនិងចំណាំងបែរនៃពន្លឺ

## 3.1 ចំណាំងផ្លាតនៃពន្លឺ

យើងពិនិត្យមើលកាំពន្លឺមួយដែលដាលក្នុងខ្យល់ទៅប៉ះនឹងផ្ទៃ “ រលោង ” រាបស្មើមួយបង្កើតបានមុំ $\theta_1$ ជាមួយនឹងខ្សែកែងកាំពន្លឺនេះចាំងផ្លាតមកមជ្ឈដ្ឋានដើមវិញបង្កើតបានមុំ $\theta'_1$ (រូបទី *4.3*) ។ យើងវាស់មុំ $\theta_1$ និង$\theta'_1$ យើងបាន $\theta_1 = \theta'_1$ ។




*រូបទី 4-3*

**ពំនោលច្បាប់ចំណាំងផ្លាត “កាំចាំងផ្លាតត្រូវស្ថិតក្នុងប្លង់ចំណាំងប៉ះនិងមុំចំណាំងផ្លាត $\theta'_1$ ប៉ុនគ្នានឹងមុំចំណាំងប៉ះ $\theta_1$ ” ។**

## 3.2 ចំណាំងបែរនៃពន្លឺ

កាលណាកាំពន្លឺដាលឆ្លងពីមជ្ឈដ្ឋានថ្លាមួយទៅក្នុងមជ្ឈដ្ឋានថ្លាមួយទៀត កាំពន្លឺមួយភាគធំចាំងចូលទៅមជ្ឈដ្ឋានទី2 ដោយមានលំងាកហើយកាំពន្លឺដែលនៅសល់ចាំងផ្លាតចូលមកមជ្ឈដ្ឋានដើមវិញ ។ កាំពន្លឺដែលដាលចូលទៅក្នុងមជ្ឈដ្ឋានទី2នេះហៅថា **កាំចាំងបែរ** ។ កាំចាំងប៉ះ កាំចាំងផ្លាត និងកាំចាំងបែរទាំងអស់ឋិតនៅក្នុងប្លង់ចំណាំងប៉ះតែមួយ(រូបទី *4.4*) ។




*រូបទី 4-4*

**ពំនោលច្បាប់ចំណាំងបែរ “កាំចាំងបែរត្រូវស្ថិតក្នុងប្លង់ចំណាំងប៉ះនិងមុំចំណាំងបែរ $\theta_2$ និងមុំចំណាំងប៉ះ $\theta_1$ ” ។**

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

តាមទំនាក់ទំនង: $\frac{\sin\theta_1}{\sin\theta_2} = \frac{v_1}{v_2} = $ ថេរ (1)

$v_1$ ជាល្បឿនពន្លឺដាលក្នុងមជ្ឈដ្ឋានទី1 និង$v_2$ ជាល្បឿនពន្លឺដាលក្នុងមជ្ឈដ្ឋានទី2 ។

## 3.3 សន្ទស្សន៍ចំណាំងបែរ

ជាទូទៅល្បឿនពន្លឺដាលក្នុងសារធាតុផ្សេងៗ វាតែងតែមានល្បឿនតូចជាងល្បឿននៅក្នុងសុញ្ញកាសហើយល្បឿនដែលដាលក្នុងសុញ្ញកាសមានតម្លៃអតិបរមា ។ សន្ទស្សន៍ចំណាំងបែរ$n$ របស់មជ្ឈដ្ឋានគឺជាផលធៀប : $\boxed{n = \frac{c}{v}}$ (2)

$c$ ល្បឿនពន្លឺដាលក្នុងសុញ្ញកាសគិតជាម៉ែត្រក្នុងមួយវិនាទី m/s

$v$ ល្បឿនពន្លឺដាលក្នុងមជ្ឈដ្ឋានគិតជាម៉ែត្រក្នុងមួយវិនាទី m/s

សមីការ(2) យើងទាញបាន $v_1 = \frac{c}{n_1}$ និង $v_2 = \frac{c}{n_2}$ ហើយជំនួសក្នុងសមីការ(1) យើងបាន :

$$\frac{\sin\theta_1}{\sin\theta_2} = \frac{c/n_1}{c/n_2} = \frac{n_2}{n_1} \Rightarrow \frac{\sin\theta_1}{\sin\theta_2} = \frac{n_2}{n_1} = \text{ថេរ} \quad (3)$$

ដូច្នេះ $\boxed{n_2\sin\theta_2 = n_1\sin\theta_1}$ ។

$n_1$ ជាសន្ទស្សន៍ចំណាំងបែរនៃមជ្ឈដ្ឋានទី1 និង $n_2$ ជាសន្ទស្សន៍ចំណាំងបែរនៃមជ្ឈដ្ឋានទី2 ។

**តារាងតម្លៃប្រហែលរបស់សន្ទស្សន៍ចំណាំងបែរនៃមជ្ឈដ្ឋានខ្លះៗ :**

| សារធាតុ | សន្ទស្សន៍ចំណាំងបែរ |
|---|---|
| សុញ្ញកាស | 1 |
| ខ្យល់ | 1.000293 |
| កាបូនឌីអុកស៊ីត | 1.00045 |
| ទឹក 20°C | 1.33 |
| អេទីលអាល់កុល | 1.361 |
| កែវ | 1.52 – 1.70 |
| ពេជ្រ | 2.419 |

***ឧទាហរណ៍ :*** រកល្បឿនពន្លឺដាលនៅក្នុងទឹក ។ ដោយដឹងថាល្បឿនដាលក្នុងខ្យល់ស្មើនឹង $c = 3 \times 10^8 \text{m/s}$ និងសន្ទស្សន៍ចំណាំងបែរនៃទឹក 1.33 ។

**ដំណោះស្រាយ**

ពីសមីការ (2) យើងបាន : $v = \frac{c}{n} = \frac{3 \times 10^8}{1.33} = 2.25 \times 10^8 \text{m/s}$

ដូច្នេះពន្លឺល្បឿនដាលក្នុងទឹកគឺ $\boxed{v = 2.25 \times 10^8 \text{m/s}}$ ។

facebook.com/moeys.gov.kh youtube.com/moeys krou.moeys.gov.kh

# ពិសោធន៍ចំណាំងផ្លាតនិងចំណាំងបែរនៃពន្លឺ

## I. ពិសោធន៍ចំណាំងផ្លាតនៃពន្លឺ

### 1. វត្ថុបំណង

បង្ហាញថាមុំចំណាំងផ្លាតប៉ុនគ្នានឹងមុំចំណាំងប៉ះតាមរយៈការពិសោធ ។

### 2. តម្រូវការ

កញ្ចក់ប្លង់មួយ ម្ជុលបារាំងបួនដើម ស្កុតមួយដុំ ក្រដាសកាតុងក្រាស់ ឬក្រដាសសម្បកកេសមួយផ្ទាំង បន្ទាត់ម៉ែតវែងមួយ ក្រដាសការ៉ូ ឬក្រដាសគូសក្រាបមួយសន្លឹក និងខ្មៅដៃមួយដើម ។

### 3. ដំណើរការពិសោធ

- ដាក់ក្រដាសគូសក្រាបលើទម្រដែលជាក្រដាសកាតុងក្រាស់ ឬក្រដាសសម្បកកេស ។
- បិទក្រដាសគូសក្រាបភ្ជាប់នឹងជើងទម្រដោយប្រើស្កុត ។
- ដាក់កញ្ចក់ប្លង់លើក្រដាសគូសក្រាប ។
- គូសបន្ទាត់មួយតាមបណ្ដោយកញ្ចក់ដូច(រូបទី *4.6*)
- ដោតម្ជុលមួយដើមនៅត្រង់ចំណុចមួយចម្ងាយប្រហែល 2cm ពីមុខកញ្ចក់ហើយចំណុចនោះតាងដោយ $O_1$ ។ ដោតម្ជុលទី 2 ត្រង់ចំណុច $O_2$ ។
- ដោតម្ជុលទី 3 ត្រង់ចំណុច $R_1$ ឱ្យរត់ត្រង់ជួរជាមួយនឹងរូបភាពនៃ $O_1$ និង $O_2$ ។ រូបភាពនៃ $O_1$ និង $O_2$ គឺ $O'_1$ និង $O'_2$ មើលឃើញក្នុងកញ្ចក់(រូបទី *4.6*) ។
- ធ្វើដូចចំណុច $f$ ដោយដោតម្ជុលទី 4 ត្រង់ចំណុច $R_2$ ។
- យកកញ្ចក់និងដកម្ជុលចេញ ។
- គូសកាំចាំងប៉ះកាត់តាមម្ជុល 1 និង 2 ហើយគូសកាំចាំងផ្លាតកាត់តាមម្ជុល 3 និង 4 ។
- គូសបន្ទាត់ឱ្យកែងទៅនឹងខ្សែដែលគូសតាមបណ្ដោយកញ្ចក់ត្រង់ចំណុចប្រសព្វរវាងកាំចាំងប៉ះនិងកាំចាំងផ្លាត ។
- វាស់ប្រវែង $\ell_0$ ពីកាំចាំងប៉ះទៅខ្សែកែង $\ell_1$ ពីកាំចាំងផ្លាតទៅខ្សែកែងនឹង $\ell_2$ ពីកញ្ចក់ទៅចំណុច $H$ លើខ្សែកែង ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh




រូបទី 4-6

## 4. លទ្ធផល

ប្រវែង $\ell_0 =$ ......... ប្រវែង $\ell_1 =$ ......... និងប្រវែង $\ell_2 =$ .........

គណនាតម្លៃរបស់ $\tan i = \frac{\ell_0}{\ell_2}$............ និង $\tan r = \frac{\ell_1}{\ell_2}$............

ទាញរក $i =$ ........... និង $r =$ ...........

## 5. សន្និដ្ឋាន

តាមលទ្ធផលយើងអាចសន្និដ្ឋានថា $i = r =$ ...... ដូច្នេះមានន័យថាមុំចំណាំងប៉ះ ...... និងមុំចំណាំងផ្លាត ។

## 6. ពិភាក្សា

ដើម្បីវាស់បានលទ្ធផលកាន់តែជាក់លាក់ តើយើងត្រូវយកចិត្តទុកដាក់លើកត្តាអ្វីខ្លះ ?

# II. ការពិសោធចំណាំងបែរនៃពន្លឺ

## 1. វត្ថុបំណង

បង្ហាញថា តម្លៃសន្ទស្សន៍នៃមជ្ឈដ្ឋានថ្លាស្មើសាច់មួយមានតម្លៃថេរ បើទោះបីជាមានបម្រែបម្រួលនៃមុំចំណាំងប៉ះ និងមុំចំណាំងបែរក៏ដោយ និងរកសន្ទស្សន៍កែវតាមរយៈការពិសោធ ។

## 2. តម្រូវការ

ម្ជុលបារាំងបួនដើម បន្ទះកែវថ្លាស្មើសាច់រាងជាប្រលេពីប៉ែតកែងមានវិមាត្រប្រហែល $5\text{cm} \times 12\text{cm} \times 1\text{cm}$ ចំនួនមួយ ក្រដាសវ៉ាម $A4$ មួយសន្លឹក ទម្រស្នោ ឬក្រដាសសម្បុកកេសមី

មួយផ្ទាំងទំហំប៉ុនក្រដាស $A4$ បន្ទាត់វែងមួយ បន្ទាត់កែងមួយ ដែកឈានមួយ ស្កុតមួយដុំ និងខ្មៅដៃចុងស្រួចមួយដើម ។

**3. ដំណើរការពិសោធ**



រូបទី 4-7

- បិទក្រដាសវ៉ាមលើទម្រស្នោ ឬក្រដាសកេសមីដោយប្រើស្កុត ។
- ដាក់កែវថ្លារាងប្រលេពីប៉ែតកែងចំកណ្ដាលក្រដាសវ៉ាម រួចគូសបន្ទាត់ស្របពីរតាមបណ្ដោយបាតកែវថ្លា ដូច(រូបទី 4.7) ។
- ដោតម្ជុល $Q$ លើបន្ទាត់ $AD$ លៃយ៉ាងណាឱ្យកែងនឹងប្លង់ក្រដាស និងខិតមកជិតខាងចំណុច $A$ (រូបទី 4.7) ។
- ដោតម្ជុលមួយទៀតត្រង់ $P_1$ ឱ្យរត់ត្រង់គ្នារាងបញ្ឆិតពីក្រោយម្ជុលទី1 ដែលបានដោតត្រង់$Q$ ។
- រកទីតាំង $R_1$ ក្បែរបន្ទាត់ $BC$ (កុំឱ្យប៉ះបន្ទះកែវថ្លា ) និងទីតាំង $S_1$ ដែលអាចមើលឃើញម្ជុល $P_1$ , $Q$ , $R_1$ និង $S_1$ រត់ត្រង់គ្នា ពេលដែលអ្នកមើលម្ជុលនេះឆ្លងកាត់បន្ទះកែវថ្លា ។
- ប្ដូរទីតាំង $P$ និងធ្វើដូចលំនាំមុនរកទីតាំង $R_1$ និង $S_1$ ចំនួន 3 ដងបន្តបន្ទាប់គ្នា $P_2$ , $P_3$ , $P_4$ ។
- យកកែវថ្លាចេញ និងគូសខ្សែកែង $NN'$ ត្រង់ចំណុច $Q$ (កែងជាមួយនឹងបន្ទាត់ $AD$ ) ដោយប្រើបន្ទាត់កែង ។ គូសបន្ទាត់ $S_1R_1$ , $S_2R_2$ , $S_3R_3$ និង $S_4R_4$ ដែលបន្ទាត់ទាំងនេះប្រសព្វនឹងបន្ទាត់ $BC$ ត្រង់ $R'_1$ , $R'_2$ , $R'_3$ និង $R'_4$ បន្ទាប់មកគូសបន្ទាត់ $QR'_1$ , $QR'_2$ , $QR'_3$ និង $QR'_4$ ហើយគូសរង្វង់មួយដែលមានផ្ចិតត្រង់ $Q$ ដោយប្រើដែកឈានដូច(រូបទី 4.8) លៃយ៉ាងណាឱ្យកាំតូចជាងទទឹងបន្ទះកែវថ្លា ។
- រកចំណុចប្រសព្វ $K_1$ រវាងរង្វង់ និងបន្ទាត់ $P_1Q$ និងចំណុចប្រសព្វ $K'_1$ រវាងរង្វង់និងបន្ទាត់ $QR'_1$ ។ ទម្លាក់ចំណោលកែងនៃចំណុច $K_1$ និង $K'_1$ ទៅលើខ្សែកែង $NN'$ ដោយប្រើបន្ទាត់កែង ពេលនោះអ្នកនឹងបានចំណុច $H_1$ និង $H'_1$ ។
- ដោយប្រើបន្ទាត់ក្រិត វាស់រកចម្ងាយ $K_1H_1$ និង $K'_1H'_1$ ។
- គណនាផលធៀប $\frac{K_1H_1}{K'_1H'_1}$
- ធ្វើដូចគ្នានឹងលំនាំមុនដែរ រកចំណុចប្រសព្វ $K_1$ ចម្ងាយនិងផលធៀប ចំពោះ $K_2$ , $K_3$ និង $K_4$ ដូច(រូបទី 4.8) ។




រូបទី 4-8

## 4. លទ្ធផល

បន្ទាប់ពីធ្វើពិសោធន៍រួច ចូរកត់ត្រាតម្លៃដែលវាស់បានចូលក្នុងតារាងខាងក្រោម :

| ពិសោធន៍ | 1 | 2 | 3 | 4 | តម្លៃមធ្យម |
|---|---|---|---|---|---|
| $KH(cm)$ | | | | | |
| $K'H'(cm)$ | | | | | |
| $n = \frac{KH}{K'H'}$ | | | | | |

## 5. សន្និដ្ឋាន

- តើអ្នកសង្កេតឃើញយ៉ាងដូចម្ដេចចំពោះតម្លៃនៃផលធៀប $KH/\ K'H'$ ?
- តម្លៃមធ្យមនៃ $n = \frac{KH}{K'H'} = \ldots$ គ្មានខ្នាតយើងហៅថា . . . . មជ្ឈដ្ឋាន (កែវថ្លា)
- ប្រៀបធៀបសន្ទស្សន៍កែវដែលអ្នកទទួលបានពីពិសោធន៍ជាមួយនឹងតម្លៃសន្ទស្សន៍ដែលសរសេរនៅក្នុងតារាងសន្ទស្សន៍ ។ដូច្នេះសន្ទស្សន៍កែវមានតម្លៃប្រហែល ........ = ថេរ ។

## 6. ពិភាក្សា

ដើម្បីវាស់បានលទ្ធផលកាន់តែជាក់លាក់ តើយើងត្រូវយកចិត្តទុកដាក់លើកត្តាអ្វីខ្លះ ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## 4. គោលការណ៍ហ៊ុយគែន




***រូបទី 4-9***

ពំនោលគោលការណ៍ហ៊ុយគែន : ចំណុចទាំងអស់លើផ្ទៃរលកដែលឱ្យ(ផ្ទៃរលកចាស់) ដោយ $AA'$ ត្រូវបានចាត់ទុកថាជាចំណុចប្រភពសម្រាប់បង្កើតរលកបន្ទាប់មានរាងជាស្វ៊ែ(ហៅថាគ្រាប់រលក)ដែលដាលពីផ្ទៃរលកចាស់ដោយល្បឿនមួយនៅក្នុងមជ្ឈដ្ឋានដំណាល ។ មួយរយៈពេលក្រោយមកទីតាំងថ្មីនៃផ្ទៃរលកថ្មីដែលជាចំណុចប៉ះនឹងគ្រាប់រលកនីមួយៗនោះត្រូវបានបង្កើតឡើង $BB'$ ដូច (រូបទី *4.9*) ។

## 5. ចំណាំងផ្លាតទាំងស្រុង

ចំណាំងផ្លាតទាំងស្រុងអាចកើតមានឡើងកាលណាពន្លឺដែលដាលឆ្លងកាត់មជ្ឈដ្ឋានមួយដែលមានសន្ទស្សន៍ចំណាំងបែរធំជាង ទៅមជ្ឈដ្ឋានមួយទៀតដែលមានសន្ទស្សន៍តូចជាង ។ ពិនិត្យមើលបាច់ពន្លឺមួយដែលដាលពីមជ្ឈដ្ឋានទី 1 ទៅជួបផ្ទៃញែករវាងមជ្ឈដ្ឋានទី 1 និងទី 2 ដែល $n_1 > n_2$ (រូបទី *4.10*.ក) ។ ទិសដៅដំណាលនៃកាំពន្លឺនីមួយៗ អាចកើតមានត្រូវបានបង្ហាញពីកាំទី 1 ដល់កាំទី 5 ។ កាំចាំងបែរងាកចេញពីកែងព្រោះ $n_1 > n_2$ ។ ត្រង់មុំចំណាំងប៉ះពិសេសមួយ $\theta_c$ ហៅថា មុំកម្រិត (រូបទី *4.10*.ក) ។ ពេលដែលកាំពន្លឺចាំងបែរផ្លាស់ទីស្របទៅនឹងផ្ទៃញែក (កាំទី 4) ពេលនោះយើងបាន $\theta_2 = 90°$ ។

ចំពោះមុំចំណាំងប៉ះធំជាង $\theta_c$ បាច់ពន្លឺត្រូវចាំងផ្លាតទាំងស្រុងកើតមានឡើង ដូចកាំទី 5 (រូបទី *4.10*.ក) ។ កាំនេះផ្លាតត្រង់ផ្ទៃញែក កាលណាវាប៉ះនឹងផ្ទៃបំផ្លាតបានល្អ និងគោរពទៅច្បាប់ចំណាំងផ្លាត មានន័យថា មុំចំណាំងប៉ះប៉ុនគ្នានឹងមុំចំណាំងផ្លាត ។




រូបទី 4-10

ប្រើច្បាប់ snell យើងបាន : $n_1 \sin\theta_c = n_2 \sin\theta_2$

ដោយ $\theta_2 = 90° \Rightarrow n_2 \sin 90° = n_2$ (ព្រោះ $\sin 90° = 1$ )

ដូច្នេះ យើងអាចសរសេរ : $\sin\theta_c = \frac{n_2}{n_1}$ (4)

សមីការ (4) នេះអនុវត្តន៍បានតែក្នុងករណី $n_1 > n_2$ ប៉ុណ្ណោះ ។ កាលណា $n_1 < n_2 \Rightarrow \sin\theta_c > 1$ គ្មានន័យព្រោះតម្លៃអតិបរិមារបស់ស៊ីនុសនៃមុំមួយមិនធំជាង 1 បានទេ ។

***ឧទាហរណ៍ទី 1 :*** គណនាមុំកម្រិតរបស់ទឹកក្នុងខ្យល់ ។

តាមសមីការ (4) យើងបាន :

$$\sin\theta_c = \frac{n_2}{n_1} = \frac{1}{1.33} = 0.752 \Rightarrow \theta_c = 48.8°$$

***ឧទាហរណ៍ទី 2 :*** គណនាមុំកម្រិតរបស់កែវក្នុងខ្យល់ $(n_{Glass} = 1.52)$ ។

តាមសមីការ (4) យើងបាន :

$$\sin\theta_c = \frac{n_2}{n_1} = \frac{1}{1.52} = 0 \cdot 657 \Rightarrow \theta_c = 41.1°$$

## 6. គោលការណ៍ហ្វឺម៉ាត

លោកព្យែរដឺហ្វឺម៉ាត (Pierre de Fermat) (1601-1665) បានអភិវឌ្ឍន៍គោលការណ៍ទូទៅមួយដែលប្រើសម្រាប់កំណត់គន្លងដំណាលរបស់ពន្លឺ ។

**ពំនោលគោលការណ៍ហ្វឺម៉ាត:** “កាលណាកាំពន្លឺដាលរវាងចំណុចពីរមានគន្លងតែមួយគត់ក្នុងចំណោមគន្លងទាំងឡាយរបស់វាដែលពន្លឺដាលត្រូវចំណាយពេលខ្លីជាងគេបំផុត ” ។

ពីគោលការណ៍ហ្វឺម៉ាត យើងទាញបានច្បាប់ snell គឺ :

$n_1 \sin\theta_1 = n_2 \sin\theta_2$ (5)

## មេរៀនសង្ខេប

- ប្រភពពន្លឺចែកចេញជាពីរគឺ ៖ ប្រភពពន្លឺធម្មជាតិនិងប្រភពពន្លឺសិប្បនិម្មិត ។
- ពន្លឺអាចដាលក្នុងមជ្ឈដ្ឋានថ្លាស្មើសាច់និងសុញ្ញកាស មានរាងជាខ្សែត្រង់ហើយល្បឿនរបស់វាអាស្រ័យទៅនឹងមជ្ឈដ្ឋានដំណាល ។
- គេអាចវាស់ល្បឿនពន្លឺបានតាមវិធីពីរយ៉ាង គឺវិធីរ៉េម៉េរ និងវិធីហ្វីហ្សូ ។
- ច្បាប់ចំណាំងផ្លាតនៃពន្លឺ ៖ កាំចាំងផ្លាតត្រូវស្ថិតក្នុងប្លង់ចំណាំងប៉ះនិងមុំចំណាំងផ្លាតប៉ុនគ្នានឹងមុំចំណាំងប៉ះ មានន័យថា $\theta'_1 \cong \theta_1$ ។
- ច្បាប់ចំណាំងបែរនៃពន្លឺ ៖ កាំចាំងបែរត្រូវស្ថិតក្នុងប្លង់ចំណាំងប៉ះ និងមុំចំណាំងបែរ $\theta_2$ និងមុំចំណាំងប៉ះ $\theta_1$ មានទំនាក់ទំនងដោយសមីការ

  $n_2 \sin\theta_2 = n_1 \sin\theta_1 \quad \Rightarrow \quad \frac{\sin\theta_1}{\sin\theta_2} = \frac{n_2}{n_1}$ ឬ $\frac{\sin\theta_1}{\sin\theta_2} = \frac{v_1}{v_2}$ ផង ។
- គោលការណ៍ហ៊ុយគែន ៖ " ចំណុចទាំងអស់លើផ្ទៃរលកចាស់ជាប្រភពសម្រាប់បង្កើតរលកបន្ទាប់ដែលដាលពីផ្ទៃរលកចាស់ដោយល្បឿនមួយនៅក្នុងមជ្ឈដ្ឋានដំណាល " ។
- ចំណាំងផ្លាតទាំងស្រុងកើតមានឡើង ក្នុងករណីដែលកាំពន្លឺដាលពីមជ្ឈដ្ឋានដែលមានសន្ទស្សន៍ចំណាំងបែរធំទៅមជ្ឈដ្ឋានដែលមានសន្ទស្សន៍ចំណាំងបែរតូចហើយមុំចំណាំងប៉ះធំជាងមុំកម្រិត ។
- គោលការណ៍ហ្វឺម៉ាត ៖ " កាលណាកាំពន្លឺដាលរវាងចំណុចពីរមានគន្លងតែមួយគត់ក្នុងចំណោមគន្លងទាំងឡាយរបស់វាដែលពន្លឺដាលត្រូវចំណាយពេលខ្លីជាងគេបំផុត " ។

## សំណួរនិងលំហាត់

1. ដូចម្តេចដែលហៅថាប្រភពពន្លឺ ? ប្រភពពន្លឺមានប៉ុន្មានយ៉ាង ?
2. ពន្លឺមានគន្លងដំណាលដូចម្តេច ?
3. តើវិធីសាស្ត្រវាស់ល្បឿនពន្លឺមានប៉ុន្មានយ៉ាង ? ចូររៀបរាប់ ?
4. ចូរពោលពីច្បាប់ចំណាំងផ្លាតនិងចំណាំងបែរ ។
5. គោលការណ៍ហ៊ុយគែនពោលពីអ្វី ?
6. ចំណាំងផ្លាតទាំងស្រុងកើតមាននៅពេលណា ?
7. គោលការណ៍ហ្វឺម៉ាតពោលពីអ្វី ?

8. កញ្ចក់មួយមានរាងប្រលេពីប៉ែតនិងមានសន្ទស្សន៍ 1.59 ។ គេដាក់កញ្ចក់នេះទៅក្នុងទឹកដែលមានសន្ទស្សន៍ 1.33 ។ កាំពន្លឺមួយដាលទៅក្នុងទឹកហើយប៉ះផ្ទៃកញ្ចក់ក្រោមមុំមួយដែលមានតម្លៃ 70° ។ គណនាមុំចំណាំងបែរនៅក្នុងកញ្ចក់ ។

9. ដុំកញ្ចក់មួយមានរាងប្រលេពីប៉ែតនិងមានសន្ទស្សន៍ 1.50 ។ គេដាក់ដុំនេះទៅក្នុងទឹកដែលមានសន្ទស្សន៍ 1.33 ។ តើនៅក្នុងមជ្ឈដ្ឋានណាដែលអាចកើតមានបាតុភូតចំណាំងផ្លាតទាំងស្រុង ? គណនាតម្លៃមុំកម្រិតក្នុងមជ្ឈដ្ឋាននោះ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

**មេរៀនទី**

# 2 ឡង់ទី

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាបានពីដំណាលរបស់កាំពន្លឺឆ្លងកាត់ឡង់ទីនិងសំណង់រូបភាព ។
- ពោលពីនិយមន័យរបស់ឡង់ទីនិងញែកបានពីភាពខុសគ្នារវាងឡង់ទីបង្រួមនិងឡង់ទីពង្រីក ។
- ធ្វើពិសោធន៍ដើម្បីកំណត់ចម្ងាយកំណុំឡង់ទី ។
- ពណ៌នាពីការអនុវត្តឡង់ទី (ភ្នែក ម៉ាស៊ីនថត កែវពង្រីក និងតេលេទស្សន៍) ។

## 1. ដំណាលកាំពន្លឺឆ្លងកាត់ឡង់ទី

កាំពន្លឺអាចប្តូរទិសដៅដំណាល កាលណាវាដាលឆ្លងកាត់មជ្ឈដ្ឋានពីរដែលមានសន្ទស្សន៍ខុសគ្នា។

ឡង់ទី គឺជាឧបករណ៍មួយដែលកើតឡើងពីបន្សំនៃកំណាត់ព្រីសធ្វើឱ្យពន្លឺអាចរីក ឬរួមបាន ។ ជាធម្មតាវាត្រូវបានផលិតឡើងពីបន្ទះកែវ ឬប្លាស្ទិចឬសារធាតុថ្លា ។

ឡង់ទីមានពីរប្រភេទ : ឡង់ទីពង្រីកនិងឡង់ទីបង្រួម ។




ឡង់ទីបង្រួម




ឡង់ទីពង្រីក

គេតាងឡង់ទីដោយនិមិត្តសញ្ញាដូចខាងក្រោម




និមិត្តសញ្ញាឡង់ទីបង្រួម




និមិត្តសញ្ញាឡង់ទីពង្រីក

រូបទី4.11

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

ដើម្បីកំណត់ប្រភេទរូបភាពដែលផ្តល់ដោយឡង់ទីពង្រីកនិងបង្រួម យើងប្រើកាំពន្លឺពិសេសពីរ ក្នុងចំណោមកាំពន្លឺពិសេសបីគឺ កាំស្រប (1) កាំកាត់តាមផ្ចិតឡង់ទី (2) និងកាំកាត់តាមកំណុំវត្ថុ (3) ដូច(រូបទី *4.12*) ។

## 1.1 សំណង់រូបភាពផ្តល់ដោយឡង់ទីបង្រួម




***រូបទី****4.12*

កាំពន្លឺចាំងប៉ះ(1) ស្របនឹងអ័ក្សមេ បន្ទាប់ពីប៉ះនឹងឡង់ទី កាំនេះកាត់តាមកំណុំរូបភាព $F'$ នៅពីខាងក្រោយឡង់ទី ។

- កាំពន្លឺចាំងប៉ះ(2) កាត់តាមផ្ចិតឡង់ទី ពេលចេញពីឡង់ទីដាលត្រង់ដោយគ្មានរងលំងាក ។
- កាំពន្លឺចាំងប៉ះ(3) កាត់តាមកំណុំ $F$ នៅពីខាងមុខឡង់ទី (ឬដូចជាចេញមកពីចំណុចកំណុំ បើ $p = f$) នោះពេលចេញពីឡង់ទីស្របនឹងអ័ក្សមេ ។

## 1.2 សំណង់រូបភាពផ្តល់ដោយឡង់ទីពង្រីក




***រូបទី****4.13*

- កាំពន្លឺចាំងប៉ះ(1) ស្របនឹងអ័ក្សមេ បន្ទាប់ពីប៉ះនឹងឡង់ទី កាំនេះលេចចេញដូចជាឆ្លងកាត់ កំណុំរូបភាព $F'$ នៅពីខាងមុខឡង់ទី ។
- កាំពន្លឺចាំងប៉ះ(3) កាត់តាមផ្ចិតឡង់ទី ពេលចេញពីឡង់ទីដាលត្រង់ដោយគ្មានរងលំងាក ។
- កាំពន្លឺចាំងប៉ះ(2) កាត់តាមកំណុំ $F$ នៅពីខាងក្រោយឡង់ទី និងលេចចេញពីឡង់ទីស្របនឹង អ័ក្សអុបទិច ។

## 2. សមីការឡង់ទី

ដើម្បីរកទីតាំងពិត និងទំហំរូបភាពឱ្យដោយឡង់ទី ដោយប្រើសមីការដូចខាងក្រោម ៖

$$\frac{1}{p}+\frac{1}{q}=\frac{1}{f} \quad (6)$$

$f$ គឺជាចម្ងាយកំណុំឡង់ទី $p$ គឺជាចម្ងាយវត្ថុ និង $q$ គឺចម្ងាយរូបភាព ។

✍ **ដំណោះស្រាយ**

យើងពិនិត្យត្រីកោណកែងក្នុងរូបខាងក្រោម $\Delta ABO$ និង $\Delta DCO$




*រូបទី 4.14*

យើងបាន :

$$\left.\begin{aligned}\tan\theta' &= \frac{h}{p}\\ \tan\theta' &= \frac{h'}{q}\end{aligned}\right\} \Rightarrow \frac{h}{p}=\frac{h'}{q} \Leftrightarrow \frac{h'}{h}=\frac{q}{p} \quad (7)$$

ដូចគ្នាដែរចំពោះត្រីកោណកែង $\Delta A'OF'$ និង $\Delta DCF'$ គេបាន :

$$\left.\begin{aligned}\tan\theta &= \frac{h}{f}\\ \tan\theta &= \frac{h'}{q-f}\end{aligned}\right\} \Rightarrow \frac{h}{f}=\frac{h'}{q-f} \Leftrightarrow \frac{h'}{h}=-\frac{q-f}{f} \quad (8)$$

ផ្ទឹមសមីការ (7) និង (8) យើងបាន :

$$-\frac{q}{p}=-\frac{q-f}{f} \Rightarrow \frac{-q}{p}=\frac{-q+f}{f} \Rightarrow \frac{-q}{p}=\frac{-q}{f}+1$$

$$\Rightarrow \frac{-q}{p}+\frac{q}{f}=1 \Rightarrow q\left(-\frac{1}{p}+\frac{1}{f}\right)=1$$

$$\Rightarrow -\frac{1}{p}+\frac{1}{f}=\frac{1}{q}$$

ដូច្នេះយើងបាន : $\frac{1}{p}+\frac{1}{q}=\frac{1}{f}$ ផ្ទៀងផ្ទាត់នឹងរូបមន្តខាងលើ ។

## 2.1 កម្រិតពង្រីក

កម្រិតពង្រីកទំហំរូបភាពត្រូវកំណត់ដោយ : $M = \frac{h'}{h}$ (9)

ពីសមីការ (7) ខាងលើយើងបាន : $\frac{h'}{h} = -\frac{q}{p}$

នាំឱ្យយើងបាន : $M = \frac{h'}{h} = -\frac{q}{p}$ (10)

## 2.2 លក្ខណៈសម្គាល់របស់ឡង់ទី

ចម្ងាយកំណុំ $\begin{cases} f > 0 & \text{ជាឡង់ទីបង្រួម} \\ f < 0 & \text{ជាឡង់ទីពង្រីក} \end{cases}$

កម្រិតពង្រីក $\begin{cases} M > 0 & \text{រូបភាពឈរត្រង់ដូចនឹងវត្ថុ} \\ M < 0 & \text{រូបភាពឈរត្រង់ច្រាសនឹងវត្ថុ} \end{cases}$

វត្ថុ $\begin{cases} p > 0 & \text{វត្ថុពិត} \\ p < 0 & \text{វត្ថុមិនពិត} \end{cases}$

រូបភាព $\begin{cases} q > 0 & \text{រូបភាពពិត} \\ q < 0 & \text{រូបភាពមិនពិត} \end{cases}$

***ឧទាហរណ៍ :*** កំណត់ទីតាំង ប្រភេទ ទំហំ និងកម្រិតពង្រីកទំហំរូបភាពរបស់វត្ថុមួយដែលមានកម្ពស់ 1.0cm ត្រូវបានដាក់នៅចម្ងាយ 5.0cm , 10cm , 15cm និង 20cm នៅពីមុខនៃឡង់ទី ។ ចម្ងាយកំណុំឡង់ទីគឺ 10cm ។ សិក្សាទាំងករណីឡង់ទីបង្រួមនិងឡង់ទីពង្រីក ។

### ដំណោះស្រាយ

កំណត់ទីតាំងប្រភេទទំហំនិងកម្រិតពង្រីកទំហំរូបភាព

យើងមាន : $\frac{1}{p} + \frac{1}{q} = \frac{1}{f} \Rightarrow q = \frac{p+f}{p-f}$

**ក. ចំពោះឡង់ទីបង្រួម**




- ករណី $p = 5.0\text{cm}$ និង $f = 10\text{cm}$
- ទីតាំងរូបភាព : $q = \frac{p \times f}{p - f}$

ដូច្នេះ $q = \dfrac{5.0\text{cm} \times 10\text{cm}}{5.0\text{cm} - 10\text{cm}} = -10\text{cm} \quad \Rightarrow q = -10\text{cm}$

- ប្រភេទរូបភាព $q = -10\text{cm} < 0$ ដូច្នេះរូបភាពជារូបភាពមិនពិត ។
- ទំហំរូបភាព :

តាមទំនាក់ទំនង $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \quad \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{10\text{cm}}{5.0\text{cm}} \times 1.0\text{cm} = 2.0\text{cm}$

ដូច្នេះ $A'B' = 2.0\text{cm}$ ។

- កម្រិតពង្រីកទំហំរូបភាព : តាមទំនាក់ទំនង $M = -\dfrac{q}{p} = -\dfrac{(-10\text{cm})}{50\text{cm}} = 2.0$ ។ ដូច្នេះ

$M > 0 \Rightarrow$ រូបភាពមានទិសដៅដូចវត្ថុមានន័យថាឈរត្រង់ដូចវត្ថុ ។

- ករណី $p = 10\text{cm}$ និង $f = 10\text{cm}$ :




- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f}$

យើងបាន $q = \dfrac{10\text{cm} \times 10\text{cm}}{10\text{cm} - 10\text{cm}} = \dfrac{100\text{cm}^2}{0\text{cm}} = \infty$

ទីតាំងរូបភាព គឺស្ថិតនៅអនន្ត ។

- ប្រភេទរូបភាព :ដោយទីតាំងរូបភាពស្ថិតនៅអនន្ត ដូច្នេះប្រភេទរូបភាពមិនអាចកំណត់បាន ។
- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \quad \Rightarrow \quad A'B' = \left|\dfrac{q}{p}\right| \cdot AB = \infty$
- កម្រិតពង្រីកទំហំរូបភាព :$M = -\dfrac{q}{p} = \infty$ ។
- ករណី $P = 15\text{cm}$ និង $f = 10\text{cm}$




- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f}$

យើងបាន $q = \dfrac{15\text{cm} \times 10\text{cm}}{15\text{cm} - 10\text{cm}} = 30\text{cm}$

- ប្រភេទរូបភាព :

$q = 30\text{cm} > 0 \quad \Rightarrow$ ជារូបភាពពិត ។

- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow (A'B') = \left|\dfrac{q}{p}\right| \times AB = \dfrac{30\text{cm}}{15\text{cm}} \times 1.0\text{cm} = 2.0\text{cm}$
- កម្រិតពង្រីកទំហំរូបភាព $M = -\dfrac{q}{p} = -\dfrac{30\text{cm}}{15\text{cm}} = -2(M < 0)$ ដូច្នេះរូបភាពឈរបញ្ច្រាសវត្ថុ ។




- ករណី $p = 20\text{cm}$ និង $f = 10\text{cm}$
- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f}$

  យើងបាន $q = \dfrac{20\text{cm} \times 10\text{cm}}{20\text{cm} - 10\text{cm}} = 20\text{cm}$
- ប្រភេទរូបភាព : $q = 20\text{cm} > 0 \Rightarrow$ ជារូបភាពពិត
- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{20\text{cm}}{20\text{cm}} \times 1.0\text{cm} = 1.0\text{cm}$
- កម្រិតពង្រីកទំហំរូបភាព :$M = -\dfrac{q}{p} = -\dfrac{20\text{cm}}{20\text{cm}} = -1 \Rightarrow M < 0$ ដូច្នេះ រូបភាពឈរបញ្ច្រាសពីវត្ថុ ។

**ខ. ចំពោះឡង់ទីពង្រីក**




- ករណី $p = 5.0\text{cm}$ និង $f = 10\text{cm}$
- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f}$

  យើងបាន $q = \dfrac{(5.0\text{cm})(-10\text{cm})}{(5.0\text{cm}) - (-10\text{cm})} = -3.3\text{cm}$
- ប្រភេទរូបភាព : $q = -3.3\text{cm} < 0 \Rightarrow$ ជារូបភាពមិនពិត
- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{3.3\text{cm}}{5.0\text{cm}} \times 1.0\text{cm} = 0.66\text{cm}$
- កម្រិតពង្រីកទំហំរូបភាព $M = -\dfrac{q}{p} = -\dfrac{(-3.3\text{cm})}{5.0\boldsymbol{m}} = -0.66 \Rightarrow M > 0$ ដូច្នេះរូបភាពឈរត្រង់ដូចវត្ថុ ។
- ករណី $p = 10\text{cm}$ និង $f = -10\text{cm}$




- ទីតាំងរូបភាព :

  $q = \dfrac{p \times f}{p - f} = \dfrac{(10\text{cm})(-10\text{cm})}{(10\text{cm}) - (-10\text{cm})} = -5.0\text{cm}$
- ប្រភេទរូបភាព : $q = -5.0\text{cm} < 0 \Rightarrow$

  ជារូបភាពមិនពិត ។
- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{5.0\text{cm}}{10\text{cm}} \times 1.0\text{cm} = 0.50\text{cm}$
- កម្រិតពង្រីកទំហំរូបភាព $M = -\dfrac{q}{p} = -\dfrac{(-5.0cm)}{10cm} = 0.50 \Rightarrow M > 0$

  ដូច្នេះរូបភាពឈរត្រង់ដូចវត្ថុ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys

- ករណី $p = 15\text{cm}$ និង $f = -10\text{cm}$




- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f}$

យើងបាន $q = \dfrac{(15\text{cm})(-10\text{cm})}{(15\text{cm}) - (-10\text{cm})} = -6.0\text{cm}$

- ប្រភេទរូបភាព : $q = -6.0\text{cm} < 0 \Rightarrow$ ជារូបភាពមិនពិត

- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{6.0\text{cm}}{15\text{cm}} \times 1.0\text{cm} = 0.40\text{cm}$

- កម្រិតពង្រីកទំហំរូបភាព

$M = -\dfrac{q}{p} = -\dfrac{(-6.0\text{cm})}{15\text{cm}} = 0.40 \Rightarrow M > 0$ ដូច្នេះរូបភាពឈរត្រង់ដូចវត្ថុ ។

- ករណី $p = 20\text{cm}$ និង $f = -10\text{cm}$




- ទីតាំងរូបភាព : $q = \dfrac{p \times f}{p - f} \Rightarrow q = \dfrac{(20\text{cm})(-10\text{cm})}{(20\text{cm}) - (-10\text{cm})} = -6.7\text{cm}$

- ប្រភេទរូបភាព : $q = -6.7\text{cm} < 0 \Rightarrow$ ជារូបភាពមិនពិត ។

- ទំហំរូបភាព : $\dfrac{A'B'}{AB} = \left|\dfrac{q}{p}\right| \Rightarrow A'B' = \left|\dfrac{q}{p}\right| \times AB = \dfrac{6.7\text{cm}}{20\text{cm}} \times 1.0\text{cm} = 0.34\text{cm}$

- កម្រិតពង្រីកទំហំរូបភាព

$M = -\dfrac{q}{p} = -\dfrac{(-6.7\text{cm})}{20\text{cm}} = 0.34 \Rightarrow M > 0$

ដូច្នេះរូបភាពឈរត្រង់ដូចវត្ថុ ។

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## ពិសោធន៍ឡង់ទី

**1. វត្ថុបំណង**

ក្នុងការធ្វើពិសោធនេះ យើងគណនាចម្ងាយកំណុំឡង់ទី ប៉ោងដើម្បីផ្ទៀងផ្ទាត់នឹងរូបមន្ត : $\frac{1}{p}+\frac{1}{q}=\frac{1}{f}$ តាមរយៈសំណួរបំផុសដោយប្រាប់ពីទំនាក់ទំនងរវាង $p$ , $q$ និង $f$ ថាតើពិតជាត្រឹមត្រូវឬទេ ?

**2. សម្ភារៈ**

ទៀនមួយដើម ឡង់ទីប៉ោង (ឬកែវពង្រីក)មួយ បន្ទាត់ម៉ែតវែងមួយដើម ក្រដាសវ៉ាម $A4$ ស្កុតមួយដុំ កន្រ្តៃកាត់ក្រដាសមួយដើម ដែកកេះ និងអេក្រង់ ។

**3. ដំណើរការពិសោធ**

- កាត់ក្រដាសវ៉ាមតាមបណ្ដោយរបស់វាយ៉ាងណាឱ្យបានទទឹងប្រហែល 4.0cm ឱ្យបានចំនួន 6 សន្លឹក(បន្ទះ)ដោយប្រើកន្ត្រៃ ។
- យកក្រដាសវ៉ាមដែលកាត់រួចនោះមកបិទបន្តគ្នា ដូចក្នុងរូបឱ្យបានប្រវែងប្រហែលពី 150cm ទៅ 180cm សន្ទឹងលើផ្ទៃតុ រួចបិទភ្ជាប់តុដោយប្រើស្កុត ។
- ប៉ាន់ប្រមាណតម្លៃកំណុំរបស់ឡង់ទីឬកែវពង្រីក ។ រកតម្លៃនោះដោយជ្រើសរើសវត្ថុណាមួយស្ថិតនៅចម្ងាយឆ្ងាយពី 5m ទៅ 10m ពីឡង់ទី រួចដាក់ឱ្យពន្លឺដាលពីវត្ថុនោះឆ្លងកាត់ឡង់ទីនិងប្រើអេក្រង់ដើម្បីត្រងរូបភាពរបស់វា ។ បន្ទាប់មកវាស់ចម្ងាយរវាងអេក្រង់ និងឡង់ទីដោយប្រើម៉ែតឬបន្ទាត់ ។ ចម្ងាយនោះ គឺចម្ងាយកំណុំឡង់ទីទទួលបានដោយការប៉ាន់ស្មាន ។
- យកម៉ែតដាក់តាមបណ្ដោយក្រដាសវ៉ាមដែលបន្ត រួចហើយគ្រិតវាឱ្យបានប្រវែងស្មើៗគ្នាក្នុងតម្លៃ 10cm ។




*រូបទី4.15*

- យកទៀនមកកាត់ឱ្យបានកម្ពស់តូចជាងអង្កត់ផ្ចិតឡង់ទីឬកែវពង្រីក រួចដាក់បិទបញ្ឈរត្រង់ផ្នែកចុងម្ខាងនៃក្រដាសវ៉ាមដូច(រូបទី *4.16*)



រូបទី4.16

- ដាក់ឡង់ទីលើក្រដាសវ៉ាមនោះនៅចម្ងាយស្មើនឹង 30cm (ប្រហែល 3 ដងនៃចម្ងាយកំណុំប៉ាន់ស្មាន) ពីវត្ថុ (ទៀន) គេបានចម្ងាយវត្ថុ $p$ = 30cm ។
- ដុតទៀន រួចដាក់អេក្រង់លើក្រដាសវ៉ាមដែលបានសន្និងនៅលើផ្ទៃតុធ្វើយ៉ាងណាឱ្យទៀន ឡង់ទី និងអេក្រង់កំណត់ត្រង់ជួរគ្នា រួចរំអិលអេក្រង់នោះដើម្បីរកទីតាំងដែលផ្តល់រូបភាពច្បាស់បំផុត ។
- បន្ទាប់ពីរកទីតាំងដែលផ្តល់រូបភាពច្បាស់បានហើយ ចូរដាក់អេក្រង់ឱ្យនៅនឹង រួចហើយកំណត់ចម្ងាយពីឡង់ទីទៅទីតាំងអេក្រង់ដែលផ្តល់រូបភាពច្បាស់នោះ ចម្ងាយនេះហៅថាចម្ងាយរូបភាពដែលគេតាងដោយ $q$ = 9cm ។

**សម្គាល់ : ប្រសិនបើទីតាំងដែលផ្តល់រូបភាពច្បាស់មានច្រើន នោះអ្នកត្រូវកំណត់ទីតាំងដើម និងទីតាំងស្រេច រួចកំណត់ចម្ងាយ $q$(cm) ពីចំណុចកណ្តាលនៃទីតាំងទាំងពីរទៅឡង់ទី ។**

- វាស់ចម្ងាយ $q$(cm) ពីឡង់ទីទៅរូបភាពដែលទទួលបានលើអេក្រង់ដោយប្រើម៉ែតឬបន្ទាត់ រួចកត់តម្លៃនេះទៅក្នុងតារាងលទ្ធផល ។
- ប្តូរតម្លៃ $p$ ឱ្យធំជាងមុនបន្តបន្ទាប់ដោយតម្លៃប្រហែល 4 ដង 6 ដងនៃចម្ងាយកំណុំប៉ាន់ស្មានរបស់ឡង់ទីគឺ 40cm , 50cm និង 60cm ។

## 4. លទ្ធផលពិសោធន៍

បន្ទាប់ពីធ្វើពិសោធន៍រួច ចូរកត់ត្រាតម្លៃដែលអ្នកវាស់បានចូលក្នុងតារាងខាងក្រោម :

| **ពិសោធន៍លើកទី** | $p$(cm) | $q$(cm) | $f$(cm) |
|---|---|---|---|
| 1 | 30 | | |
| 2 | 40 | | |
| 3 | 50 | | |
| 4 | 60 | | |
| តម្លៃមធ្យមនៃ $f$(cm) | $f = (f_1 + f_2 + f_3 + f_4)/4 =$ ......(cm) | | |

ពីសមីការ $\frac{1}{p} + \frac{1}{q} = \frac{1}{f}$ ទាញរកតម្លៃនៃ $f$ ទៅតាមតម្លៃ $p$ និង $q$ នីមួយៗដែលបានវាស់ទាំង 4 ដងខាងលើ ។

5. **សន្និដ្ឋាន**

ក. តើអ្នកសង្កេតឃើញយ៉ាងដូចម្ដេចចំពោះតម្លៃនៃ $f$ ធៀបទៅតម្លៃ $p$ និង $q$ ?

ខ. ចូរប្រើទិន្នន័យដែលអ្នកវាស់បានរួចគណនាតម្លៃនៃ $f$ ទៅតាមតម្លៃ $p$ និង $q$ នីមួយៗ ដែលបានវាស់ទាំង 4 ដងខាងលើ ។

គ. គណនារកតម្លៃមធ្យមនៃចម្ងាយកំណុំឡង់ទីដែលបានធ្វើទាំង 4 លើកខាងលើ ។ តម្លៃនេះជាចម្ងាយកំណុំរបស់ឡង់ទី ឬកែវពង្រីកដែលទទួលបានពីពិសោធន៍ ។

6. **សំណួរពិភាក្សា**

ក. ចូរពន្យល់ថាតើនឹងមានអ្វីកើតឡើង ប្រសិនបើគេដាក់ឡង់ទីនៅចម្ងាយមួយធំជាងចម្ងាយកំណុំប៉ាន់ស្មានបន្តិចបន្តួច ?

ខ. ប្រសិនបើទីតាំងដែលផ្ដល់រូបភាពច្បាស់លើអេក្រង់មានច្រើននោះអ្នកត្រូវកំណត់ទីតាំងដើម និងទីតាំងស្រេច រួចកំណត់ចម្ងាយ $q(\mathrm{cm})$ ពីចំណុចកណ្ដាលនៃទីតាំងទាំងពីរទៅឡង់ទី ។ ហេតុអ្វី ?

គ. ពិសោធន៍នេះអ្នកត្រូវការបន្ទប់មួយដែលស្ងប់ ពោលគឺគ្មានចរន្តខ្យល់បក់ ព្រោះថាកាលណាមានចរន្តខ្យល់ ពេលនោះទីតាំងនៃអណ្ដាតភ្លើងទៀនវិលវល់តាមចរន្តខ្យល់ ។ ដូច្នេះដើម្បីទទួលបានលទ្ធផលល្អ តើអ្នកគួររៀបចំការពិសោធយ៉ាងដូចម្ដេចខ្លះ ក្រៅពីការរកបន្ទប់ដែលស្ងប់ខ្យល់ ? ចូរបង្ហាញចំណុចទាំងនោះ ។

# 3. អនុវត្តន៍ឡង់ទី

## 3.1 ភ្នែក

ភ្នែកគឺជាគ្រឿងទទួលពន្លឺមួយដ៏សំខាន់បំផុតនិងជាប្រព័ន្ធអុបទិចមួយដែលមានភាពស្មុគស្មាញ ។

### ក. ទម្រង់ភ្នែក



*រូបទី4.17* ***ពំនុះភ្នែក***

រូបខាងក្រោមតាងពំនុះភ្នែកក្នុងនោះយើងឃើញថា កែវភ្នែក (ប្រភេទឡង់ទីប៉ោង) ជាអ្នកបង្កើតរូបភាពនៃវត្ថុដែលត្រូវមើល ។ រេទីនជាស្រទាប់រួសពន្លឺ (រូបភាពជិតលើរេទីន) សាច់ដុំកងធ្វើបម្រែបម្រួលទ្រង់ទ្រាយកែវភ្នែកដើម្បីឱ្យភ្នែកមើលឃើញជិតឬឆ្ងាយ ។ អង្កត់ផ្ចិតរន្ធប្រស្រីប្រែប្រួលដើម្បីលៃតម្លៃបរិមាណពន្លឺចូល : 2mm ចំពោះពន្លឺខ្លាំង និង 8mm ចំពោះពន្លឺខ្សោយ ។

កោសិកា (កោន និងដំបង)ឋិតនៅលើរេទីន កាលណាកោសិកាណាមួយទទួលបានពន្លឺស៊ីញ៉ាល់ត្រូវបញ្ជូនទៅខួរក្បាលតាមសរសៃប្រសាទអុបទិច ។ ភ្នែកមានភាពរួសខ្លាំងនៅជុំវិញស្នាមលឿង (មានកោនច្រើន) ហើយភាពរួសនេះមានតម្លៃសូន្យនៅត្រង់ចំណុចខ្វាក់ (គ្មានកោននិងដំបងទេ) ។

## ខ. ដំណើរប្រព្រឹត្តទៅនៃភ្នែក

កាលណាវត្ថុភ្លឺមួយឋិតនៅពីមុខភ្នែក វាបញ្ជូនពន្លឺទៅដល់ភ្នែកហើយកែវភ្នែកផ្តុំពន្លឺនោះត្រង់ចំណុច $A'$ មួយលើរេទីន ។ $A'$ ជារូបភាពរបស់ $A$ ។ បើចំណុចរូបភាព $A'$ នោះនៅមុខ ឬនៅក្រោយរេទីនគេមើលវត្ថុមិនច្បាស់ទេ ។ កោន និងដំបងគឺជាអ្នកទទួលពន្លឺ ។ ដំបងរួសជាមួយពន្លឺខ្សោយ តែមិនអាចញែកពណ៌បានទេ ។ ឯកោនត្រូវការចាំបាច់ពន្លឺខ្លាំងតែវាស្គាល់បាននូវពណ៌ផ្សេងៗ ។

កោនមាន 3 ប្រភេទ : កោនរួសនឹងពន្លឺក្រហម ពន្លឺខៀវ និងពន្លឺបៃតង ។ កោននីមួយៗ ចាប់ពណ៌ណាមួយដែលត្រូវនឹងខ្លួនវា ហើយបញ្ជូនព័ត៌មានទៅខួរក្បាលដើម្បីវិនិច្ឆ័យ ។



រូបទី4.18

**ទីតាំងនៃដែនគំហើញជិត** (Near point) របស់ភ្នែក ធម្មតាគឺជាចម្ងាយខ្លីបំផុតដែលឡង់ទីកែវភ្នែកអាចសម្រួលដើម្បីផ្តុំពន្លឺលើរេទីន ។ ចម្ងាយនេះជាធម្មតាកើនឡើងតាមអាយុ ។ ចំពោះមនុស្សអាយុ : 10 ឆ្នាំ 20 ឆ្នាំ 30 ឆ្នាំ 40 ឆ្នាំ 50 ឆ្នាំ និង 60 ឆ្នាំ ចម្ងាយនៃដែនគំហើញជិតប្រហែល 7cm 10cm 14cm 22cm 40cm និង 200cm រៀងទៅ ។



រូបទី4.19

ចំណែកឯ **ទីតាំងនៃដែនគំហើញឆ្ងាយ** ( Far point) វិញតាងឱ្យចម្ងាយធំបំផុតដែលឡង់ទីកែវភ្នែកអាចសម្រួលដើម្បីផ្តុំពន្លឺលើរេទីន ។ មនុស្សមើលឃើញធម្មតាអាចឃើញវត្ថុនៅយ៉ាងឆ្ងាយ ដូច្នេះទីតាំងនៃដែនគំហើញឆ្ងាយមិនកំណត់ទេ ។



រូបទី4.20

## គ. លក្ខខណ្ឌនៃភ្នែក

កាលណាភ្នែកមានជំងឺ ចម្ងាយរូបភាពដែលឱ្យដោយប្រព័ន្ធឡង់ទី-ករនេ និងប្រវែងពីកែវភ្នែកទៅរេទីនមិនត្រូវគ្នា(មិនស៊ីគ្នាទេ) ។ ជាលទ្ធផលកាំពន្លឺដាលពីវត្ថុនៅក្បែរៗភ្នែកទៅដល់រេទីនមុននឹងវាបង្រួមដើម្បីបង្កើតរូបភាព ។ គេហៅលក្ខខណ្ឌនេះថា **អ៊ីពែមេត្រូប** ។ អ្នកអ៊ីពែមេត្រូបជាធម្មតាអាចមើលឃើញវត្ថុនៅឆ្ងាយច្បាស់ ប៉ុន្តែវត្ថុនៅជិតមើលឃើញមិនច្បាស់ទេ ។ ដើម្បីឱ្យមើលឃើញបានច្បាស់ គេត្រូវប្រើឡង់ទីបង្រួមមួយនៅខាងមុខភ្នែក ។

អ្នកម៉្យូប អាចមើលឃើញវត្ថុនៅជិតច្បាស់ ។ ចំណែកវត្ថុនៅឆ្ងាយមើលឃើញមិនច្បាស់ទេ ។ ដែនគំហើញឆ្ងាយរបស់អ្នកម៉្យូបអាចតូចជាងមួយម៉ែត ។ ចម្ងាយកុំណុំអតិបរមារបស់ភ្នែកម៉្យូបមិនគ្រប់គ្រាន់ដើម្បីបង្កើតរូបភាពច្បាស់លើរេទីនទេ ហើយកាំពន្លឺដែលដាលពីវត្ថុនៅឆ្ងាយបង្រួមនិងផ្តុំគ្នានៅមុខរេទីន ។ បន្ទាប់មកវាបន្តដាលឆ្លងកាត់ចំណុចនេះជាបាច់ពន្លឺរីកមុនទៅដល់រេទីន ។ នេះជាមូលហេតុបណ្តាលឱ្យអ្នកភ្នែកម៉្យូបមើលឃើញមិនច្បាស់ ។ ដូចនេះដើម្បីអ្នកម៉្យូបមើលឃើញច្បាស់ គេត្រូវឡង់ទីពង្រីកមួយ ។

## 4.2 ម៉ាស៊ីនថតរូប

ម៉ាស៊ីនថតរូបផ្សំឡើងដោយឡង់ទីបង្រួម ប្រអប់បិទជិតមានរន្ធឆ្នារតូចមួយដែលអាចឱ្យពន្លឺដាលចូលបាន និងហ្វីលរួសនឹងពន្លឺដើម្បីថតរូបភាព ។ ម៉ាស៊ីនថតរូបមានដំណើរការដូចភ្នែកមនុស្សដែរ ។ វាបង្កើតរូបភាពពិតតូច ឈរបញ្ច្រាសនៅលើហ្វីលដូចបង្ហាញក្នុងរូប ។ គេប្រើកងកំណុំដើម្បីរំកិលឡង់ទីឱ្យឆ្ងាយពីហ្វីល ឬមកជិតហ្វីលដើម្បីទទួលបានរូបភាពច្បាស់ពេញលេញនៅលើហ្វីល ។ វត្ថុនៅឆ្ងាយផ្តល់រូបភាពនៅលើហ្វីលដែលមានចម្ងាយស្មើនឹងចម្ងាយកំណុំនៃឡង់ទី ។ ចំណែកឯវត្ថុនៅជិតផ្តល់ចម្ងាយរូបភាពធំជាងចម្ងាយកំណុំ ។




ឡង់ទីបង្រួមក្នុងម៉ាស៊ីនថតរូបបង្កើតរូបភាពពិតតូចនិងឈរបញ្ច្រាសពីវត្ថុ

*រូបទី4.21*

## 4.3 កែវពង្រីកដាយ

កែវពង្រីកដាយ គឺជាឧបករណ៍អុបទិចមួយយ៉ាងសាមញ្ញ ដែលត្រូវបានបង្កើតពីឡង់ទីបង្រួមមួយ ។ ឧបករណ៍នេះបង្កើនទំហំទំនងរបស់វត្ថុ ។ ឧបមាថាគេមើលវត្ថុមួយចម្ងាយ p ពីភ្នែក (រូបទី 4.22 ក) ទំហំរូបភាពលើរេទីនអាស្រ័យលើ $\theta$ កើនឡើងហើយគេសង្កេតឃើញថារូបភាពមានទំហំធំជាង ។ ចំពោះភ្នែកធម្មតាគិតជាមធ្យមមិនអាចមើលឃើញវត្ថុដែលមានចម្ងាយតូចជាង $25cm$ ច្បាស់បានទេ ។ត្រង់ចំណុចមួយដែលមានចម្ងាយ$25cm$ ពីភ្នែក ចំណុចនេះហៅថាដែនគំហើញជិត (រូបទី 4.22ខ) ។ ដូច្នេះ $\theta$ អតិបរមាត្រង់ដែនគំហើញជិត ។




(ក) (ខ)

ដើម្បីបង្កើនទំហំមុំទំនងរបស់វត្ថុ គេដាក់ឡុងទីបង្រួមមួយនៅពីមុខភ្នែក(រូបទី 4.22 គ)ដែលវត្ថុស្ថិតនៅត្រង់ចំណុច O ចន្លោះចំណុចកំណុំ F និងឡង់ទី ។ ត្រង់ទីតាំងនេះឡង់ទីបង្កើតរូបភាពមិនពិតមួយមានទំហំធំជាងវត្ថុ និងឈរត្រង់ដូចវត្ថុដែរ ។ យើងកំណត់កម្រិតពង្រីកមុំ m គឺជាផលធៀបរវាងមុំ $\theta$ និងមុំ $\theta_0$ ។



រូបទី4.22

គេសរសេរ : $m = \dfrac{\theta}{\theta_0}$ (11)

$\theta$ ជាមុំដែលបង្កើតដោយវត្ថុដោយប្រើឡង់ទី(រូបទី 4.22 គ)និង $\theta_0$ ជាមុំដែលបង្កើតដោយវត្ថុដាក់ត្រង់ដែនគំហើញជិតដោយមិនប្រើឡង់ទី(រូបទី 4.22 ខ) ។

កម្រិតពង្រីកមុំអតិបរមា កាលណារូបភាពស្ថិតត្រង់ដែនគំហើញជិតរបស់ភ្នែក មានន័យថា កាលណា $q = -25\text{cm}$ ។

ចម្ងាយវត្ថុត្រូវទាញបានពីសមីការឡង់ទីបង្រួម

$$\frac{1}{p} + \frac{1}{-25\text{cm}} = \frac{1}{f} \Rightarrow p = \frac{25f}{25+f}$$

ដែល $f$ ជាចម្ងាយកំណុំរបស់កែវពង្រីក គិតជា cm ។ បើមុំតូច គេបាន

$$\tan\theta_0 \approx \theta_0 = \frac{h}{25} \text{ និង } \tan\theta \approx \theta = \frac{h}{p}$$

ដូច្នេះ កម្រិតពង្រីកមុំអតិបរមាគឺ

$$m_{max} = \frac{\theta}{\theta_0\rho} = \frac{h/p}{h/25} = \frac{25}{p} = \frac{25}{25f/(25+f)} = 1 + \frac{25}{f} \Rightarrow m_{max} = 1 + \frac{25}{f}$$

ភ្នែកអាចមើលឃើញរូបភាពគ្រប់ទីកន្លែងទាំងអស់ កាលណារូបភាពស្ថិតចន្លោះដែនគំហើញជិត និងអនន្ត ប៉ុន្តែមិនអាចមើលឃើញទេកាលណារូបភាពស្ថិតនៅអនន្ត ។ រូបភាពនៅអនន្ត កាលណាវត្ថុស្ថិតត្រង់ចំណុចកំណុំរបស់ឡង់ទី ។ ក្នុងករណីនេះគេបាន

$$\theta_0 = \frac{h}{25} \text{ និង } \theta = \frac{h}{f}$$

ដូច្នេះកម្រិតពង្រីកមុំអប្បបរមាគឺ : $m_{min} = \dfrac{\theta}{\theta_0} = \dfrac{25}{f}$

***ឧទាហរណ៍ :*** តើកម្រិតពង្រីកមុំអតិបរមារបស់ឡង់ទីមួយដែលមានចម្ងាយកំណុំ 10cm មានតម្លៃប៉ុន្មាន ? ហើយកម្រិតពង្រីកមុំអប្បបរមាមានតម្លៃស្មើនឹងប៉ុន្មាន កាលណារូបភាពស្ថិតនៅអនន្ត ?

### ដំណោះស្រាយ

ផលធៀបមុំពង្រីកមានតម្លៃអតិបរមា កើតមានឡើងនៅពេលដែលរូបភាពឋិតនៅត្រង់ទីតាំងជិតកែវភ្នែក (រូបទី 4.22 ខ) យើងបាន :

$$m_{max} = \frac{q+f}{f} = \frac{q}{f} + \frac{f}{f} = \frac{q}{f} + 1 = \frac{25cm}{10cm} + 1 = \frac{35}{10} = 3.5$$

កាលណាយើងបន្ថយចម្ងាយភ្នែកពីទីតាំងរូបភាព (ដូចរូបខ.) ពេលនោះយើងបាន

$$m_{min} = \frac{\theta}{\theta_0} = \frac{q}{f} = \frac{25\text{cm}}{10\text{cm}} = \frac{25}{10} = 2.5$$

## 4.4 តេលេទស្សន៍




*រូបទី4.23*

គេបង្កើតតេលេទស្សន៍ដើម្បីជំនួយក្នុងការមើលវត្ថុដែលនៅឆ្ងាយៗដូជាភពផ្សេងៗនៅក្នុងប្រព័ន្ធព្រះអាទិត្យ ។ តេលេទស្សន៍មានពីរប្រភេទ : តេលេទស្សន៍បំបែរនិងបំផ្លាតពន្លឺ ។ តេលេទស្សន៍បំបែរពន្លឺប្រើបង្គុំឡង់ទីដើម្បីបង្កើតរូបភាព(រូបទី 4.23 ក) ។ ចំណែកឯតេលេទស្សន៍បំផ្លាតពន្លឺប្រើកញ្ចក់ស៊្វែមួយនិងឡង់ទីមួយ(រូបទី4.23 ខ) ។ យើងសិក្សាតែតេលេទស្សន៍បំបែរ ចំណែកឯតេលេទស្សន៍បំផ្លាតនឹងសិក្សានៅសាកលវិទ្យាល័យ ។

### ដំណើរពន្លឺឆ្លងកាត់តេលេទស្សន៍បំបែរ

(រូបទី 4.23 ក)បង្ហាញថាឡង់ទី $L_0$ (ហៅថា Objective) បង្កើតរូបភាពរបស់វត្ថុដែលនៅឆ្ងាយជារូបភាពពិត $I_1$ ឈរបញ្ច្រាសនឹងវត្ថុស្ថិតត្រង់ចំណុចកំណុំរូបភាព $F_0$ របស់ឡង់ទី $L_0$ ។ រូបភាព $I_1$ មាននាទីជាវត្ថុពិតចំពោះឡង់ទី $L_e$ ហៅថា អាយភីស (Eyepiece) បង្កើតរូបភាព $I_2$ ជារូបភាពពិតមានទំហំធំ ឈរត្រង់ដូចគ្នានឹង $I_1$ នៅខាងមុខឡង់ទី $L_e$ ។ ដើម្បីបានកម្រិតពង្រីកធំបំផុតនោះចាំបាច់ត្រូវមានចម្ងាយរូបភាពស្រេចធំបំផុត (អនន្ត) ។ ដូច្នេះរូបភាព $I_1$ ដែលបង្កើតដោយ $L_0$ ត្រូវស្ថិតត្រង់ចំណុចកំណុំ $f_e$ របស់ឡង់ទី $L_e$ ។ ឡង់ទីទាំងពីរត្រូវឃ្លាតពីគ្នាចម្ងាយ $f_0 + f_e$ ដែលត្រូវគ្នានឹងប្រវែងបំពង់របស់តេលេទស្សន៍ ។

កម្រិតពង្រីកមុំរបស់តេលេទស្សន៍ត្រូវឱ្យដោយ $\frac{\theta}{\theta_0}$ ដែល $\theta_0$ ជាមុំត្រង់ $L_e$ បង្កើតដោយ $I_1$ និង $\theta$ ជាមុំត្រង់ភ្នែកអ្នកសង្កេតបង្កើតដោយរូបភាពស្រេច $I_2$ ។ $\tan\theta_0 \approx \theta_0 = -\frac{h'}{f_0}$ និង $\tan\theta \approx \theta = -\frac{h'}{f_e}$ យើងមិនប្រើសញ្ញា (-) ព្រោះរូបភាពស្រេច $I_2$ និង $I_1$ មានទិសដៅដូចគ្នា។ ដូច្នេះកម្រិតពង្រីកមុំរបស់តេលេទស្សន៍គឺ : $m = \frac{\theta}{\theta_0} = \frac{h'/f_e}{-h'/f_0} = -\frac{f_0}{f_e}$ ។

យើងឃើញថា កម្រិតពង្រីកមុំរបស់តេលេទស្សន៍ស្មើនឹងផលធៀបរវាងចម្ងាយកំណុំរបស់ឡង់ទី $L_0$ និងចម្ងាយកំណុំរបស់ឡង់ទី $L_e$ ។ សញ្ញា (-) បង្ហាញថារូបភាពមានទិសដៅផ្ទុយពីវត្ថុ ។

## មេរៀនសង្ខេប

- ឡង់ទីគឺជាឧបករណ៍មួយដែលធ្វើឱ្យពន្លឺអាចរីកឬរួមបាន ។ ជាធម្មតាវាត្រូវបានផលិតឡើងពីបន្ទះកែវ ប្លាស្ទិច ឬសារធាតុថ្លា ។
- ឡង់ទីមានពីរប្រភេទៈ ឡង់ទីពង្រីកនិងឡង់ទីបង្រួម ។ ឡង់ទីបង្រួមជាឡង់ទីមានគែមស្តើងនិងឡង់ទីពង្រីកជាឡង់ទីមានគែមក្រាស់ ។
- រូបមន្តរបស់ឡង់ទី : $\frac{1}{p} + \frac{1}{q} = \frac{1}{f}$
- កម្រិតពង្រីកគឺជាផលធៀបរវាងប្រវែងរូបភាព និងប្រវែងវត្ថុ : $m = \frac{h'}{h} = \frac{q}{p}$
- ភ្នែកជាគ្រឿងទទួលពន្លឺមួយដ៏សំខាន់បំផុត និងជាគំហើញនៃប្រព័ន្ធអុបទិចមួយដែលមានភាពស្មុគស្មាញ ។
- កែវពង្រីកជាឧបករណ៍អុបទិចយ៉ាងសាមញ្ញ គឺជាឡង់ទីបង្រួមដែលមានចម្ងាយកំណុំខ្លីនិងមានផលធៀបមុំគឺ $m \equiv \frac{\theta}{\theta_0}$ ។
- ម៉ាស៊ីនថតរូប ឬកាមេរ៉ាផ្សំឡើងដោយឡង់ទីបង្រួមវាជាប្រអប់បិទជិត (មានរន្ធឆ្មារតូចមួយដែលអាចឱ្យពន្លឺជាលចូលបាន) និងហ្វីល (រួសនឹងពន្លឺដើម្បីថតរូបភាព) ។
- គេបង្កើតតេលេទស្សន៍ដើម្បីជំនួយក្នុងការមើលវត្ថុដែលនៅឆ្ងាយៗដូចជាភពផ្សេងៗ នៅក្នុងប្រព័ន្ធព្រះអាទិត្យ ។ តេលេទស្សន៍មានពីរប្រភេទ : តេលេទស្សន៍បំបែរនិងបំផ្លាតពន្លឺ ។

## សំណួរនិងលំហាត់

**1.** ដូចម្តេចហៅថាឡង់ទី ? តើឡង់ទីមានប៉ុន្មានប្រភេទ ? ចូរគូររូបតាងប្រភេទឡង់ទីនីមួយៗ ។

**2.** ដូចម្តេចហៅថាចំណុចកំណុំរបស់ឡង់ទី ?

**3.** ហេតុអ្វីបានជាវត្ថុភ្លឺស្ថិតនៅឆ្ងាយពីឡង់ទីបង្រួមមានទីតាំងរូបភាពស្ថិតនៅលើកំណុំនៃឡង់ទី ?

4. តើកែវភ្នែកជាប្រភេទឡង់ទីអ្វី ? តើវាមានតួនាទីជាអ្វី ?

5. តើកែវពង្រីកធ្វើពីឡង់ទីប្រភេទណា ? ហេតុអ្វីបានជាឡង់ទីដែលយកមកធ្វើកែវពង្រីកត្រូវមានចម្ងាយកំណុំខ្លី ?

6. ឡង់ទីផ្សំឡើងដោយកំណាត់ព្រីសតូចដូចរូប ។ តើកំណាត់ព្រីស (ក) និង(ខ)មួយណាបំបែរកាំពន្លឺខ្លាំងជាង ? ចូរគូរកាំពន្លឺដាលឆ្លងកាត់កំណាត់ព្រីសទាំងពីរ ។




7. ចូរគូរកាំពន្លឺពិសេសបំពេញរូបខាងក្រោមដើម្បីរកទីតាំងរូបភាព :



8. ចូរគូរកាំពន្លឺពិសេសបំពេញលើរូបខាងក្រោម ។ គណនាចម្ងាយរូបភាពនិងចម្ងាយកំណុំរបស់វា ដោយដឹងថាកម្រិតពង្រីករបស់ឡង់ទីស្មើនឹង 2.0 និងចម្ងាយវត្ថុស្មើ 20cm ។




9. តើគេត្រូវដាក់បន្ទាត់ភ្លឺមួយនៅត្រង់កន្លែងណា ដើម្បីឱ្យឡង់ទីបង្រួមមួយដែលមានចម្ងាយកំណុំ $f = 20cm$ បានរូបភាពមួយធំជាងបន្ទាត់ភ្លឺបួនដងដោយរកក្នុងករណីរូបភាពពិតនិងមិនពិត ?




10. កំណត់ប្រភេទនិងទីតាំងនៃវត្ថុដែលឡង់ទីពង្រីកមួយអាចផ្តល់រូបភាពធំជាងវត្ថុបីដង ។ តើរូបភាពស្ថិតនៅត្រង់កន្លែងណា បើគេដឹងថាឡង់ទីនេះមានចម្ងាយកំណុំ $f = 12cm$ ?



## ? សំណួរនិងលំហាត់ជំពូក 4

**I.** ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវតែមួយគត់ :

**1.** តាមករណីខាងក្រោមនេះ ករណីណាមួយជាពំនោលចំណាំងផ្លាត :

ក. ☐ មុំដែលកើតឡើងរវាងកាំចាំងប៉ះនិងខ្សែកែងនឹងផ្ទៃកញ្ចក់ស្មើនឹងមុំដែលកើតឡើងរវាងផ្ទៃកញ្ចក់និងកាំចាំងផ្លាត ។

ខ. ☐ មុំដែលកើតឡើងរវាងកាំចាំងប៉ះនិងផ្ទៃកញ្ចក់ស្មើនឹងមុំដែលកើតឡើងរវាងផ្ទៃកញ្ចក់និងកាំចាំងផ្លាត ។

គ. ☐ មុំដែលកើតឡើងរវាងកាំចាំងប៉ះនិងខ្សែកែងនឹងកញ្ចក់ស្មើនឹងមុំដែលកើតឡើងរវាងខ្សែកែងនិងកាំចាំងផ្លាត ។

ឃ. ☐ មុំដែលកើតឡើងរវាងកាំចាំងប៉ះនិងខ្សែកែងនឹងផ្ទៃកញ្ចក់ជាមុំបំពេញរវាងខ្សែកែងនិងកាំចាំងផ្លាត ។

**2.** តាមករណីខាងក្រោមនេះ តើករណីណាមួយដែលកាំចាំងបែរមានលំងាកមកជិតខ្សែកែងន័រម៉ាល់ :

ក. ☐ $n_1 > n_2$ កាលណា $\theta_1 = 20°$ ។

ខ. ☐ ពីខ្យល់ទៅកញ្ចក់ មានមុំចំណាំងប៉ះស្មើនឹង 30° ។

គ. ☐ ពីកញ្ចក់ទៅខ្យល់មានមុំចំណាំងប៉ះស្មើនឹង 30° ។

**3.** ដ្យាក្រាមខាងក្រោមបង្ហាញកាំពន្លឺចាំងប៉ះលើផ្ទៃអង្គធាតុរាវ ។

សន្ទស្សន៍ចំណាំងបែរនៃអង្គធាតុនាំឱ្យ :




☐ ក. $\frac{\sin 60°}{\sin 50°}$ ☐ ខ. $\frac{\sin 30°}{\sin 50°}$

☐ គ. $\frac{\sin 60°}{\sin 40°}$ ☐ ឃ. $\frac{\sin 50°}{\sin 60°}$

**4.** សន្ទស្សន៍ចំណាំងបែរនៃបង់សែនគឺ 1.5 ។ តើមុំកម្រិតនៃបង់សែនស្មើនឹងប៉ុន្មាន ?

☐ ក. 0.667° ☐ ខ. 42° ☐ គ. 48° ☐ ឃ. 90°

**5.** ដ្យាក្រាមខាងក្រោមបង្ហាញពីមនុស្សម្នាក់ចង់វាស់ចម្ងាយកំណុំឡង់ទី ។



តើចម្ងាយណាមួយជាចម្ងាយកំណុំឡង់ទី?

☐ក. $x$ ☐ខ. $y$ ☐គ. $z$ ☐ឃ. $x+z$ ។

6. ដ្យាក្រាមបង្ហាញពីអង្គធាតុមួយដាក់ពីមុខឡង់ទីបង្រួមដែលមានចម្ងាយកំណុំ $f$ ។ តើរូបភាពត្រូវបង្កើតត្រង់ទីតាំងណា ?

☐ក. នៅពីមុខចំណុច $A$

☐ខ. នៅត្រង់ចំណុច $A$

☐គ. នៅត្រង់ចំណុច $B$

☐ឃ. នៅត្រង់ចំណុច $D$




7. រូបភាពបង្កើតលើហ្វីលនៃម៉ាស៊ីនថតរូបងាយគឺ

☐ក. រូបភាពពិត តូចជាង និងមានទិសដៅផ្ទុយពីវត្ថុ ។

☐ខ. រូបភាពពិត តូចជាង និងមានទិសដៅដូចវត្ថុ ។

☐គ. រូបភាពពិត ធំជាង និងមានទិសដៅដូចវត្ថុ ។

☐ក. រូបភាពពិត ធំជាង និងមានទិសដៅផ្ទុយពីវត្ថុ ។

## II. ចូរបំពេញនូវល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :

1. វត្ថុនៅខាងក្នុងចំណុចឡង់ទីរបស់ម៉ាស៊ីនថតជា . . . . . . . ។
2. វត្ថុនៅខាងក្រៅចំណុចកំណុំរបស់ម៉ាស៊ីនថតជា . . . . . . នៃគំហើញ ។
3. ប្រភេទរូបភាពដែលបង្កើតឡើងដោយករនេ និងឡង់ទីនៅលើរ៉េទីនជា . . . . . . . ។
4. វត្ថុនៅខាងក្រៅចំណុចកំណុំចំណាំងបែរនៃតេលេទស្សន៍ជា . . . . . របស់ឡង់ទី ។

## III. លំហាត់

1. គេឱ្យល្បឿនពន្លឺក្នុងសុញ្ញកាសគឺ $3.0\times10^{8}\mathrm{m/s}$ ។ គណនាល្បឿនពន្លឺក្នុងកែវដែលមានសន្ទស្សន៍ចំណាំងបែរ 1.52 ។

2. រូបខាងក្រោមបង្ហាញពីកាំពន្លឺចាំងប៉ះលើផ្ទៃញែកដែលមានមុំចំណាំងប៉ះ 60° ។ សន្ទស្សន៍ចំណាំងបែរនៃទឹកគឺ 1.33 ។




ក. គណនាមុំចំណាំងបែរ ។

ខ. បំពេញដ្យាក្រាមដោយគូសកាំចាំងបែរនៅក្នុងទឹក ។

3. ពិនិត្យរូប រួចគណនាមុំកម្រិតនៃព្រីសកែងមួយដែលមានសន្ទស្សន៍ចំណាំងបែរ 1.5 ។




4. កង់បង្វិលរបស់លោកហ្វីហ្សូមានធ្មេញ $N = 360$ និងវិលដោយប្រេកង់ $W = 27.5$ ជុំក្នុង $1s$ ។ កាលណាពន្លឺឆ្លងកាត់ធ្មេញ $O$ ពន្លឺដាលទៅដល់កញ្ចក់ រួចផ្លាតត្រឡប់មកវិញ ។ បើពេលវាផ្លាតត្រលប់មកប៉ះធ្មេញ $B$ វាមិនអាចដាលឆ្លងកាត់កង់បានទេ ប៉ុន្តែបើវាមកឆ្លងកាត់ប្រលោះនោះ វាអាចឆ្លងកាត់បាន ។ ចម្ងាយពីកង់ទៅកញ្ចក់គឺ $L = 7500m$ ។ តើល្បឿនពន្លឺមានតម្លៃស្មើនឹងប៉ុន្មាន ?

5. វត្ថុមួយដាក់នៅបាតផើងថ្លាមួយដែលមានផ្ទុកទឹកដូចរូប ។ កាំចាំងប៉ះដាលចេញពីវត្ថុ A បង្កើតបានមុំ a មួយជាមួយខ្សែកែង ។ ចូរគណនា $dina$ ក្នុងករណីចំណាំងផ្លាតទាំងស្រុង ។




6. អ្នកសង្កេតម្នាក់សម្លឹងមើលពីចំណុច 0 មួយទៅកញ្ចក់ប្លង់មួយដែលឋិតនៅចម្ងាយ 1m ។តើភ្នែកនេះឋិតនៅចម្ងាយប៉ុន្មានពីរូបភាពដែលមើលឃើញនៅក្នុងកញ្ចក់ ?




7. គេដាក់កញ្ចក់រាងប្រលេពីប៉ែតមួយលើទំព័រសៀវភៅមើល ។ ដុំប្រលេពីប៉ែតនេះមានកម្រាស់ 8cm ហើយមានសន្ទស្សន៍ 1.50 ។ តើអក្សរលើទំព័រដែលជាប់នឹងបាតកញ្ចក់ទទួលកំហិតជិតប៉ុន្មាន ?




youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

**ជំពូក 5**

# ថាមពលនិងជីវិត



*វារីអគ្គិសនីគីរីរម្យ*

ពិភពលោកសព្វថ្ងៃនេះកំពុងប្រើប្រាស់ថាមពលច្រើនបែបច្រើនយ៉ាង ។ តើយើងប្រើប្រាស់ថាមពលទាំងនោះបែបណាខ្លះ ? អ្នកធ្លាប់ឮគេនិយាយថានឹងមានវិបត្តិថាមពលឬទេ ? តើថាមពលអាចអស់ពីលើពិភពលោកឬទេ ?

## មេរៀនទី 1 : ការបំប្លែងថាមពលដែលមានប្រភពខុសៗគ្នាឱ្យទៅជាថាមពលអគ្គិសនី

## មេរៀនទី 2 : ការបំប្លែងថាមពលអគ្គិសនីឱ្យទៅជាថាមពលផ្សេងៗ

youtube.com/moeys
facebook.com/moeys.gov.kh
edu.moeys.gov.kh

មេរៀនទី

# 1 ការបំប្លែងថាមពលដែលមានប្រភពខុសៗគ្នាឱ្យទៅជាថាមពលអគ្គិសនី

**ចប់មេរៀននេះ សិស្សអាច**

❒ បំប្លែងថាមពលដែលមានប្រភពខុសគ្នាឱ្យទៅជាថាមពលអគ្គិសនី ។

## 1. ថាមពលពន្លឺ

ថាមពលពន្លឺបានមកពីការបញ្ចេញរស្មីនៃព្រះអាទិត្យ ។ ជាច្រើនសតវត្សមកហើយ ថាមពលពន្លឺត្រូវបានប្រើប្រាស់សម្រាប់សម្ងួតអាហារឬបង្ហួតទឹកក្នុងស្រែអំបិល ។ ផ្ទះបៃតងជួនកាលក៏ប្រើថាមពលពន្លឺដើម្បីដុតកម្ដៅខ្យល់ក្នុងផ្ទះដែរ ។ គេអាចប្រើកញ្ចក់ស្វ៊ែផតដ៏ធំ ដើម្បីប្រមូលពន្លឺឱ្យទៅរួមត្រង់តំបន់មួយតូចដើម្បីដុតកម្ដៅទឹកឱ្យក្លាយជាចំហាយ រួចចំហាយទឹកទៅបង្វិលតួប៊ីនដែលអាចផលិតជា ថាមពលអគ្គិសនី ។

ថ្មពិលផូតូវ៉ុលតែក (Photovoltaic) ត្រូវបានឱ្យឈ្មោះថាថ្មពិលព្រះអាទិត្យ (Solar cell) ។ ពាក្យផូតូវ៉ុលតែកចេញមកពីពាក្យក្រិក : Phos មានន័យថាពន្លឺ (light) និងឈ្មោះអ្នកប្រាជ្ញអ៊ីតាលីម្នាក់ វ៉ុលតា (Volta) ដែលចេញពីពាក្យនេះមានពាក្យវ៉ុល ( Volt និង Voltage) ។ វាមានន័យចំថា ពន្លឺនិងអគ្គិសនី ។

ប្រសិទ្ធភាពនៃថ្មពិលព្រះអាទិត្យត្រូវបានទទួលស្គាល់ជាលើកដំបូងក្នុងឆ្នាំ **1839** ដោយអ្នកប្រាជ្ញបារាំងអាឡិចសង់អេដម៉ុងបែកឺរ៉ែល( Alexandre Edmond Becquerel) ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ថ្មពិលព្រះអាទិត្យត្រូវបានបង្កើតឡើងជាដំបូងដោយលោក ឆាលហ្វ្រិត (Charles Fritts) ដែលគាត់ប្រើសឺមីកុងឌុចទ័រស៊ីលីញ៉ូម (Selenium) ស្រោបដោយបន្ទះមាសយ៉ាងស្តើង ។ ក្នុងឆ្នាំ 1954 សម័យកាលនៃបច្ចេកវិទ្យាទំនើបរបស់ថ្មពិលព្រះអាទិត្យ គឺការរកឃើញរបស់មន្ទីរពិសោធន៍ **បែល** (Bell) ។ របកគំហើញនោះគឺជា **ស៊ីលីស្យូម** បើគេរំលាយធាតុមិនសុទ្ធបន្តិចចូលទៅក្នុងវា សឺមីកុងឌុចទ័រនេះមានភាពរស់នឹងពន្លឺយ៉ាងខ្លាំង ។

youtube.com/moeys krou.moeys.gov.kh facebook.com/moeys.gov.kh

ថ្មពិលព្រះអាទិត្យជាគ្រឿងសឺមីកុងឌុចទ័រដែលបំប្លែងថាមពលពន្លឺព្រះអាទិត្យទៅជាថាមពលអគ្គិសនី ។ វាផ្សំឡើងពីសឺមីកុងឌុចទ័រពីរ គឺសឺមីកុងឌុចទ័រប្រភេទ p និងសឺមីកុងឌុចទ័រប្រភេទ n ដាក់ភ្ជាប់គ្នា ។ សឺមីកុងឌុចទ័រនេះធ្វើឡើងពីស៊ីលីស្យូម ។ កាលណាពន្លឺព្រះអាទិត្យចាំងប៉ះលើបន្ទះស៊ីលីស្យូម អេឡិចត្រុងបានខ្ទាតចេញពីអាតូមរួចហូរឆ្លងកាត់សារធាតុហើយបង្កើតបានជាចរន្តអគ្គិសនី ។ ព្រមពេលជាមួយគ្នានោះ បន្ទុកវិជ្ជមានក៏ត្រូវបានបង្កើតឡើងហៅថា **រន្ធ** រួចហូរតាមទិសដៅច្រាសពីអេឡិចត្រុង ។ ថ្មពិលព្រះអាទិត្យបំប្លែងថាមពលពន្លឺព្រះអាទិត្យឱ្យទៅជាចរន្តអគ្គិសនីជាប់ដែលអាចប្រើប្រាស់បាន ។ វាអាចបំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនីបានត្រឹមតែពី10 ទៅ 18% ប៉ុណ្ណោះ ។



*រូបទី 5.1 ថ្មពិលព្រះអាទិត្យ*

**គុណសម្បត្តិ និងគុណវិបត្តិការប្រើប្រាស់ថ្មពិលព្រះអាទិត្យ**

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| - គ្មានការបំពុលបរិស្ថាន ។<br>- ថ្មពិលព្រះអាទិត្យទាមទារការថែទាំតិចតួចបំផុត ។ | - ថាមពលអគ្គិសនីផ្តល់ដោយវាមានតម្លៃថ្លៃ ។<br>- វាអាចផ្តល់ថាមពលតែក្នុងពេលដែលមានពន្លឺ ដូច្នេះ គេត្រូវប្រើបាតរីអាគុយនិងអាំងវែទ័រ (Invertors) ដើម្បីស្តុកនិងបំប្លែងថាមពល ។ |

## 2. ថាមពលមេកានិច

### 2.1 ថាមពលខ្យល់

នៅសហរដ្ឋអាមេរិកកង្ហារខ្យល់ជាងប្រាំមួយលានគ្រឿងត្រូវបានប្រើសម្រាប់បូមទឹក ។ ស្នប់បូមទឹកដែលដើរដោយចរន្តអគ្គិសនីត្រូវបានជំនួសដោយកង្ហារខ្យល់ ។ សព្វថ្ងៃនេះថាមពលអគ្គិសនីដែលបានមកពីចំហេះឥន្ធនៈមានតម្លៃខ្ពស់ ។ ដូច្នេះការប្រើប្រាស់ថាមពលខ្យល់ផ្តល់នូវសារប្រយោជន៍យ៉ាងខ្លាំង ។

ថាមពលរបស់ខ្យល់អាចប្រើប្រាស់សម្រាប់បង្វិលកង្ហារ ។ កង្ហារមាន ថាមពលមេកានិចរួចវាបង្វិលជនិតា ដើម្បីផលិតជាថាមពលអគ្គិសនី ។ កង្ហារដែលមានព្រួញចង្អុលទិសខ្យល់ អាចផ្តល់អានុភាពអគ្គិសនី 7.2MW ចំពោះអង្កត់ផ្ចិតកង្ហារ 130m ។ របៀបស្តុកថាមពលខ្យល់មានពីរបែប ។ របៀបស្តុកទីមួយគឺគេប្រើបាតឺរីអាគុយ ហើយរបៀបទីពីរគេប្រើថាមពលអគ្គិសនីបូមទឹកស្តុកក្នុងអាងមួយ ។ នៅថ្ងៃណាមួយដែលគ្មានខ្យល់ទេ គេបង្ហូរទឹកឆ្លងកាត់តួប៊ីនដើម្បីបង្វិលជនិតា ។



*រូបទី 5.2 កង្ហារផលិតអគ្គិសនី*

គុណវិបត្តិនៃការប្រើប្រាស់ថាមពលខ្យល់គឺសម្លេងរង្វិលតួប៊ីនអាចរំខានដល់មជ្ឈដ្ឋានជុំវិញ ហើយម្យ៉ាងទៀតស្លាបកង្ហារវែងៗធ្វើពីលោហៈអាចរំខានដល់រលកធាតុអាកាសនៃទូរទស្សន៍និងទូរគមនាគមន៍ ។

## 2.2 ថាមពលទឹកជោរ

ទឹកជោរនៅសមុទ្របង្កើតឡើងដោយសារទំនាញសកល រវាងផែនដី ព្រះចន្ទ និងព្រះអាទិត្យ ។ ជាញឹកញាប់ ជំនោរអាចប្រើជាប្រភពថាមពលបាន ។ នៅពេលដែលផែនដីវិល ជំនោរនៅកន្លែងខ្លះផ្លាស់ប្តូរជាញឹកញាប់ក្នុងមួយថ្ងៃៗ ។ នៅពេលដែលទឹកជោរនិងនាច ទឹកហូរចូលនិងចេញពីមាត់ព្រែក ។ បើសិនជាមាត់ព្រែកអាចបិទដោយសារទំនប់ ថាមពលនៃទឹកហូរអាចស្ទាក់ដើម្បីបង្វិលតួប៊ីន ។ ថាមពលបែបនេះហៅថា ថាមពលទឹកជោរ ។ ដូចជាថាមពលវារីអគ្គិសនីដែរ ថាមពលទឹកជោរប្រើកម្មន្តរបស់ទឹកដែលហូរពីទីខ្ពស់ទៅទីទាប ។




*រូបទី 5.3 វារីអគ្គិសនីដើរដោយកម្លាំងទឹកជោរនាច*

ទីតាំងដែលអាចធ្វើការអភិវឌ្ឍថាមពលទឹកជោរមានប្រហែល 24 ។ ក្នុងចំណោមទីតាំងទាំងនោះ មានទីតាំងពីរដែលត្រូវបានធ្វើការអភិវឌ្ឍ គឺមួយនៅស្រុកបារាំងនិងមួយទៀតនៅអតីតសហភាពសូវៀត ។ ទឹកជោរខ្ពស់បំផុតដែលអាចមានការផ្លាស់ប្តូរប្រហែល 15m គឺកើតមាននៅឆ្នេរ (Fundy New Brunswick ) ក្នុងប្រទេសកាណាដា ។

ការផលិតថាមពលអគ្គិសនីដោយទឹកជោរ គឺមិនមានការបំពុលបរិស្ថានទេ ប៉ុន្តែក៏នៅមានបញ្ហាដូចជា ការផលិតថាមពលបែបផ្សេងៗទៀតដែរ ។ ទឹកសមុទ្រប្រៃអាចស៊ីគ្រឿងចក្រហើយសំណង់ទំនប់ឆ្លងកាត់មាត់សមុទ្រអាចប្តូរជំនោរនិងអាចបំផ្លាញបរិស្ថាននៅតំបន់នោះ ។

## 2.3 ថាមពលវារីអគ្គិសនី

ថាមពលអគ្គិសនីផ្តល់ដោយវារីអគ្គិសនីបានមកពីថាមពលមេកានិចរបស់ទឹក ។ ទំនប់ទឹកដែលស្តុកទឹកក្នុងទន្លេមានថាមពលប៉ូតង់ស្យែលបម្រុង ។ ពេលទឹកត្រូវបានបង្ហូរឆ្លងកាត់តួប៊ីន ថាមពលប៉ូតង់ស្យែលរបស់ទឹកត្រូវបានបំប្លែងទៅជាថាមពលស៊ីនេទិចរបស់តួប៊ីន ។ តួប៊ីនវិលហើយទាញបង្វិលជនិតា (អាល់ទែណាទ័រ)ដែលអាចផលិតនូវថាមពលអគ្គិសនី ។




*រូបទី5.4*

បច្ចុប្បន្ននេះ ថាមពលវារីអគ្គិសនីបានផ្គត់ផ្គង់ការប្រើប្រាស់ប្រហែល 715,000 MW គឺ 19% នៃថាមពលអគ្គិសនីនៅលើពិភពលោក (16% ក្នុងឆ្នាំ 2003) ។ ទំនប់ធំៗកំពុងតែត្រូវបានធ្វើគម្រោងសាងសង់ ។ ក្រៅពីប្រទេសមួយចំនួនតូចដែលសម្បូរទៅដោយទំនប់វារីអគ្គិសនី សេចក្តីត្រូវការថាមពលវារីអគ្គិសនី កើនឡើងខ្ពស់បំផុតក្នុងប្រទេសផ្សេងទៀត ។ ទោះបីជាយ៉ាងណាក៏ដោយក្នុងប្រទេសជឿនលឿនថាមពលវារីអគ្គិសនីប្រហែលមិនមែនជាជម្រើសសំខាន់ទេ ក្នុងការផលិតនៅពេលអនាគត ព្រោះទឹកន្លែងសំខាន់ៗភាគច្រើនក្នុងប្រទេសទាំងនោះជាមួយនឹងសក្តានុពលដែលផ្តល់ប្រយោជន៍បែបនេះ ត្រូវបានគេទាញយកឬក៏មិនអាចដោយសារតែហេតុផលផ្សេងៗដូចជាការគិតគូរពីបញ្ហាបរិស្ថានជាដើម ។

ការផលិតថាមពលវារីអគ្គិសនីជាសំខាន់ គឺគ្មានកាបូនអុកស៊ីត ($CO_2$) ឬការបញ្ចេញគ្រោះថ្នាក់ផ្សេងៗទៀតដែលផ្ទុយពីការផលិតថាមពលដោយចំហេះឥន្ធនៈឬឧស្ម័ន ។ថាមពលវារីអគ្គិសនីមានតម្លៃថោកជាងថាមពលអគ្គិសនីផលិតដោយចំហេះឥន្ធនៈនិងដោយថាមពលនុយក្លេអ៊ែរ ។កន្លែងណាដែលសម្បូរដោយថាមពលវារីអគ្គិសនី កន្លែងនោះមានការទាក់ទាញរោងចក្រយ៉ាងខ្លាំងដោយសារតែតម្លៃថាមពលអគ្គិសនីថោក ។

គុណប្រយោជន៍សំខាន់នៃទំនប់វារីអគ្គិសនី គឺលទ្ធភាពរបស់វាដែលអាចត្រួតពិនិត្យតាមរដូវក៏ដូចតាមថ្ងៃនូវការផ្ទុកខ្ពស់បំផុត (ប៉ុន្តែទំនប់វារីអគ្គិសនីខ្លះក៏មិនអាចត្រួតពិនិត្យបានដែរ) ។ នៅពេលដែលតម្រូវការអគ្គិសនីថយចុះ ទំនប់គ្រាន់តែស្តុកទឹកបន្ថែមទៀត ។ ជនិតាអគ្គិសនីខ្លះ ប្រើប្រាស់ទឹកក្នុងទំនប់ដែលស្តុកថាមពលហួសកំណត់ (ជាទូទៅនៅពេលយប់) ដោយប្រើចរន្តអគ្គិសនីបូមទឹកឡើងទៅលើអាង ។ ចរន្តអគ្គិសនីអាចត្រូវបង្កើតជាថ្មី កាលណាសេចក្តីត្រូវការកើតឡើង ។ ក្នុងការអនុវត្តការប្រើប្រាស់ទឹកស្តុកក្នុងទន្លេ ជួនកាលជួបការលំបាកដោយសារតម្រូវការនៃធារាសាស្ត្រដែលអាចកើតមានយូរៗម្តងជាមួយនឹងតម្រូវការខ្ពស់នៃចរន្តអគ្គិសនី ។

អានុភាពនៃវារីអគ្គិសនីអាចវាស់បានទៅតាមបរិមាណអានុភាពដែលអាចប្រើប្រាស់បាន ឬថាមពលក្នុងមួយខ្នាតនៃពេល ។ អានុភាពក្នុងស្ថានភាពណាមួយ វាជាអនុគមន៍នៃកម្រិតកម្ពស់ទឹកក្នុងអាងធៀបទៅនឹងតួប៊ីននិងល្បឿននៃការហូរ ។

ថាមពល $E$ ដែលបានមកពីការទម្លាក់អង្គធាតុមួយមានម៉ាស m ពីរយៈកម្ពស់ h ក្នុងដែនទំនាញផែនដីគឺ : $E = mgh$ ($g$ សំទុះទំនាញផែនដី) ។

ថាមពលប្រើការបានរបស់វារីអគ្គិសនីគឺជាថាមពលដែលបានមកពីការទម្លាក់ទឹកក្នុងបែបមួយដែលអាចត្រួតពិនិត្យបាន ។ ទំនាក់ទំនង អានុភាពនឹងធារទឹកដែលហូរឆ្លងកាត់តួប៊ីនក្នុងមួយខ្នាតពេលគឺ

$\frac{E}{t} = \frac{mgh}{t}$ ឬ $\frac{E}{t} = \frac{m}{t}gh$ តែ $P = \frac{E}{t}$ និង $m = \rho V$

$\Rightarrow P = \frac{V}{t}\rho gh$ តាង $\frac{V}{t} = \varphi$

យើងបានកន្សោមដូចខាងក្រោម

$$P = \varphi\rho gh$$

$P$ អានុភាពគិតជាវ៉ាត់ (W)

$\varphi$ ធារទឹកដែលហូរឆ្លងកាត់តួប៊ីនគិតជាម៉ែត្រគូបក្នុងមួយវិនាទី ($m^3/s$)

$\rho$ ម៉ាសមាឌទឹកគិតជាគីឡូក្រាមក្នុងមួយម៉ែត្រគូប ($kg/m^3$)

$g$ សំទុះទំនាញផែនដីគិតជា ($m/s^2$)

$h$ កម្ពស់គិតជាម៉ែត្រ (m) ។

***ឧទាហរណ៍ :*** វារីអគ្គិសនីមួយផ្តល់នូវអានុភាពអគ្គិសនី $P = 10MW$ ។ ទម្លាក់ទឹកមានកម្ពស់ $h = 100m$ ។ តើក្នុងរយៈពេល $t = 1h$ ម៉ាសទឹកដែលហូរធ្លាក់ចុះស្មើនឹងប៉ុន្មាន ? ឧបមាថាទិន្នផល 100 % ។

✍ ដំណោះស្រាយ

$$P = \frac{mgh}{t} \quad \Rightarrow \quad m = \frac{Pt}{gh}$$

$$P = 10\text{MW} = 10 \times 10^6\text{W} \quad , t = 1\text{h} = 3600\text{s} \quad , g = 9.80\text{m/s}^2 \, , h = 100\text{m}$$

$$m = \frac{10 \times 10^6\text{W} \times 3600\text{s}}{9.80\text{m/s}^2 \times 100\text{m}} = 3.67 \times 10^7\text{kg}$$

$m = 3.67 \times 10^4$ តោន

## មេរៀនសង្ខេប

- ថាមពលពន្លឺព្រះអាទិត្យអាចបំប្លែងទៅជាថាមពលអគ្គិសនី ។ គេអាចឱ្យពន្លឺព្រះអាទិត្យដុតកម្តៅទឹកឱ្យក្លាយជាចំហាយ ដើម្បីបង្វិលតួប៊ីន ។ ថ្មពិលព្រះអាទិត្យក៏ជាឧបករណ៍សម្រាប់បំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនី ។ ថ្មពិលព្រះអាទិត្យធ្វើឡើងពីសឺមីកុងឌុចទ័រប្រភេទ $p$ និងប្រភេទ $n$ ។ វាអាចបំប្លែងថាមពលពន្លឺទៅជាអគ្គិសនីបានពី 10 ទៅ 18% ។
- ថាមពលខ្យល់អាចបង្កើតជាថាមពលមេកានិចនៃកង្ហារខ្យល់ ហើយថាមពលនេះអាចបំប្លែងទៅជាថាមពលអគ្គិសនីតាមរយៈតួប៊ីនដែលបង្វិលអាល់ទែណាទ័រ ។
- ថាមពលប៉ូតង់ស្យែលទឹកដែលទប់ក្រោយទំនប់ អាចបំប្លែងជាថាមពលស៊ីនេទិចនៃតួប៊ីននៅពេលគេបង្ហូរវាចុះក្រោម ។ តួប៊ីនវិលហើយទាញបង្វិលអាល់ទែណាទ័រដែលអាចផលិតទៅជាថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ ។
- នៅពេលទឹកជោរគេបើកទំនប់ឱ្យទឹកចូល រួចគេបិទទំនប់ ។ នៅពេលទឹកនាចគេបង្ហូរទឹកឱ្យបង្វិលតួប៊ីន រួចតួប៊ីនបង្វិលអាល់ទែណាទ័រដែលអាចផលិតថាមពលអគ្គិសនី ។

## សំណួរនិងលំហាត់

1. ចូររៀបរាប់ពីទម្រង់ថ្មពិលព្រះអាទិត្យ ។
2. តើគុណសម្បត្តិនិងគុណវិបត្តិនៃកង្ហារខ្យល់យ៉ាងដូចម្តេចខ្លះ ?
3. តើគុណសម្បត្តិនិងគុណវិបត្តិនៃថ្មពិលព្រះអាទិត្យយ៉ាងដូចម្តេចខ្លះ ?
4. តើការផលិតថាមពលអគ្គិសនីដោយប្រើថាមពលទឹកជោរមានគុណសម្បត្តិ និងគុណវិបត្តិយ៉ាងណាខ្លះ ?

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

មេរៀនទី

# 2 ការបំប្លែងថាមពលអគ្គិសនីឱ្យទៅជាថាមពលផ្សេងៗ

**ចប់មេរៀននេះ សិស្សអាច**

❒ បំប្លែងថាមពលអគ្គិសនីឱ្យទៅជាថាមពលកម្ដៅ ពន្លឺ និងថាមពលមេកានិច ។

## 1. ថាមពលអគ្គិសនីបំប្លែងទៅជាថាមពលកម្ដៅ

អង្គធាតុចម្លងមួយឆ្លងកាត់ដោយចរន្តអគ្គិសនី ហើយបំប្លែងថាមពលអគ្គិសនីឱ្យទៅជាថាមពលកម្ដៅ ។ ខ្សែចម្លងត្រូវបានដុតកម្ដៅរួចផ្ដល់កម្ដៅទៅឱ្យមជ្ឈដ្ឋានក្រៅតាមរយៈការចម្លងកម្ដៅ ចរន្តវិលវល់និងការបញ្ចេញរស្មី ។ នៅពេលដែលសីតុណ្ហភាពខ្សែកើនឡើង បរិមាណកម្ដៅដែលផ្ដល់ទៅឱ្យមជ្ឈដ្ឋានក្រៅក្នុងមួយខ្នាតនៃពេលក៏កើនឡើងដែរ ។ នៅពេលដែលខ្សែផ្ដល់នូវបរិមាណកម្ដៅក្នុង 1វិនាទីស្មើនឹងអានុភាពអគ្គិសនីដែលវាទទួល ខ្សែចម្លងលែងកើនសីតុណ្ហភាពទៀតហើយ គេថារបបអចិន្ត្រៃយ៍កើតឡើងហើយសីតុណ្ហភាពខ្សែបានឡើងដល់សីតុណ្ហភាពលំនឹងមួយ ។

ការដុតកម្ដៅដោយអគ្គិសនីត្រូវបានប្រើធាតុកម្ដៅជាខ្សែនីកែលក្រូមឬដែកនីកែល (សំលោហៈមិនរងអុកស៊ីតកម្ម ទោះបីជាក្ដៅក៏ដោយ) ។ ធាតុកម្ដៅនេះទ្រដោយបន្ទះអ៊ីសូឡង់ ហើយគេឱ្យវាឆ្លងកាត់ដោយចរន្តអគ្គិសនី ។



*រូបទី 5.5 ឧបករណ៍បំប្លែងថាមពលអគ្គិសនីទៅជាថាមពលកម្ដៅ*

នៅក្នុងឧបករណ៍អគ្គិសនីខ្លះ ដូចជាចង្ក្រានអគ្គិសនី ប្រដាប់ដុតកម្ដៅទឹក កំសៀវអគ្គិសនី ឆ្នាំងអ៊ុត ។ល។ ធាតុកម្ដៅត្រូវបានស្រោបដោយមីកា ស៊ីលីស្យូម ឬដីឥដ្ឋដុត ។ សីតុណ្ហភាពលំនឹងមានតម្លៃប្រហែលពី 700 ទៅ 900°C ដើម្បីអាចឱ្យវាឡើងក្រហមហើយផ្ដល់កម្ដៅទៅឱ្យវត្ថុទាំងឡាយដែលនៅជុំវិញខ្លួនវា ។ ការដុតកម្ដៅដោយអគ្គិសនីមានភាពស្អាតហើយងាយស្រួលប្រើប្រាស់និងមិនបំពុលបរិស្ថានទេ ។

**អំពូលរង្គុំ :** អំពូលរង្គុំដំណើរការដោយការដុតកម្ដៅប្រឆេះដោយចរន្តអគ្គិសនី ។ ប្រឆេះធ្វើឡើងពីខ្សែចម្លងតង់ស្តែន ។ គេជ្រើសរើសតង់ស្តែន ព្រោះវាមានរេស៊ីស្ទីវីតេធំនិងចំណុចរលាយខ្ពស់ (3400°C) ។ម្យ៉ាងទៀតតង់ស្តែនអាចធ្វើឱ្យផ្នារខ្លាំង(មុខកាត់តូច) ដើម្បីឱ្យមានរេស៊ីស្តង់ធំជាងរេស៊ីស្តង់សៀគ្វីខាងក្រៅ ។ នៅពេលដែលចរន្តឆ្លងកាត់ប្រឆេះ វាឡើងក្ដៅហើយមានពណ៌ស ( សីតុណ្ហភាពប្រហែល 2500°C )។ កាលណាសីតុណ្ហភាពប្រឆេះឡើងកាន់តែខ្ពស់ ថាមពលអគ្គិសនីដែលត្រូវបំប្លែងទៅជាពន្លឺកាន់តែខ្លាំង ។ នេះពន្យល់ពីមូលហេតុដែលគេត្រូវជ្រើសរើសតង់ស្តែន ដែលមានចំណុចរលាយខ្ពស់ ។ នៅក្នុងអំពូលកែវគេប្រើឧស្ម័នកម្រ ដូចជានីត្រូសែន ឬអាកុងដែលមិនធ្វើឱ្យប្រឆេះតង់ស្តែនរងអុកស៊ីតកម្ម ។



**រូបទី5.6 អំពូលរង្គុំ**

គុណវិបត្តិនៃអំពូលរង្គុំមានពីរ :

- មានតែ 10% នៃថាមពលអគ្គិសនីទេដែលត្រូវបំប្លែងទៅជាពន្លឺ ចំណែក 90% ទៀតត្រូវបំប្លែងទៅជាថាមពលកម្ដៅ ។ ទាំងអស់នេះពន្យល់ពីមូលហេតុថា ហេតុអ្វីបានជាក្ដៅខ្លាំងពេលដែលយើងប្រើអំពូលរង្គុំ ។
- ប្រៀបធៀបនឹងអំពូលភ្លុយអរ អំពូលរង្គុំចោលស្រមោលយ៉ាងខ្លាំងមិនសមរម្យសម្រាប់ប្រើប្រាស់ក្នុងការិយាល័យឬក្នុងសាលារៀនទេ ។

## 2. ថាមពលអគ្គិសនីបំប្លែងទៅជាថាមពលពន្លឺ

### 1.1 ឌីយ៉ូតបន្សាយពន្លឺ

ឌីយ៉ូតបន្សាយពន្លឺឬអំពូលឌីយ៉ូត (*LED*) ជាឧបករណ៍បំប្លែងថាមពលអគ្គិសនីទៅជាថាមពលពន្លឺ ។ វាធ្វើឡើងពីសីមីកុងឌុចទ័រពីរភ្ជាប់គ្នា គឺសីមីកុងឌុចទ័រប្រភេទ *p* (*p* គឺ *positive* មានន័យថាខ្វះអេឡិចត្រុងឬមានរន្ធ) និងសីមីកុងឌុចទ័រប្រភេទ *n* (*n* គឺ *negative* មានន័យថាលើសអេឡិចត្រុង) ។



**រូបទី**5.7

កាលណាគេបង្កើតឱ្យមានផលសងប៉ូតង់ស្យែលនៅចុងសងខាងឌីយ៉ូត(LED) តាមទិសដៅចរន្តឆ្លងកាត់ដូចរូបខាងលើ អេឡិចត្រុងផ្លាស់ទីពី n ទៅ p ដែលជាហេតុធ្វើឱ្យមានការទង្គិចរវាងបន្ទុក (– ) និងបន្ទុក( + ) នៅត្រង់តំបន់ភ្ជាប់គ្នា ពេលនោះមានពន្លឺកកើតមានឡើង ។

ឌីយ៉ូតបន្សាយពន្លឺមានគុណភាពប្រសើរជាងអំពូលរង្គុំ ព្រោះឌីយ៉ូតត្រូវការចរន្តយ៉ាងតូច និងបំប្លែងថាមពលអគ្គិសនីទៅជាថាមពលពន្លឺបានរហូតដល់ 90 % ។

## 2.2 អំពូលភ្លុយអ៊ីរឬអំពូលម៉ែត

ប្រៀបធៀបទៅនឹងអំពូលរង្គុំ អំពូលភ្លុយអ៊ីរមានប្រសិទ្ធភាពជាងប្រហែលបីដង គិតទាំងការចំណាយនិងរយៈពេលប្រើប្រាស់ ។ អំពូលភ្លុយអ៊ីរអាចប្រើបានក្នុងរយៈពេល 3000 ម៉ោង បើប្រៀបធៀបទៅនឹងអំពូលរង្គុំដែលអាចប្រើបានតែ 1000 ម៉ោង ។



***រូបទី5.8 អំពូលភ្លុយអ៊ីរ***

អំពូលភ្លុយអ៊ីរមិនមានប្រឆេះទេ តែវាមានអេឡិចត្រូតពីរ ។ កាលណាគេឱ្យបន្ទុកអគ្គិសនីឆ្លងកាត់ចន្លោះអេឡិចត្រូតទាំងពីរ ចំហាយបារតនៅក្នុងបំពង់កែវបញ្ចេញកាំរស្មីស្វាយអ៊ុលត្រានិងកាំរស្មីមើលឃើញផ្សេងទៀត ។ កាំរស្មីស្វាយអ៊ុលត្រានេះ ត្រូវបានបំប្លែងទៅជាកាំរស្មីមើលឃើញដោយសារម្សៅភ្លុយអ៊ីរដែលមាននៅក្នុងបំពង់កែវ ។

អំពូលភ្លុយអ៊ីរត្រូវបានប្រើប្រាស់ជាទូទៅ នៅក្នុងការិយាល័យ សាលារៀន សម្រាប់គ្រប់ការបំភ្លឺ ព្រោះវាជាប្រភពពន្លឺលាតហើយចោលស្រមោលខ្សោយ ។

# 3. ថាមពលអគ្គិសនីបំប្លែងទៅជាថាមពលមេកានិច

ម៉ូទ័រអគ្គិសនីធ្វើឡើងពីមេដែកនិងប៊ូប៊ីនរុំដោយខ្សែចម្លង ។ ប៊ូប៊ីនត្រូវបានដាក់នៅចន្លោះប៉ូលទាំងពីរនៃមេដែក ។ កាលណាគេឱ្យចរន្តឆ្លងកាត់ប៊ូប៊ីនដែលស្ថិតក្នុងដែនម៉ាញេទិច វាបង្កើតនូវកម្លាំងដែលជាហេតុធ្វើឱ្យ ប៊ូប៊ីនវិល ។ ប៊ូប៊ីនត្រូវបានតភ្ជាប់ទៅនឹងដងវង្វិលមួយដែលថាមពលស៊ីនេទិចត្រូវបានបញ្ជូនតាមដងវង្វិលទៅកាន់រ៉កនិងខ្សែពាន ។ ដូច្នេះជាហេតុបណ្តាលឱ្យយើងអាចប្រើប្រាស់ថាមពលមេកានិចនេះបានយ៉ាងងាយ ។



***រូបទី 5.9 ម៉ូទ័រអគ្គិសនី***

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeysgov.kh

ម៉ូទ័រអគ្គិសនីបំប្លែងថាមពលអគ្គិសនីទៅជាថាមពលមេកានិចដែលអាចបង្កើតជាកម្មន្ត ។ ម៉ូទ័រអគ្គិសនីដែលយើងប្រើប្រាស់សព្វថ្ងៃមាន ម៉ាស៊ីនស្វាន កង្ហារ ម៉ាស៊ីនសម្ងួតខោអាវ ម៉ាស៊ីនសម្ងួតសក់ ម៉ាស៊ីនទឹកក្រឡុក ម៉ូទ័របូមទឹក ម៉ូទ័រនៃម៉ាស៊ីនគាបទឹកអំពៅ ។ល ។

ម៉ូទ័រអគ្គិសនីខ្លះមានភាពសាំញ៉ាំជាងម៉ូទ័រងាយដែលយើងរៀបរាប់ខាងលើ ។ ភាពខុសគ្នាសំខាន់គឺវាធ្វើឡើងពីបូប៊ីនច្រើនហើយភ្ជាប់ទៅនឹងដងរង្វិលតែមួយ ។ បើបូប៊ីនមានកាន់តែច្រើន ម៉ូទ័រមានអានុភាពកាន់តែធំ ។

## មេរៀនសង្ខេប

- ថាមពលអគ្គិសនីអាចបំប្លែងទៅជាថាមពលកម្ដៅ ។ គេឱ្យចរន្តអគ្គិសនីឆ្លងកាត់ធាតុកម្ដៅ ហើយវាឡើងក្ដៅ រួចបញ្ចេញកម្ដៅទៅឱ្យមជ្ឈដ្ឋានដែលនៅជិតវា ។ ឧបករណ៍ដែលបំប្លែង ថាមពលអគ្គិសនីទៅជាថាមពលកម្ដៅមាន : ឆ្នាំងអ៊ុត ចង្ក្រានអគ្គិសនី កំសៀវអគ្គិសនីអំពូលរង្គុំ ។
- ឌីយ៉ូតបន្សាយពន្លឺ ឬអំពូលឌីយ៉ូត (LED) បំប្លែងថាមពលអគ្គិសនីទៅជាថាមពលពន្លឺ ។
- អំពូលភ្លុយអ៊ីរក៏បំប្លែងថាមពលអគ្គិសនីទៅជាថាមពលពន្លឺដែរ ។
- ម៉ូទ័រអគ្គិសនីជាឧបករណ៍បំប្លែងថាមពលអគ្គិសនីទៅជាថាមពលមេកានិច ។ ម៉ូទ័រអគ្គិសនីមានដូចជា កង្ហារ ម៉ាស៊ីនខួង ប្រដាប់សម្ងួតសក់ ម៉ាស៊ីនទឹកក្រឡុក ម៉ូទ័រនៃម៉ាស៊ីនគាបទឹកអំពៅ ។ល ។

## សំណួរនិងលំហាត់

1. តើឧបករណ៍អ្វីខ្លះដែលបំប្លែងថាមពលអគ្គិសនីទៅជាថាមពលកម្ដៅ ?
2. តើឧបករណ៍អ្វីខ្លះដែលបំប្លែងថាមពលអគ្គិសនីទៅជាថាមពលមេកានិច ?
3. ចូររៀបរាប់ពីទម្រង់ម៉ូទ័រអគ្គិសនីងាយ ។
4. ចូររៀបរាប់ពីគុណវិបត្តិ គុណសម្បត្តិនៃអំពូលរង្គុំ និងអំពូលភ្លុយអ៊ីរ ។

## សំណួរនិងលំហាត់ជំពូក 5

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយដែលត្រឹមត្រូវមានតែមួយគត់ :**

**1.** ថាមពលពន្លឺត្រូវបានបំប្លែងទៅជាថាមពលអគ្គិសនីដោយ :

- ☐ ក. ថ្មពិលស្ងួត
- ☐ ខ. អាគុយ
- ☐ គ. ថ្មពិលព្រះអាទិត្យ
- ☐ ឃ. អាល់ទែណាទ័រ

**2.** ថ្មពិលព្រះអាទិត្យធ្វើឡើងពី :

- ☐ ក. ស៊ីមីកុងឌុចទ័រប្រភេទ p
- ☐ ខ. ស៊ីមីកុងឌុចទ័រប្រភេទ n
- ☐ គ. ស៊ីមីកុងឌុចទ័រប្រភេទ p និងប្រភេទ n
- ☐ ឃ. ស៊ីមីកុងឌុចទ័រ

**3.** ទំនប់វារីអគ្គិសនី :

- ☐ ក. បំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនី
- ☐ ខ. បំប្លែងថាមពលប៉ូតង់ស្យែលទឹកទៅជាថាមពលអគ្គិសនី
- ☐ គ. បំប្លែងថាមពលខ្យល់ទៅជាថាមពលអគ្គិសនី
- ☐ ឃ. បំប្លែងថាមពលស៊ីនេទិចទៅជាថាមពលអគ្គិសនី

**4.** ឧបករណ៍ដែលបំប្លែងថាមពលអគ្គិសនីទៅជាថាមពលកម្ដៅសុទ្ធគឺ :

- ☐ ក. អំពូលរង្គុំ　　☐ ខ. ឆ្នាំងអ៊ុត
- ☐ គ. អំពូលភ្លុយអ៊ីរ　　☐ ឃ. ថ្មពិលព្រះអាទិត្យ

**5.** ឧបករណ៍បំប្លែងថាមពលអគ្គិសនីទៅជាថាមពលមេកានិចគឺ

- ☐ ក. ជនិតា　　☐ ខ. ម៉ូទ័រ
- ☐ គ. ឌីយ៉ូត LED　　☐ ឃ. ចង្ក្រានអគ្គិសនី

youtube.com/moeys
krou.moeys.gov.kh
facebook.com/moeys.gov.kh

## II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

1. . . . . . . . . . . បំប្លែងថាមពលពន្លឺទៅជាថាមពលអគ្គិសនី ។
2. ទឹកជោរ ទឹកនាចក៏ជា . . . . . . . . . មួយបែបដែលអាចបំប្លែងទៅជាថាមពល . . . . . . ។
3. វារីអគ្គិសនីបំប្លែងថាមពល . . . . . . . . . ទៅជាថាមពល . . . . . . . . . . ។
4. ឌីយ៉ូត LED បំប្លែងថាមពល . . . . . . . . ទៅជាថាមពល . . . . . . . . . ។
5. ឆ្នាំងអ៊ុត ចង្ក្រានអគ្គិសនី កំសៀវអគ្គិសនី បំប្លែងថាមពល . . . . . ទៅជាថាមពល . . . . . ។
6. អំពូលរង្គុំបំប្លែងថាមពល . . . . . . ទៅជាថាមពល . . . . . . និងថាមពល . . . . ។
7. ម៉ូទ័រអគ្គិសនីជាឧបករណ៍ដែលបំប្លែងថាមពល . . . . . . ទៅជាថាមពល . . . . . និង ថាមពល . . . . . . . ។

## III. លំហាត់

1. អាល់ទែណាទ័រមួយទទួលថាមពលពីទម្លាក់ទឹកដែលមានកម្ពស់ $h = 40\text{m}$ និងធារទឹក $\varphi = 156\text{m}^3/\text{s}$ ។ អាល់ទែណាទ័រអាចផ្តល់អានុភាពអគ្គិសនីប្រើការបាន $P = 50\text{MW}$ ។ គណនាទិន្នផលនៃសំណង់វារីអគ្គិសនីនេះ ។
2. វារីអគ្គិសនីមួយផ្តល់នូវអានុភាពអគ្គិសនី $P = 100\text{MW}$ ។ ទម្លាក់ទឹកមានកម្ពស់ $h = 100\text{m}$ ។ គណនាធារទឹក បើគេដឹងថាទិន្នផលនៃវារីអគ្គិសនីនេះ 90 % ? គេឱ្យម៉ាសមាឌទឹក $\rho = 10^3\text{kg/m}^3$ និង $g = 9.80\text{m/s}^2$ ។

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

# បទានុក្រម

| | |
|---|---|
| **កម្តៅ** | ជាបរិមាណថាមពលកម្តៅដែលផ្ទេរពីអង្គធាតុក្តៅទៅអង្គធាតុត្រជាក់ជាង ។ |
| **កម្តៅម៉ាស** | ជាបរិមាណកម្តៅចាំបាច់ដែលត្រូវផ្តល់ឱ្យអង្គធាតុមួយ 1kg ឬដកចេញពីអង្គធាតុដើម្បីដំឡើងឬតំហាយសីតុណ្ហភាព 1°C ។ |
| **កម្តៅម៉ាសឡាតង់** | ជាកម្តៅចាំបាច់ដើម្បីឱ្យម៉ាសនៃអង្គធាតុ 1kg ប្តូរពីភាពរឹងទៅរាវឬច្រាស់មកវិញដោយគ្មានការផ្លាស់ប្តូរសីតុណ្ហភាព ។ |
| **កម្តៅម៉ាសឡាតង់បង្ហួត** | ជាកម្តៅចាំបាច់ដើម្បីបង់ក្លាយម៉ាស 1kg របស់សារធាតុទៅជាចំហាយនៅសីតុណ្ហភាពដដែល ។ |
| **កម្តៅឡាតង់រលាយ** | ជាកម្តៅចាំបាច់ដើម្បីប្តូរភាពនៃអង្គធាតុ 1kg ពីរឹងទៅរាវ ឬច្រាស់មកវិញដោយគ្មានការផ្លាស់ប្តូរសីតុណ្ហភាព ។ |
| **កម្តៅឡាតង់បង្ហួត** | ជាកម្តៅចាំបាច់ដើម្បីបង់ក្លាយអង្គធាតុ 1kg ពីភាពរាវទៅចំហាយឬច្រាស់មកវិញដោយគ្មានការផ្លាស់ប្តូរសីតុណ្ហភាព ។ |
| **កំណជាញើស** | ជាការបំប្លែងពីភាពជាចំហាយទៅភាពជាញើស ។ |
| **កំណក** | ជាដំណើរផ្លាស់ភាពនៃអង្គធាតុពីរាវទៅរឹង ។ |
| **កម្មន្ត** | ជាថាមពលដែលផ្ទេរទៅឱ្យអង្គធាតុ ឬបានមកពីអង្គធាតុដោយសារកម្លាំងដែលមានអំពើលើអង្គធាតុនោះ ។<br>ជាផលគុណរវាងកម្លាំងក្នុងទិសដៅបំលាស់ទីនិងទំហំនៃបំលាស់ទីនោះ ។ |
| **ករនេ** | ជាស្រទាប់ថ្លាដែលស្រោបខាងក្រៅកែវភ្នែក ។ |
| **កុម្មុយតាទ័រ** | ជាកងលោហៈក្នុងម៉ូទ័រដើរដោយចរន្តជាប់ប្រើសម្រាប់ប្តូរទិសដៅចរន្តអគ្គិសនីក្នុងបូប៊ីនរាល់កន្លះជុំម្តង ។ |

| | |
|---|---|
| **ការបន្ទឹមមេដែក** | ជាទង្វើដែលធ្វើឱ្យដែកសុទ្ធឬដែកថែបមានលក្ខណៈម៉ាញេទិច ។ |
| **កាឡាក់ស៊ី** | ជាកញ្ចុំផ្កាយ ។ |
| **កែវពង្រីក** | ជាឧបករណ៍មួយដែលប្រើសម្រាប់ពង្រីកទំហំទំនងរបស់វត្ថុតូចៗដើម្បីឱ្យភ្នែកមើលឃើញច្បាស់ ។ |
| **កោន** | ជាអ្នកប្រមូលផ្ដុំពន្លឺ ។ |
| **គ្រាប់រលក** | ជាកូនរលកតូចៗមានរាងជាស្វ៊ែ ។ |
| **ចំណុចកំណុំ** | ជាចំណុចរួមនៃបាច់ពន្លឺប្រសព្វគ្នាត្រង់ចំណុចមួយ ។ |
| **ចំណាំងផ្លាតនៃពន្លឺ** | ជាការដាលនៃពន្លឺឆ្លងកាត់ពីមជ្ឈដ្ឋានមួយ ហើយពន្លឺនោះត្រូវបានចាំងត្រឡប់មកវិញ គេហៅថាចំណាំងផ្លាត ។ |
| **ចំណាំងបែរនៃពន្លឺ** | ជាការដាលនៃពន្លឺឆ្លងកាត់ពីមជ្ឈដ្ឋានមួយទៅមជ្ឈដ្ឋានមួយទៀតហើយមានលំងាក គេហៅថា ចំណាំងបែរ ។ |
| **ចរន្តអគ្គិសនីជាប់** | ជាចរន្តអគ្គិសនីដែលមានទិសដៅតែមួយ ផលសងប៉ូតង់ស្យែលមិនអាស្រ័យនិងពេលហើយចំនួនបន្ទុកអគ្គិសនីដែលផ្លាស់ទីក្នុងខ្សែចម្លងឥតប្រែប្រួល ។ |
| **ចរន្តឆ្លាស់** | ជាចរន្តអគ្គិសនីដែលប្ដូរទិសដៅពីរដងក្នុងមួយខួប ។ |
| **ចល័ត** | ជាវត្ថុដែលមានចលនា ។ |
| **ចម្ងាយចរ** | ជាចម្ងាយដែលចល័តបានចរដោយមិនគិតទិសដៅ ។ |
| **ចំណុចនឹងទាប** | ជាកម្រិតនៃភាពត្រជាក់របស់អង្គធាតុ ឧទាហរណ៍ ៖ ក្នុងមាត្រដ្ឋានសែលស្យុសចំណុចនឹងទាប គឺចំណុចកំណត់នៃទឹក ។ |

youtube.com/moeys
khmer.moeys.gov.kh
facebook.com/moeys.gov.kh

| | |
|---|---|
| **ចំណុចនឹងខ្ពស់** | ជាកំរិតនៃភាពក្តៅរបស់អង្គធាតុ ។ ឧទាហរណ៍ ៖ ក្នុងមាត្រដ្ឋានសតភាគ ចំណុចនឹងខ្ពស់ គឺចំណុចចំហាយនៃទឹក ។ |
| **ចំណុចមួយនៃភាពទាំងបីរបស់ទឹក** | ជាចំណុចប្រសព្វមួយនៃសីតុណ្ហភាព និងសម្ពាធដែលភាពទាំងបី (រឹង រាវ ឧស្ម័ន) មានលំនឹងរួមគ្នា ។ |
| **ចំណុះកម្តៅ** | ជាបរិមាណកម្តៅចាំបាច់ដើម្បីបង្កើនសីតុណ្ហភាពរបស់អង្គធាតុមួយ 1K ឬ 1°C ។ |
| **ជនិតាវ៉ាន់ឌឺក្រាហ្វ** | ជាជនិតាដែលអាចបង្កើនតង់ស្យុងលើសពី 14 លាន វ៉ុល ត្រូវបានគេយកទៅប្រើក្នុងការស្រាវជ្រាវនុយក្លេអ៊ែ ដើម្បីពន្លឿនល្បឿននៃភាគល្អិតផ្ទុកបន្ទុកអគ្គិសនី ។ |
| **ដំបង** | ជាសេនសឺរនៃពន្លឺស្រអាប់ ។ |
| **ដែនគំហើញ** | ជាលំហដែលភ្នែកអាចមើលឃើញច្បាស់ ។ |
| **ឌីណាម៉ូម៉ែត** | ជាឧបករណ៍សម្រាប់វាស់កម្លាំង ។ |
| **ឌីយ៉ូតបន្សាយពន្លឺ** | ជាសឺមីកុងឌុចទ័រដែលអាចបន្សាយពន្លឺនៅពេលដែលមានចរន្តឆ្លងកាត់ ។ |
| **ឌីយ៉ូត** | ឧបករណ៍សម្រាប់ត្រួតពិនិត្យទិសដៅចរន្ត ហើយអាចបំប្លែងចរន្តឆ្លាស់ឱ្យទៅជាចរន្តជាប់បាន ។ |
| **តួប៊ីន** | ជាកង់យ៉ាងធំអាចវិលបាននៅពេលណាដែលចំហាយទឹកឬទឹកបង្វិលស្លាបវា ។ |
| **ត្រង់ស្វូ** | ជាឧបករណ៍ប្រើសម្រាប់ដំឡើងឬតំហាយតង់ស្យុង ។ |
| **តេឡេទស្សន៍** | ជាឧបករណ៍ប្រើសម្រាប់មើលវត្ថុនៅឆ្ងាយៗ ។ |

| | |
|---|---|
| **ថ្មពិលវ៉ុលតា** | ជាថ្មពិលដែលរកឃើញដោយអ្នកប្រាជ្ញអ៊ីតាលីមានអេឡិចត្រូតពីរគឺ Zn និង Cu ដាក់ក្នុងសូលុយស្យុង $H_2SO_4$ ។ |
| **ថាមពល** | ជាសមត្ថភាពនៃអង្គធាតុដើម្បីបំពេញកម្មន្ត ។ |
| **ថាមពលស៊ីនេទិច** | ជាថាមពលដែលមានទំនាក់ទំនងទៅនឹងល្បឿនវត្ថុ ។ |
| **ថាមពលប៉ូតង់ស្យែល** | ជាថាមពលដែលអាស្រ័យទៅនឹងទីតាំងវត្ថុ ។ |
| **ទិន្នន័យ** | ជាពត៌មានដែលប្រមូលបានមកពីពិសោធន៍ ។ |
| **ទន្លាក់សេរី** | ជាចលនាធ្លាក់ក្រោមអំពើតែមួយគត់នៃទម្ងន់ ។ |
| **ទែម៉ូឌីណាមិច** | ជាផ្នែកមួយនៃរូបវិទ្យាដែលសិក្សាពីកម្ដៅ ។ |
| **ទម្ងន់** | ជាកម្លាំងនៃដែនទំនាញផែនដី ។ |
| **ធ្យូង** | ជាកុងតាក់សម្រាប់ផ្ដល់ចរន្តទៅឱ្យកុម្មុយតាទ័រ ។ |
| **បំលាស់ទី** | ជាការផ្លាស់ប្ដូរទីតាំងមួយធៀបទៅនឹងទីតាំងមួយទៀត និងវាស់តាមខ្សែត្រង់ពីទីតាំងដើមទៅទីតាំងស្រេច និងមានទិសដៅពីទីតាំងដើមទៅទីតាំងស្រេច ។ |
| **បន្ទះបម៉ាញេទិច** | ជាទង្វើដែលធ្វើឱ្យមេដែកមួយអស់លក្ខណៈម៉ាញេទិច ។ |
| **បារ៉ូម៉ែត** | ជាឧបករណ៍សម្រាប់វាស់សម្ពាធបរិយាកាស ។ |
| **ប្រព័ន្ធខ្នាតអន្តរជាតិ** SI | ជាខ្នាតនិងខ្នាតគំរូនៃរង្វាស់ដែលអ្នកវិទ្យាសាស្ត្រទូទាំងពិភពលោកប្រើប្រាស់ ។ |
| **ផូតូវ៉ុលតែក** | ជាគ្រឿងបំប្លែងថាមពលពន្លឺព្រះអាទិត្យឱ្យទៅជាថាមពលអគ្គិសនី ។ |

| | |
|---|---|
| **មុំកម្រិត** | ជាមុំចំណាំងប៉ះពិសេសមួយដែលមានកាំពន្លឺចាំងបែរស្របនឹងផ្ទៃញែក ហើយបង្កើតបានមុំចាំងបែរស្មើនឹង 90° ។ |
| **ម៉ូទ័រ** | ជាគ្រឿងបំប្លែងថាមពលអគ្គិសនីទៅជាថាមពលមេកានិច ។ |
| **ម៉ាណូម៉ែត** | ជាឧបករណ៍សម្រាប់វាស់សម្ពាធឧស្ម័ន ។ |
| **មាត្រដ្ឋានសីតុណ្ហភាព** | ជាគំនូសក្រិតដែលសំគាល់ឱ្យទំហំខ្នាតសីតុណ្ហភាព ។ |
| **មេកានិច** | ជាវិទ្យាសាស្ត្រដែលសិក្សាអំពីកម្លាំងនិងអំពើរបស់វា ។ គេចែកមេកានិចជាបីផ្នែក :<br>+ **ស្តាទិច** : ជាផ្នែកមួយនៃមេកានិចដែលសិក្សាអំពីលំនឹង និងអំពើនៃកម្លាំងលើវត្ថុដែលគ្មានចលនា ។<br>+ **ស៊ីនេម៉ាទិច** : ជាផ្នែកមួយនៃមេកានិចដែលសិក្សាអំពីចលនានៃវត្ថុដោយគ្មានគិតពីបុព្វហេតុដែលបណ្តាលឱ្យមានចលនាគិតតែពីទំនាក់ទំនងរវាងចលនា និងពេល ។<br>+ **ឌីណាមិច** : ជាផ្នែកមួយនៃមេកានិចដែលសិក្សាអំពីចលនាក្រោមអំពើនៃកម្លាំង ។ |
| **ម៉ាស៊ីនអាត់វូត** | ជាឧបករណ៍ដែលផ្សំឡើងពីរ៉ក ខ្សែមិនយឺត និងអង្គធាតុ ។ |
| **រលាយ** | ជាដំណើរផ្លាស់ភាពនៃអង្គធាតុពីរឹងទៅរាវ ។ |
| **រំពុះ** | ជាការបង្កយ៉ាងរហ័សនៃអង្គធាតុរាវឱ្យកើតជាពពុះចំហាយដែលលេចចេញពីផ្ទៃអង្គធាតុរាវនោះ ។ |
| **រំហួត** | ជាដំណើរផ្លាស់ភាពពីអង្គធាតុរាវទៅឧស្ម័ន ។ |
| **ល្បឿន** | ជាការកំណត់ភាពលឿន ឬយឺតនៃចលនា ។ |
| **ល្បឿនមធ្យម** | ជាបម្រែបម្រួលចម្ងាយចរក្នុងមួយខ្នាតពេល ។ |

| | |
|---|---|
| **វ៉ិចទ័រល្បឿន** | ជាល្បឿនដែលបានបញ្ជាក់ទិសដៅច្បាស់លាស់ ។ |
| **វ៉ិចទ័រល្បឿនមធ្យម** | ជាបម្រែបម្រួលនៃបំលាស់ទីក្នុងមួយខ្នាតពេល ។ |
| **វ៉ិចទ័រល្បឿនខណៈ** | ជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះត្រង់ចំណុចមួយនៃខ្សែកោងតាង (បំលាស់ទី-ពេល ) នៅខណៈនោះ ។ |
| **សីតុណ្ហភាព** | ជាទំហំមួយដែលកំណត់ដោយកម្រិតកម្តៅ ឬកម្រិតត្រជាក់នៃអង្គធាតុ ។ |
| **សឺមីកុងឌុចទ័រ** | ជាអង្គធាតុដែលមានរេស៊ីស្តង់នៅចន្លោះ $10^{-4}\Omega\cdot\text{m}$ និង $10^{4}\Omega\cdot\text{m}$ ហើយជាអង្គធាតុដែលចម្លងអគ្គិសនីកាលណាវាទទួលនូវសីតុណ្ហភាពប្រែប្រួល ។ |
| **ស៊ីនេទិច** | ជាពាក្យមកពីភាសាក្រិចមានន័យថា ចលនា ។ |
| **សំទុះខណៈ** | ជាបម្រែបម្រួលវ៉ិចទ័រល្បឿននៅខណៈនោះ ។<br>ជាមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះខ្សែកោង វ៉ិចទ័រល្បឿន-ពេលនៅខណៈនោះ ។ |
| **សូលេណូអ៊ីត** | ជាបូប៊ីនវែងដែលមានប្រវែងបណ្តោយធំជាងកាំចាប់ពី 5 ដងឡើងទៅ ។ |
| **ស្ប៉ិចម៉ាញេទិច** | ជាសំណុំខ្សែដែនម៉ាញេទិច ។ |
| **សន្ទនីយ** | ជាអង្គធាតុរាវនិងឧស្ម័នដែលអាចហូរបាន ។ |
| **សឺមីកុងឌុចទ័រ** | ជាអង្គធាតុដែលមានរេស៊ីស្តង់នៅចន្លោះអង្គធាតុចម្លងនិងអ៊ីសូឡង់ ។ វាចម្លងចរន្តអគ្គិសនីខ្សោយបំផុត ។ |
| **សឺមីកុងឌុចទ័រប្រភេទ : n** | ជាសឺមីកុងឌុចទ័រប្រភេទអវិជ្ជមាន ។ គេយកធាតុដែលអាតូមមានអេឡិចត្រុងនៅស្រទាប់ក្រៅច្រើនជាងទៅរំលាយចូលសឺមីកុងឌុចទ័រ ។ |

| | |
|---|---|
| **សីមីកុងឌុចទ័រប្រភេទ : $p$** | ជាសីមីកុងឌុចទ័រប្រភេទវិជ្ជមាន ។ គេយកធាតុដែលអាតូមមានអេឡិចត្រុងនៅស្រទាប់ក្រៅតិចជាងទៅរំលាយចូលសីមីកុងឌុចទ័រ ។ |
| **ឡង់ទី** | ជាឧបករណ៍មួយដែលកើតឡើងពីបន្សំកំណាត់ព្រីសហើយអាចពង្រីកឬបង្រួមកាំពន្លឺបាន ។ |
| **អានុភាព** | ជាផលធៀបរវាងកម្មន្ត និងរយៈពេលដែលបានបំពេញកម្មន្តនោះ ។ |
| **អានុភាពខណៈ** | ជាផលគុណស្កាលែរវាងវ៉ិចទ័រកម្លាំង និងវ៉ិចទ័រល្បឿនខណៈនៅខណៈនោះ ។ |
| **អគ្គិសនីកម្ម** | ជាអំពើដែលធ្វើឱ្យអង្គធាតុមួយលើស ឬខ្វះអេឡិចត្រុង ។ |
| **អគ្គិសនីស្តាទិច** | ជាបន្ទុកអគ្គិសនីដែលបានមកពីការកកិតឬខាត់ ។ |
| **អង្គធាតុណឺត** | ជាអង្គធាតុដែលមិនលើស ឬមិនខ្វះអេឡិចត្រុង ។ |
| **អេឡិចត្រូស្តាទិច** | ជាការសិក្សាពីបាតុភូតដែលកើតមាននៅជុំវិញបន្ទុកអគ្គិសនីនៅនឹង ។ |
| **អេឡិចត្រុង** | ជាធាតុបន្ទុកអគ្គិសនីដែលមានបន្ទុកអវិជ្ជមាន ។ |
| **អេឡិចត្រូទស្សន៍** | ជាឧបករណ៍ប្រើសម្រាប់ឱ្យគេដឹងថា អង្គធាតុមួយផ្ទុកបន្ទុកអគ្គិសនី ឬនៅ ។ |
| **អេឡិចត្រូមេដែក** | ជាមេដែកអនាចិន្ត្រៃយ៍កើតពីសូលេណូអ៊ីតស៊កបញ្ចូលស្នូលដែក ហើយឆ្លងកាត់ដោយចរន្ត ។ |
| **អាល់ទែណាទ័រ** | ជាជនិតាចរន្តឆ្លាស់ ។ |
| **ឧបករណ៍វង្វាស់ពេល** | ជាឧបករណ៍ប្រើសម្រាប់វាស់ចម្ងាយចរក្នុងរយៈពេលស្មើគ្នា ។ |